**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**
**និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

## របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា

# ការជំរុញលើកស្ទួយសេដ្ឋកិច្ចជនបទ ករណីឃុំប្រាសាទ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង

កម្មសិក្សាពីថ្ងៃទី ០២ ខែមេសា ឆ្នាំ២០១៨ ដល់ថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០១៨

ឈ្មោះស្ថាប័ន៖ **សាលាឃុំប្រាសាទ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង**

តាក់តែងឡើងដោយ
និស្សិតឈ្មោះ **គង់ សេកលីម**
**ទូច សេរីព័រ**

សាស្ត្រាចារ្យណែនាំ
បណ្ឌិត **ឈុន ពហុ**

ថ្នាក់បរិញ្ញាបត្រ សេដ្ឋកិច្ចអភិវឌ្ឍន៍
ជំនាន់ទី ២

ឆ្នាំចូលសិក្សា ២០១៤
ឆ្នាំសរសេររបាយការណ៍ ២០១៨

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំជានិស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្រុម D4A1 ជំនាញ សេដ្ឋកិច្ចអភិវឌ្ឍន៍ បានធ្វើរបាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ក្រោមប្រធានបទ "ការជំរុញលើកស្ទួយសេដ្ឋកិច្ចជនបទ ករណីឃុំប្រាសាទ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង" បានបញ្ចប់ជាស្ថាពរ។

ឆ្លៀតក្នុងឱកាសនេះ យើងខ្ញុំទាំងពីរ សូមសំដែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅពុំអាចកាត់ថ្លៃបាន ពីគុណូបការៈចំពោះអ្នកមានគុណទាំងពីរ ដែលលោកទាំងពីរតែងតែចិញ្ចឹមបីបាច់ អប់រំ ប្រៀនប្រដៅ ទំនុកបម្រុង កូនមានថ្ងៃនេះគឺដោយសារការខិតខំប្រឹងប្រែងរបស់លោកទាំងទ្វេ។

របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សាមួយនេះ អាចទទួលបានលទ្ធផលជាផ្លែផ្កាដូចពេលនេះ ក៏ដោយសារតែមានការចូលរួមពីគ្រប់ផ្នែក ដូច្នេះយើងខ្ញុំសូមធ្វើការថ្លែងអំណរគុណ ដល់អ្នកទាំងអស់គ្នា ដូចដែលមានរៀបរាប់ដូចខាងក្រោម៖

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ ឯកឧត្តមសាកលវិទ្យាធិការ ឯកឧត្តមសាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង សាស្ត្រាចារ្យ និងមន្ត្រីរាជការទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

ជាពិសេស យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ លោកសាស្ត្រាចារ្យបណ្ឌិត ឈុន ពហុ ដែលលោកគ្រូបានជួយជ្រោមជ្រែងអស់ពីកម្លាំងកាយចិត្ត ទាំងយោបល់ ក៏ដូចជា ផ្តល់នូវអនុសាសន៍សម្រាប់របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សានេះតាំងពីចាប់ផ្តើមរហូតដល់បញ្ចប់នៃការស្រាវជ្រាវ។

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ អាជ្ញាធរមូលដ្ឋាន មេឃុំ ប្រធានភូមិ និងប្រជាជនទាំងអស់នៅក្នុងឃុំ ដែលបានចំណាយពេលវេលាដ៏មានតម្លៃរបស់ពួកគាត់ដើម្បីចូលរួមផ្តល់នូវបទសម្ភាសន៍ ដល់យើងខ្ញុំ តាំងពីដើមរហូតដល់ចប់ការស្រាវជ្រាវ។

ជាទីបញ្ចប់ យើងខ្ញុំទាំងពីរ សូមប្រសិទ្ធពរជ័យ សិរីសួស្តី ជ័យមង្គល វិបុលសុខ មហាប្រសើរ ចូរកើតមានដល់អ្នកមានគុណទាំងទ្វេរបស់រូបយើងខ្ញុំទាំងពីរ និងអ្នកទាំងឡាយដែលបានជួយជ្រោមជ្រែង ក្នុងការស្រាវជ្រាវនេះ ឲ្យជួបប្រទះតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និង ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

បច្ចុប្បន្ន ប្រទេសនៅលើពិភពលោកកំពុងយកចិត្តទុកដាក់លើបញ្ហាសេដ្ឋកិច្ចជាចម្បងក្នុងប្រទេសរបស់ខ្លួន។ ប្រទេសនីមួយៗខិតខំទាញយកផលប្រយោជន៍ ឬផលចំណេញសេដ្ឋកិច្ចរៀងៗខ្លួន ដោយសារយុគសម័យនេះ ជាសម័យសាកលភាវូបនីយកម្ម ដែលតម្រូវឲ្យមានការប្រកួតប្រជែងខ្ពស់។ ក្រឡេកមកមើលទិដ្ឋិភាពប្រទេសកម្ពុជាសព្វថ្ងៃ មានបញ្ហាជាច្រើនដែលកើតឡើងពីការប្រកួតប្រជែងនេះ ជាពិសេសនៅតាមតំបន់ជនបទដែលជាលទ្ធផលធ្វើឲ្យប្រជាជនពិបាកក្នុងការប្រកបមុខរបរចិញ្ចឹមជីវិត។ វាអាចបណ្តាលមកពីមូលហេតុសំខាន់ៗដូចជា កង្វះហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត កង្វះចំណេះជំនាញលើមុខរបរ... ដែលរុញច្រានឲ្យផលិតភាពទាប នាំឲ្យថ្លៃដើមផលិតកម្មខ្ពស់ ពិបាកក្នុងការប្រកួតប្រជែង។ ហេតុដូច្នេះហើយ ទើបយើងខ្ញុំសម្រេចចិត្តថានឹងជ្រើសរើសយកប្រធានបទមួយដែលលើកឡើងថា "ការជំរុញលើកស្ទួយសេដ្ឋកិច្ចជនបទ ករណីឃុំប្រាសាទ" មកធ្វើការសិក្សាស្រាវជ្រាវ។

ចំពោះកម្រងឯកសារស្រាវជ្រាវដែលលោកអ្នកកំពុងកាន់នៅនឹងដៃនេះ ជាសមិទ្ធិផលមួយដែលឆ្លងកាត់ការស្រាវជ្រាវ ពីសំណាក់កម្រងឯកសារជាច្រើន រួមនឹងការតម្រែតម្រង់ទិសពីសំណាក់ សាស្ត្រាចារ្យដ៏ជំនាញផងដែរ ។ យើងខ្ញុំសង្ឃឹមថា កិច្ចការស្រាវជ្រាវមួយនេះ នឹងអាចចូលរួមចំណែកក្នុងការជួយសម្រួលដល់ស្ថាប័នដែលពាក់ព័ន្ធនឹងការអភិវឌ្ឍ ក៏ដូចជាអ្នកសិក្សាស្រាវជ្រាវទាំងឡាយផងដែរ។

យើងខ្ញុំសូមអភ័យទោសទុកជាមុនរាល់កំហុសឆ្គងទាំងឡាយណា ដែលបានកើតឡើងដោយអចេតនា ព្រោះការធ្វើរបាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សាមួយឡើង រមែងតែងតែមានកំហុសខ្លះកើតឡើងដោយចៀសមិនផុតឡើយ។ យើងខ្ញុំទាំងពីរសូមស្វាគមន៍ នូវរាល់ការរិះគន់ដើម្បីស្ថាបនាពីសំណាក់លោកអ្នក ដែលបានអានគ្រប់មជ្ឈដ្ឋានទាំងអស់ ដើម្បីធ្វើអោយសៀវភៅមួយក្បាលនេះកាន់តែល្អប្រសើរឡើងជាងនេះមួយកម្រិតទៀត។

# មាតិកា

បញ្ជីតារាង ........ iv
បញ្ជីរូបភាព ........ v
បញ្ជីក្រាហ្វិក ........ vi
បញ្ជីឧបសម្ព័ន្ធ ........ vii

## សេចក្តីផ្តើម

១. លំនាំបញ្ហា ........ ១
២. ចំណោទបញ្ហា ........ ២
៣. គោលបំណងនៃការស្រាវជ្រាវ ........ ២
៤. ទំហំ និងដែនកំណត់ស្រាវជ្រាវ ........ ២
៥. វិធីសាស្រ្តស្រាវជ្រាវ ........ ៣
៦. សារៈសំខាន់នៃការស្រាវជ្រាវ ........ ៣
៧. រចនាសម្ព័ន្ធស្រាវជ្រាវ ........ ៤

## ជំពូកទី ១
## ការសិក្សាលើទ្រឹស្តី

១.១ និយមន័យ ........ ៥
១.២ សញ្ញាណសំខាន់ៗ ........ ៧
១.២.១ វដ្តនៃការអភិវឌ្ឍ ........ ៧
១.២.២ មូលហេតុនៃការអភិវឌ្ឍ ........ ៨
១.២.៣ គោលដៅទាំងឡាយនៃការអភិវឌ្ឍ ........ ៩
១.២.៤ កត្តាដែលជំរុញឲ្យមានការអភិវឌ្ឍ ........ ១០
១.២.៥ កត្តាដែលនាំឲ្យរាំងស្ទះដល់ការអភិវឌ្ឍ ........ ១២
១.២.៦ បញ្ហាភាគបែងចែកប្រាក់ចំណូលរបស់វិទ្យាស្ថានជាតិស្ថិតិ ........ ១៤
១.៣ ទ្រឹស្តីអ្នកប្រាជ្ញ ........ ១៥
១.៤ គោលនយោបាយ និងផែនការយុទ្ធសាស្រ្តដែលពាក់ព័ន្ធ ........ ១៩
១.៤.១ ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ ........ ១៩
១.៤.១.១ ការអភិវឌ្ឍជនបទ ........ ១៩

១.៤.១.២ គោលនយោបាយលើកស្ទួយវិស័យកសិកម្ម ......................................................១៩
១.៤.១.៣ គោលនយោបាយទឹក និងប្រព័ន្ធធារាសាស្ត្រ .......................................................២១
១.៥.១.៤ ការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងហេដ្ឋារចនាសម្ព័ន្ធ ..............២២
១.៤.២ យុទ្ធសាស្ត្រគាំទ្រខ្សែសង្វាក់ផលិតកម្ម.......................................................................២៣
១.៤.៣ គោលនយោបាយអភិវឌ្ឍកសិកម្ម..................................................................................២៣
១.៤.៤ គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម...........................................................២៤
១.៤.៥ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ .......................................................................២៥
១.៤.៦ យុទ្ធសាស្ត្រនៃការអភិវឌ្ឍសហគមន៍ .............................................................................២៥
១.៥ បទពិសោធន៍បរទេស : បទពិសោធន៍ភូមិ១ផលិតផល១ .........................................................២៧
សន្និដ្ឋានជំពូក ..........................................................................................................................៣៦

## ជំពូកទី ២

## ស្ថានភាពទូទៅនៃឃុំប្រាសាទ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង

២.១ ប្រវត្តិ និងទីតាំងភូមិសាស្ត្រ ........................................................................................... ៣៧
២.១.១ ប្រវត្តិឃុំប្រាសាទ ........................................................................................................... ៣៧
២.១.២ ទីតាំងភូមិសាស្ត្រ.............................................................................................................៣៨
២.១.៣ ស្ថានភាពប្រជាជនបច្ចុប្បន្ននៃឃុំប្រាសាទ .....................................................................៣៨
២.២ ចក្ខុវិស័យ គោលបំណង គោលដៅ និងយុទ្ធសាស្ត្រនៃការអភិវឌ្ឍ ...........................................៣៩
២.៣ រចនាសម្ព័ន្ធគ្រប់គ្រង និងតួនាទីភារកិច្ចសមាជិកឃុំប្រាសាទ ....................................................៣៩
២.៣.១ រចនាសម្ព័ន្ធគ្រប់គ្រងឃុំ ..................................................................................................៣៩
២.៣.២ តួនាទី និងភារកិច្ចរបស់ឃុំប្រាសាទ ...................................................................................៤២
២.៤ ការប្រព្រឹត្តិទៅនៃដំណើរអភិវឌ្ឍន៍ជីវភាពប្រជាជនរបស់ឃុំប្រាសាទ ..........................................៤៦
២.៤.១ ដំណើរការលើការអភិវឌ្ឍជីវភាពប្រជាជនក្នុងឃុំ.................................................................៤៦
២.៤.២ ភាពជោគជ័យ និងបញ្ហាដែលជួបប្រទះ..................................................................................៥២
២.៤.២.១ សមិទ្ធិផលនៃការអភិវឌ្ឍឃុំប្រាសាទ ....................................................................................៥២
២.៤.២.២ បញ្ហាដែលជួបប្រទះ ..........................................................................................................៥៨
២.៤.៣ ដំណោះស្រាយ.......................................................................................................................៦០
សន្និដ្ឋានជំពូក ...........................................................................................................................៦២

# ជំពូកទី ៣

# ការពិភាក្សាលើលទ្ធផលស្រាវជ្រាវ


៣.១ ស្ថានភាពទូទៅ និងស្ថានភាពផលិតកម្មកសិកម្ម, សេវាកម្ម, និងសិប្បកម្ម........................៦៣
៣.១.១ ស្ថានភាពទូទៅ ........................................................................................៦៣
៣.១.១.១ មុខរបរចម្បងរបស់ប្រជាជនក្នុងឃុំប្រាសាទ ...................................................៦៣
៣.១.១.២ កម្រិតជីវភាពរបស់ប្រជាជននៅក្នុងឃុំ.......................................................៦៤
៣.១.១.៣ កម្រិតជីវភាពតាមមុខរបរចម្បងទាំងបីក្នុងឃុំ..................................................៦៥
៣.១.១.៤ ចំនួនសមាជិកនៃគ្រួសារក្នុងឃុំ..................................................................៦៦
៣.១.២ បកស្រាយកម្រងសំនួរលើមុខរបរផ្នែកកសិកម្ម....................................................៦៧
៣.១.២.១ ផ្នែកកសិកម្មធ្វើស្រែ ................................................................................៦៧
៣.១.២.១ ផ្នែកកសិកម្មចិញ្ចឹមសត្វ ...........................................................................៧២
៣.១.៣ បកស្រាយកម្រងសំនួរលើមុខរបរផ្នែកសេវាកម្ម ..................................................៧៩
៣.១.៣ បកស្រាយកម្រងសំនួរលើមុខរបរផ្នែកសិប្បកម្ម...................................................៨២
៣.២ ការវិភាគលើអថេរបញ្ហាក្នុងការប្រកបមុខរបរ....................................................................៨៧
៣.២.១ បញ្ហាចម្បងក្នុងមុខរបរផ្នែកកសិកម្ម..................................................................៨៧
៣.២.២ បញ្ហាចម្បងក្នុងមុខរបរផ្នែកសេវាកម្ម .................................................................៨៧
៣.២.៣ បញ្ហាចម្បងក្នុងមុខរបរផ្នែកសិប្បកម្ម..................................................................៨៨
៣.៣ ដំណោះស្រាយ .............................................................................................៨៨
៣.៣.១ ដំណោះស្រាយចំពោះមុខរបរចម្បងផ្នែកកសិកម្ម...................................................៨៩
៣.៣.២ ដំណោះស្រាយចំពោះមុខរបរចម្បងផ្នែកសេវាកម្ម .................................................៩២
៣.៣.៣ ដំណោះស្រាយចំពោះមុខរបរចម្បងផ្នែកសិប្បកម្ម...................................................៩៤
សន្និដ្ឋានជំពូក.................................................................................................... ៩៧


# សេចក្ដីសន្និដ្ឋាន និងការផ្ដល់អនុសាសន៍


១. សេចក្ដីសន្និដ្ឋាន...........................................................................................៩៨
២. ការផ្ដល់អនុសាសន៍ .........................................................................................៩៩


**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# បញ្ជីតារាង

១. តារាង១.១ ៖ លទ្ធផលចំនួនផលិតផលនៃចលនាភូមិ១ផលិតផល១តាមឆ្នាំ........................ ៣៥
២. តារាង ៣.១ ៖ កម្រិតជីវភាពតាមមុខរបរចម្បងនីមួយៗក្នុងឃុំ ............................................ ៦៥
៣. តារាង ៣.២ : ចំនួនសមាជិកគ្រួសារក្នុងឃុំ..................................................................... ៦៦
៤. តារាង ៣.៣ : តារាងចំនួនដីធ្វើស្រែសរុប ចំនួនដងនៃការប្រមូលផល និងទិន្នផល ............. ៦៧
៥. តារាង ៣.៤ ៖ ពណ៌នាប្រភេទសត្វ រយៈពេលទទួលផល និងចំណូលដែលទទួលបាន......... ៧២
៦. តារាង ៣.៥ ៖ អំពីចំណាយជាមធ្យមក្នុងមុខរបរកសិកម្មចិញ្ចឹមសត្វ .................................... ៧៤
៧. តារាង ៣.៦ ៖ ពណ៌នាដំណើរការផលិតកម្មក្នុងមុខរបរផ្នែកសេវាកម្ម................................. ៨០
៨. តារាង ៣.៧ ៖ ពណ៌នាដំណើរការផលិតកម្មក្នុងមុខរបរផ្នែកសិប្បកម្ម................................ ៨៣

# បញ្ជីរូបភាព

១. រូបភាព ១.១ ៖ យុទ្ធសាស្រ្តគាំទ្រខ្សែសង្វាក់ផលិតកម្ម........................................................២៣
២. រូបភាព ១.២ ៖ គំនូសបំព្រួញ យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី ៣..............................២៥
៣. រូបភាព ១.៣ ៖ របៀបដែលបានដំណើរការនៅក្នុងចលនាភូមិ១ផលិតផល១ ........................២៩
៤. រូបភាព ១.៤ ៖ គោលការណ៍ ៣ របស់ចលនាភូមិ១ផលិតផល១.........................................៣០

# បញ្ជីក្រាហ្វិក


១. ក្រាហ្វិក ៣.១ ៖ ក្រាបបង្ហាញពីមុខរបរចម្បងរបស់ប្រជាជនក្នុងឃុំ.................................... ៦៣
២. ក្រាហ្វិក ៣.២ ៖ ក្រាបបង្ហាញពីកម្រិតជីវភាពរបស់ប្រជាជនក្នុងឃុំ .................................... ៦៤
៣. ក្រាហ្វិក ៣.៣ ៖ ការប្រើប្រាស់ពូជ ................................................................................... ៧០
៤. ក្រាហ្វិក ៣.៤ ៖ ការភ្ជួររាស់................................................................................................ ៧០
៥. ក្រាហ្វិក ៣.៥ ៖ ការប្រើប្រាស់ជី .......................................................................................... ៧១
៦. ក្រាហ្វិក ៣.៦ ៖ ការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិត............................................................ ៧១
៧. ក្រាហ្វិក ៣.៧ ៖ ការច្រូតកាត់............................................................................................ ៧១
៨. ក្រាហ្វិក ៣.៨ ៖ បញ្ហាទឹកភ្លើងដែលកើតមានឡើងក្នុងមុខរបរផ្នែកកសិកម្ម......................... ៧៤
៩. ក្រាហ្វិក ៣.៩ ៖ បញ្ហាផ្លូវដែលកើតមានក្នុងមុខរបរផ្នែកកសិកម្ម......................................... ៧៥
១០. ក្រាហ្វិក ៣.១០ ៖ បញ្ហាប្រព័ន្ធធារាសាស្ត្រដែលកើតមានក្នុងមុខរបរផ្នែកកសិកម្ម............. ៧៥
១១. ក្រាហ្វិក ៣.១១ ៖ បញ្ហាបច្ចេកទេសកសិកម្មដែលកើតមានក្នុងមុខរបរផ្នែកកសិកម្ម.......... ៧៦
១២. ក្រាហ្វិក ៣.១២ ៖ បញ្ហាទីផ្សារដែលកើតមានក្នុងមុខរបរផ្នែកកសិកម្ម...............................៧៧
១៣. ក្រាហ្វិក ៣.១៣ ៖ បញ្ហាថ្លៃដើមដែលកើតមានក្នុងមុខរបរផ្នែកកសិកម្ម ............................៧៧
១៤. ក្រាហ្វិក ៣.១៤ ៖ បញ្ហាដើមទុនដែលកើតមានក្នុងមុខរបរផ្នែកកសិកម្ម ........................... ៧៨
១៥. ក្រាហ្វិក ៣.១៥ ៖ ប្រភេទសេវាកម្ម ................................................................................ ៧៨
១៦. ក្រាហ្វិក ៣.១៦ ៖ បញ្ហាផ្លូវក្នុងមុខរបរផ្នែកសេវាកម្ម ...................................................... ៨១
១៧. ក្រាហ្វិក ៣.១៧ ៖ បញ្ហាថ្លៃដើមក្នុងមុខរបរផ្នែកសេវាកម្ម ..................................................៨២
១៨. ក្រាហ្វិក ៣.១៨ ៖ ប្រភេទនៃសិប្បកម្ម .................................................................................៨២
១៩. ក្រាហ្វិក ៣.១៩ ៖ បញ្ហាផ្លូវក្នុងមុខរបរផ្នែកសិប្បកម្ម ....................................................... ៨៤
២០. ក្រាហ្វិក ៣.២០ ៖ បញ្ហាបច្ចេកទេសក្នុងមុខរបរផ្នែកសិប្បកម្ម........................................... ៨៥
២១. ក្រាហ្វិក ៣.២១ ៖ បញ្ហាទីផ្សារក្នុងមុខរបរផ្នែកសិប្បកម្ម.................................................... ៨៥
២២. ក្រាហ្វិក ៣.២២ ៖ បញ្ហាថ្លៃដើមក្នុងមុខរបរផ្នែកសិប្បកម្ម.................................................. ៨៦
២៣. ក្រាហ្វិក ៣.២៣ ៖ បញ្ហាចម្បងៗកើតមានក្នុងមុខរបរផ្នែកកសិកម្ម.................................. ៨៧
២៤. ក្រាហ្វិក ៣.២៤ ៖ បញ្ហាចម្បងៗកើតមានក្នុងមុខរបរផ្នែកសេវាកម្ម.................................. ៨៧
២៥. ក្រាហ្វិក ៣.២៥ ៖ បញ្ហាចម្បងៗកើតមានក្នុងមុខរបរផ្នែកសិប្បកម្ម.................................. ៨៨

# បញ្ជីឧបសម្ព័ន្ធ


ឧបសម្ព័ន្ធទី ១ ៖ ផែនទីខេត្តព្រៃវែង នៃព្រះរាជាណាចក្រកម្ពុជា

ឧបសម្ព័ន្ធទី ២ ៖ ផែនទីឃុំប្រាសាទ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង

ឧបសម្ព័ន្ធទី ៣ ៖ ចក្ខុវិស័យ គោលបំណង គោលដៅ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ឃុំ

ឧបសម្ព័ន្ធទី ៤ ៖ ព័ត៌មាននៃសកម្មភាពដែលបានអនុវត្តក្នុងឆ្នាំ ២០១៦

ឧបសម្ព័ន្ធទី ៥ ៖ គម្រោង សកម្មភាពវិនិយោគឃុំ ដែលមានថវិកាគាំទ្រ

ឧបសម្ព័ន្ធទី ៦ ៖ គម្រោង សកម្មភាពអាទិភាពឃុំ ដែលមិនទាន់មានថវិកាគាំទ្រ

ឧបសម្ព័ន្ធទី ៧ ៖ កម្រងសំណួរស្រាវជ្រាវ

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

ក្នុងបណ្តាប្រទេសនៅលើសាកលលោក ប្រទេសណាក៏ដូចប្រទេសណាដែរតែងតែរិះរកនូវគ្រប់មធ្យោបាយធ្វើយ៉ាងណា ដើម្បីឲ្យប្រទេសរបស់ខ្លួនមានកំណើនសេដ្ឋកិច្ចកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ហើយកំណើនសេដ្ឋកិច្ចនេះ ពឹងផ្អែកលើវិស័យធំៗទាំងបី រួមមានវិស័យកសិកម្ម សេវាកម្ម និងឧស្សាហកម្ម។ មិនខុសពីប្រទេសដទៃដែរ ប្រទេសកម្ពុជាយើង វិស័យទាំងបីនេះបានរុញច្រានកំណើនសេដ្ឋកិច្ចជារៀងរាល់ឆ្នាំ ជាក់ស្តែងក្នុងឆ្នាំ ២០១៧ សេដ្ឋកិច្ចកម្ពុជាត្រូវបានប៉ាន់ស្មានថារក្សាកំណើនក្នុងរង្វង់ ៧.០% ដែលក្នុងនោះ វិស័យកសិកម្មមានកំណើនក្នុងអត្រា ២.០% វិស័យឧស្សាហកម្ម (រួមមានសិប្បកម្ម សហគ្រាស...) មានកំណើនក្នុងអត្រា ១០.៧% និងវិស័យសេវាកម្មមានកំណើនក្នុងអត្រា ៦.៥%។ ក្នុងគំនិតនេះដដែល បើយើងបម្លែងការសិក្សាពីលក្ខណៈទ្រង់ទ្រាយធំទៅតូច ដោយក្រឡេកមកមើលក្នុងលក្ខខណ្ឌសេដ្ឋកិច្ចជនបទ (ថ្នាក់ឃុំ) ក៏ត្រូវការវិស័យទាំងបីនេះដើម្បីរុញឲ្យមានកំណើនសេដ្ឋកិច្ចឃុំដែរ។ ជាដំបូង យើងត្រូវសិក្សាលំអិតទៅលើឫសគល់ដែលនាំឲ្យវិស័យទាំងបីនេះកើនបាន ដែលវាចាប់ផ្តើមពីផលិតភាពរបស់ប្រជាជនដែលប្រកបមុខរបរក្នុងវិស័យទាំងនេះ មានន័យថា លុះត្រាតែយើងជំរុញផលិតភាពរបស់គាត់ឲ្យអស់សក្តានុពល ទើបធ្វើឲ្យលេចឡើងជាកំណើនតាមវិស័យនីមួយៗ ក៏ដូចជាកំណើនសេដ្ឋកិច្ចឃុំទាំងមូល។

ស្របតាមការបកស្រាយខាងលើ ផលិតភាពពិតជាមានសារៈសំខាន់ណាស់សម្រាប់រុញច្រានឲ្យវិស័យទាំងបីមានកំណើន ប៉ុន្តែបើជួបបញ្ហាណាមួយដែលរាំងស្ទះដល់ដំណើរការផលិតកម្ម វានឹងធ្វើឲ្យផលិតភាពទាប នោះនឹងនាំឲ្យកំណើនសេដ្ឋកិច្ចទាបតាមនោះដែរ។ បច្ចុប្បន្ន ផលិតករក្នុងស្រុករបស់យើងទាំងបីវិស័យកំពុងតែជួបបញ្ហា នៅក្នុងដំណើរការរកស៊ីទទួលទានរបស់ពួកគាត់ រហូតដល់ធ្វើឲ្យផលិតករខ្លះបញ្ឈប់ការផលិតរបស់ខ្លួន ដោយសារតែមានការប្រកួតប្រជែងខ្ពស់ក្នុងទីផ្សារសេរី។ ឫសគល់នៃបញ្ហាដ៏ស្មុគស្មាញនេះគឺ បណ្តាលមកពីបញ្ហាផលិតភាពទាប និងបញ្ហាផ្សេងៗជាច្រើនទៀត ជាពិសេសនៅតាមបណ្តាតំបន់ជនបទនៃផ្ទៃប្រទេស។

ដោយសារតែមើលឃើញថា បញ្ហានេះកំពុងតែជួបប្រទះច្រើនផង និងជាបញ្ហាជះឥទ្ធិពលអវិជ្ជមានយ៉ាងខ្លាំងដល់កំណើនសេដ្ឋកិច្ចផង ទើបយើងខ្ញុំទាំងពីរនាក់បានសម្រេចចិត្តជ្រើសយកប្រធានបទមួយនេះមកធ្វើការបកស្រាយ។

## ២. ចំណោទបញ្ហា

សំណួរស្រាវជ្រាវដែលចោទសួរលើប្រធានបទរបស់យើងគឺ ៖

- តើប្រជាជនក្នុងឃុំប្រកបមុខរបរអ្វីខ្លះ និងកម្រិតជីវភាពពួកគាត់ក្នុងដំណើរការផលិតកម្មក្នុងវិស័យកសិកម្ម, សេវាកម្ម, និងឧស្សាហកម្ម ឬសិប្បកម្ម?
- តើបញ្ហាអ្វីខ្លះជាបញ្ហាចម្បងក្នុងដំណើរការផលិតកម្មនៃវិស័យទាំងបី?
- តើធ្វើដូចម្តេចដើម្បីរកដំណោះស្រាយដ៏មានប្រសិទ្ធភាព និងស្របតាមលទ្ធភាពដែលពួកគាត់អាចធ្វើទៅតាមបាន?

## ៣. គោលបំណងនៃការស្រាវជ្រាវ

យើងខ្ញុំធ្វើរបាយការណ៍កម្មសិក្សាក្នុងប្រធានបទនេះឡើង គឺដោយសារចង់រុករកនូវរបកគំហើញថ្មី ដែលមានប្រសិទ្ធភាពក្នុងការដោះស្រាយបញ្ហាជាក់ស្តែងដែលកើតមានក្នុងសង្គម ជាពិសេសក្នុងតំបន់ជនបទ។ ដើម្បីសម្រេចបាននូវគោលបំណងនៃការស្រាវជ្រាវមួយនេះ របាយការណ៍បានដំណើរការតាមទិសដៅដូចខាងក្រោម ៖

- ការសិក្សាលើទ្រឹស្តីពាក់ព័ន្ធ
- សិក្សាអំពីស្ថានភាព និងមុខរបររបស់ប្រជាពលរដ្ឋក្នុងឃុំ
- សិក្សាអំពីបញ្ហានានា ក្នុងការប្រកបមុខរបរ
- រកដំណោះស្រាយលើអថេរបញ្ហា ដើម្បីលើកស្ទួយជីវភាពប្រជាជនក្នុងឃុំ។

## ៤. ទំហំ និងដែនកំណត់ស្រាវជ្រាវ

នៅក្នុងការសិក្សាស្រាវជ្រាវមួយនេះ យើងបានធ្វើការជ្រើសរើសយកឃុំមួយនៅទីជនបទ ដែលឃុំនោះមានឈ្មោះថា **ឃុំប្រាសាទ** ស្ថិតក្នុងស្រុកកំពង់ត្របែក ខេត្តព្រៃវែង ដើម្បីធ្វើកម្មសិក្សាចុះសិក្សាស្រាវជ្រាវពាក់ព័ន្ធទៅនឹងប្រធានបទ "ការជំរុញលើកស្ទួយសេដ្ឋកិច្ចជនបទ ករណីឃុំប្រាសាទ ស្រុកកំពង់ត្របែកខេត្តព្រៃវែង" ចាប់ពីឆ្នាំ ២០១២ មកដល់បច្ចុប្បន្ន។

## ៥. វិធីសាស្ត្រស្រាវជ្រាវ

ក្នុងការសម្រេចបាននូវរបាយការណ៍ស្រាវជ្រាវមួយនេះ យើងបានធ្វើការបកស្រាយតាមរយៈព័ត៌មាន ដែលបានមកពីប្រភពទិន្នន័យចម្បង និងទិន្នន័យបន្ទាប់បន្សំ ដើម្បីឆ្លើយតបនឹងចំណោទបញ្ហា និងគោលបំណងនៃការសិក្សាស្រាវជ្រាវ។

- ទិន្នន័យចម្បង ៖ ប្រមូលព័ត៌មានបានតាមរយៈការចុះសម្ភាសន៍ប្រជាជនដែលរស់នៅក្នុងមូលដ្ឋានផ្ទាល់ ដោយប្រើប្រាស់កម្រងសំណួរបែបបរិមាណវិស័យ និងគុណវិស័យមួយផ្នែកតូច។
- ទិន្នន័យបន្ទាប់បន្សំ ៖ ប្រមូលបានតាមរយៈការអនុញ្ញាតិ និងអនុគ្រោះរបស់មេឃុំ មេភូមិ សមាជិកឃុំដទៃទៀត នូវការផ្តល់ជាឯកសាររបាយការណ៍ឃុំ និងមួយផ្នែកទៀតប្រមូលពីសៀវភៅ ឯកសារ ព្រឹត្តិប័ត្រ របាយការណ៍ដែលពាក់ព័ន្ធ រួមមាន ឯកសារដែលបានចងក្រងកន្លងមករបស់សិស្សច្បង ឯកសារបោះពុម្ពទាក់ទងនឹងជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍ ឯកសារក្នុងបណ្ណាល័យសេដ្ឋកិច្ចនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឯកសាររបស់រាជរដ្ឋាភិបាលទាក់ទងនឹងគោលនយោបាយ ឬយុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ និង អត្ថបទ/ឯកសារដែលដកស្រង់ចេញពីគេហទំព័រអ៊ីនធើណេតមួយចំនួន។

ការជ្រើសរើសគំរូតាងត្រូវបានធ្វើឡើងតាមរយៈ ការប្រើប្រាស់បញ្ជាភាគនៃការបែងចែកប្រាក់ចំណូលរបស់ប្រជាជនជនបទឆ្នាំ ២០១៦ របស់វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ទៅសាកសួរព័ត៌មានពីឃុំ ដើម្បីដឹងអំពីចំនួនប្រជាជនក្នុងកម្រិតជីវភាពនីមួយៗលើមុខរបរទាំងបីវិស័យនៃភូមិនីមួយៗ។

ក្នុងដំណើរការនៃការវិភាគទិន្នន័យ យើងបានប្រើប្រាស់កម្មវិធីកុំព្យូទ័រ២ប្រភេទគឺ កម្មវិធី SPSS និងកម្មវិធី Microsoft Excel ដើម្បីជាជំនួយក្នុងការគណនា ការពណ៌នាស្ថិតិ បង្ហាញក្រាហ្វិកវិភាគ ក៏ដូចជាការបង្ហាញពី Frequency នៃចំណុចសំខាន់ក្នុងស្ថិតិមួយចំនួន។

## ៦. សារៈសំខាន់នៃការស្រាវជ្រាវ

របាយការណ៍កម្មសិក្សាមួយនេះមានសារៈសំខាន់ដូចជា៖

- ជាឯកសារ ឬជាសៀវភៅជំនួយស្មារតីដល់អ្នកដែលមានភារកិច្ចក្នុងការអភិវឌ្ឍសង្គមជាតិ
- ជាប្រយោជន៍ដល់ប្រជាជនដែលជាផលិតករក្នុងស្រុក
- ជាប្រយោជន៍ដល់សង្គមជាតិតាមរយៈការជម្រុញអភិវឌ្ឍសេដ្ឋកិច្ចជនបទ

- ជាសៀវភៅ ឬឯកសារសម្រាប់បង្កើនចំណេះដឹងដល់សិស្សានុសិស្ស ឬនិស្សិតជំនាន់ក្រោយ។

## ៧. រចនាសម្ព័ន្ធស្រាវជ្រាវ

របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សានេះ ចែកចេញជា ៣ ជំពូក ដូចខាងក្រោម៖

- **ជំពូកទី ១** រួមមាន និយមន័យនៃពាក្យគន្លឹះដែលទាក់ទងនឹងប្រធានបទ, សញ្ញាណសំខាន់ៗពាក់ព័ន្ធនឹងប្រធានបទ, ទ្រឹស្តីរបស់អ្នកប្រាជ្ញ, គោលនយោបាយ ផែនការយុទ្ធសាស្ត្រនានាដែលពាក់ព័ន្ធ, ចុងក្រោយការបង្ហាញពីបទពិសោធន៍បរទេស និងសន្និដ្ឋានជំពូក។
- **ជំពូកទី ២** រួមមាន ប្រវត្តិ និងទីតាំងភូមិសាស្ត្ររបស់ឃុំប្រាសាទ រួមជាមួយស្ថានភាពទូទៅក្នុងឃុំ, ចក្ខុវិស័យ គោលបំណង គោលដៅ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍, បង្ហាញពីរចនាសម្ព័ន្ធចាត់តាំង និងតួនាទីភារកិច្ចសមាជិកឃុំ, ការប្រព្រឹត្តិទៅនៃដំណើរអភិវឌ្ឍន៍ រួមជាមួយភាពជោគជ័យ បញ្ហា និងដំណោះស្រាយឃុំ, និងសន្និដ្ឋានជំពូក។
- **ជំពូកទី ៣** រួមមាន ស្ថានភាពទូទៅ និងស្ថានភាពផលិតកម្មកសិកម្ម សេវាកម្ម និងសិប្បកម្ម, ការវិភាគលើអថេរកម្មវត្ថុ, បង្ហាញពីដំណោះស្រាយ, និងសន្និដ្ឋានជំពូក។

# ជំពូកទី ១
# ការសិក្សាលើទ្រឹស្តីពាក់ព័ន្ធ

# ជំពូកទី ១
# ការសិក្សាលើទ្រឹស្តី

## ១.១ និយមន័យ

### ក. និយមន័យនៃការអភិវឌ្ឍ

អត្ថន័យនៃការអភិវឌ្ឍតាមគំនិតបែបសម័យទំនើប យល់ឃើញថាការអភិវឌ្ឍជាការធ្វើ ឲ្យប្រសើរឡើងនូវគុណភាពជីវិតរបស់ប្រជាជនដូចជា លទ្ធភាព ទទួលបានការអប់រំ ខ្យល់ស្អាត ទឹកស្អាត ការគាំពារសុខភាព ឱកាសការងារ លទ្ធភាពទទួលបាន និងគ្មានការគំរាមកំហែងផ្នែកឧក្រិដ្ឋកម្ម។ល។[1]

### ខ. ការអភិវឌ្ឍជនបទ

- ការអភិវឌ្ឍជនបទ គឺជាដំណើរការដែលមានគោលដៅធ្វើឲ្យស្តង់ដារនៃការរស់នៅរបស់ប្រជាជនមានភាពប្រសើរឡើង។ ស្តង់ដារនៃការរស់នៅសំដៅលើសទ្ធស្សន៍នៃការអភិវឌ្ឍមនុស្សដែលត្រូវបានកំណត់ដោយអង្គការសហប្រជាជាតិឆ្នាំ១៩៦០ ដែលពាក់ព័ន្ធទៅនឹងការសង្ឃឹមរស់ ការចេះអាននិងចេះសរសេរអក្សរសម្រាប់មនុស្សពេញវ័យ Real GDP សម្រាប់មនុស្សម្នាក់ៗ សមភាពយេនឌ័រ និងសិទ្ធិនៃការចូលរួម។
- ការអភិវឌ្ឍជនបទ សំដៅលើការប្រែក្លាយពីទីជនបទទៅជាទីប្រជុំជន និងធ្វើឲ្យមានគម្លាតនៃការរស់នៅរវាងទីក្រុង និងជនបទមានកម្រិតទាបបំផុត តាមរយៈការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធជនបទ ការជួសជុល ការស្តារ និងការថែទាំធ្វើយ៉ាងណាជួយលើកទឹកចិត្តដល់ប្រជាជន ដើម្បីជាឱកាសនៃការបង្កើនប្រាក់ចំណូលក្នុងគ្រួសារនៅតំបន់ជនបទ និងចូលរួមចំណែកជាមួយរដ្ឋាភិបាលក្នុងការកសាងសេដ្ឋកិច្ចជាតិ។[2]

### គ. និយមន័យកសិកម្ម

គេអាចឲ្យនិយមន័យរបស់ពាក្យថាកសិកម្មបានច្រើនយ៉ាង ដូចខាងក្រោម :

- កសិកម្មគឺជា ផ្នែកមួយនៃផលិតកម្មរបស់មនុស្សជំនាន់ដើមដែលមានការចូលរួមពី កត្តាផលិតកម្មរបស់វាដូចជា កត្តាពលកម្មរបស់មនុស្ស កត្តាធម្មជាតិ (ដី ទឹក...) និងឧបករណ៍ផលិតកម្ម។

[1] សៀវភៅ "សេដ្ឋកិច្ចអភិវឌ្ឍន៍", រៀបរៀងដោយបណ្ឌិត ជ្រឹង ហៃ និងបណ្ឌិត ទិន ហេង, បោះពុម្ពនៅថ្ងៃទី០៤ ខែធ្នូ ឆ្នាំ ២០១៧, ទំព័រទី៤

[2] មេរៀនក្នុងមុខវិជ្ជា "អភិវឌ្ឍន៍ជនបទ " របស់សាស្ត្រាចារ្យបណ្ឌិត ឈុន ពហុ ឆ្នាំសិក្សា ២០១៧-២០១៨

- កសិកម្មគឺជា អំពើរបស់មនុស្ស ក្នុងការកែប្រែដីធ្លី ការដាំដុះ និងការចិញ្ចឹមសត្វ។
- កសិកម្មគឺជា សិល្បៈ ឬវិទ្យាសាស្ត្រនៃការកែច្នៃដីធ្លី ការផលិត ការប្រើប្រាស់គ្រាប់ពូជ ការបង្កាត់ពូជសត្វ ដើម្បីទទួលបាននូវស្បៀងអាហារគ្រប់មុខ សម្រាប់ផ្គត់ផ្គង់សេចក្តីត្រូវការរបស់មនុស្ស។
- ការអភិវឌ្ឍកសិកម្មសំដៅលើ ការធ្វើឲ្យមានការប្រែប្រួលជាវិជ្ជមាននូវទិន្នផលកសិកម្ម និងការកែប្រែគុណភាពក្នុងផលិតកម្មពីទាបទៅខ្ពស់ ឬការផ្លាស់ប្តូរបច្ចេកវិទ្យាថ្មីក្នុងផលិតកម្មកសិកម្ម។[3]

## ឃ. និយមន័យសហគ្រាស

សហគ្រាស គឺជាអង្គភាពមួយដែលបន្លែងនូវ Input (ជាធនធានទាំងឡាយដែលមានដូចជា មនុស្ស ផលិតកម្ម សម្ភារៈ ហិរញ្ញវត្ថុ ។ល។) អោយចេញទៅជាទិន្នផល (Output = ផលិតផលដែលផលិតបាន) រួចហើយយកផលិតផលនេះទៅផ្គត់ផ្គង់ដល់ទីផ្សារ ក្នុងគោលដៅសម្រេចគោលបំណងដែលខ្លួនកំណត់ ជាពិសេស គឺប្រាក់ចំណេញ។

សហគ្រាស មានតួនាទីបំពេញនូវតម្រូវការអតិថិជន ដែលត្រូវការអ្វីៗដែលប្លែកៗ ដូចនេះសហគ្រាសត្រូវបង្កើន ឬបង្កើតផលិតផលថ្មីៗទាំងឡាយ អោយសមស្របតាមតម្រូវការនោះ។

គេអាចបែងចែកសហគ្រាសទៅតាមលទ្ធភាព ឬទំហំ ដូចខាងក្រោម ៖

- តម្រូវការទុន Capital Requirement
- ចំណែកទីផ្សារ Market Segment
- ចំនួនបុគ្គលិក Number of Worker
- ចំណូលលក់សរុប Turnover ។[4]

[3] មេរៀនក្នុងមុខវិជ្ជា "សេដ្ឋកិច្ចកសិកម្ម" របស់សាស្ត្រាចារ្យបណ្ឌិត ឈុន ពហុ ឆ្នាំសិក្សា ២០១៦-២០១៧

[4] សៀវភៅ "សេដ្ឋកិច្ចសហគ្រាស" រៀបរៀងដោយសាស្ត្រាចារ្យ ស សុភាព, បោះពុម្ព លើកទី១ ឆ្នាំ ២០១៣, ទំព័រទី ១

### ង. និយមន័យសេវាកម្ម

សេដ្ឋវិទូបានបែងចែកផលិតផលទាំងអស់ជាពីរក្រុមសំខាន់ៗគឺ ទំនិញ និង សេវាកម្ម។ ចំពោះសេវាកម្ម មានន័យថាជាផលិតផលអរូបីយ (មិនអាចប៉ះផ្ទាល់) ឬជាសកម្មភាពដែលមនុស្សសម្តែងចេញ ដែលត្រូវបានផ្ទេរពីអ្នកផ្គត់ផ្គង់ទៅអ្នកត្រូវការ។ ឧទាហរណ៍នៃសេវាកម្មមានដូចជា : សេវាអប់រំ, សេវាទំនាក់ទំនង, សេវាដឹកជញ្ជូន, សេវាសុខភាព, សេវាធនាគារ, ការលក់ដុំ, ការលក់រាយ, និងសេវាជំនាញទាំងអស់ដូចជា វិស្វកម្ម វិជ្ជសាស្ត្រ និង សេវាដែលផ្តល់ដោយរដ្ឋាភិបាលជាដើម។ល។

## ១.២ សញ្ញាណសំខាន់ៗ

### ១.២.១ វដ្តនៃការអភិវឌ្ឍ

វដ្តនៃការអភិវឌ្ឍ គឺជានីតិវិធីនៃការអភិវឌ្ឍទៅលើវិស័យណាមួយ នៅទីកន្លែងណាមួយពិតប្រាកដ។[5]




[5] សៀវភៅ "ការអភិវឌ្ឍជនបទ" របស់សាស្ត្រាចារ្យ ព្រំ ទេវី, សាកលវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ឆ្នាំ ២០០៥

### ១.២.២ មូលហេតុនៃការអភិវឌ្ឍ [6]

**Why we need to develop?**




[6] Prof. Dr. DUY CHANDINA, *Economic Development*, Academic year 2013-2014, page 30

### ១.២.៣ គោលដៅទាំងឡាយនៃការអភិវឌ្ឍ

ប្រទេសផ្សេងគ្នា មានគោលដៅជាអាទិភាពនៅក្នុងគោលនយោបាយអភិវឌ្ឍន៍ផ្សេងៗគ្នាដែរ។ សំណួរដែលត្រូវចោទសួរគឺថា តើគោលដៅអភិវឌ្ឍន៍គឺធ្វើឡើងដើម្បីបង្កើនទ្រព្យសម្បត្តិជាតិ ឬដើម្បីធ្វើអោយប្រសើរឡើងនូវសុខុមាលភាពរបស់ប្រជាជនភាគច្រើន ឬក៏ធ្វើអោយប្រាកដថាប្រជាជនមានសិទ្ធិសេរីភាពគ្រប់គ្រាន់មែនឬ? ឬបង្កើនសន្តិសុខសេដ្ឋកិច្ចរបស់ពួកគេមែនទេ?

ឯកសារអង្គការសហប្រជាជាតិថ្មីៗនេះបានបញ្ជាក់ថា **ការអភិវឌ្ឍមនុស្ស** ត្រូវកំណត់ដោយអាយុកាល (រយៈពេលសង្ឃឹមរស់) អក្ខរកម្មរបស់មនុស្សពេញវ័យ លទ្ធភាពទទួលបានការអប់រំទាំងបីកម្រិត ថែមទាំងប្រាក់ចំណូលជាមធ្យមរបស់ប្រជាជន ដែលកំណត់នូវសេរីភាពនៃការជ្រើសរើស។ នៅក្នុងន័យទូលំទូលាយជាងនេះ គេយល់ឃើញការអភិវឌ្ឍមនុស្ស ត្រូវរួមបញ្ចូលគ្រប់ទុដ្ឋភាពនៃសុខុមាលភាពបុគ្គលមួយរូបៗ ដែលមានចាប់តាំងពីស្ថានភាពសុខភាពរបស់ពួកគេ រហូតដល់សេរីភាពខាងផ្នែកនយោបាយ និងសេដ្ឋកិច្ច។

ជាការពិតណាស់ សេដ្ឋកិច្ចបែបប្រពៃណីដែលទាក់ទងទៅនឹងកំណើនសេដ្ឋកិច្ចតាមរយៈការបង្កើនទ្រព្យសម្បត្តិជាតិសរុបនោះអាចជួយពង្រឹងសក្តានុពលក្នុងការកាត់បន្ថយភាពក្រីក្របាន ក៏ប៉ុន្តែឧទាហរណ៍មានច្រើនប្រភេទ ដែលកំណើនសេដ្ឋកិច្ចមិនត្រូវបានឆ្លើយតបនៅក្នុងដំណើរការអភិវឌ្ឍន៍មនុស្ស។

គោលដៅសេដ្ឋកិច្ច ត្រូវតែទទួលបានការទ្រទ្រង់ដោយផ្លែផ្កានៃការអភិវឌ្ឍមនុស្ស ដែលមានកត្តាជំរុញរួមមាន សេវាសុខភាព សេវាអប់រំ អធិបតេយ្យ ឱកាសការងារ កិច្ចការពារបរិស្ថាន ។ល។ ផ្ទុយទៅវិញការអភិវឌ្ឍមនុស្ស ដែលមានលក្ខណៈយឺតយ៉ាវអាចរារាំងមិនអោយមានកំណើនសេដ្ឋកិច្ចយ៉ាងលឿន ដែលមានកត្តាជំរុញរួមមានកំលាំងពលកម្មដែលមានសមត្ថភាពគ្រប់គ្រាន់ របកគំហើញបច្ចេកវិទ្យាថ្មី ការដឹកនាំដ៏ប្រសើរ។ **ការអភិវឌ្ឍមនុស្ស** គឺជាមធ្យោបាយមួយដែលសម្រាប់ជំរុញអោយមានកំណើនសេដ្ឋកិច្ច។[7]

[7] សៀវភៅ "សេដ្ឋកិច្ចអភិវឌ្ឍន៍" រៀបរៀងដោយបណ្ឌិត ជ្រឹង ហៃ និងបណ្ឌិតទិនហេង, បោះពុម្ពនៅថ្ងៃទី០៤ ខែធ្នូ ឆ្នាំ ២០១៧, ទំព័រទី៥

### ១.២.៤ កត្តាដែលជំរុញឲ្យមានការអភិវឌ្ឍ

បើយោងតាមការសិក្សាស្រាវជ្រាវទៅលើទស្សនៈវិទូជាច្រើនយល់ឃើញថា តួនាទីរបស់ពលកម្ម និងមូលធនជាស្នូលដែលជំរុញឲ្យមានការអភិវឌ្ឍ។ ក្រៅពីកត្តាទាំងពីរខាងលើ ក៏មានកត្តាធនធានធម្មជាតិ ដែលជាកត្តាសំខាន់តែមួយគត់នៅក្នុងការអភិវឌ្ឍ ដោយផ្អែកលើពេលវេលា និងការរកឃើញថ្មីៗដទៃទៀតដូចជា កត្តារចនាសម្ព័ន្ធជាដើម។

**ក. កត្តាធនធានធម្មជាតិ**

ធនធានធម្មជាតិមានប្រភពមកពីបួនកន្លែងនៅលើពិភពលោកយើងនេះគឺ នៅលើដី នៅលើអាកាស ក្រោមដី និងក្នុងទឹក។ ធនធានធម្មជាតិទាំងនេះត្រូវបានគេចាត់ទុកថាជាវត្ថុដ៏មានតម្លៃបំផុតនៅលើពិភពលោកយើង នេះដោយសារតែធនធានធម្មជាតិ ត្រូវបានគេយកមកកែច្នៃដើម្បីផលិតនូវផលិតផលសម្រេចនានា ដើម្បីផ្គត់ផ្គង់ការរស់នៅរបស់មនុស្សផង និងដើម្បីអភិវឌ្ឍលើគ្រប់វិស័យរបស់ស្ថាប័នប្រទេសផង។ ធនធានធម្មជាតិក៏មានតួនាទីយ៉ាងសំខាន់ផងដែរសម្រាប់ការអភិវឌ្ឍ ក៏ដូចជាការប្រែមុខមាត់នៃបណ្ដាប្រទេសដែលជាសមាជិកអង្គការ OPEC ( Organization of Petroleum Exporting Countries ) ឲ្យក្លាយពីប្រទេសកំពុងអភិវឌ្ឍន៍ទៅជាប្រទេសអភិវឌ្ឍន៍បានដោយប្រើប្រាស់នូវធនធានប្រេងដែលបូមពីធម្មជាតិនេះឯង ដែលប្រទេសទាំងនោះរួមមានដូចជា៖ ប្រទេសអារ៉ាប់ប៊ីសាអ៊ូឌីត ប្រទេសប្រុយណេ និងវេណេហ្ស៊ុយអេឡាជាដើម។

**ខ. កត្តាធនធានមនុស្ស**

កត្តាមនុស្ស ជាកត្តាសំខាន់មួយក្នុងការអភិវឌ្ឍ ព្រោះការអភិវឌ្ឍស្ថិតក្នុងគោលបំណងដើម្បីមនុស្ស និងសង្គមមនុស្ស។ ម្យ៉ាងទៀតមនុស្ស មានគំនិតច្រើនក្នុងការអភិវឌ្ឍ មានមនុស្សគឺមានតម្រូវការ។ ដូច្នេះមនុស្សច្រើននាំឲ្យមានតម្រូវការច្រើន ហើយផលិតកម្មក៏បានបង្កើនដែរដើម្បីបំពេញសេចក្ដីត្រូវការរបស់មនុស្ស។ អ្វីដែលសំខាន់ជាងនេះទៅទៀតនោះគឺ មនុស្សជាកម្លាំងពលកម្មដែលជាកត្តាផលិតកម្មក្នុងវិស័យផលិតកម្ម មិនថាក្នុងវិស័យកសិកម្ម ឧស្សាហកម្ម ឬសេវាកម្មឡើយ គឺចូលរួមគ្រប់សកម្មភាពផលិត ដែលជាកត្តាសំខាន់មួយក្នុងការអភិវឌ្ឍសេដ្ឋកិច្ច។

ចំពោះកត្តាមនុស្សនេះ មានការសិក្សា និងសំណួរដែលមានការចោទឡើងជាច្រើនអំពីកត្តាពលកម្មក្នុងកិច្ចដំណើរការអភិវឌ្ឍ។ កម្រិតសមត្ថភាពពលកម្មពោលគឺ ធនធានមនុស្សតែងតែមានភាពខុសប្លែក គ្នារវាងបណ្ដា ប្រទេសជឿនលឿន និងប្រទេសកំពុងអភិវឌ្ឍន៍។ តាមទ្រឹស្ដីរបស់លោក Mare Penouil គាត់យល់ថា ដំបូងពលកម្មរបស់មនុស្សដែលធ្វើឡើង ឬផលិតអ្វីមួយឡើង គឺក្នុងគោលបំណងត្រឹមតែបំពេញសេចក្ដីត្រូវការសម្រាប់សម្រាប់ជីវិតប៉ុណ្ណោះ ពោលគឺធ្វើពលកម្ម

ដើម្បីចិញ្ចឹមជីវិតខ្លួនឯងដោយគ្មានផលកម្រៃពីអ្នកដទៃឡើយ ដែលវាមានន័យថាទាញយកប្រយោជន៍ពីធម្មជាតិទៅតាមលទ្ធភាពដែលខ្លួនអាចធ្វើបាន។ លុះក្រោយមកដោយមានការវិវត្តទាំងផ្នែកខួរក្បាល និងបច្ចេកវិទ្យា ធ្វើឲ្យមនុស្សភាគច្រើនបង្វែរទិសពី ការចិញ្ចឹមជីវិតដោយធម្មជាតិងាកទៅរកការកែច្នៃ និងបង្កើតពីការប្រើនូវកម្លាំងពលកម្មតូចតាចឲ្យទៅជាការប្រើកម្លាំងពលកម្មដែលមានជំនាញ។

## គ. កត្តាធនធានមូលធន

នៅក្នុងដំណើរការអភិវឌ្ឍ ក្រៅពីប្រភពធនធានធម្មជាតិ និងកត្តាមនុស្សយើងនៅមានកត្តាមួយទៀតដែលកត្តានេះមានសារៈសំខាន់ដែរ ដោយមូលធន គឺជាប្រភពដែលនាំឲ្យមានឧបករណ៍ទំនើបៗដោយអាចបង្កើនកត្តាផលិតកម្មឲ្យកាន់តែខ្ពស់បន្ថែមទៀត និងប្រកបដោយគុណភាពល្អថែមទៀតផង។ មូលធនក៏ជាប្រភពចាំបាច់មួយសម្រាប់ការចាប់ផ្ដើមអភិវឌ្ឍផងដែរ ដោយសារត្រូវបានគេចាត់ទុកជាឧបករណ៍ស្នូលសម្រាប់ចចារដោះដូរនូវទំនិញនានា ដែលទាំងនេះហើយទើបមូលធនក្លាយទៅជាប្រភពនៃតម្រូវការចាំបាច់មួយសម្រាប់មនុស្ស ប្រភពនៃតម្រូវការនេះហើយទើបនាំឲ្យមានលក្ខខណ្ឌដោះដូរមួយគឺមានចំណូល ទើបមានការបញ្ចេញនូវកម្លាំងពលកម្មរបស់មនុស្សដើម្បីអភិវឌ្ឍន៍ ឬកែប្រែអ្វីមួយនៅក្នុងសង្គម។

ចំពោះការកើនឡើងនៃមូលធនចេញជាលទ្ធផល គឺនៅពេលដែលសមាមាត្រនៃចំណូលបច្ចុប្បន្ន ត្រូវបានសន្សំ និងវិនិយោគដើម្បីធ្វើឲ្យកើនឡើងនូវទិន្នផល និងប្រាក់ចំណូលនៅពេលអនាគត។ រោងចក្រថ្មីៗ គ្រឿងយន្ត ម៉ាស៊ីន សំភារៈបរិក្ខារ និងវត្ថុធាតុដើមបង្កើននូវស្តុកមូលធនរូបវន្តនៃជាតិមួយ (សរុបតម្លៃជាក់ស្តែងនៃផលិតភាពមូលធនទំនិញរូបវន្តទាំងអស់) ហើយការកើនឡើងមូលធននឹងធ្វើឲ្យមានលទ្ធភាពពង្រីកទិន្នផលដើម្បីសម្រេចគោលបំណង។ ការវិនិយោគផ្ទាល់ដែលឲ្យផលទាំងនោះ គឺត្រូវបានបន្ថែមដោយការវិនិយោគទៅលើអ្វីដែលត្រូវបានស្គាល់ក្នុងហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច និងសង្គមដូចជា ផ្លូវថ្នល់ អគ្គិសនី ទឹកស្អាត ទាក់ទងនឹងការសម្របសម្រួលគ្នាក្នុងសកម្មភាពសមាហរណកម្មសេដ្ឋកិច្ច។

## ឃ. កត្តារចនាសម្ព័ន្ធ

ក្រៅពីកត្តាទាំងបីខាងលើ កត្តារចនាសម្ព័ន្ធជាផ្នែកមួយសំខាន់ដែរក្នុងការកំណត់ទិសដៅ និង ខ្សែបន្ទាត់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចក៏ដូចជាប្រទេសជាតិផងដែរ។ រចនាសម្ព័ន្ធនយោបាយ ស្ថេរភាពសង្គម និងលទ្ធិប្រជាធិបតេយ្យជាកូនសោដ៏សំខាន់ ព្រោះថាបើកាលណាប្រទេសជាតិមួយ

ពោរពេញទៅដោយស្ថេរភាពសង្គម និងនយោបាយនោះការអភិវឌ្ឍនឹងមានកំណើនយ៉ាងឆាប់រហ័សជាក់ជាមិនខាន។

កត្តាទាំងនេះហើយជាដែលជំរុញដល់ការអភិវឌ្ឍ ប៉ុន្តែការអភិវឌ្ឍជាទូទៅពុំអាចធ្វើឲ្យមានភាពស្មើគ្នានៅគ្រប់ទីកន្លែងឡើយជាពិសេសការអភិវឌ្ឍនៅបណ្តាប្រទេសតតិយលោក ឬប្រទេសកំពុងអភិវឌ្ឍន៍តែម្តង គឺដោយសារតែភាពក្រីក្រ និងកំណើនប្រជាជនហួសប្រមាណ ព្រមជាមួយការអប់រំនៅមានកម្រិតទាបក្នុងប្រទេសទាំងនោះ។[8]

### ១.២.៥ កត្តាដែលនាំឲ្យរាំងស្ទះដល់ការអភិវឌ្ឍ

ការធ្វើឲ្យរាំងស្ទះដល់កិច្ចដំណើរការរីកចម្រើនទៅលើហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច សង្គមកិច្ច ឬស្ថាប័ននៃប្រទេសមួយ មានន័យថាជាការរំខានដល់កិច្ចដំណើរការអភិវឌ្ឍនៃប្រទេសនោះ។

តើមានឧបសគ្គអ្វីខ្លះ ដែលរាំងស្ទះដល់ដំណើរការនៃការអភិវឌ្ឍនោះ?

**ក. ភាពក្រីក្រ**

ភាពក្រីក្រ ត្រូវបានគេចាត់ទុកថាជាអ្នកបំផ្លិចបំផ្លាញបរិស្ថានដ៏ធ្ងន់ធ្ងរបំផុត នៅលើលោកយើងនេះ។ ហើយភាពក្រីក្រក៏ត្រូវបានគេចាត់ទុកជាអ្នកធ្វើឲ្យរាំងស្ទះ ដល់ការអភិវឌ្ឍផងដែរ ដោយសារតែភាពក្រីក្រ ឬដូចគេហៅថាក្រស្ទើរតែដាច់ពោះនោះ បានធ្វើឲ្យពួកគេចំណាយធនធានដ៏មានតម្លៃរបស់ពួកគេមានដូចជា ព្រៃឈើ បរិស្ថានទៅជាថ្នូរដោះដូរនឹងចំណីអាហារតែមួយចម្អែតប៉ុណ្ណោះ ជាក់ស្តែងដូចជានៅតំបន់ Sao Puolo របស់ប្រទេសប្រស៊ីល ទីនោះត្រូវបានគេចាត់ទុកថាជាតំបន់ដែលទទួលរងនូវការបំពុលបរិស្ថានខ្លាំងក្លាបំផុត និងជាកន្លែងមួយពិបាកក្នុងការអភិវឌ្ឍដែរ ដើម្បីរស់ពួកគេសុខចិត្តកាប់បំផ្លាញធនធានធម្មជាតិ ដ៏មានតម្លៃរបស់ពួកគេដូចជាឈើល្អៗមួយចំនួនដើម្បីយកមកធ្វើជាអូសសម្រាប់តែចម្អិនអាហារតែប៉ុណ្ណោះ។ ម្យ៉ាងវិញទៀតបើផ្អែកលើទ្រឹស្តីរបស់ពួក Classic ថាភាពក្រីក្រជាកត្តាមួយដែលធ្វើឲ្យមានសន្សំទាប ការសន្សំទាបនេះធ្វើឲ្យវិនិយោគក៏ទាបដែរ ព្រោះសន្សំជាប្រភពនៃការវិនិយោគ កង្វះវិនិយោគនាំឲ្យមានផលិតកម្មទាបធ្វើឲ្យប្រាក់ចំណូលទាប។ ចំណែក Keynes យល់ថានៅពេលដែលក្រធ្វើឲ្យមានតម្រូវការទាប ដែលនាំឲ្យទីផ្សារតូច ធ្វើឲ្យកង្វះវិនិយោគ នាំឲ្យផលិតកម្មទាប ចុងបញ្ចប់ធ្វើឲ្យប្រាក់ចំណូលទាប។ បញ្ហាប្រាក់សន្សំ ការវិនិយោគ និងមូលធនគឺជាបញ្ហាដែលរាំងស្ទះដល់ការអភិវឌ្ឍបញ្ហាទាំងនេះតែងតែកើតមានឡើងចំពោះតំបន់ដែលក្រីក្រ។

---

[8] សារណាបញ្ចប់ការសិក្សា "ការចូលរួមរបស់សហគ្រាសធុនតូច និងមធ្យមក្នុងការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា" របស់និស្សិត ពេជ្រ សម្បត្តិ និងជូរ ចន្ទារី ឆ្នាំសរសេរ ២០១២, ទំព័រទី១១

## ខ. អត្រាកំណើនប្រជាជនខ្ពស់

យោងតាមការអង្កេតរបស់សេដ្ឋវិទូជាច្រើនបានឲ្យដឹងថា នៅក្នុងប្រទេសតតិយលោកអត្រាកំណើនប្រជាជនមានការកើនឡើងលឿនជាងពីរដង ច្រើនជាងប្រទេសអភិវឌ្ឍន៍ដែលកត្តានេះបានធ្វើឲ្យរាំងស្ទះដល់ការអភិវឌ្ឍក្នុងប្រទេសក៏ដូចជាក្នុងតំបន់ដែរ។ មូលហេតុនៃការកើនឡើងយ៉ាងលឿននេះបណ្ដាលមកពីការប្រកាន់ទំនៀមទំលាប់ ដ៏ចាស់គំរិលរបស់ប្រទេសតតិយលោកមួយចំនួនដូចជា មនុស្សមានអាយុក្រោម ១៨ឆ្នាំ ចាស់ទុំមានការគិតគូររៀបអាពាហ៍ពិពាហ៍ទាំងវ័យក្មេង និងមានកត្តាជាច្រើនផ្សេងៗទៀត។

កំណើនប្រជាជនខ្ពស់អាចជះឥទ្ធិពលដល់ការសន្សំ និងវិនិយោគ ៖ ចំពោះគ្រួសារដែលមានសមាជិកច្រើនគេមិនសូវមានការសន្សំប៉ុន្មានទេ ដោយសារចំណូលដែលរកបានត្រូវបានបែងចែកលើការចំណាយផ្សេងៗជាច្រើនដែលធ្វើឲ្យការសន្សំមានតិចតួច ឬក៏គ្មានតែម្ដង។

ការជះឥទ្ធិពលលើផលិតភាព ៖ នៅពេលដែលចំនួនប្រជាជនច្រើនមានការកើនឡើងខ្លាំងគេចាំបាច់ត្រូវទាក់ទាញវិស័យវិនិយោគឲ្យមានការកើនឡើងផងដែរ ដើម្បីឲ្យមានកំណើនផលិតភាព បើពុំដូច្នោះទេប្រជាពលរដ្ឋមួយចំនួននឹងអត់ការងារធ្វើជាមិនខាន។

កំណើនប្រជាជនខ្ពស់អាចប៉ះពាល់ទីក្រុង ៖ នៅពេលមានកំណើនប្រជាជនខ្លាំងវាក៏ជះឥទ្ធិពលដល់ទីក្រុងដោយមានមនុស្សកកកុញនៅទីក្រុង និងមានបញ្ហាជាច្រើនកើតឡើងដូចជា អំពើឆក់ប្លន់ ពេស្យាចារ និងការរស់នៅដោយគ្មានផាសុខភាព កង្វះអនាម័យ និងបរិស្ថានកង្វក់ជាដើម។

## គ. ការអប់រំនៅទាប

នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ភាគច្រើនអត្រាអនក្ខរជនមានចំនួនច្រើនដែលជាពិសេសនៅតាមតំបន់ជនបទ ចំណែកឯទីក្រុងវិញអត្រាអនក្ខរជនមានចំនួនតិចតួចនេះបញ្ជាក់ថាវិស័យអប់រំនៅក្នុងប្រទេសនៅមិនទាន់ជ្រួតជ្រាបបានគ្រប់ទីកន្លែងនៅឡើយ ធ្វើឲ្យអ្នកមានជំនាញបច្ចេកវិទ្យានៅកម្រិតដែលជះឥទ្ធិពលអាក្រក់ និងធ្វើឲ្យមានការពិបាកក្នុងការអភិវឌ្ឍប្រទេស។ ក៏ប៉ុន្តែដោយសារតែមានសហគ្រាសខ្នាតតូច និងមធ្យមដែលភាពច្រើនពុំតម្រូវឲ្យបុគ្គលិករបស់ខ្លួនមានចំណេះវិជ្ជាខ្ពស់ដើម្បីបម្រើការងារនោះទេ ដូច្នេះទើបយើងឃើញថា សហគ្រាសនេះពិតជាអាចចូលរួមចំណែកក្នុងការអភិវឌ្ឍប្រាកដមែន។

## ឃ. បញ្ហានិកម្មភាព

បញ្ហានេះកើតមានច្រើននៅតាមបណ្ដាប្រទេសកំពុងអភិវឌ្ឍន៍ ភាគច្រើនប្រទេសនេះមានមនុស្សធ្វើចំណាកស្រុក ដើម្បីស្វែងរកការងារធ្វើនៅទីក្រុងដែលធ្វើឲ្យទីក្រុងមានមនុស្សច្រើនកុះ

ករ។ ការចំណាកស្រុកមកទីក្រុង គឺបណ្ដាលមកពីនិកម្មភាពនៅទីក្រុងមានកម្រិតទាប និងនៅជនបទពុំសូវមានការងារធ្វើ។ ការអភិវឌ្ឍរវាងទីក្រុង និងទីជនបទគ្មានភាពស្មើគ្នា និងការធ្វើអន្តោប្រវេសន៍របស់ជនបរទេសជាដើម ដែលធ្វើឲ្យបញ្ហានិកម្មភាពកើតមានកាន់តែច្រើនឡើង។

**ង. កត្តានយោបាយ**

កត្តាស្ថេរភាពនយោបាយជាទំនុកចិត្តដ៏សំខាន់ និង ខ្លាំងក្លាដែលជួយជំរុញឲ្យមាននូវកំណើនវិនិយោគក្នុងប្រទេស និងជាកត្តាចាំបាច់បំផុតដែលមនុស្សជាតិលើលោកត្រូវការដែលមិនអាចខ្វះបាន។ នៅពេលដែលប្រទេសមួយមានអស្ថេរភាពនយោបាយ នោះនឹងធ្វើឲ្យកើតមានវិបត្តិយ៉ាងច្រើនដូចជា អំពើហឹង្សា ការព្រាត់ប្រាស់គ្រួសារ អយុត្តិធម៌ក្នុងសង្គម និងការបាត់បង់សីលធម៌ក្នុងសង្គមជាដើម។

**ច. ការប្រើប្រាស់បច្ចេកវិទ្យានៅមានកម្រិតទាប**

បច្ចេកវិទ្យា គឺជា កាតាលីករមួយដ៏សំខាន់ដែលជួយជំរុញដល់កំណើនសេដ្ឋកិច្ចរបស់ប្រទេស ក៏ដូចជាទូទាំងសកលលោកផងដែរ។ បច្ចេកវិទ្យានាំមកនៅការចំណាយដើមទុនផលិតតិចតែទទួលបានផលិតផលច្រើន។ ប៉ុន្តែប្រសិនបើប្រទេសមួយដែលពុំមានការរីកចម្រើនផ្នែកបច្ចេកវិទ្យានោះទេ វានាំមកនូវផលវិបាកជាច្រើនដូចជា មិនអាចវាយលុកទៅទីផ្សារក្រៅប្រទេសបាន (ដោយសារតែផលិតផលទាំងនោះមានគុណភាពទាប ការចំណាយលើដំណើរការផលិតខ្ពស់)។ ទាំងនេះដោយសារការប្រើប្រាស់បច្ចេកវិទ្យានៅមានកម្រិតទាប។[9]

### ១.២.៦ បញ្ជាភាគបែងចែកប្រាក់ចំណូលរបស់វិទ្យាស្ថានជាតិស្ថិតិ

ជាទូទៅ ការបែងចែកកម្រិតជីវភាពប្រជាជននៅជនបផ្សេងៗ គេធ្វើតាមបញ្ជាភាគបែងចែកប្រាក់ចំណូលសុទ្ធសម្រាប់មនុស្សម្នាក់គិតជាតម្លៃជាមធ្យមក្នុងមួយខែ ដែលបែងចែកជា ៥ក្រុម (វិធី Quintile) ដូចខាងក្រោម៖

- ក្រុមទាបបំផុត មានប្រាក់ចំណូលសុទ្ធសម្រាប់មនុស្សម្នាក់គិតជាតម្លៃជាមធ្យមក្នុងមួយខែស្មើចន្លោះពី ៩៩០០០ ដល់ក្រោម ១៥៩០០០រៀល។
- ក្រុមទាបទីពីរ មានប្រាក់ចំណូលសុទ្ធសម្រាប់មនុស្សម្នាក់គិតជាតម្លៃជាមធ្យមក្នុងមួយខែស្មើចន្លោះពី ១៥៩០០០ ដល់ក្រោម ២៦៣០០០រៀល។

[9] សារណាបញ្ចប់ការសិក្សា "ការចូលរួមរបស់សហគ្រាសធុនតូច និងមធ្យមក្នុងការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា" របស់និស្សិត ពេជ្រ សម្បត្តិ និងជួរ ចន្ធារី ឆ្នាំសរសេរ ២០១២, ទំព័រទី១២

- ក្រុមកណ្តាល មានប្រាក់ចំណូលសុទ្ធសម្រាប់មនុស្សម្នាក់គិតជាតម្លៃជាមធ្យមក្នុងមួយខែស្មើចន្លោះពី ២៦៣០០០ ដល់ក្រោម ៣៩៣០០០រៀល។
- ក្រុមខ្ពស់ទីបួន មានប្រាក់ចំណូលសុទ្ធសម្រាប់មនុស្សម្នាក់គិតជាតម្លៃជាមធ្យមក្នុងមួយខែស្មើចន្លោះពី ៣៩៣០០០ ដល់ក្រោម ៨៧១០០០រៀល។
- ក្រុមខ្ពស់បំផុត មានប្រាក់ចំណូលសុទ្ធសម្រាប់មនុស្សម្នាក់គិតជាតម្លៃជាមធ្យមក្នុងមួយខែស្មើនឹង ៨៧១០០០រៀលឡើងទៅ។[10]

## ១.៣ ទ្រឹស្តីអ្នកប្រាជ្ញ

### ក. ទ្រឹស្តីលោក Michel P. Todaro

តាមទ្រឹស្តីនៃការអភិវឌ្ឍរបស់លោក MICHAEL P. TODARO សន្និដ្ឋានថា ការអភិវឌ្ឍមានអត្ថន័យទាំងពីរយ៉ាង គឺជាវិទ្យាសាស្ត្ររូបនិយមពិត និងជាភារៈដែលមាននៅក្នុងសង្គម តាមរយៈការរួមផ្សំមួយចំនួន នៃដំណើរការស្ថាប័នសេដ្ឋកិច្ច និងសង្គម ដែលបានផ្សារភ្ជាប់ ការអភិវឌ្ឍទៅនឹងការធ្វើឲ្យជីវិតមានភាពប្រសើរឡើង។ អ្វីដែលជាធាតុផ្សំនៃសមាសភាគជាក់ស្តែងទាំងឡាយ ដើម្បីឲ្យជីវិតប្រសើរឡើងនោះ គឺជាការអភិវឌ្ឍក្នុងសង្គមទាំងមូល ដែលត្រូវមានគោលដៅយ៉ាងហោចណាស់ ៣ ដូចខាងក្រោមនេះ ៖

ក. ដើម្បីបង្កើនភាពដែលអាចរកបាន រួមជាមួយនឹងការបំពេញតម្រូវការជាមូលដ្ឋាន ដូចជា អាហារ ទីជម្រក សុខភាព និងការការពារ ដើម្បីទ្រទ្រង់ជីវិត។

ខ. ដើម្បីលើកស្ទួយកម្រិតជីវភាពរស់នៅ និងការបន្ថែមប្រាក់ចំណូលឲ្យកាន់តែខ្ពស់ ផ្តល់ការងារ ការអប់រំល្អ ហើយនិងការយកចិត្តទុកដាក់ជាធំលើតម្លៃវប្បធម៌ និងមនុស្ស។ វាថែមទាំងអនុញ្ញាតឲ្យបុគ្គលម្នាក់ៗអាចប្រើប្រាស់វាដើម្បីលើកស្ទួយតម្លៃជាតិខ្លួនផងដែរ។

គ. ដើម្បីជំរុញតម្លៃសេដ្ឋកិច្ច និងបង្កើនជម្រើសនៅក្នុងសង្គម ដែលអាចទទួលយកបានជាលក្ខណៈបុគ្គល និងលក្ខណៈជាតិដោយធ្វើឲ្យពួកគេរួចផុតពីភាពអវិជ្ជា និងទុរគតភាព។[11]

### ខ. ទ្រឹស្តីរបស់លោក Mabud Vi-Haq

លោក Mabud Vi-Haq យល់ថា យើងត្រូវបានបង្រៀនអោយព្រួយបារម្ភអំពីផលិតផលជាតិសរុបពីព្រោះ វានឹងអាចដោះស្រាយបាននូវភាពក្រីក្រដើម្បីបង្កើននូវផលិតផលជាតិសរុប។ ការ

[10] "Cambodia Socio-Economic Survey 2016", National Institute of Statistics, Ministry of Planning, Phnom Penh, October 2017, page 74

[11] សារណាបញ្ចប់ការសិក្សា "ការអភិវឌ្ឍអគ្គិសនីភាវូបនីយកម្មជនបទដើម្បីកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ករណីភូមិព្រែកកែវ" របស់និស្សិត តឹក ហង្សនិតា និង ទូច ម៉េងឡេង ឆ្នាំសរសេរ ២០១៤, ទំព័រទី ៧

អភិវឌ្ឍគ្មានន័យទាល់តែសោះ បើអ្វីដែលវាសម្រេចបានគ្រាន់តែធ្វើអោយកើនឡើងនូវផលិតផលជាតិសរុបរបស់ប្រទេសមួយ។ យើងត្រូវតែប្រឈមមុខនឹងការពិតថាការអភិវឌ្ឍមានន័យ ប្រសិនបើវាអាចដោះស្រាយនូវតម្រូវការសង្គម។ គោលដៅសំខាន់ៗនៃការអភិវឌ្ឍដែលធ្វើអោយប្រសើរឡើងនូវគុណភាពជីវិតរបស់ប្រជាជន ការកើនឡើងនៃផលិតកម្ម ឬការរីកចម្រើនសេដ្ឋកិច្ច គឺគ្រាន់តែជាមធ្យោបាយដើម្បីសម្រេចអោយបានគោលដៅប៉ុណ្ណោះសម្រាប់ការអភិវឌ្ឍនៃប្រជាជន។ ការអភិវឌ្ឍនឹងគ្មានន័យ ប្រសិនបើវាគ្មានផ្តល់ផលប្រយោជន៍ដល់ជនក្រីក្រ។ ការអភិវឌ្ឍត្រូវតែធ្វើព្រមគ្នាទាំងបីផ្នែកគឺ ធ្វើការអភិវឌ្ឍ សេដ្ឋកិច្ច បុគ្គល និងសង្គមៈ

- ការអភិវឌ្ឍសេដ្ឋកិច្ចសំដៅលើ ការបង្កើនប្រាក់ដើម្បីបំប៉នជីវភាពគ្រួសារ។
- ការអភិវឌ្ឍបុគ្គលសំដៅលើ ការអភិវឌ្ឍស្មារតីរបស់បុគ្គលម្នាក់ៗ អោយគាត់យល់នូវអ្វីដែលល្អសម្រាប់សហគមន៍របស់គាត់។
- ការអភិវឌ្ឍសង្គមសំដៅលើ ការបង្កើនការយល់ដឹងជាមូលភាពរបស់សមាជិកសហគមន៍ទាំងអស់។

ចំពោះការបង្កើនវិជ្ជាជីវៈ គឺជាមធ្យោបាយសំខាន់សម្រាប់អោយគាត់មានប្រាជ្ញាឈ្លាសវៃមានការងារធ្វើ ហើយអាចធ្វើវិភាគទានពេញដល់សង្គមជាតិ ហើយមិនអាចទទួលយកគំនិតបុគ្គលនិយមជាគំនិតប្រឆាំងនឹងការងារអភិវឌ្ឍន៍បានទេ។[12]

**គ. ទ្រឹស្តីរបស់លោក Walt Withman Rostow**

ទ្រឹស្តីនេះចែកចេញជា ៥ ដំណាក់កាលគឺៈ

១. សង្គមប្រពៃណី : គឺជាសង្គមមួយដែលគ្មានកំណើនទាល់តែសោះ ហើយការផលិតធ្វើតែរៀងៗខ្លួន ដូចនេះផលដែលទទួលបានមានកម្រិតទាប។ ប្រជាជនយកមុខរបរកសិកម្ម ជាវិស័យចំបងក្នុងការផលិត ហើយពួកគេមិនមានគំនិតក្នុងការផ្លាស់ប្តូរអ្វីៗទាំងអស់ គឺ បណ្តោយតាមយថាកម្ម។

២. លក្ខណៈដែលធ្វើអោយមានការអភិវឌ្ឍ : វានឹងឈានទៅដល់កាលណាបើមានការចូលរួមបញ្ចូលឥទ្ធពលពិតប្រាកដ ដែលធ្វើអោយមានផលចំណេញដល់សង្គម ដែលការផ្លាស់ប្តូរនេះត្រូវបានដាក់ចេញមានដូចជាៈ

- ការពង្រីកហេដ្ឋារចនាសម្ព័ន្ធ

[12] សារណាបញ្ចប់ការសិក្សា "វិស័យកសិកម្ម និងការអភិវឌ្ឍ" របស់និស្សិត កង តារ៉ាវុធ និង ពូក សុភាព ឆ្នាំសរសេរ ២០១២, ទំព័រទី ៩

- ការធ្វើអោយប្រសើរឡើងផ្នែកបច្ចេកវិទ្យា-ត្រូវបង្ខំអោយលឿនជាពិសេសក្នុងវិស័យកសិកម្ម
- ការធ្វើអោយប្រជាជនមានសិទ្ធិជាម្ចាស់លើអចលនវត្ថុ ព្រមទាំងធ្វើអោយកើនឡើងនៃសន្សំ និងវិនិយោគ។ ជាប្រទេសដែលស្ថិតនៅចន្លោះអន្តរកាលនៃការអភិវឌ្ឍន៍។

៣. ដំណាក់កាលនៃការកើនឡើងនៃការអភិវឌ្ឍន៍ :

- វិស័យអត្ថិភាពនៃសេដ្ឋកិច្ចបានចាប់កំណើត និងរីកធំធាត់ជាលំដាប់
- កំណើនសេដ្ឋកិច្ចបានក្លាយទៅជាបញ្ហាសាមញ្ញ
- អាចរក្សាបានជាស្វ័យប្រវត្តិនូវស្ថេរភាពសេដ្ឋកិច្ច

ប្រសិនបើប្រទេសទាំងអស់មានចំណុចដូចគ្នាខាងលើ គេហៅប្រទេសទាំងនោះថា ជាប្រទេសឧស្សាហកម្មថ្មីដោយពឹងផ្អែកលើ :

- ភាពខ្លាំងក្លានៃអត្រាវិនិយោគ
- ស្ថេរភាពនយោបាយ និងស្ថាប័នដែលនាំអោយមានការរំកិលនៃកំណើន
- ការបង្កើតនូវឧស្សាហកម្មសំខាន់ៗ ដើម្បីជាការផ្លាស់ប្តូរ។

៤. ដំណាក់កាលទុំ : ការអភិវឌ្ឍ បានជ្រាបចូលទៅគ្រប់ច្រកល្ហក់នៅក្នុងផ្ទៃប្រទេស ជាពិសេសគឺ វិស័យថ្មីៗនៃផលិតកម្ម ដែលបានលេចឡើងជារចនាសម្ព័ន្ធនៃការផលិតបានចេញពីវិស័យកសិកម្មទៅឧស្សាហកម្ម។ ការអភិវឌ្ឍចេះតែឈានទៅមុខ ឧស្សាហកម្មដែលមានវ័យចំណាស់ត្រូវបានផ្លាស់ប្តូរចេញ ដោយធ្វើអោយមានភាពកាន់តែទំនើបថែមទៀត ឬវិស័យឧស្សាហកម្មថ្មី។

៥. ដំណាក់កាលនៃបំរើបំរាស់ក្នុងទ្រង់ទ្រាយធំ : ការផលិតទំនិញ និងសេវាកម្មក្នុងគោលបំណងប្រើប្រាស់ចុងក្រោយ ត្រូវបានធ្វើនៅលើវិស័យឧស្សាហកម្មនៃផលិតកម្មទំនិញ។ ដោយសារចំណូលរបស់ប្រជាជនកើនឡើង បានអនុញ្ញាតដល់ការប្រើប្រាស់ក្នុងទ្រង់ទ្រាយធំនៃទំនិញ ដែលមិនមានការចាំបាច់ ត្រង់ចំណុចនេះបញ្ជាក់ថា ៖

- សេចក្តីត្រូវការមូលដ្ឋាន ត្រូវបានដោះស្រាយជាស្ថាពរ
- មានការអភិវឌ្ឍវិស័យសុខុមាលភាពសង្គម
- អំណាចសេដ្ឋកិច្ចត្រូវបានពង្រីក។

លោក Walt Withman Rostow បានយកចិត្តទុកដាក់នូវភាពសំខាន់នៃការរីកសាយនៃគ្រឿងយន្តដែលមានតម្លៃថោក ដែលវាធ្វើអោយមានឥទ្ធិពលដល់ជីវិតនៃសង្គម ការបែងចែកប្រាក់ចំណូលថ្មី និងបង្កើតប្រព័ន្ធគ្រោងទុកនៃសង្គម។[13]

**ឃ. ទ្រឹស្តី Big Push**

អ្នកដែលបង្កើតទ្រឹស្តីនេះឡើងគឺ លោក Paul Rosenstein-Rodan នៅក្នុងឆ្នាំ ១៩៤៣ បន្ទាប់មកនៅក្នុងឆ្នាំ ១៩៨៩ លោក Murphy និង Robert W. Vishny បានយកម៉ូដែលសេដ្ឋកិច្ចនេះមកវិភាគនៅក្នុងទ្រឹស្តីល្បែង (Game theory)ទៀតផង។

Big push គឺជាទ្រឹស្តីដែលបង្ហាញអំពីកត្តាដែលធ្វើឲ្យប្រទេសនីមួយៗមានកំណើនសេដ្ឋកិច្ចតាមរយៈការបង្កើននូវការវិនិយោគឲ្យកាន់តែច្រើនទៅលើហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងការអប់រំ រួមផ្សំនឹងការវិនិយោគជាលក្ខណៈឯកជន វានឹងអាចធ្វើឲ្យកើនឡើងនូវផលិតភាពក្នុងការផលិតទំនិញ និងសេវា ។

ហើយទ្រឹស្តី Big push នេះក៏ជាទ្រឹស្តីមួយនៅក្នុងសេដ្ឋកិច្ចអភិវឌ្ឍន៍ ឬសេដ្ឋកិច្ចទីផ្សារសេរីដែលផ្តោតសំខាន់ទៅលើការសម្រេចចិត្តផ្ទាល់របស់សហគ្រាស ឬក្រុមហ៊ុនមុននឹងធ្វើអ្វីមួយ ឬមិនធ្វើវាមិនអាស្រ័យលើការសម្រេចចិត្តរបស់សហគ្រាស ឬក្រុមហ៊ុនផ្សេងទេ។ នៅពេលដែលសហគ្រាស ឬក្រុមហ៊ុនទាំងនោះរំពឹងទុកនឹងទទួលបានផលចំណេញពួកគេនឹងធ្វើសកម្មភាពអាជីវកម្ម និងឧស្សាហកម្មរបស់ពួកគេ។[14]

**ង. ទ្រឹស្តី Salter cycle**

យោងទៅតាមទ្រឹស្តី Salter cycle កំណើនសេដ្ឋកិច្ចនៃប្រទេសមួយ ឬតំបន់មួយ អាចកើតមានឡើងតាមរយៈការបង្កើននូវផលិតភាពផលិតកម្ម ដែលកាត់បន្ថយនូវបរិមាណ Inputs (ពលកម្ម, មូលធន, វត្ថុធាតុដើម, ថាមពល...) សម្រាប់ផលិតចេញជាផលិតផលសម្រេច (Output) ។

ការធ្វើឲ្យធ្លាក់ចុះនៃថ្លៃដើមផលិតកម្ម នាំឲ្យមានការកើនឡើងបរិមាណតម្រូវការទំនិញ និងសេវាកម្ម ក៏ដូចជាធ្វើឲ្យកើនឡើងការវិនិយោគឧបករណ៍ (Capital investment) ដើម្បីបង្កើនលទ្ធភាពផលិត ដែលវាគឺមានប្រសិទ្ធភាពខ្លាំងជាងមុនដោយសារបន្ថែមបច្ចេកវិទ្យាថ្មី និងរីកចម្រើនវិធីសាស្ត្រផលិត និង Economies of Scale ។[15]

---

[13] Rostow's stage of Growth ដកស្រង់ចេញពីសៀវភៅ Micheal P.Todaro Economic Development, Eight Edition

[14] មេរៀនក្នុងមុខវិជ្ជា "កំណើនសេដ្ឋកិច្ច" របស់សាស្ត្រាចារ្យ ហាស់ វង់ដារ៉ា ឆ្នាំសិក្សា ២០១៧-២០១៨, ទំព័រទី ៥៩

[15] មេរៀនក្នុងមុខវិជ្ជា "កំណើនសេដ្ឋកិច្ច" របស់សាស្ត្រាចារ្យ ហាស់ វង់ដារ៉ា ឆ្នាំសិក្សា ២០១៧-២០១៨, ទំព័រទី ៥៤

**ច. ទ្រឹស្តី Cognitive capitalism**

ទ្រឹស្តីនេះត្រូវបានបង្កើតឡើងដោយចិត្តវិទូ ២រូប គឺ Heiner Rindermann និង James Thompson។ លោកទាំងពីរបានអះអាងថា លទ្ធភាពនៃប្រាជ្ញាគឺជាកត្តាសំខាន់ណាស់ ដែលបង្កើតភាពសម្បូរសប្បាយនៅក្នុងសេដ្ឋកិច្ចទំនើប។ ប្រាជ្ញា ភាពឆ្លាតវៃ និងចំណេះដឹង គាំទ្រឲ្យមានការរុករកនូវគំនិតច្នៃប្រឌិតថ្មីៗនៃបច្ចេកវិទ្យា, ប្រសិទ្ធភាពកិច្ចការរដ្ឋបាល, ស្ថាប័នឯករាជ្យ និងសេរីភាពសេដ្ឋកិច្ច។[16]

# ១.៤ គោលនយោបាយ និងផែនការយុទ្ធសាស្ត្រដែលពាក់ព័ន្ធ

## ១.៤.១ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨

### ១.៤.១.១ ការអភិវឌ្ឍជនបទ

រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៥នៃរដ្ឋសភា នៅតែចាត់ទុកថាការកាត់បន្ថយភាពក្រីក្រតាមរបៀបមួយដ៏ឆាប់តាមដែលអាចធ្វើបាន គឺជាអាទិភាពដ៏ចម្បងមួយ។ ការអភិវឌ្ឍជនបទគឺមានសារៈសំខាន់បំផុតសម្រាប់ការកាត់បន្ថយភាពក្រីក្រ ដោយហេតុថាប្រជាជនក្រីក្រច្រើនជាង ៧៥% រស់នៅតាមជនបទ។ រាជរដ្ឋាភិបាល នឹងបន្តជំរុញការអនុវត្តកម្មវិធីអភិវឌ្ឍន៍ជនបទជម្រុះ ដែលផ្តោតការយកចិត្តទុកដាក់ជាសំខាន់ទៅលើកត្តា ដែលមានផលប៉ះពាល់ជាវិជ្ជមានទៅលើប្រជាពលរដ្ឋក្រីក្រនៅតាមតំបន់ជនបទ ដូចជាពង្រឹងសមត្ថភាពស្ថាប័ន និងការអភិវឌ្ឍធនធានមនុស្ស ការអនុវត្តការធ្វើផែនការមូលដ្ឋានចម្រុះ ការកសាងផ្លូវជនបទ ការផ្គត់ផ្គង់ទឹកនៅជនបទ ការថែទាំសុខភាពបឋមនិងការងារអនាម័យជនបទ ការអភិវឌ្ឍសហគន៍ និងការអភិវឌ្ឍសេដ្ឋកិច្ចជនបទ ដើម្បីលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាជនកម្ពុជាឲ្យមានភាពប្រសើរជាងមុន ជាពិសេស ប្រជាជននៅជនបទ។[17]

### ១.៤.១.២ គោលនយោបាយលើកស្ទួយវិស័យកសិកម្ម

**ក. ការលើកកម្ពស់ផលិតភាព ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្ម**

ក្នុងនីតិកាលទី៥នៃរដ្ឋសភា រាជរដ្ឋាភិបាលនឹងខិតខំរក្សាកំណើនក្នុងវិស័យកសិកម្មនេះឲ្យបានក្នុងរង្វង់ ៥% ក្នុងមួយឆ្នាំ ដោយបន្តលើកកម្ពស់ផលិតភាព ធ្វើពិពិធភាវូបនីយកម្ម និងធ្វើពាណិជ្ជូបនីយកម្ម។ រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើះ

- ការបន្តបង្កើនផលិតភាពស្រូវ និងដំណាំផ្សេងទៀត តាមរយៈការពង្រឹង ការពង្រីក និងការធានាចីរភាពនៃប្រព័ន្ធសេវាបច្ចេកទេស និងព័ត៌មានទីផ្សារកសិកម្ម។

---

[16] មេរៀនក្នុងមុខវិជ្ជា "កំណើនសេដ្ឋកិច្ច" របស់សាស្ត្រាចារ្យ ហាស់ វង់ដារ៉ា ឆ្នាំសិក្សា ២០១៧-២០១៨, ទំព័រទី ៥៣

[17] ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨, រាជរដ្ឋាភិបាលកម្ពុជា, ទំព័រទី២៤៣

- ការបន្តជំរុញពិពិធកម្ម តាមរយៈការលើកកម្ពស់ការស្រាវជ្រាវ និងការអភិវឌ្ឍ ការផ្សព្វផ្សាយមុខដំណាំថ្មីៗដែលមានសក្តានុពលសម្រាប់ដាំដុះ និងការនាំចេញ ការពង្រឹកបរិស្ថានអនុគ្រោះ សម្រាប់ទាក់ទាញការវិនិយោគឯកជន ពិសេសក្នុងការស្រាវជ្រាវ ការផលិត ការចែកចាយពូជ និងការកែច្នៃកសិកម្ម ការបង្កើនកិច្ចសហប្រតិបត្តិការជាមួយគ្រប់ដៃគូពាក់ព័ន្ធទាំងអស់ក្នុងការផ្ទេរចំណេះដឹង ចំណេះធ្វើ និងបច្ចេកវិទ្យាថ្មីៗដល់កសិករ និងការជំរុញការប្រើប្រាស់គ្រឿងយន្តកសិកម្ម។
- ការបន្តលើកកម្ពស់ពាណិជ្ជូបនីយកម្ម តាមរយៈការជំរុញការអនុវត្តច្បាប់ និងគោលនយោបាយព្រមទាំងការពង្រឹងយន្តការស្ថាប័ន ដើម្បីជំរុញការធ្វើពាណិជ្ជកម្ម និងការនាំចេញកសិផល រួមមានការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវច្បាប់ស្តីពីសហគមន៍កសិកម្ម ការលើកកម្ពស់សមត្ថភាពកែច្នៃ ការសម្រួលថែមទៀតនូវកិច្ចសម្រួលពាណិជ្ជកម្ម រួមមាននូវយន្តការ **ច្រកចេញចូលតែមួយ** ផង ការពង្រឹងប្រព័ន្ធឡូជិស្ទីក ការលើកស្ទួយគុណភាពកសិផលអោយស្របតាមបទដ្ឋានអន្តរជាតិ ការបង្កើនសមត្ថភាពក្នុងការផ្តល់ហិរញ្ញប្បទានតាមថ្លៃសមរម្យ ការលើកស្ទួយភាពជាដៃគូរវាងកសិករ និងពាណិជ្ជករ ក៏ដូចជារវាងកសិឧស្សាហកម្មខ្នាតធំ និងកសិកម្មលក្ខណៈគ្រួសារ។
- ការបន្តជំរុញការអនុវត្ត **គោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ** និង**យុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍកៅស៊ូធម្មជាតិនៅកម្ពុជាឆ្នាំ២០១១-២០២០** ឲ្យសម្រេចជោគជ័យតាមការគ្រោងទុក។
- ការជំរុញអោយអនុវត្តកម្មវិធីពិសេសសម្រាប់លើកកម្ពស់កសិករ ដែលពឹងផ្អែកលើកសិកម្មអោយទទួលបានសេវាហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុសម្រាប់ការងារកសិកម្ម ផលិតផលមានទីផ្សារ និងកំណត់តម្លៃច្បាស់លាស់។

## ខ. ការលើកកម្ពស់ការចិញ្ចឹមសត្វ និងវារីវប្បកម្ម

ក្នុងនីតិកាលទី៥នៃរដ្ឋសភានេះ រាជរដ្ឋាភិបាលមានគោលដៅជំរុញលើកកម្ពស់ចលនាចិញ្ចឹមសត្វ និងវារីវប្បកម្មអោយបានកាន់តែទូលំទូលាយថែមទៀត តាមរយៈការបង្កើតក្របខ័ណ្ឌគោលនយោបាយដែលផ្អែកលើគោលការណ៍ខ្សែសង្វាក់ ដើម្បីដោះស្រាយជាកញ្ចប់នូវបញ្ហាជាឧបសគ្គដល់ការអភិវឌ្ឍវិស័យទាំងនេះ ដោយគិតគូរផងដែលដល់បញ្ហាសុវត្ថិភាពចំណីអាហារ និងកិច្ចដំណើរការទីផ្សារ ពិសេសអនាម័យ និងភូតគាមអនាម័យ ទន្ទឹមនឹងការបន្តអនុវត្តវិធានការមុត

ស្រួចនានា សំដៅធានាចីរភាពនៃធនធានជលផលទាំងក្នុងដែនទឹកសាប និងសមុទ្រ។ រាជរដ្ឋាភិបាលនឹងផ្ដោតអាទិភាពលើ៖

- ការបន្តជំរុញអនុវត្ត **ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រវិស័យជលផល ២០១០-២០១៩** សំដៅបង្កើនផលិតផលត្រី។
- ការជំរុញការលើកកម្ពស់ការស្រាវជ្រាវ និងការអភិវឌ្ឍលើការបង្កាត់ពូជ ការគ្រប់គ្រងសុខភាពសត្វ ការផលិតចំណីសត្វ និងប្រព័ន្ធកសិដ្ឋាន ទាំងក្នុងវិស័យបសុសត្វ និងវារីវប្បកម្ម។
- ការជំរុញអនុម័តច្បាប់ស្ដីពីសុខភាពសត្វ និងផលិតកម្មសត្វ ដើម្បីជាមូលដ្ឋានសម្រាប់រៀបចំស្ថាប័ន និងគ្រប់គ្រងវិស័យនេះ ក្នុងគោលដៅពង្រឹងការអនុវត្តស្តង់ដារអនាម័យលើផលិតផលពីសត្វ ការពង្រឹង និងជំរុញអនុវត្តវិធានការអនាម័យសត្វ ភូតគាមអនាម័យដើម្បីបង្ការទប់ស្កាត់ និងលុបបំបាត់ការឆ្លងរាលដាលជំងឺសត្វ ក៏ដូចជាដើម្បីការពារសុខភាពសាធារណៈ។
- ការជំរុញលើកទឹកចិត្តការវិនិយោគលើការផលិតចំណីសត្វ ក្នុងទ្រង់ទ្រាយមធ្យម និងធំ ដើម្បីគាំទ្រដល់ចលនាចិញ្ចឹមសត្វ រួមជាមួយនឹងការលើកកម្ពស់ប្រព័ន្ធផ្តល់សេវាបច្ចេកទេស ពូជ ឥណទាន និងការរកទីផ្សារជូនកសិករ ការលើកកម្ពស់ការវិនិយោគឯកជនក្នុងការកែច្នៃផលិតផលបសុសត្វ និងផលិតផលជលផល ការបង្កើតសត្តឃាតដ្ឋានទំនើប ព្រមទាំងការសម្រួលពាណិជ្ជកម្មលើបសុសត្វ និងផលិតផលមានដើមកំណើតពីសត្វ និងផលិតផលជលផល។[18]

### ១.៤.១.៣ គោលនយោបាយទឹក និងប្រព័ន្ធធារាសាស្ត្រ

#### គោលនយោបាយអាទិភាពសំខាន់ៗសម្រាប់នីតិកាលទី៥

រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៥នៃរដ្ឋសភា នឹងបន្តលើកកម្ពស់ការគ្រប់គ្រងធនធានទឹកនិងការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រ បង្កើនប្រសិទ្ធភាពនៃការថែទាំ និងជួសជុលហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ ជំរុញសមាហរណកម្មប្រព័ន្ធធារាសាស្ត្រជាមួយនឹងការអភិវឌ្ឍវារីអគ្គិសនី និងប្រព័ន្ធដឹកជញ្ជូន ព្រមទាំងលើកកម្ពស់ការអភិវឌ្ឍក្របខ័ណ្ឌគតិយុត្ត ស្ថាប័ន និងធនធានមនុស្ស។ រាជរដ្ឋាភិបាល នឹងផ្តោតអាទិភាពលើ៖

[18] ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨, រាជរដ្ឋាភិបាលកម្ពុជា, ទំព័រទី២១០

- ការជំរុញវិត្ថារកម្មប្រព័ន្ធធារាសាស្ត្រ និងការបន្តរៀបចំប្រព័ន្ធប្រឡាយស្រោចស្រពអោយបានពេញលេញ ដោយយកចិត្តទុកដាក់ផងដែរដល់ភាពចាំបាច់ក្នុងការត្រៀមខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ។
- ការលើកកម្ពស់ប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រងធារាសាស្ត្រ ដោយផ្តោតលើការពង្រឹងក្របខ័ណ្ឌគោលនយោបាយ ក្របខ័ណ្ឌគិតយុត្ត (ពិសេស **ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា**) និងយន្តការនៃការប្រើប្រាស់ទឹក ការថែទាំ និងហិរញ្ញប្បទាន។
- ការបន្តពង្រីកវិសាលភាពនៃការផ្គត់ផ្គង់ទឹកស្អាតនៅតំបន់ជនបទ និងទីប្រជុំជន។
- ការបន្តខិតខំពង្រឹង និងពង្រីកយន្តការតាមដាន ព្យាករ និងផ្សព្វផ្សាយព័ត៌មានជលសាស្ត្រ និងឧតុនិយមឲ្យបានទាន់ពេលវេលា និងឲ្យកាន់តែមានសុក្រឹតភាព។[19]

**១.៥.១.៤ ការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងហេដ្ឋារចនាសម្ព័ន្ធគោលនយោបាយអាទិភាពសំខាន់ៗសម្រាប់នីតិកាលទី៥**

រាជរដ្ឋាភិបាលនីតិកាលទី៥ ដាក់ចេញនូវគោលដៅបន្តអភិវឌ្ឍបណ្តាញហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ដឹកជញ្ជូនគ្រប់ប្រភេទ ឲ្យក្លាយទៅជាប្រព័ន្ធភស្តុភារកម្មមួយដ៏រស់រវើក មានសុវត្ថិភាព និងមានប្រសិទ្ធភាព សំដៅរួមចំណែកលើកកម្ពស់ភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចជាតិ ព្រមទាំងជួយលើកស្ទួយសុខុមាលភាពរបស់ប្រជាជន។ រាជរដ្ឋាភិបាលនឹងផ្តល់អាទិភាពលើ៖

- ការបន្តជំរុញកសាងផ្លូវជាតិ ផ្លូវខេត្ត និងផ្លូវជនបទ ជាពិសេសការខិតខំក្រាលកៅស៊ូនិងចាក់បេតុង ផ្លូវជនបទឲ្យបានពី៣០០ទៅ៤០០គីឡូម៉ែត្រក្នុងមួយឆ្នាំ។
- ការបង្កើនការយកចិត្តទុកដាក់លើការជួសជុល និងការថែទាំប្រព័ន្ធគមនាគមន៍ដឹកជញ្ជូនពិសេសផ្លូវថ្នល់។
- ការរៀបចំ និងការអនុវត្ត**ផែនការមេនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ដឹកជញ្ជូន** ដើម្បីតភ្ជាប់ផ្ទៃក្នុងប្រទេសផង និងជាមួយប្រទេសជិតខាងផង។[20]

[19] ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨, រាជរដ្ឋាភិបាលកម្ពុជា, ទំព័រទី២៥៧

[20] ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨, រាជរដ្ឋាភិបាលកម្ពុជា, ទំព័រទី២៤៩

## ១.៤.២ យុទ្ធសាស្ត្រគាំទ្រខ្សែសង្វាក់ផលិតកម្ម

រូបភាព ១.១ ៖ យុទ្ធសាស្ត្រគាំទ្រខ្សែសង្វាក់ផលិតកម្ម

រូបភាពទី ១



រូបភាពទី ២



ប្រភព : សៀវភៅ "តើអ្វីជាការជំរុញចលនាភូមិ១ផលិតផល១?"

រូបភាពទីមួយ ចង់បង្ហាញពីការសហការធ្វើអោយសម្រេចនូវខ្សែសង្វាក់ផលិតកម្ម ដោយកិច្ចសហការគ្នានៃថ្នាក់ជាតិ ដែលមានគណៈកម្មាធិការជាតិជំរុញចលនាភូមិ១ផលិតផល១ ដោយមានអគ្គលេខាធិការដ្ឋានជាសេនាធិការ និងថ្នាក់ក្រោមជាតិ ព្រមទាំងដៃគូនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិទាំងឡាយ។ ខ្សែសង្វាក់ផលិតកម្ម ផ្សំឡើងដោយកង់មូល៣ ដែលធានាថាជោគជ័យលុះត្រាតែកង់ទាំង៣ វិលស្របគ្នា ពោលគឺកង់ផលិតកម្មវត្ថុធាតុដើម ដែលផលិតអោយអស់សក្តានុពល ហើយត្រូវបានបន្តដោយការកែច្នៃយ៉ាងម៉ត់ចត់ និងត្រូវបានយកទៅលក់ដាច់នៅលើទីផ្សារថែមទៀត។ ប៉ុន្តែរូបនេះក៏បង្ហាញផងដែរថា កង់មូលទី១ ត្រូវបានធ្វើហើយ អាចត្រូវរំលង់ទៅកង់ទី៣ គឺការរកទីផ្សារលក់ផលិតផលអោយបានដាច់អស់ ដោយមិនទាន់បានកែច្នៃក៏បាន សម្រាប់ប្រទេសយើងដែលនៅខ្វះការពង្រីកសិប្បកម្ម ឬឧស្សាហកម្មកែច្នៃនោះ។ ដោយឡែករូបទី២ គឺចង់សំដៅពីភាពរលូននៃកង់ទាំង៣ ដែលអាចបន្សីជាកង់ធំតែមួយ មានន័យថា កង់មូលទាំង៣ ត្រូវបានវិលស្របគ្នាតែម្តង គឺក្រោយពីការផលិតនូវផលិតផលដំបូង ជាវត្ថុធាតុដើមអោយអស់សក្តានុពលហើយ គឺបន្តដោយការកែច្នៃប្រកបដោយសក្តានុពល និងអាចបន្តចែកចាយ ដាក់លក់លើទីផ្សារទាំងក្នុង និងក្រៅប្រទេសរហូតបានលក់ដាច់ថែមទៀត។[21]

### ១.៤.៣ គោលនយោបាយអភិវឌ្ឍកសិកម្ម

**ការបង្កើតជាមជ្ឈមណ្ឌលកសិកម្មគំរូ**

សំដៅលើ ការបង្កើតអោយមានជាមជ្ឈមណ្ឌលកសិកម្មគំរូ ដែលជាកន្លែងពិសោធន៍ស្រាវជ្រាវ និងរក្សាស្នាដៃសម្រាប់ការផ្សព្វផ្សាយ និងបណ្តុះបណ្តាលដល់កសិករដែលមានបំណង

[21] សៀវភៅ "តើអ្វីជាការជំរុញចលនាភូមិ១ផលិតផល១?" និពន្ធដោយ ហាស់ វង់ដារ៉ា ឆ្នាំ២០១៦, ទំព័រទី៤៥

ចង់អភិវឌ្ឍន៍ដំណាំណាមួយនោះ។ គប្បីបង្កើតអោយបានច្រើនកន្លែង និងច្រើនឯកទេស ដើម្បីងាយស្រួលក្នុងការចូលរួមរបស់កសិករ ដែលមជ្ឈមណ្ឌលនេះត្រូវបានទ្រទ្រង់ដោយហិរញ្ញវត្ថុសាធារណៈ។[22]

### ១.៤.៤ គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម

**ក. ចក្ខុវិស័យ** : ប្រែក្លាយពីឧស្សាហកម្មអតិពលកម្ម ទៅជាឧស្សាហកម្មអតិជំនាញត្រឹមឆ្នាំ២០១៥។

**ខ. គោលដៅចំនួនបី** ដែលបានកំណត់ក្នុងគោលនយោបាយនេះ ៖

- បង្កើនចំណែកវិស័យឧស្សាហកម្មក្នុង ផលិតផលក្នុងស្រុកសរុប អោយបានដល់ ៣០% នៅឆ្នាំ២០២៥
- ជំរុញពិពិធកម្មទំនិញនាំចេញ ដោយបង្កើនការនាំចេញទំនិញកម្មន្តសាល មិនមែនវាយនភ័ណ្ឌអោយបាន ១៥% នៃបរិមាណនាំចេញសរុបនៅឆ្នាំ ២០២៥ ទន្ទឹមនឹងជំរុញការនាំចេញទំនិញកែច្នៃកសិកម្មអោយបាន ១២% នៃបរិមាណនាំចេញសរុបនៅឆ្នាំ ២០២៥
- ត្រឹមឆ្នាំ ២០២៥ អោយសហគ្រាសធុនតូចចំនួន ៨០% និងសហគ្រាសធុនមធ្យមចំនួន ៩៥% ត្រូវបានចុះបញ្ជីការគណនេយ្យ និងតារាងតុល្យការត្រឹមត្រូវ។

**គ. យុទ្ធសាស្ត្រគន្លឹះបួន** ដើម្បីសម្រេចបានគោលដៅខាងលើនៃគោលនយោបាយនេះ ៖

- កៀរគរ និងទាក់ទាញវិនិយោគផ្ទាល់ពីបរទេស និងវិនិយោគឯកជន ដោយផ្តោតលើឧស្សាហកម្មធំៗ ព្រមទាំងការអភិវឌ្ឍ និងផ្ទេរបច្ចេកវិទ្យា
- អភិវឌ្ឍន៍ និងធ្វើទំនើបកម្មសហគ្រាសធុនតូច និងមធ្យម
- កែលម្អបរិស្ថាននិយ័តកម្ម ដើម្បីពង្រឹងភាពប្រកួតប្រជែង
- សម្របសម្រួលគោលនយោបាយគាំទ្រ (ការអភិវឌ្ឍធនធានមនុស្ស / បណ្តុះបណ្តាលជំនាញ, កែលម្អទំនាក់ទំនងឧស្សាហកម្ម, ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រ និងប្រព័ន្ធបច្ចេកវិទ្យា)។[23]

---

[22] អត្ថបទមេរៀន មុខវិជ្ជា "សេដ្ឋកិច្ចកសិកម្ម" បង្រៀនដោយសាស្ត្រាចារ្យបណ្ឌិត ឈុន ពហុ ឆ្នាំសិក្សា ២០១៦-២០១៧

[23] បទបង្ហាញ "កម្ពុជា អតីតកាល បច្ចុប្បន្ន និងអនាគត", បង្ហាញដោយ ឯកឧត្តម វង្សី វិស្សុត រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាអនុប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ, ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១៧

## **១.៤.៥ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣**[24]

រូបភាព ១.២ ៖ គំនូសបំព្រួញ យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី ៣




## **១.៤.៦ យុទ្ធសាស្ត្រនៃការអភិវឌ្ឍសហគមន៍**

### **ក. ការបង្កើតសកម្មភាពអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន**

បង្កើនសន្តិសុខស្បៀងនៅក្នុងតំបន់របស់អង្គការ តាមរយៈការពង្រឹងសមត្ថភាពបុគ្គលិកជាពិសេសកសិករ ដើម្បីធានានូវការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពក្នុងការអភិវឌ្ឍកសិកម្មក្នុងការបង្កើនមុខដំណាំដាំដុះ និងសកម្មភាពរកប្រាក់ចំណូលផ្សេងៗទៀត។

ទិសដៅនេះសម្រេចទៅបានតាមរយៈ ៖

- ការជួយអោយកសិករប្រើប្រាស់បច្ចេកទេស និងឧបករណ៍ទំនើបដើម្បីបង្កើនទិន្នផលកសិកម្មអោយប្រសើរឡើង ដោយធានានូវស្បៀងអាហារដែលគ្មានគ្រោះថ្នាក់ និងមានជីវជាតិសម្រាប់ធានាដល់សុខភាពរបស់មនុស្ស ដើម្បីឆ្លើយតបទៅនឹងកម្រិតជីវភាពប្រចាំថ្ងៃ។
- ពង្រឹងផលិតកម្មពីដំណាំស្រូវទៅដំណាំផ្សេងៗទៀត តាមរយៈការបង្កើនមុខដំណាំដាំដុះនានា។

[24] សៀវភៅ "យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី ៣" របស់រាជរដ្ឋាភិបាលនីតិកាលទី ៥ នៃរដ្ឋសភា, រាជធានីភ្នំពេញ ខែកញ្ញា ឆ្នាំ ២០១៣

- ផ្តល់ឱកាសបន្ថែមទៀតដល់កសិករក្នុងការរកប្រាក់ចំណូល ដូចជាការចិញ្ចឹមត្រី ជ្រូក មាន់ ទា ជំនួញខ្នាតតូចជាដើម។
- ផ្តល់សេវាចាំបាច់ជាមូលដ្ឋានដូចជា ហេដ្ឋារចនាសម្ព័ន្ធ និងគាំទ្រតាមរយៈការស្តារ ជួសជុល និងថែរក្សានូវបណ្តាញផ្លូវថ្នល់ និងប្រព័ន្ធធារាសាស្ត្រ។

**ខ. ការអភិវឌ្ឍសង្គម**

បង្កើនដោយប្រសិទ្ធភាព និងភាពសក្តិសិទ្ធនូវលទ្ធផលទទួលសេវាសង្គម ដូចជាសុខាភិបាល ទឹកស្អាត និងអនាម័យ ព្រមទាំងការអប់រំ។

- បង្កើនសមត្ថភាពបុគ្គលិករបស់សហគមន៍លើទិដ្ឋភាពបច្ចេកទេស ក៏ដូចជាការគ្រប់គ្រង ដើម្បីធានាការផ្តល់សេវាកម្មប្រកបដោយប្រសិទ្ធភាព និងភាពសក្តិសិទ្ធ។
- បង្កើនការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីបញ្ហាសុខភាព ដើម្បីធានាការចូលរួមរបស់ប្រជាពលរដ្ឋក្នុងគ្រប់សកម្មភាព ការអប់រំពីបញ្ហាសុខភាព និងទឹកស្អាត។
- ផ្តល់លទ្ធភាពក្នុងការប្រើប្រាស់សេវាទឹកស្អាត និងអនាគតដោយអនុវត្ត អណ្តូងស្នប់មួយសម្រាប់ ៣-៥គ្រួសារ អណ្តូងល្អមួយសម្រាប់ ៣-៥គ្រួសារ។
- លើកទឹកចិត្តស្ត្រីអោយចូលរួមក្នុងសកម្មភាពអភិវឌ្ឍន៍។
- បញ្ចូលបញ្ហានានា ដែលទាក់ទងនឹងតុល្យភាពបុរស និងស្ត្រី ទៅក្នុងរាល់កិច្ចខិតខំប្រឹងប្រែងក្នុងការងារអភិវឌ្ឍសហគមន៍។
- ផ្តល់នូវការបណ្តុះបណ្តាលអំពីការកសាងផែនការដល់បុគ្គលិករបស់ខ្លួន ជនបង្គោលរបស់ខ្លួន ជនបង្គោលរបស់ផែនការ និងថ្នាក់ដឹកនាំសហគមន៍។

**គ. ការពង្រឹងស្ថាប័ន**

ផ្តល់នូវឧបករណ៍សម្ភារៈសម្រាប់ធ្វើដំណើរការ និងការបណ្តុះបណ្តាលដល់បុគ្គលិកលើការងារគ្រប់គ្រង និងបច្ចេកទេសជំនាញ ដូចជាកសាងផែនការគម្រោង និងរៀបចំផែនការ ការគ្រប់គ្រងហិរញ្ញវត្ថុ ការគ្រប់គ្រងកិច្ចសន្យា ការអនុវត្ត ការត្រួតពិនិត្យ និងវាយតម្លៃ។

**ឃ. ការបង្កើនការចូលរួមពីប្រជាជនក្នុងសកម្មភាពអភិវឌ្ឍន៍**

ការចូលរួមរបស់សហគមន៍ គឺចាំបាច់បំផុតសម្រាប់អភិវឌ្ឍ ប្រកបដោយជោគជ័យ និងនិរន្តភាព។ ដូច្នេះរចនាសម្ព័ន្ធអភិវឌ្ឍន៍ នឹងត្រូវបង្កើតឡើងដោយទទួលការបណ្តុះបណ្តាល បំពាក់

ឧបករណ៍ សម្ភារៈ និងទទួលនូវសិទ្ធិអំណាច ដើម្បីធានានូវការចូលរួមយ៉ាងពេញលេញក្នុងការកសាងផែនការ ការអនុវត្ត ការគ្រប់គ្រង ការត្រួតពិនិត្យ និងវាយតម្លៃសកម្មភាពអភិវឌ្ឍន៍។[25]

## ១.៥ បទពិសោធន៍បរទេស : បទពិសោធន៍ភូមិ១ផលិតផល១

**ក. ទីកន្លែងចាប់ផ្ដើម**: ខេត្តអយតា (Oita Prefecture) នៃប្រទេសជប៉ុន

- ស្ថិតនៅផ្នែកខាងត្បូង (ឬខាងក្រោមនៃផែនទីប្រទេសជប៉ុន) ពោលគឺខេត្តនេះស្ថិតនៅខាងជើងឆៀងខាងកើតនៃកោះ គ្យូស្យុ (Kyushu) ហើយដែលកោះនេះស្ថិតនៅភាគខាងត្បូងនៃប្រទេសជប៉ុន។
- មានផ្ទៃក្រឡាប្រមាណ ៦,៣៣៩គីឡូម៉ែត្រក្រឡា និងមានប្រវែងពីកើតទៅលិច ១១៩ គីឡូម៉ែត្រ និងពីជើងទៅត្បូងប្រវែង ១០៦គីឡូម៉ែត្រ។
- មានប្រជាជនសរុប (ថយចុះ) គឺ ១,២៧៧,០០០នាក់នៅឆ្នាំ១៩៥៥ បានថយមក ១,១៥៦,០០០នាក់ក្នុងឆ្នាំ១៩៧០ បានកើនឡើងវិញដល់ ១,២៥០,០០០នាក់នៅឆ្នាំ១៩៨៥ និងធ្លាក់មក ១,២៣១,០០០នាក់នៅឆ្នាំ១៩៩៥ (និងថយមកនៅ ១,១៦៦,៧២៩នាក់នៅឆ្នាំ ២០១៥)។
- មានដង់ស៊ីតេប្រជាជន ៦៩៤,១នាក់ ក្នុងមួយគីឡូម៉ែត្រការ៉េ នៅឆ្នាំ១៩៩៥ (និង១៨៤នាក់នៅឆ្នាំ២០១៥)។
- មានអត្រាកើត ០,៩១% និងអត្រាស្លាប់០,៨៧% នៅឆ្នាំ១៩៩៧។
- ប្រជាជនម្នាក់ៗ៖ នៅឆ្នាំ១៩៩៥ មាន២,៦៩៨,០០០យ៉េន នៅឆ្នាំ១៩៩៦មាន២,៧២៧,០០០ យ៉េន និងនៅឆ្នាំ២០០០មាន២,៧៥៦,០០០យ៉េន។
- មានផ្ទៃប្រមាណតែ២៨%តែប៉ុណ្ណោះដែលមនុស្សអាចរស់នៅបាន មានន័យថា ៧២%ជាតំបន់ព្រៃភ្នំ។
- បែងចែកជា ៥តំបន់ ដែលមានអាកាសធាតុខុសៗគ្នា។

**ខ. អ្នកផ្ដួចផ្ដើម : លោក ម៉ូរីហ៊ីកូ ហ៊ីរ៉ាមាត្សូ (Morihiko HIRAMATSU)**

- លោកទទួលបានសញ្ញាបត្រច្បាប់ពី សាកលវិទ្យាល័យតូក្យូ និងក្រោយមកទទួលបានសញ្ញាបត្របណ្ឌិតពីសាកលវិទ្យាល័យអាស៊ីប៉ាស៊ីភិច ឬសាកលវិទ្យាល័យរិត្សូម៉េខាន់ (APU) ដែលលោកបានបង្កើតឡើង ដោយសារកត្តាជោគជ័យ នៃចលនាភូមិ១ផលិតផល១របស់ខេត្តនេះ។

---

[25] Cheam Phan Viriya, (October 2004). CICP Working Paper. *NGOs Approach to Community Development in Rural Cambodia. No 30*

- លោកធ្លាប់ជាមន្ត្រីជាន់ខ្ពស់ នៅក្រសួងពាណិជ្ជកម្ម និងឧស្សាហកម្ម (MIT) ដែលសព្វថ្ងៃជាក្រសួងពាណិជ្ជកម្មអន្តរជាតិ និងឧស្សាហកម្ម។
- លោកត្រូវបានតែងតាំងជាអភិបាលរងខេត្ត អយតា នៅឆ្នាំ១៩៧៥។
- លោកត្រូវបានជាប់ឆ្នោតជាចៅហ្វាយខេត្ត អយតា នៅឆ្នាំ១៩៧៩ និងបានបម្រើខេត្តអយតារយៈពេល២៤ឆ្នាំ ដោយបានជាប់ឆ្នោតបីលើកជាប់ៗគ្នា និងបានចូលនិវត្តន៍ នៅឆ្នាំ២០០៣។
- លោកបានជំរុញអោយមានការរីកលូតលាស់រស់រវើកនៅក្នុងខេត្តអយតាចាប់ពីឆ្នាំ ១៩៧៩ ដោយសារចលនាភូមិ១ផលិតផល១របស់លោក។
- លោកទទួលបានការកោតសរសើរយ៉ាងក្រៃលែងទាំងក្នុង និងក្រៅប្រទេសនូវអ្វីដែលជាសមិទ្ធិផលជោគជ័យនៃការជម្រុញចលនាភូមិ១ផលិតផល១នេះ។
- លោកបានទទួលរង្វាន់ជាតិ និងអន្តរជាតិជាច្រើន ដោយសារការអភិវឌ្ឍទាំងក្នុងនិងក្រៅប្រទេសតាមចលនាភូមិ១ផលិតផល១នេះ។
- លោកបានទទួលមរណៈភាពនៅថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ក្នុងជន្មាយុ ៩២ឆ្នាំ។

**គ. គោលបំណងនៃចលនាភូមិ១ផលិតផល១ នៅខេត្តអយតា**

- ដើម្បីអោយប្រជាជននៅខេត្តអយតាទាំងអស់ មានចំណូលក្នុងម្នាក់ៗប្រហាក់ប្រហែលនឹងចំណូលប្រជាជននៅសហរដ្ឋអាមេរិក។
- ដើម្បីទទួលបាននូវការផ្លាស់ប្តូរពីសង្គមមួយដែលគិតពីផលិតកម្មដុល ឬកំណើននៃចំណូលទៅសង្គមមួយ ដែលគិតពីការពេញចិត្តជាធំ ពោលគឺ ធ្វើអោយប្រជាជនទាំងអស់មានអារម្មណ៍ពេញចិត្តទាំងស្រុង ចំពោះការរស់នៅរបស់ខ្លួននៅក្នុងភូមិស្ថានសហគមន៍នីមួយៗ។
- ដើម្បីអោយសហគមន៍នីមួយៗ អាចពុះពារបង្កើត និងរកទីផ្សារបានសំរាប់ផលិតផលមួយ ឬច្រើន ហើយដែលជាប្រភពនៃមោទនភាពសំរាប់ប្រជាជននៅក្នុងសហគមន៍នោះដោយប្រើប្រាស់សក្តានុពលធនធានទាំងឡាយតាមមូលដ្ឋាន ធ្វើយ៉ាងណាបង្កើតអោយបាននូវផលិតផលពិសេស ដែលមានតម្លៃបន្ថែមខ្ពស់ និងរក្សាបាននូវប្រព័ន្ធបរិស្ថានវិទ្យា និងបរិស្ថានល្អ។
- គោលបំណងចុងក្រោយបង្អស់នៃចលនានេះ គឺធ្វើយ៉ាងណាបង្កើតអោយបាននូវអ្វីៗដែលជាមោទនភាពដល់ប្រជាជន ចំពោះទីក្រុង និងភូមិឋានរបស់ខ្លួន និងធ្វើអោយមនុស្សគ្រប់វ័យទាំងអស់ ក្លាយជាម្ចាស់លើជោគវាសនារបស់ខ្លួន។

## ឃ. របៀបដំណើរការនៃចលនាភូមិ១ផលិតផល១នៅខេត្តអយតា

រូបភាព ១.៣ ៖ របៀបដែលបានដំណើរការនៅក្នុងចលនាភូមិ១ផលិតផល១នៅខេត្តអយតា




ប្រភព : សៀវភៅ "តើអ្វីជាការជំរុញចលនាភូមិ១ផលិតផល១?"

តាមរូបភាពខាងលើ រដ្ឋបាលមូលដ្ឋានដើរតួនាទីដ៏សំខាន់ៗមួយចំនួន ដូចជាជួយតម្រង់ទិសការអនុវត្តចលនា ការបង្ហាញពីគម្រូដែលបានធ្វើការត្រួតពិនិត្យការអនុវត្តការងារដោយស្តាប់សម្លេងផ្ទាល់ពីក្រុមការងារ និងប្រជាជននៅមូលដ្ឋាន តាមរយៈការជួបជុំនៅទីក្រុងតូចៗតាមភូមិ ការគាំទ្រផ្នែកបច្ចេកទេស ការគាំទ្រផ្នែកគ្រប់គ្រង និងការជួយគាំទ្រជំរុញសេវាទីផ្សារ។ល។រដ្ឋបាលមូលដ្ឋានជួយការងារទាំងនេះ ដោយឈរលើគោលការណ៍គ្រឹះសំខាន់បី គឺទី១-គិតជាសកលដោយធ្វើតាមមូលដ្ឋាន ទី២-ភាពម្ចាស់ការ ឬការពឹងផ្អែកលើខ្លួនឯង និងគំនិតច្នៃប្រឌិតរស់រវើក និងទី៣-ការ ជម្រុញអភិវឌ្ឍន៍ធនធានមនុស្ស។

តួនាទីសំខាន់ៗរបស់រដ្ឋបាលមូលដ្ឋាន ត្រូវធ្វើដោយមានគោលការណ៍គ្រឹះសំខាន់បី ដូចបានលើកឡើងខាងលើ គឺធ្វើយ៉ាងណាជួយប្រជាជននៅតាមមូលដ្ឋាន អោយសម្រេចគោលបំណងបី ទី១-ផ្លាស់ប្តូរផ្នត់គំនិតពីការគិតថា ធ្វើអ្វីមិនកើត ឬគំនិតអវិជ្ជមាន ទៅការគិតថាអាចធ្វើអ្វីៗកើត ឬគំនិតវិជ្ជមាន។ ទី២-រៀបចំការងារជំរុញទីផ្សារ អោយមានលក្ខណៈជាប្រព័ន្ធ ដែលតាមគំនិតរបស់លោក ម៉ូរីហ៊ីកូ ហ៊ីរ៉ាមាត្សុ ឬតាមទស្សនទានភូមិ១ផលិតផល១ គឺការផ្តួចផ្តើមគំនិតទីផ្សារលក់ឲ្យបានប្រសើរ ឬទីផ្សារលក់អោយដល់កំពូល ការផ្គត់ផ្គង់ខ្សែសង្វាក់ផលិតកម្មដោយផ្ទាល់ និងការយកចិត្តទុកដាក់លើស្លាកយីហោ។ ទី៣- ការបញ្ចូលបច្ចេកវិទ្យាទំនើប និងសហគ្រិនភាពក្នុងការអភិវឌ្ឍផលិតផលភូម១ផលិតផល១ លើគ្រប់ខ្សែសង្វាក់ផលិតកម្ម។

## ង. គោលការណ៍ជាមូលដ្ឋាន :

រូបភាព ១.៤ ៖ គោលការណ៍ ៣ របស់ចលនាភូមិ១ផលិតផល១




ប្រភព : សៀវភៅ "តើអ្វីជាការជំរុញចលនាភូមិ១ផលិតផល១?"

១. គិតជាសាកល ដោយធ្វើតាមមូលដ្ឋាន (Think globally, Act locally)

ចង់សំដៅលើគំនិតដែលថា ជាមួយនឹងវប្បធម៌ និងលក្ខណ:ពិសេសផ្សេងៗ ដែលមានតាមមូលដ្ឋាន ពួកគេបង្កើតផលិតផលទាំងឡាយ ដែលអាចរកទីផ្សារបានទូទាំងប្រទេសជប៉ុន និងពិភពលោកទាំងមូល។ យើងអាចលំអិតគំនិតនេះបន្ថែមទៀតថា៖

- ផលិតផលពិសេសៗតាមមូលដ្ឋាន អាចលក់បានមិនត្រឹមតែទីផ្សារក្នុងទីក្រុងតូក្យូទេ ប៉ុន្តែថែមទាំងអាចលក់បាននូវលើផ្សារអន្តរជាតិ និងទទួលបាននូវកិត្តិយស កិត្តិនាម ហើយនិងភាពល្បីល្បាញនៅលើសាកលលោកទៀត។
- ឧទាហរណ៍ : ការបណ្តុះផ្សិត ស៊ីអ៊ីតាកេ (Shiitake mushrooms) នៅលើទីផ្សារផ្សិតផលិតនៅប្រទេសជប៉ុន។ គួរកត់សំគាល់ដែរថាផលិតផលដែលលក់បានតម្លៃជាង ១,០០០លានយ៉េន ក្នុងមួយឆ្នាំមានដូចជា៖ ១-ខ្ទឹមសបារាំង ២-គោបានហ្គោ ៣-សិប្បកម្មពីឫស្សី ៤-ក្រូចក្វិច ៥-ស្លឹកថ្នាំពិសេសម៉្យាង ៦-ត្រីស្រស់ ៧-ត្រីងៀតបាល ៨-ត្រីចិញ្ចឹមកន្ទុយលឿង ៩-ស្លឹកថ្នាំជក់ ១០-ផ្លែព័រអាស៊ី ១១-ទឹកដោះគោ ១២-ផ្សិតអេណូគី ១៣-ត្រីម៉្យាងនៅសមុទ្រប៉េភុ ១៤-បង្កង ១៥-ស្រាសូស៊ុ។ល។
- យើងអាចចោទសួរថាតើហេតុអ្វីផលិតផលទាំងនេះពិសេស? លោកអភិបាលខេត្តអយតាបានពន្យល់គួរអោយចាប់អារម្មណ៍ថាផលិតផលទាំងនេះ ថ្លៃជាងរថយន្តគិតក្នុងទម្ងន់ដូចគ្នា ឧទាហរណ៍ ផ្សិតស៊ីអ៊ីតាកេក្នុង១០០ក្រាមថ្លៃ ១៧០០យ៉េន ដែលត្រូវនឹង១៦.២០$ រីឯរថ

យន្ត១៥០០គីឡូក្រាមថ្លៃ ៣លានយ៉េន បើគិតក្នុង១០០ក្រាមថ្លៃតែ២០០យ៉េនគឺស្មើនឹងជាង ១$ ប៉ុណ្ណោះ(ពេលនោះ)។

- គំនិតមួយទៀតគឺថា ជាជាងការលើកទឹកចិត្តក្រុមហ៊ុនមួយអោយមកវិនិយោគ សាងសង់រោងចក្រនៅខេត្តអយតា ដែលជាការជំរុញការអភិវឌ្ឍមួយពឹងផ្អែកលើផ្នែកខាងក្រៅ ខេត្តសម្រេចជ្រើសយកការប្រើប្រាស់ឲ្យអស់សក្តានុពលនៃធនធានមូលដ្ឋាន ដែលខ្លួនមានដើម្បីបង្កើតផលិតផលពិសេស ដែលមានតម្លៃបន្ថែមខ្ពស់ និងរក្សាបាននូវបរិស្ថានល្អថែមទៀត។
- ដើម្បីពង្រឹងគោលការណ៍នេះ ជាពិសេសការជួយសម្រួលក្នុងការផលិតនូវផលិតផលឬធ្វើសកម្មភាពផ្សេងទៀត ខេត្តអយតាបានបង្កើតមជ្ឈមណ្ឌល ឬទីកន្លែងសំខាន់មួយចំនួនដូចជាការបង្កើត៖ ទី១-មជ្ឈមណ្ឌលណែនាំដំណើរការ ផលិតនូវផលិតផលកសិកម្មនិងត្រី ទី២-មជ្ឈមណ្ឌលផ្តល់ការណែនាំ និងស្រាវជ្រាវផ្សិត ទី៣-មជ្ឈមណ្ឌលវិទ្យាសាស្ត្រសម្រាប់សមុទ្រនិងត្រី ទី៤-មជ្ឈមណ្ឌលបច្ចេកវិទ្យាកសិកម្ម ទី៥-ស្ថានីយ៍ពិសោធន៍ក្រូច ទី៦-មជ្ឈមណ្ឌលផ្តល់ការណែនាំ និងស្រាវជ្រាវអំពីទឹកក្តៅ ទី៧-ស្ថានីយ៍ពិសោធន៍បសុសត្វ និងទី៨-មជ្ឈមណ្ឌលពិសោធន៍បច្ចេកវិទ្យាឧស្សាហកម្មជាដើម។ល។

២. ភាពម្ចាស់ការឬការពឹងផ្អែកលើខ្លួនឯង និងការច្នៃប្រឌិតរស់រវើក(Independence/Self-reliance and Creativity)

មានន័យថាប្រជាជនក្នុងស្រុកអាចសម្រេចនូវផលិតផលអ្វីៗទាំងទំនិញនិងសេវាកម្មសំរាប់ចលនាភូមិ១ផលិតផល១របស់ពួកគេ។ គួរកត់សម្គាល់ថាភូមិ១អាចជ្រើសយកផលិតផល៣ ឬភូមិ២រួមគ្នាដើម្បីបង្កើតផលិតផល១។ រដ្ឋបាលមូលដ្ឋាននឹងផ្តល់ជំនួយផ្នែកបច្ចេកទេស និងការរកទីផ្សារ ហើយយើងអាចលំអិតគំនិតនេះបន្ថែមដូចខាងក្រោម៖

- សហគមន៍នីមួយៗ ជ្រើសយកផលិតផលនិងប្រើប្រាស់ការច្នៃប្រឌិតរស់រវើករបស់ខ្លួនដើម្បីផលិតនូវផលិតផលទាំងនោះ។
- ភាពម្ចាស់ការ ឬការជឿជាក់លើខ្លួនឯង ទីក្រុងតូចៗនិងភូមិចំនួន៤៧ និងទីក្រុងធំៗចំនួន ១១ ត្រូវសម្រេចចិត្តលើជំរើសផលិតផលពិសេសៗដែលនឹងត្រូវធ្វើ។ សម្រាប់ដំណើរការនេះ រដ្ឋបាលថ្នាក់ខេត្ត និងថ្នាក់មូលដ្ឋានផ្តល់ប្រឹក្សា និងមិនផ្តល់ការឧបត្ថម្ភទេ។ម្យ៉ាងទៀត ប្រសិនបើខេត្តជួយឧបត្ថម្ភលើផលិតផល១ ហើយក្នុងករណីដែលមូលដ្ឋានមិនអាចលក់ដាច់នៅលើទីផ្សារទេ នោះពួកគេនឹងស្នើអោយរដ្ឋាភិបាលជួយទិញផលិតផលទាំងនោះ។ ការពឹងផ្អែកទាំងស្រុងលើរដ្ឋ ធ្វើអោយប្រជាជនក្នុងមូលដ្ឋានបាត់បង់ភាពម្ចាស់ការ និងច្នៃ

ប្រឌិតរស់រវើករបស់ខ្លួន ជាពិសេសគឺគុណភាព។ ត្រង់ចំណុចនេះមានសេដ្ឋវិទូជាច្រើនបាន លើកឡើងថា ការជួយផ្តល់ផ្នែកសំភារៈឬប្រាក់កាស ដោយផ្ទាល់ដល់ប្រជាជននឹងធ្វើអោយ ពួកគេខ្ជិលច្រអូស (លើកលែងតែករណីបន្ទាន់នៃកង្វះខាត ដោយគ្រោះមហន្តរាយឬគ្រោះ ថ្នាក់អ្វីផ្សេងៗ) ដែលស្របនឹងសុភាសិតដែលថា មិនគួរអោយត្រីទេ គួរបង្រៀនអោយចេះ ស្ទូចត្រី ទើបគេអាចរកត្រីបានមួយជីវិត។

- សំណួរដែលអាចចោទសួរផងដែរ ថាតើខេត្តអាចជួយអ្វីខ្លះក្នុងដំណើរការនេះ? ចម្លើយ : ជាការពិតណាស់ ខេត្តប្រាកដជាជួយ ប៉ុន្តែផ្តល់នូវជំនួយផ្នែកបច្ចេកទេស និងការណែនាំផ្សេងៗ ដើម្បីធ្វើអោយផលិតផលរបស់ពួកគេបានធ្វើឡើងរឹតតែប្រសើរឡើង។ ខេត្តក៏នឹងជួយរកទីផ្សារ និងការផ្សាយពាណិជ្ជកម្មផងដែរ។ មូលនិធិចាំបាច់នៅចំណុចចាប់ផ្តើម រដ្ឋអាចសម្របសម្រួលជួយផ្តល់អោយដែរ។ ចំណុចសំខាន់នោះគឺថា ទីក្រុងទាំងតូចទាំងធំ និងភូមិទាំងឡាយ បង្កើតនូវប្រភពធនធានរបស់ខ្លួនទាំងប្រាក់កាស និងចំណេះធ្វើ។
- ពួកគេត្រូវមានការទទួលខុសត្រូវ និងការច្នៃប្រឌិតរស់រវើក និងចងចាំក្នុងចិត្តថាចលនានេះអាចជា **ភូមិ១ផលិតផល១** ឬ **ភូមិ១វប្បធម៌១** ឬ **ភូមិ១កីឡា១** ឬ **ភូមិ១ចម្រៀង១បទ** ឬ **ភូមិ១ការស្រមៃ១** ជាដើម។ល។
- យើងអាចជ្រើសយកគំនិតផ្សេងៗ ដើម្បីពន្យល់បន្ថែមពីភាពត្រឹមត្រូវនៃគោលការណ៍នេះ ដោយលើកឡើងនូវទស្សនៈអ្នកប្រាជ្ញ លោក**អេនឌ្រូ ខានេហ្គី** (Andrew Carnegie) ដែលអះអាងថា មនុស្សដែលទទួលបាននូវលទ្ធផលធ្វើជាម្ចាស់ដ៏ពេញលេញលើចិត្តគំនិតរបស់ខ្លួន ក៏អាចធ្វើជាម្ចាស់នៃអ្នកដទៃ ឬរបស់អ្វីផ្សេងៗទៀតដែលត្រូវបានគេផ្តល់សិទ្ធិអោយផងដែរ។ ដូចនេះ ឯករាជភាព ឬភាពម្ចាស់ការ ឬការជឿជាក់លើខ្លួនឯង និងគំនិតច្នៃប្រឌិតរស់រវើកជាគន្លឹះឈានទៅរកភាពជោគជ័យ។

៣. ការជំរុញការអភិវឌ្ឍធនធានមនុស្ស (Promoting Human Resources Development)

គោលដៅចុងក្រោយបង្អស់នៃចលនានេះគឺការអភិវឌ្ឍធនធានមនុស្ស។ វានឹងពុំមានភាពជោគជ័យទេប្រសិនបើគ្មានការប្រមើលមើលទៅថ្ងៃមុខ របស់អ្នកដឹកនាំតាមមូលដ្ឋានទេ។ វាជាការចាំបាច់ណាស់ក្នុងការអភិវឌ្ឍសហគមន៍មួយ ដែលត្រូវឆ្លើយតបប្រកបដោយការច្នៃប្រឌិតរស់រវើក នៅពេលប្រឈមមុខនូវការលំបាកផ្សេងៗ។ យើងអាចលំអិតគំនិតនេះដូចខាងក្រោម៖

- ធនធានមនុស្សមានសារៈសំខាន់ ដើម្បីជំរុញធ្វើអោយមានការរីកលូតលាស់រស់រវើកនៅក្នុងតំបន់។ ដូចនេះការចេះប្រើប្រាស់ធនធានមនុស្សគឺជាគន្លឹះនៃភាពជោគជ័យសម្រាប់ចលនានេះ។
- តួនាទីសំខាន់នៃភាពជាអ្នកដឹកនាំ នឹងនាំដល់ស្ថានភាពមួយដែលប្រជាជនតាមមូលដ្ឋានអាចបញ្ចេញនូវសមត្ថភាព និងលទ្ធភាពដែលខ្លួនមាន។ ឧទាហរណ៍ ការដឹកនាំដើម្បីបណ្តុះផ្សិត ឬអភិវឌ្ឍន៍ផលិតផលថ្មី ឬកន្លែងកំសាន្តថ្មីក្នុងទីក្រុងតូចៗនិងតាមភូមិ ឬការផ្តល់នូវគំរូផលិតផលផ្សេងៗ មិនមែនកសិកម្ម។ល។
- ចំណុចសំខាន់នៃចំណុចនេះនៅត្រង់ថា តើត្រូវធ្វើយ៉ាងណាដើម្បីអភិវឌ្ឍន៍ធនធានមនុស្ស? ឧទាហរណ៍មួយចំនួនដែលបញ្ជាក់ថា ខេត្តអយតាបានបង្កើតអ្វីឡើងដើម្បីអភិវឌ្ឍធនធានមនុស្សដូចជា :
    - សាលាបណ្តុះបណ្តាលដែលគេអោយឈ្មោះថា **សាលាដែលបណ្តុះបណ្តាលនៃទឹកដីដែលសំបូរបែប** ( Land of Abundance Training School) ដែលផ្តល់នូវស្ថាប័នអប់រំបណ្តុះបណ្តាលយុវជនសំរាប់ធ្វើជាអ្នកបន្តវេនដឹកនាំ ដើម្បីកសាងសង្គមមួយកាន់តែសំបូរធនធានមនុស្សឡើងៗ។
    - សាលាបណ្តុះបណ្តាលអភិវឌ្ឍន៍តំបន់ដែលមានឈ្មោះថា **Toyo Kuni Regional Development Training School** ។ អ្នកដែលត្រូវទទួលការបណ្តុះបណ្តាលរួមមានស្ត្រីមេផ្ទះ កសិករ គ្រូបង្រៀន និងយុវជនក្នុងមូលដ្ឋាន។ ពួកគេអាចចូលសិក្សារយៈពេលពីរឆ្នាំ ហើយដែលក្នុងរយៈពេលនេះគេធ្វើការនៅពេលថ្ងៃ និងសិក្សានៅពេលយប់លើចំណុចសំខាន់ ថាតើនឹងត្រូវធ្វើយ៉ាងណាអោយសហគមន៍មានការរីកធំធាត់ឡើង។
    - គួរកត់សំគាល់ដែរថា គេបានបង្កើតកន្លែងអប់រំ និងបណ្តុះបណ្តាលមួយចំនួនទៀតដូចជា សាកលវិទ្យាល័យសំរាប់មនុស្សវ័យជំទង់ សាលាបណ្តុះបណ្តាលនៃសតវត្សទី២១ សាលាបណ្តុះបណ្តាលកសិកម្ម សាលាបណ្តុះបណ្តាលភូមិ១ផលិតផល១ សមាគមរៀបចំតំបន់ ការបង្កើតក្រុមស្ត្រី១ដែលមានឈ្មោះថា **ទុកភូមិ១ផលិតផល១អោយក្រុមស្ត្រីដែលមានសមាជិក១០០នាក់** និង**ក្រុមអភិវឌ្ឍន៍តំបន់**។
    - ចំណុចសំខាន់បំផុតមួយទៀតក្នុងការអភិវឌ្ឍធនធានមនុស្ស **គឺការសាងសង់សាកលវិទ្យាល័យអាស៊ីប៉ាស៊ីភិច រីស្សូម៉េកាន់** (Ritsumeikan Asia Pacific University-

APU) ដែលមានទីតាំងនៅទីក្រុងបេភុកាលពីខែមេសា ឆ្នាំ២០០០ដែលទទួលបាននិស្សិតមកសិក្សាពីជាង៥០ប្រទេសនៅក្នុងឆ្នាំនោះ។

○ គោលដៅនៃការបង្កើតសាកលវិទ្យាល័យនោះ គឺដើម្បីផ្តល់ផលប្រយោជន៍ទៅវិញទៅមកនៃការទំនាក់ទំនងរបស់មនុស្សក្នុងតំបន់អាស៊ីប៉ាស៊ីភិច និងជំរុញអ្នកដែលមានភាពសកម្មជាអន្តរជាតិ។ ពាក់កណ្តាលនៃនិស្សិត ដែលបានចូលរៀនគឺជាជនបរទេស។ ស្ថាប័នបណ្ឌិតសភាអាកាដេមិចតែមួយនេះនឹងជំរុញការផ្លាស់ប្តូរគ្នាទៅវិញទៅមកជាអន្តរជាតិ ក៏ដូចជាការធ្វើអោយតំបន់មានការរីកលូតលាស់រស់រវើក ហើយនឹងក្លាយទៅជាមូលដ្ឋានសំខាន់ សំរាប់បណ្តុះបណ្តាលមនុស្ស ដែលមានលក្ខណៈសកម្មនៅតំបន់អាស៊ីប៉ាស៊ីភិច។ តាមរយៈសកលវិទ្យាល័យនេះខេត្តអយតាទទួលបាននូវភាពរីករាយបំផុតក្នុងការផ្លាស់ប្តូរបទពិសោធ និងចំណេះដឹងគ្នាទៅវិញទៅមករវាងតំបន់ទាំងឡាយនៅទ្វីបអាស៊ី សម្រាប់ចលនាភូមិ១ផលិតផល១ និងសម្រាប់ភាពជោគជ័យនៃការអនុវត្តសេចក្តីប្រកាសរួម របស់សន្និសីទកំពូលនៃតំបន់អាស៊ី និងកោះត្យូស្យុ។ល។

ចំណុចនេះ យើងអាចនិយាយដោយខ្លីថា ជាការពង្រឹងសមត្ថភាព (Capacity Building) ដែលជាគន្លឹះឈានទៅរកភាពជោគជ័យ ព្រោះថា **សមត្ថភាព គឺជាអានុភាពដឹងពីព័ត៌មានដែលនឹងជួយអោយដោះស្រាយបញ្ហា តាមមធ្យោបាយមួយនាំអោយកើតមាននូវការរីកលូតលាស់ ការរីករាលដាលនិងការត្រួតបញ្ញាខ្លួនឯង** (Albert Low)។

## ច. សមិទ្ធិផលទទួលបាននៅខេត្តអយតា

តារាង១.១ ៖ លទ្ធផលចំនួនផលិតផលនៃចលនាភូម១ផលិតផល១តាមឆ្នាំ

| ឆ្នាំ | ១៩៨០ | ១៩៨៥ | ១៩៩១ | ១៩៩៣ | ១៩៩៥ | ១៩៩៧ | ១៩៩៨ | ១៩៩៩ | ២០០១ |
|---|---|---|---|---|---|---|---|---|---|
| ចំនួនផលិតផល | ១៤៣ | ២០៥ | ២៧៣ | ២៦៩ | ២៨៩ | ៣០៦ | ៣១២ | ៣១៩ | ៣៣៦ |

Sources: Oita Prefecture Government, Japan

គួរកត់សំគាល់ថា តារាងខាងលើនេះបានបង្ហាញថា ចាប់តាំងពីការចាប់ផ្តើមអនុវត្តចលនាភូមិ១ផលិតផល១នៅឆ្នាំ១៩៧៩មក ខេត្តអយតាទទួលបានលទ្ធផលគួរជាទីមោទនៈបំផុត ដោយសារតែចំនួនផលិតផលបានកើនឡើងជាលំដាប់ ជាក់ស្តែងនៅឆ្នាំ១៩៨០ មានផលិតផលចំនួន១៤៣ បានកើនដល់៣១៩នៅឆ្នាំ១៩៩៩ និងដល់៣៣៦នៅឆ្នាំ២០០១។ លើសពីនេះខេត្តអយតាទទួលបាន :

- ផលិតផលសរុបនៅអយតាទទួលបានចំណូលជាង ៣លានលាន (ទ្រីលាន) យ៉េន។ បានជាប់ចំណាត់ថ្នាក់លេខ៣៣នៅក្នុងប្រទេសជប៉ុន (ក្នុងចំណោមខេត្តចំនួនចំនួន៤៧)។ រីឯចំណូលមធ្យមប្រចាំឆ្នាំសំរាប់ប្រជាជនម្នាក់ៗរបស់ខេត្តមាន ២,៦៩៨,០០០យ៉េន នៅឆ្នាំ១៩៩៥ ដែលជាចំណូលខ្ពស់បំផុតទី២នៅកោះគ្យូស្យូ និងទទួលបានចំណាត់ថ្នាក់លេខ៣១នៅប្រទេសជប៉ុន ហើយនៅឆ្នាំ១៩៩៦បានកើនដល់ ២,៧២៧,០០០យ៉េន។
- ផលិតផលកសិកម្មដុល ទទួលបាន ១៦៥៣ពាន់លានយ៉េននៅឆ្នាំ១៩៩៦ និងមានចំណាត់ថ្នាក់លេខ២២ នៅប្រទេសជប៉ុន។
- ផលិតផលព្រៃឈើដុលមាន ៣៤ពាន់លានយ៉េននៅឆ្នាំ១៩៩៦ និងមានចំណាត់ថ្នាក់លេខ៣ នៅប្រទេសជប៉ុន។
- ផលិតផលត្រីដុលមាន ៦១ពាន់លានយ៉េននៅឆ្នាំ១៩៩៦ និងមានចំណាត់ថ្នាក់លេខ៩ នៅប្រទេសជប៉ុន។
- សន្ទស្សន៍ជីវិតមនុស្សនៅឆ្នាំ១៩៩៨ ទទួលបានចំណាត់ថ្នាក់លេខ ១ នៅកោះគ្យូស្យូ និងលេខ ១៤ នៅក្នុងប្រទេសជប៉ុន។

ដោយសារតែភាពជោគជ័យនៃចលនាភូមិ១ផលិតផល១នេះ ចំណូលរបស់ខេត្តអយតាបានកើនឡើងជាលំដាប់ ដែលជាហេតុធ្វើអោយខេត្តមានលទ្ធភាព ជំរុញដំណើរការគោលនយោបាយផ្សេងៗទៀតដូចជា :

- ការបង្កើតសហគមន៍ដែលមានមនុស្សរស់នៅជាប្រចាំ និងមានការកដោះដូរយ៉ាងសកម្ម ក៏ដូចជាការពង្រឹងប្រព័ន្ធដឹកជញ្ជូន និងទូរគមនាគមន៍។
- ជំរុញការបង្ការគ្រោះមហន្តរាយ និងវិធានការសន្តិសុខ។
- ជំរុញវិស័យកសិកម្ម ព្រៃឈើ និងត្រី ព្រមជាមួយនឹងក្តីសង្ឃឹមទៅអនាគត។
- ជំរុញពាណិជ្ជកម្ម ឧស្សាហកម្ម និងទេសចរណ៍សំរាប់សតវត្សថ្មី។
- ជំរុញការអភិវឌ្ឍធនធានមនុស្ស សំរាប់ដឹកនាំសតវត្សទី២១ និងជំរុញវប្បធម៌និងកីឡា។[26]

[26] សៀវភៅ "តើអ្វីជាការជំរុញចលនាភូមិ១ផលិតផល១?" និពន្ធដោយ ហាស់ វង់ដារ៉ា ឆ្នាំ២០១៦

## សន្និដ្ឋានជំពូក

សរុបសេចក្តីមក មុននឹងយើងអាចបកស្រាយលើប្រធានបទស្រាវជ្រាវថ្មីមួយ ជាដំបូងយើងត្រូវស្គាល់ច្បាស់ពីនិយមន័យនៃពាក្យគន្លឹះ ឬអត្ថន័យនៃប្រធានបទនោះជាមុនសិន និងសញ្ញាណសំខាន់ៗដូចជា មូលហេតុដែលតម្រូវឲ្យយើងសិក្សាលើប្រធានបទ, គោលដៅនៃការសិក្សាលើប្រធានបទ រួមជាមួយកត្តាជំរុញឆ្ពោះទៅសម្រេចគោលដៅ និងកត្តារាំងស្ទះ។ល។ រួមបញ្ចូលនឹងការសិក្សាស្វែងយល់លើទ្រឹស្តីរបស់អ្នកប្រាជ្ញជាច្រើន គោលនយោបាយ ឬផែនការយុទ្ធសាស្ត្រនានា និងបទពិសោធន៍បរទេស ដែលពាក់ព័ន្ធនឹងប្រធានបទ ធ្វើឲ្យយើងងាយស្រួលក្នុងការសិក្សាបកស្រាយទៅលើប្រធានបទដោយមានមូលដ្ឋានយ៉ាងរឹងមាំ។

# ជំពូកទី ២
# ស្ថានភាពទូទៅនៃ ឃុំ
# ប្រាសាទ ស្រុកកំពង់ត្របែក
# ខេត្តព្រៃវែង

# ជំពូកទី ២

# ស្ថានភាពទូទៅនៃ ឃុំប្រាសាទ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង

## ២.១ ប្រវត្តិ និងទីតាំងភូមិសាស្ត្រ

### ២.១.១ ប្រវត្តិឃុំប្រាសាទ

កាលពីសម័យបុរាណ ប្រហែលអំឡុងឆ្នាំ ៥២០ ទឹកដីដែលគេស្គាល់ថាជាស្រុកកំពង់ត្របែកសព្វថ្ងៃ មានវត្តតែ២ ប៉ុណ្ណោះគឺ វត្តប្រាសាទ និង វត្តព្រៃរៀវ។ វត្តប្រាសាទ ត្រូវបានអ្នកស្រុកអ្នកភូមិជំនាន់នោះទទួលស្គាល់ថាជាទីសក្ការៈបូជាដ៏សក្តិសិទ្ធបំផុត ជាពិសេសមានប្រាសាទបុរាណធំមួយក្នុងបរិវេនវត្តនេះ ដែលមានវត្ថុបុរាណមានតម្លៃជាច្រើនសន្ធឹកសន្ធាប់ទៀតផង (ដោយសារគេឃើញមានកំទេចកំទីផ្ទាំងថ្ម គ្រឹះប្រាសាទយ៉ាងធំ និងជីកឃើញរបស់របរមានតម្លៃជាច្រើននៅក្រោមដីដូចជារទេះ, មាស, ពាង...)។ លើសពីនេះទៅទៀត ប្រាសាទនេះកាលដើមឡើយមិនសូវមានអ្នកហ៊ានចូលនោះទេ ព្រោះមានព្រៃក្រាស់ព័ទ្ធជុំ ដែលក្រោយមកត្រូវបានគេត្រាយអស់ក្នុងសម័យខ្មែរក្រហម (ពុលពត)។ ពីសង្គមចាស់ វត្តនេះល្បីល្បាញ និងមានបារមីខ្លាំងពូកែជាទីបំផុត ដែលកាលពីសម័យនោះ កាលណាអ្នកស្រុកខ្វះខាតរបស់របរប្រើប្រាស់ (ពេលមានពិធីបុណ្យការ ផ្សេងៗ) អាចសុំខ្ចីចាន ឆ្នាំង ឬរបស់របរទាំងនោះមកប្រើបាន ដោយគ្រាន់តែអុជធូបបន់ស្រន់សុំខ្ចីពីក្នុងប្រាសាទនោះ លុះស្អែកឡើងអាចយកសង្រែកមករែកចានឆ្នាំងដែលតម្រៀបគរក្នុងប្រាសាទជាស្រេច។ ជាក់ស្តែង លោកយាយដែលផ្តល់បទសម្ភាសន៍បានបន្តទៀតថា លោកយាយផ្ទាល់ធ្លាប់រៀនព្រះធម៌នៅទីនោះ និងធ្លាប់ឃើញពាងបុរាណដែលថានោះមែន ដែលពាងនោះមានមាត់តូចអាចត្រឹមតែលូកដៃចុះប៉ុណ្ណោះ។ ក្នុងពាងនោះ សុទ្ធតែរបស់របរពេញ ប៉ុន្តែលោកយាយបន្តថា ដោយសារមនុស្សលោកមានចិត្តមិនទៀងត្រង់ កាលណាសម្លឹងក្នុងពាងដំបូងឃើញមាស យូរៗទៅបែរជាឃើញដង្កូវ ឬពស់ទៅវិញ ដូចនេះមិនមានអ្នកហ៊ានប្រថុយយកនោះទេ។ ដូចករណីដែលល្បីតៗគ្នាថា លោកតាម្នាក់ដែលនៅក្បែរនោះ គាត់ត្រូវបានប្រាប់អោយទៅយកវត្ថុសំខាន់មួយនៅក្រោមដើមពោធិ៍នៅទិសនិរតីនៃវត្តដដែលនេះ (មាននៅដល់សព្វថ្ងៃ) លោកតានោះត្រូវតម្រូវអោយទៅយកពេលថ្ងៃត្រង់ តែបម្រាមហាមងើបមើលខាងលើ ប៉ុន្តែគាត់មិនប្រយ័ត្នក៏ភ្លេចខ្លួនល្មើសបម្រាម ទីបំផុតក៏តក់ស្លុតរត់មកផ្ទះ ហើយថ្នាក់ធ្លាក់ខ្លួនឈឺរហូតស្លាប់ខ្លួន។ បន្ថែមលើសពីនេះទៀតគឺ វត្តនេះតែងតែជាទីជម្រករបស់អ្នកស្រុកនៅជំនាន់នោះ ព្រោះកាលបើដល់ខែទឹកឡើងជន់គ្រប់ទិសទីស្ទើរតែលិចគ្មានសល់ តែផ្ទុយទៅវិញដោយសារវត្តនេះមានទីទួលប្រាសាទ ដែលហាក់ដូចជាអណ្តែតមិនលិចទឹក ទើបប្រជាជនតែងតែស្នាក់អាស្រ័យដើម្បីផុតពីគ្រោះភ័យនានា។ នៅ

មានរឿងរ៉ាវជាច្រើនទៀត ដែលបញ្ជាក់ពីជំនឿបារមីសក្តិសិទ្ធនៃវត្តនេះ ដែលវាធ្វើអោយប្រជាជននៅម្តុំនោះជឿជាក់ និងគោរពបូជាយ៉ាងខ្ជាប់ខ្ជួន ថែមទាំងមូលមតិជ្រើសយកឈ្មោះវត្តជាតំណាងនៃឃុំទាំងមូល។ ហេតុដូច្នេះហើយ ទើបឃុំនេះជាប់ឈ្មោះជា**ឃុំប្រាសាទ** រហូតមកដល់បច្ចុប្បន្ននេះ។[27]

### ២.១.២ ទីតាំងភូមិសាស្ត្រ

ឃុំប្រាសាទ ជាតំបន់វាលរាបហើយស្ថិតនៅទិសខាងកើតនៃទីរួមស្រុកកំពង់ត្របែក ចម្ងាយ ៧ គីឡូម៉ែត្រ ដែលមានព្រំប្រទល់៖

- ខាងជើងទល់នឹងឃុំកន្សោមអក និងឃុំគោខ្ចក
- ខាងត្បូងដល់នឹងឃុំអន្សោង
- ខាងកើតទល់នឹងឃុំព្រៃឈរ
- ខាងលិចទល់នឹងឃុំកំពង់ត្របែក[28]

ឃុំនេះមានផ្ទៃដីសរុបចំនួន ២ ៩០៨ ហិកតា ផ្ទៃដីបង្កបង្កើនផលមានចំនួន ២ ៤១១ ហិកតា ផ្ទៃដីសាធារណៈនិងផ្ទៃដីលំនៅដ្ឋានមានចំនួន ៤៩៧ ហិកតា។ ចំនួនភូមិនៅក្នុងឃុំប្រាសាទមានចំនួន០៩ភូមិគឺ ៖ ភូមិប្រាសាទ ភូមិចំបក់ ភូមិអំពិល ភូមិពាន់វត្ត ភូមិជ្រលង ភូមិដូនទង់ ភូមិបី ភូមិភ្លូង និងភូមិថ្កូវ។ [29]

### ២.១.៣ ស្ថានភាពប្រជាជនបច្ចុប្បន្ននៃឃុំប្រាសាទ

ចំនួនប្រជាពលរដ្ឋសរុបចំនួន ១៣ ០១៧ នាក់ក្នុងនោះស្រីមានចំនួន ៦ ៥១២ នាក់ហើយមានចំនួនគ្រួសារសរុបចំនួន ២ ៧៩៦ គ្រួសារ និងចំនួនខ្នងផ្ទះមាន ២ ៥១២។ ចំនួនមនុស្សពេញវ័យ អាយុ ១៨ឆ្នាំឡើងសរុបមានចំនួន ៨ ៧៥៦ នាក់ក្នុងនោះមានស្រី ៤ ៣១៦ នាក់។ ភាគច្រើននៃប្រជាពលរដ្ឋនៅក្នុងឃុំ (៧៥%)ប្រកបមុខរបរធ្វើស្រែ ចំណែកឯខ្លះទៀត(២៤%)ប្រកបមុខរបរក្នុងផ្នែក សេវាកម្ម និង(១%)ប្រកបរបរក្នុងផ្នែកសិប្បកម្ម។ ចំនួនប្រជាជនចំណាកស្រុកសរុប ១៩១០

[27] បទសម្ភាសន៍ផ្ទាល់ពីលោកយាយជីនៅក្នុងវត្តប្រាសាទ និងលោកមេភូមិជ្រលងនៃឃុំប្រាសាទ, ថ្ងៃទី៩ ខែ មេសា ឆ្នាំ ២០១៨

[28] ឯកសារ "កម្មវិធីវិនិយោគឃុំឆ្នាំ ២០១៧ ឃុំប្រាសាទ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង" ខែមករាឆ្នាំ២០១៧

[29] របាយការណ៍បូកសរុបវាយតម្លៃការអនុវត្តកម្មវិធីនយោបាយរបស់គណបក្សក្នុងការអភិវឌ្ឍឃុំប្រាសាទឆ្នាំ ២០១២-២០១៧ និងគោលនយោបាយរបស់គណបក្សសម្រាប់អភិវឌ្ឍន៍ឃុំប្រាសាទពីឆ្នាំ ២០១៧-២០២២, ថ្ងៃទី ០១ ខែមករា ឆ្នាំ ២០១៧, ទំព័រទី ១

នាក់ក្នុងនោះស្រី ១០៨២ នាក់។ អត្រាកំណើនប្រជាជនជាមធ្យមក្នុងរយៈពេល ៥ឆ្នាំចុងក្រោយ (២០១២-២០១៦) មានអត្រាចំនួន ១.៦៦% ។[30]

## ២.២ ចក្ខុវិស័យ គោលបំណង គោលដៅ និងយុទ្ធសាស្ត្រនៃការអភិវឌ្ឍ

នៅក្នុងអាណត្តិទី៤ របស់ក្រុមប្រឹក្សាឃុំប្រាសាទនេះ បានយកចិត្តទុកដាក់លើការអភិវឌ្ឍមូលដ្ឋានលើកកំពស់អភិបាលកិច្ចល្អ ប្រកបដោយនិរន្តរភាព ធានាបាននូវគុណភាពជីវិត និងលើកកំពស់ជីវភាពរបស់ប្រជាពលរដ្ឋកាន់តែល្អប្រសើរ តាមរយៈការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ប្រព័ន្ធធារាសាស្ត្រ ការផ្គត់ផ្គង់អគ្គីសនី ទឹកស្អាត ការកែលម្អគុណភាពអប់រំ សេវាសុខាភិបាល ការបណ្តុះបណ្តាលបច្ចេកទេសកសិកម្មចម្រុះ ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបង្កើនការយកចិត្តទុកដាក់សន្តិសុខសណ្តាប់ធ្នាប់សង្គមជូនបងប្អូនប្រជាពលរដ្ឋ។ ម្យ៉ាងទៀត ដើម្បីធានាបាននូវសន្តិសុខស្បៀង និងមានប្រាក់ចំណូលកើនឡើង រដ្ឋបាលឃុំត្រូវយកចិត្តទុកដាក់កសាងហេដ្ឋារចនាសម្ព័ន្ធ ប្រព័ន្ធប្រពលវប្បកម្មចម្រុះ គុណភាពសេវាសុខាភិបាល ការអប់រំ សង្គមកិច្ច វប្បធម៌ យេនឌ័រ និងចូលរួមថែរក្សាការពារធនធានធម្មជាតិ និងបរិស្ថាន ជាពិសេសបង្កើនការយកចិត្តទុកដាក់ការផ្តល់សេវាជូនប្រជាពលរដ្ឋប្រកបដោយគុណភាព រហ័សទាន់ចិត្ត និងធានាបានសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ។ រីឯគោលដៅអភិវឌ្ឍន៍ឃុំគឺ បង្កើនការយកចិត្តទុកដាក់វិស័យហេដ្ឋារចនាសម្ព័ន្ធ ប្រព័ន្ធប្រពលវប្បកម្មចម្រុះ លើកកំពស់សុខុមាលភាពរបស់ប្រជាពលរដ្ឋ តាមរយៈការបង្កើនគុណភាពផ្តល់សេវាសុខាភិបាល អប់រំ សង្គមកិច្ច វប្បធម៌ យេនឌ័រ និងចូលរួមថែរក្សាធនធានធម្មជាតិនិងបរិស្ថាន និងបង្កើនការយល់ដឹងពីការប្រែប្រួលអាកាសធាតុ។ ចំណែកឯ យុទ្ធសាស្ត្រអភិវឌ្ឍន៍ឃុំគឺ ពង្រឹង និងកែលម្អ ការគ្រប់គ្រងផ្នែកសេដ្ឋកិច្ច សង្គមកិច្ច ការប្រើប្រាស់ដីធ្លី ធនធានធម្មជាតិនិងបរិស្ថាន និងផ្តល់សេវារដ្ឋបាល ពិសេសសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ។[31]

## ២.៣ រចនាសម្ព័ន្ធគ្រប់គ្រង និងតួនាទីភារកិច្ចសមាជិកឃុំប្រាសាទ

### ២.៣.១ រចនាសម្ព័ន្ធគ្រប់គ្រងឃុំ

[30] ឯកសារ "កម្មវិធីវិនិយោគឃុំឆ្នាំ ២០១៧ ឃុំប្រាសាទ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង", ខែមករាឆ្នាំ២០១៧ និងរបាយការណ៍បូកសរុបវាយតម្លៃការអនុវត្តកម្មវិធីនយោបាយរបស់គណបក្សក្នុងការអភិវឌ្ឍឃុំប្រាសាទឆ្នាំ ២០១២-២០១៧ និងគោលនយោបាយរបស់គណបក្សសម្រាប់អភិវឌ្ឍន៍ឃុំប្រាសាទពីឆ្នាំ ២០១៧-២០២២, ថ្ងៃទី ០១ ខែមករា ឆ្នាំ ២០១៧, ទំព័រទី ១

[31] ឯកសារ "ផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ (២០១៧-២០២១) ឃុំប្រាសាទ", ឆ្នាំ២០១៧ ទំព័រទី១៥

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ខេត្ត ព្រៃវែង**
**ស្រុក កំពង់ត្របែក**
**ឃុំ ប្រាសាទ**




លោក ញ៉ែម វ៉ានី ស្មៀនឃុំ
ភូមិជ្រលង
ភូមិត្លង
ភូមិដូនទុង
ភូមិពាន់វត្ត
ភូមិប្រាសាទ
ភូមិថ្កូវ
ភូមិចំបក់
ភូមិបី
ភូមិអំពិល
មេភូមិ
លោក អ៊ុន សំអាង
លោក យា ហឿន
លោក ហ៊ិន ហេង
លោក ស ស៊ន់
លោក ទូន ឡាន់
លោកស្រី នុត ទូច
លោក ជុំ សារ៉ន
លោក ម៉ម ចាន់រ៉ា
លោក សៅ ណាត្រី
អនុមេភូមិ
លោក នុត គន
លោក វ៉ា ជា
លោក ឡាយ សុខ
លោក ញៀប អឿម
លោក យឹម សារិន
លោក នៅ ឆារី
លោក ហ៊ុន ឡាង
លោក គង់ ប៊ុនធឿន
លោក ប៉ុល អៀង
ជំនួយការភូមិ
លោកស្រី អ៊ី សុគាជ
លោកស្រី ងឹង អាយ
លោកស្រី គ្រួច រុំ
លោកស្រី ប៊ិច សោភ័ណ
លោក ហែម សុខ
លោក ហេង សៀង
លោកស្រី ស៊ឹម សារុំ
លោកស្រី ប្រេះ ស៊ីណា
លោកស្រី អ៊ុំ បុផា

### ២.៣.២ តួនាទី និងភារកិច្ចរបស់ ឃុំប្រាសាទ[32]

**ក. ប្រធានក្រុមព្រឹក្សាឃុំ សង្កាត់**

- ធ្វើជាអធិបតីនៅក្នុងកិច្ចប្រជុំរបស់ក្រុមព្រឹក្សាឃុំ សង្កាត់
- ធានាថា ក្រុមព្រឹក្សាឃុំ សង្កាត់បានប្រជុំយ៉ាងតិចមួយដងក្នុងមួយខែ
- ធានាថា កិច្ចប្រជុំក្រុមព្រឹក្សាឃុំ សង្កាត់ត្រូវបានធ្វើឡើងស្របតាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមព្រឹក្សាឃុំ សង្កាត់
- រក្សារបៀបរៀបរយ និងសណ្តាប់ធ្នាប់ក្នុងពេលប្រជុំក្រុមព្រឹក្សាឃុំ សង្កាត់។

**ខ. សមាជិកក្រុមព្រឹក្សាឃុំ សង្កាត់**

- ធានាថាក្រុមព្រឹក្សាឃុំ សង្កាត់ប្រើប្រាស់អំណាចតួនាទី និងមុខងារដូចមានចែងនៅក្នុងច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធ
- ចូលរួមក្នុងកិច្ចប្រជុំក្រុមព្រឹក្សាឃុំ សង្កាត់
- ធ្វើសហប្រតិបត្តិការជាមួយនឹងប្រជាពលរដ្ឋ។

**គ. មេឃុំ ចៅសង្កាត់**

- ធានាថា សេចក្តីសម្រេចរបស់ក្រុមព្រឹក្សាឃុំ សង្កាត់ត្រូវបានអនុវត្ត
- រាយការណ៍អំពីការបំពេញការងារប្រចាំខែជូនក្រុមប្រឹក្សាឃុំ សង្កាត់
- ផ្តល់យោបល់ និងជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់លើការងារកសាងផែនការ ការងារថវិកាហិរញ្ញវត្ថុ និងការអនុវត្តអំណាច តួនាទី និងមុខងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- បំពេញភារកិច្ចផ្សេងទៀតដែលក្រុមប្រឹក្សាឃុំ សង្កាត់ប្រគល់ឲ្យ
- ផ្ទេរសិទ្ធដល់ជំទប់ ចៅសង្កាត់រងតាមឋានុក្រមពេលខ្លួនអវត្តមាន ។

**ឃ. ជំទប់ទី១ ចៅសង្កាត់រងទី១**

- ទទួលជួយមេឃុំចៅសង្កាត់លើកិច្ចការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បំពេញការងារជាមេឃុំ ចៅសង្កាត់ស្តីទី ក្នុងករណីដែលមេឃុំ ចៅសង្កាត់អវត្តមាន
- បំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់របស់មេឃុំ ចៅសង្កាត់ ។

[32] ប្រភពឯកសារពីឃុំ "ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ" របស់ក្រសួងមហាផ្ទៃ, ខែកក្កដា ឆ្នាំ២០១៧ ទំព័រទី ១២

**ង. ជំទប់ទី២ ចៅសង្កាត់រងទី២**

- ជួយមេឃុំ ចៅសង្កាត់លើការងារផ្នែករដ្ឋបាល សេវាសង្គមកិច្ច សេវាសាធារណៈ និងសណ្តាប់ធ្នាប់សាធារណៈ
- បំពេញការងារជាមេឃុំ ចៅសង្កាត់ស្តីទី ក្នុងករណីដែលមេឃុំ ចៅសង្កាត់ និងជំទប់ទី១ ចៅសង្កាត់រងទី១ អវត្តមាន
- បំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់របស់មេឃុំ ចៅសង្កាត់ ។

**ច. គណៈកម្មាធិការនានា**

- ផ្តល់យោបល់ និងជួយការងារជាក់លាក់ណាមួយរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ដូចជាការកសាងផែនការ និងថវិកា
- រាយការណ៍អំពីការវិវឌ្ឍការងារប្រចាំខែរបស់ខ្លួន
- ផ្តល់យោបល់ពីវិធានការត្រូវអនុវត្តដែលពាក់ព័ន្ធទៅនឹងការងារជាសមត្ថកិច្ចរបស់ខ្លួន ។

**ឆ. ស្មៀនឃុំ សង្កាត់**

ថ្វីត្បិតតែស្មៀនឃុំ សង្កាត់ជាបុគ្គលិកស្ថិតនៅក្នុងក្របខ័ណ្ឌរដ្ឋបាលស៊ីវិលរបស់ក្រសួងមហាផ្ទៃក៏ពិតមែន ប៉ុន្តែក្នុងការអនុវត្តការងារស្មៀនឃុំ សង្កាត់ត្រូវស្ថិតនៅក្រោមការដឹកនាំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។ ស្មៀនឃុំ សង្កាត់ជាអ្នក ៖

- ជួយក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង និងគណៈកម្មាធិការនានា បំពេញតួនាទី និងមុខងារស្របទៅតាមតម្រូវការផ្នែកច្បាប់
- បំពេញការងាររដ្ឋបាល
- ធានាថាសេចក្តីសម្រេច និងការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ស្របទៅនឹងល័ក្ខខ័ណ្ឌច្បាប់
- ជួយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការរៀបចំ និងការអនុវត្តកិច្ចប្រជុំរបស់ក្រុមប្រឹក្សា និងគណៈកម្មាធិការនានារបស់ឃុំ សង្កាត់
- ចូលរួមគ្រប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ឬគណៈកម្មាធិការលើកលែងតែបានទទួលការអនុញ្ញាតឲ្យអវត្តមានជាមុនពីក្រុមប្រឹក្សាឃុំ សង្កាត់ ឬមេឃុំ ចៅសង្កាត់
- ជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការរៀបចំឲ្យមានក្តាខៀនព័ត៌មានមួយ ឬច្រើនកន្លែងដើម្បីបិទផ្សាយសេចក្តីជូនដំណឹង សេចក្តីសម្រេច និងលិខិតបទដ្ឋានផ្សេងៗរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងមេឃុំ ចៅសង្កាត់ សម្រាប់ឲ្យសាធារណៈជនទូទៅបានដឹងព័ត៌មាន។

## ជ. បុគ្គលិកឃុំ សង្កាត់

មាត្រា២៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ចែងថា "ឃុំ សង្កាត់អាចជ្រើសរើសបុគ្គលិកក្រៅក្របខណ្ឌរដ្ឋ ដើម្បីជួយកិច្ចការរបស់ខ្លួនតាមសេចក្តីត្រូវការ និងការចាំបាច់នៃការងារ និងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងអាណត្តិ ហើយអាចបន្ថយការងារតាមការសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិបន្ទាប់" ។

បែបបទនៃការជ្រើសរើសបុគ្គលិកឃុំ សង្កាត់មានបរិយាយនៅក្នុងសៀវភៅណែនាំស្តីពីកិច្ចការរដ្ឋបាលឃុំ សង្កាត់ ។

## ឈ. មេភូមិ និងជំនួយការមេភូមិ

*ឈ.១. មេភូមិ*

- ទទួលខុសត្រូវរួមក្នុងភូមិរបស់ខ្លួន
- តំណាងឲ្យប្រជាពលរដ្ឋទាំងអស់ក្នុងភូមិ និងជាខ្សែរយៈចម្បងសម្រាប់ភ្ជាប់ទំនាក់ទំនងរវាងភូមិ និងក្រុមប្រឹក្សាឃុំសង្កាត់
- បង្កើនការពិគ្រោះយោបល់ ទទួលការណែនាំ និងធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន
- ចូលរួមក្នុងកិច្ចប្រជុំគណៈកម្មាធិការនានារបស់ឃុំ សង្កាត់នៅពេលដែលក្រុមប្រឹក្សាឃុំ សង្កាត់តម្រូវ ដើម្បីផ្តល់យោបល់អំពីកិច្ចការដែលពាក់ព័ន្ធក្នុងភូមិរបស់ខ្លួនមានជាអាទិ៍ ៖
    - ផ្តល់យោបល់ដល់ក្រុមប្រឹក្សាឃុំ សង្កាត់អំពីតម្រូវការ និងផលប្រយោជន៍របស់ភូមិ
    - ផ្តល់យោបល់ដល់ក្រុមប្រឹក្សាឃុំ សង្កាត់អំពីរបៀបបង្កើន និងកសាងសមត្ថភាព និងធនធានរបស់ភូមិ
    - ផ្តល់យោបល់ដល់គណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ សង្កាត់អំពី ៖
        + តម្រូវការ និងអាទិភាពរបស់ភូមិ ដើម្បីបញ្ចូលក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់
        + ការអនុវត្តផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ក្នុងភូមិរបស់ខ្លួន
        + ការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ក្នុងភូមិរបស់ខ្លួន ។
- ត្រូវធ្វើសេចក្តីរាយការណ៍រាល់បញ្ហាពាក់ព័ន្ធនឹងភូមិរបស់ខ្លួន ដើម្បីដាក់បញ្ចូលក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់

- ត្រូវចូលរួមកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងករណីមានសំណូមពរពីក្រុមប្រឹក្សាឃុំ សង្កាត់
- ត្រូវជានាផ្តល់ព័ត៌មានជាឯកសារសាធារណៈដែលពាក់ព័ន្ធនឹងភូមិរបស់ខ្លួនជូនដល់ប្រជាពលរដ្ឋរបស់ខ្លួន ។ ឯកសារព័ត៌មានទាំងនោះអាចរួមមានព័ត៌មានស្តីពីការប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ផែនការអភិវឌ្ឍន៍ និងថវិកាឃុំ សង្កាត់
- ត្រូវទទួលខុសត្រូវអនុវត្តកិច្ចការដែលបានប្រគល់ឲ្យដោយក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន។

**បញ្ជាក់** ៖

- មេភូមិមិនមានសិទ្ធិអំណាចចុះហត្ថលេខាលើកិច្ចសន្យា ឬការផ្ទេរអំណាច ឬការ ចាត់ចែងដទៃទៀតក្នុងនាមភូមិបានឡើយ ។
- មេភូមិពុំមានសិទ្ធិអំណាចសម្រេចបញ្ហាណាមួយដែលស្ថិតក្នុងសមត្ថកិច្ចរបស់ក្រុម ប្រឹក្សាឃុំ សង្កាត់ដោយគ្មានការផ្ទេរអំណាចពីក្រុមប្រឹក្សាឃុំ សង្កាត់ស្របតាម ប្រកាសរបស់ក្រសួងមហាផ្ទៃបានឡើយ ។
- ក្រុមប្រឹក្សាឃុំ សង្កាត់មិនអាចផ្ទេរអំណាចដល់បុគ្គល ឬគណៈកម្មាធិការ ឬអង្គការ ណាមួយនៅក្នុងភូមិបានឡើយ លើកលែងតែមានការអនុញ្ញាតដែលបានចែងក្នុង ប្រកាសរបស់ក្រសួងមហាផ្ទៃ ។

*ឈ.២. ជំនួយការមេភូមិ*

- **អនុប្រធានភូមិ** ទទួលការងារជំនួសមេភូមិក្នុងពេលដែលមេភូមិអវត្តមាន ដោយមានមូលហេតុច្បាស់លាស់ ដូចជាមានជំងឺ ឬមានបេសកកម្មចេញក្រៅឃុំ សង្កាត់របស់ខ្លួនលើសពី ១ថ្ងៃ ។ ក្រៅពីនេះអនុប្រធានភូមិត្រូវទទួលជួយមេភូមិលើការអនុវត្តគម្រោងអភិវឌ្ឍន៍នានាក្នុងភូមិតាមគម្រោងផែនការរបស់ឃុំ សង្កាត់ ។
- **សមាជិកភូមិ** ទទួលជួយធ្វើជាលេខាធិការឲ្យមេភូមិ និងទទួលជួយមេភូមិលើការងារស្ថិតិការចុះបញ្ជីប្រជាពលរដ្ឋ និងការរក្សាទុកឯកសារនានារបស់ភូមិ ។

**បញ្ជាក់** ៖ ក្រៅពីការងារខាងលើនេះមេភូមិអាចធ្វើការបែងចែក ឬប្រគល់ភារកិច្ចដល់ អនុប្រធានភូមិ និងសមាជិកភូមិតាមការចាំបាច់ និងធ្វើសេចក្តីរាយការណ៍ជូនមេឃុំ ចៅសង្កាត់សាមី ។

## ២.៤ ការប្រព្រឹត្តិទៅនៃដំណើរអភិវឌ្ឍន៍ជីវភាពប្រជាជនរបស់ឃុំប្រាសាទ

### ២.៤.១ ដំណើរការលើការអភិវឌ្ឍជីវភាពប្រជាជនក្នុងឃុំ

ក្រុមប្រឹក្សាឃុំប្រាសាទ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង បានរៀបចំផែនការអភិវឌ្ឍន៍ ដោយផ្ដល់ឱកាសអោយមានការចូលរួមដោយផ្ទាល់ពីប្រជាពលរដ្ឋនៅក្នុងឃុំ និងអ្នកពាក់ព័ន្ធនានានៅក្នុងដំណើរការនៃការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ឃុំរយៈពេល៥ឆ្នាំ។ ផែនការអភិវឌ្ឍន៍ឃុំ ដែលបានបង្កើតឡើងនេះមានសារៈសំខាន់ណាស់ ដើម្បីជួយតម្រង់ទិសឃុំ ក្នុងការរៀបចំ និងអនុវត្តគម្រោង ឬសកម្មភាពអភិវឌ្ឍន៍អោយឆ្លើយតបទៅនឹងតម្រូវការពិតប្រាកដរបស់ប្រជាពលរដ្ឋនៅក្នុងឃុំ ជាពិសេសសំរាប់ណែនាំរាល់ការធ្វើសេចក្ដីសម្រេចចិត្តអំពីការងារអភិវឌ្ឍន៍ឃុំ ការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ និងការរៀបចំថវិកាប្រចាំឆ្នាំរបស់ឃុំ។

ក្នុងនាមក្រុមប្រឹក្សាឃុំប្រាសាទ អាណត្តិទី៤ សូមថ្លែងអំណរគុណដល់ប្រជាពលរដ្ឋក្នុងឃុំដែលបានចូលរួមលើកឡើងអំពីបញ្ហាជាក់ស្ដែង ដែលបានជួបប្រទះ និងសេចក្ដីត្រូវការអភិវឌ្ឍន៍នានា។ ជាមួយគ្នានេះដែរ ក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់គណៈកម្មាធិការកសាងផែនការ និងថវិការឃុំ ជនបង្គោលនានារបស់ឃុំ មន្ត្រីបច្ចេកទេសគាំទ្រឃុំ បុគ្គលិកគាំទ្របច្ចេកទេសស្រុក ទីប្រឹក្សាស្រុក តំណាងមន្ទីរការិយាល័យអង្គភាព និងអង្គការមិនមែនរដ្ឋាភិបាលដែលបានចូលរួមចំណែក និងគាំទ្រនៅក្នុងដំណើរការនៃការកសាងផែនការអភិវឌ្ឍន៍ឃុំរហូតសំរេចជាស្ថាពរ។

ក្នុងនាមក្រុមប្រឹក្សាឃុំ សូមអំពាវនាវដល់មន្ទីរវិស័យ អង្គភាព អង្គការមិនមែនរដ្ឋាភិបាល សប្បុរសជន និងដៃគូអភិវឌ្ឍន៍នានា ជួយគាំទ្ររាល់គម្រោង ឬសកម្មភាពជាអាទិភាពដែលឆ្លើយតបនឹងក្របខ័ណ្ឌអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ សម្រាប់អាណត្តិក្រុមប្រឹក្សាឃុំ។

ក្រុមប្រឹក្សាឃុំប្រាសាទ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង បានរៀបចំផែនការអភិវឌ្ឍន៍ឃុំរយៈពេល៥ឆ្នាំ (២០១៧-២០២១) សម្រាប់អាណត្តិទី៤របស់ក្រុមប្រឹក្សាឃុំ ដោយយោងតាមច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងប្រកាសអន្តរក្រសួងលេខ ០៨០ ផក ចុះថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០១៧ ស្ដីពីការដាក់អោយប្រើប្រាស់សេចក្ដីណែនាំបច្ចេកទេស ស្ដីពីការរៀបចំ និងការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់។

ក្រុមប្រឹក្សាឃុំ បានរៀបចំកម្មវិធីវិនិយោគឃុំ ដើម្បីប្រមូលផ្ដុំនូវសេចក្ដីត្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋក្នុងឃុំ និងកៀរគរធនធាននានាក្នុងការឆ្លើយតបទៅនឹងសេចក្ដីត្រូវការជាអាទិភាពទាំងនោះ ដែលចូលរួមចំណែកដោយផ្ទាល់ដល់ជីវភាពរស់នៅ និងសុខុមាលភាពរបស់ប្រជា

ពលរដ្ឋ។ ផែនការអភិវឌ្ឍន៍ឃុំ ក៏ត្រូវបានប្រើប្រាស់ជាមូលដ្ឋានក្នុងការធ្វើសេចក្តីសម្រេចចិត្តអំពីការងារអភិវឌ្ឍន៍ឃុំ និងប្រើប្រាស់ជាមូលដ្ឋានក្នុងការរៀបចំថវិកាប្រចាំឆ្នាំរបស់ឃុំផងដែរ។

**ក. ផ្នែកសេដ្ឋកិច្ច**

ឃុំ ប្រាសាទ ជាឃុំមួយដែលប្រជាពលរដ្ឋភាគច្រើនប្រកបរបរកសិកម្មធ្វើស្រែ សម្រាប់ទ្រទ្រង់ជីវិត ហើយគ្រួសារទាំងនោះជាទូទៅធ្វើស្រែពីររដូវគឺ ស្រែវស្សា និងស្រែប្រាំង។ ប្រជាពលរដ្ឋក្រៅពីនេះ មានមួយចំនួនតូចរកស៊ី លក់ដូរ និងធ្វើពាណិជ្ជកម្ម អាជីវកម្មនៅក្នុងផ្សារកអណ្តើក ដែលជាទីប្រជុំជនរបស់ឃុំ។

ទន្ទឹមនឹងនេះផងដែរ ប្រជាជននៅក្នុងឃុំតែងតែមានការជួបប្រទះ ផលពិបាកខ្លះៗដូចជា ផ្លូវពិបាកធ្វើដំណើរ ខ្វះប្រព័ន្ធធារាសាស្ត្រសម្រាប់ស្រោចស្រពដីកសិកម្ម ខ្វះការយល់ដឹងពីបច្ចេកទេសកសិកម្ម ខ្វះពូជ មាន់ ទា ជ្រូក ត្រី ខ្វះបច្ចេកទេសធ្វើជីកំប៉ុស្តិ៍ ហើយមានប្រជាពលរដ្ឋមួយចំនួនទៀតបានចេញទៅរកការងារធ្វើនៅទីក្រុង ជាកម្មករសំណង់ កម្មករលីសែង និងកម្មកររោងចក្រ។

ឆ្លងតាមបញ្ហាទាំងអស់នេះឃុំបានខិតខំប្រឹងប្រែងស្វែងរកការឧបត្ថម្ភគាំទ្រពី អង្គការនានា មន្ទីរវិស័យសប្បុរសជន និងដៃគូរអភិវឌ្ឍន៍ដើម្បីជួយផ្តល់សេវាទាំងអស់នេះ។[33]

**ខ. ផ្នែកសង្គមកិច្ច**

ឃុំប្រាសាទមានមន្ទីរពេទ្យបង្អែកស្រុក មានបុគ្គលិកសុខាភិបាល បានសហការណ៍ជាមួយ ភូមិ ឃុំ អ្នកស្ម័គ្រចិត្តភូមិ រួមគ្នាណែនាំអោយប្រជាពលរដ្ឋមួយចំនួនធំយល់ដឹងពីសារៈប្រយោជន៍នៃការចាក់វ៉ាក់សាំងការពារជំងឺ៨មុខដល់កុមារ យល់ដឹងពីសារៈប្រយោជន៍នៃការពិនិត្យផ្ទៃពោះនៅមណ្ឌលសុខភាព យល់ដឹងពីសុខភាពអនាម័យ និងការប្រើប្រាស់ទឹកស្អាត។ ចំពោះវិស័យអប់រំ ឃុំមានសាលាបឋមសិក្សាចំនួន៤កន្លែង ដែលមានអគារសរុបចំនួន១២ខ្នង ស្មើនឹង៥៣បន្ទប់ ឃុំមានវិទ្យាល័យមួយកន្លែងមានចំនួន៩អគារ ស្មើនឹង៤៤បន្ទប់ និងមានមត្តេយ្យសិក្សាសហគមន៍ ចំនួន៣កន្លែង។

ទន្ទឹមនឹងការរីកចម្រើនទាំងនេះ ក៏នៅមានប្រជាពលរដ្ឋមួយចំនួនមិនទាន់យល់ដឹងពីសុខភាពអនាម័យ សារៈប្រយោជន៍នៃការចាក់ថ្នាំបង្ការជំងឺដល់កុមារ និងការប្រើប្រាស់ទឹកស្អាតមិនទាន់បានត្រឹមត្រូវ ហើយកុមារមួយចំនួនដែលគ្រប់អាយុមិនទាន់បានចូលរៀនគ្រប់គ្នា។ ហេតុដូច្នេះឃុំ

[33] ឯកសារ "កម្មវិធីវិនិយោគឃុំឆ្នាំ ២០១៧ ឃុំប្រាសាទ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង" ខែមករាឆ្នាំ២០១៧

សូមអំពាវនាវដល់ដៃគូអភិវឌ្ឍន៍នានា សូមជួយគាំទ្រលើគម្រោងរបស់ឃុំដើម្បីដោះស្រាយបញ្ហាទាំងនេះ។

ចំណែកវិស័យយេនឌ័រសព្វថ្ងៃនេះ មានស្ត្រីជាសមាជិកនៃអង្គការ ជាគណៈកម្មាធិការ ជាសមាជិកភូមិ ដែលផ្តល់ផលប្រយោជន៍ដល់ស្ត្រី និងកុមារ សមភាពយេនឌ័រនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តទាក់ទងនឹងការងារអភិវឌ្ឍន៍។ ទន្ទឹមនឹងការរីកចម្រើនទាំងអស់នេះនៅមានប្រជាពលរដ្ឋមួយចំនួនតូចមិនទាន់យល់ច្បាស់ពី ច្បាប់ប្រឆាំងអំពើហឹង្សាក្នុងគ្រួសារ សិទ្ធិស្មើគ្នារវាងបុរសនិងស្ត្រីជាដើម។ ផ្អែកតាមបញ្ហាទាំងអស់នេះឃុំបានលើកឡើងនូវគម្រោងជាច្រើនដូចជា : ផ្សព្វផ្សាយច្បាប់ទបស្កាត់ប្រឆាំងអំពើហឹង្សាក្នុងគ្រួសារ ច្បាប់ប្រឆាំងការជួញដូរស្ត្រី និងកុមារ ច្បាប់សិទ្ធិមនុស្ស យេនឌ័រ ដោយសង្ឃឹមជឿជាក់ថាប្រាកដជាមានការគាំទ្រពីមន្ទីរវិស័យ និងដៃគូអភិវឌ្ឍន៍នានា។[34]

## គ. ផ្អែកធនធានធម្មជាតិ និងបរិស្ថាន

ឃុំប្រាសាទមានស្រះសហគមន៍សម្រាប់ជាជម្រកត្រី និង សម្រាប់អោយប្រជាពលរដ្ឋនេសាទផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃ ហើយក៏មានទីប្រជុំជនផ្សារកអណ្តើកជាទីផ្សារទំនិញ ប៉ុន្តែទីប្រជុំជនផ្សារនេះគ្មានកន្លែងទុកដាក់សំរាម គ្មានលូបង្ហូរទឹកស្អុយចេញពីផ្សារ ដែលជាកត្តាធ្វើអោយផ្សារមានភាពកខ្វក់ ឃុំពុំមានលទ្ធភាពដោះស្រាយបញ្ហាទាំងនេះនៅឡើយ។ ឆ្លងកាត់បញ្ហាទាំងនេះឃុំបានខិតខំសហការណ៍និងស្វែងរកការឧបត្ថម្ភគាំទ្រពីមន្ទីរវិស័យ អង្គការជាតិ និងអន្តរជាតិ ដៃគូអភិវឌ្ឍន៍នានា ដើម្បីសុំការគាំទ្រចំពោះគម្រោងឬសកម្មភាពជាអាទិភាពរបស់ឃុំ។[35]

## ឃ. ផ្អែកសេកម្មរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

ឃុំប្រាសាទ មានសន្តិសុខសណ្តាប់ធ្នាប់ល្អ អំពើចោរកម្ម អំពើហឹង្សាក្នុងគ្រួសារ ការរំលោភបំពានលើសិទ្ធិស្ត្រីនិងកុមារ ការជួញដូរ បញ្ហាទំនាស់ផ្សេង ឃុំបានទប់ស្កាត់ទាន់ពេលវេលា និងបានសម្របសម្រួលតាមផ្លូវច្បាប់ ដោយឃុំបានធ្វើការផ្សព្វផ្សាយជាសាធារណៈនូវច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់ការងារអគ្រានុកូលដ្ឋាន ដែលជំរុញឲ្យប្រជាពលរដ្ឋចុះអគ្រានុកូលដ្ឋានបានប្រហែល៩០%។

ទន្ទឹមនឹងការរីកចម្រើនទាំងនេះ ឃុំនៅមានជួបបញ្ហាខ្លះៗដូចជា : ក្មេងទំនើង ក្រុមបងតូចបងធំ បានវាយតប់គ្នានៅក្នុងពិធីបុណ្យ តាមវត្ត តាមផ្ទះ និងពិធីរៀបមង្គលការជាដើម។ រីឯប្រជា

[34] ឯកសារ "កម្មវិធីវិនិយោគឃុំឆ្នាំ ២០១៧ ឃុំប្រាសាទ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង" ខែមករាឆ្នាំ២០១៧

[35] ឯកសារ "កម្មវិធីវិនិយោគបីឆ្នាំរំកិល (២០១៨-២០២០) ឃុំប្រាសាទស្រុកកំពង់ត្របែក ខេត្តព្រៃវែង"

ពលរដ្ឋមួយចំនួនទៀតពុំទាន់យល់ដឹងពីច្បាប់ភូមិបាល ជាហេតុបង្កអោយមានទំនាស់ដីធ្លីកើតឡើង មួយចំនួនទៀតមិនទាន់យល់ដឹងពីសារៈប្រយោជន៍នៃការចុះសំបុត្រអត្រានុកូលដ្ឋាន ពិសេសកូន ដែលទើបកើតឪពុកម្តាយមិនព្រមទៅចុះសំបុត្រកំណើត។

ឆ្លងកាត់បញ្ហាទាំងនេះ ឃុំបានលើកគម្រោងផ្សព្វផ្សាយច្បាប់ភូមិបាល សារៈប្រយោជន៍នៃ ការចុះសំបុត្រអត្រានុកូលដ្ឋាន ដើម្បីស្វែងរកការឧបត្ថម្ភគាំទ្រពី មន្ទីរជំនាញនិងដៃគូអភិវឌ្ឍន៍នានា ដើម្បីជួយដល់ប្រជាពលរដ្ឋនៅក្នុងឃុំ។[36]

**ពត៌មាននៃសកម្មភាពដែលបានអនុវត្តក្នុងឆ្នាំ ២០១៦**

ក. ផ្នែកហេដ្ឋារចនាសម្ព័ន្ធរូបវន្តៈ ឃុំបានជួសជុលផ្លូវលំដីក្រាលខ្សាច់ភ្នំនៅក្នុងភូមិ ប្រាសាទ , ដូនទុង, និងភូមិភ្លូង ចំនួន២៤៨០ម៉ែត្រ ដោយប្រើប្រាស់មូលនិធិឃុំ២០១៦។

ខ. ផ្នែកហេដ្ឋារចនាសម្ព័ន្ធអរូបវន្ត ឃុំបានធ្វើសកម្មភាពដូចជា៖

- ចុះផ្តល់សេវានៅមូលដ្ឋាន គ្រប់ភូមិ ចំនួន២១៦លើក, យុទ្ធនាការដាក់ថ្នាំអាប៊ែតនៅតាម ពាង និងអាងទឹក ដែលបានអនុវត្តគ្រប់ភូមិ ចំនួន១៨លើក, ចុះអប់រំផ្សព្វផ្សាយជំងឺគ្រុន ឈាមដល់ប្រជាជននៅគ្រប់ភូមិ ចំនួន៤លើក ដោយសកម្មភាពទាំងនេះទទួលបានការគាំ ទ្រពីការិយាល័យសុខាភិបាល
- ផ្តល់សេវាឥណទាននៅគ្រប់ភូមិរយៈពេលមួយឆ្នាំ ដោយទទួលបានការគាំទ្រពី ACLEDA, និរន្តរ, វីសិនហ្វាន់, ស្ថាបនា, មហានរគ, LOLC, អម្រឹត
- ផ្តល់សេវាដាក់ប្រាក់បញ្ញើសន្សំ, សេវាផ្ទេរប្រាក់, សេវាចាត់ចែងសាច់ប្រាក់, សេវាធានា រ៉ាប់រងអាយុជីវិត, សេវាអេឡិចត្រូនិច អនុវត្តនៅគ្រប់ភូមិរយៈពេលមួយឆ្នាំ ដែលគាំទ្រដោយ ធនាគារពាណិជ្ជអេស៊ីលីដា
- កម្មវិធីបង្ការ ការថែទាំជំងឺអេដស៍នៅគ្រប់ភូមិរយៈពេល១២ខែ ដែលគាំទ្រដោយវ៉ូមែន
- ជួយឧបត្ថម្ភកុមារដែលគេបោះបង់ចោល រស់នៅក្នុងភូមិចំបក់ ដែលទទួលបានការគាំទ្រពី អង្គការកុមារ
- ជួយក្មេងដែលឪពុកធ្វើចំណាកស្រុក ឬក្រដែលជាប់ចំណាត់ថ្នាក់នូវថវិការក្នុង១នាក់ ៦០,០០០៛ ដែលទទួលបានការគាំទ្រពីអង្គការកុមារ។

**គម្រោង សកម្មភាពវិនិយោគឃុំដែលមានថវិកាគាំទ្រ**

ក. គម្រោង សកម្មភាពប្រើបាស់មូលនិធិឃុំ

[36] ឯកសារ "ផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ (២០១៧-២០២១) ឃុំប្រាសាទ", ឆ្នាំ២០១៧ ទំព័រទី១៣

- ជួសជុលផ្លូវលំដីស ស្ថិតក្នុងភូមិអំពិល ចំនួន២,៦គីឡូម៉ែត្រ
- សាងសង់លូកាត់ផ្លូវ ស្ថិតក្នុងភូមិអំពិល ចំនួន៣កន្លែង

ខ. គម្រោង សកម្មភាពដែលទទួលបានការគាំទ្រពីផ្នែកអ្នកពាក់ព័ន្ធ

- ថែទាំផ្លូវជាប្រចាំ(DBST) ស្ថិតនៅក្នុងភូមិចំបក់ ចំនួន១,២គីឡូម៉ែត្រ ដែលអង្គភាពអនុវត្តគឺមន្ទីរអភិវឌ្ឍន៍ជនបទ
- ការអនុវត្តផែនការយុទ្ធសាស្ត្រ គណនេយ្យភាពសង្គម គ្រប់ភូមិ ប្រភពមូលនិធិ JSDF WB
- កម្មវិធីផ្តល់ការថែទាំគាំទ្រដល់អ្នកជំងឺអេដស៍ និងអ្នកផ្ទុករោគអេដស៍ គ្រប់ភូមិ ប្រភពមូលនិធីពី NCHAD
- ផ្តល់សេវាឥណទាន, សេវាបញ្ញើ-សន្សំ, សេវាផ្ទេរប្រាក់, សេវាធនាគារអេឡិចត្រូនិច, សេវាចាត់ចែងសាច់ប្រាក់, សេវាហិរញ្ញប្បទានពាណិជ្ជកម្ម, សេវាធានារ៉ាប់រងអាយុជីវិត, និងសេវាភតិសន្យាហិរញ្ញវត្ថុ អនុវត្តគ្រប់ភូមិ ប្រភពមូលនិធិពី ACLEDA
- ផ្តល់សេវាឥណទានសាច់ប្រាក់ គ្រប់ភូមិរយៈពេល១២ខែ ប្រភពមូលនិធិពី LOLC
- ផ្តល់សេវាឥទានសាច់ប្រាក់ គ្រប់ភូមិរយៈពេល១២ខែ ប្រភពមូលនិធិពីប្រាសាក់។

**គម្រោង សកម្មភាព អាទិភាពឃុំដែលមិនទាន់មានថវិកាគាំទ្រ**

ក. ផ្នែកសេដ្ឋកិច្ច

- ជួសជុលផ្លូវលំដីស ទីតាំងភូមិ ប្រាសាទ, ចំបក់, ពាន់វត្ត, ជ្រលង, ភូមិបី, និងភូមិថ្កូវ ចំនួន៦,៦គីឡូម៉ែត្រ
- ជួសជុលផ្លូវលំក្រាលខ្សាច់ក្រហម ទីតាំងភូមិ ប្រសាទ, ចំបក់, អំពិល, ពាន់វត្ត, ជ្រលង, ភូមិបី, និងភូមិថ្កូវ ចំនួន៧,៦គីឡូម៉ែត្រ
- ដាក់លូកាត់ផ្លូវ ទីតាំងភូមិប្រាសាទ, ចំបក់, ពាន់វត្ត, ជ្រលង, និងភូមិថ្កូវ ចំនួន១១កន្លែង
- ស្តារប្រឡាយស្រោចស្រព ទីតាំងភូមិប្រាសាទ, អំពិល, ពាន់វត្ត, ជ្រលង, ភូមិបី, ដូនទុង, និងភូមិថ្កូវ ចំនួន១០គីឡូម៉ែត្រ
- បណ្តុះបណ្តាលបច្ចេកទេសដំណាំស្រូវ ទីតាំងគ្រប់ភូមិ ចំនួន២វគ្គ
- បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វ ទីតាំងគ្រប់ភូមិ ចំនួន២វគ្គ
- ផ្តល់ពូជបន្លែគ្រប់មុខ ទីតាំងគ្រប់ភូមិ ចំនួន១៣៥កញ្ចប់
- ឥណទានការប្រាក់ទាប ទីតាំងគ្រប់ភូមិ ចំនួន៣៥០គ្រួសារ

ខ. ផ្នែកសង្គមកិច្ច

- បើកថ្នាក់មត្តេយ្យសហគមន៍ ទីតាំងភូមិប្រាសាទ, ចំបក់, ពាន់វត្ត, ភូមិបី, ភ្លង, និងភូមិថ្កូវ ចំនួន៦ថ្នាក់
- ថ្នាក់មត្តេយ្យសិក្សាសហគមន៍ ទីតាំងគ្រប់ភូមិ ចំនួន៩លើក
- ផ្តល់សំភារៈថ្នាក់មត្តេយ្យ ទីតាំងគ្រប់ភូមិ ចំនួន៩កំប្លេ
- ផ្តល់គ្រូមត្តេយ្យ គ្រប់ភូមិ ចំនួន១លើក
- ផ្តល់អាហារូបករណ៍សិស្សក្រីក្រ ទីតាំងគ្រប់ភូមិ ចំនួន៤៤៣នាក់
- ផ្សព្វផ្សាយពីសារៈប្រយោជន៍ពីការចាក់វ៉ាក់សាំង ទីតាំងគ្រប់ភូមិ ចំនួន៩លើក
- សាងសង់បង្គន់អនាម័យតាមខ្នងផ្ទះ ទីតាំងគ្រប់ភូមិ ចំនួន៤៥បង្គន់
- សាងសង់ប្រព័ន្ធទឹកស្អាត ទីតាំងភូមិប្រាសាទ ចំនួន១កន្លែង
- ផ្សព្វផ្សាយពីសុខភាពអនាម័យ ទីតាំងគ្រប់ភូមិ ចំនួន៩លើក
- ផ្តល់ការគាំទ្រដល់អ្នកកើតមេរោគអេដស៍ ទីតាំងគ្រប់ភូមិ ចំនួន១លើក
- ផ្តល់ឈើច្រត់ រទេះរុញ ជើងសិប្បនិម្មិត ទីតាំងគ្រប់ភូមិ ចំនួន១លើក
- ផ្សព្វផ្សាយច្បាប់ចរាចរណ៍ផ្លូវគោក ទីតាំងគ្រប់ភូមិ ចំនួន៩លើក
- បណ្តុះបណ្តាលពីយេនឌ័រ ទីតាំងគ្រប់ភូមិ ចំនួន១វគ្គ
- ផ្សព្វផ្សាយច្បាប់ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ទីតាំងគ្រប់ភូមិ ចំនួន៩លើក
- ស្នើរសុំបុគ្គលិកពេទ្យបន្ថែម៥នាក់ ទីតាំងមណ្ឌល
- ស្នើរសុំសំភារៈពិនិត្យផ្ទៃពោះ ទីតាមមណ្ឌល ចំនួន១កំប្លេ

គ. ផ្នែកធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនិងការប្រែប្រួលអាកាសធាតុ

- ផ្សព្វផ្សាយពីផលប៉ះពាល់នៃបម្រែបម្រួលអាកាសធាតុ ទីតាំងគ្រប់ភូមិ ចំនួន៩លើក
- ផ្សព្វផ្សាយវិធានការត្រៀមបង្ការគ្រោះមហន្តរាយ ទីតាំងគ្រប់ភូមិ ចំនួន៩លើក

ឃ. ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

- ផ្សព្វផ្សាយពីសារៈប្រយោជន៍នៃការចុះអត្រានុកូលដ្ឋាន ទីតាំងគ្រប់ភូមិ ចំនួន៩លើក
- បណ្តុះបណ្តាលភាពជាអ្នកដឹកនាំជាស្ត្រី ទីតាំងគ្រប់ភូមិ ចំនួន១វគ្គ
- សាងសង់អគារសាលាឃុំ ទីតាំងភូមិដូនទុង ចំនួន១អគារ
- ផ្សព្វផ្សាយច្បាប់ភូមិបាល ទីតាំងគ្រប់ភូមិ ចំនួន៩លើក ។

## ២.៤.២ ភាពជោគជ័យ និងបញ្ហាដែលជួបប្រទះ

### ២.៤.២.១ សមិទ្ធិផលនៃការអភិវឌ្ឍឃុំប្រាសាទ

**១. ការគ្រប់គ្រងរដ្ឋបាលឃុំ**

ក. អំពីក្រុមប្រឹក្សា

ឃុំប្រាសាទ មាន៩រូប ស្រី ១រូប រីឯ ការលើកកំពស់ប្រសិទ្ធិភាព ការគ្រប់គ្រងរដ្ឋបាលឃុំ តាមរយៈការប្រជុំ យោងតាមបទបញ្ជាផ្ទៃក្នុង ក្រុមប្រឹក្សាឃុំ បានធ្វើការប្រជុំអាណត្តិទៀតទាត់ជារៀងរាល់ខែ និង ការប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សា បានប្រជុំអនុម័តលើការងារចាំបាច់ និងកិច្ចការផ្សេងៗទៀតដែលជាតម្រូវការរបស់ប្រជាពលរដ្ឋ។ លើសពីនេះទៅទៀត ក្រុមប្រឹក្សាឃុំបានប្រជុំពិគ្រោះយោបល់ ជាមួយប្រជាពលរដ្ឋ នូវផែនការ៥ឆ្នាំ និងកម្មវិធីវិនិយោគឃុំ ១ឆ្នាំម្តងៗស្វែងរកតម្រូវការនិងដំណោះស្រាយជូនប្រជាពលរដ្ឋ។ ហើយ ក្រុមប្រឹក្សាឃុំ និង គ.ក.ន. បានប្រជុំលើកនៅផែនការ និងកម្មវិធីវិនិយោគឃុំ បញ្ចូលនូវគម្រោងមួយចំនួនពាក់ព័ន្ធស្ត្រី និងកុមារ ដើម្បីក្រុមប្រឹក្សាឃុំធ្វើការអនុម័ត។

ខ.ការងាររដ្ឋបាល

ការផ្តល់សេវារដ្ឋបាល : ក្នុងការធ្វើលិខិតស្នាមផ្សេងៗ មានដូចជា ច្បាប់ការ ច្បាប់បុណ្យ សំបុត្រកំណើតចំនួន ៨៥៣នាក់ សំបុត្របញ្ជាក់កំណើតចំនួន ១៥៨៩នាក់ សំបុត្រអាពាហ៍ពិពាហ៍ចំនួន ២៧៤គូរ សំបុត្រ មរណៈភាពចំនួន ២៣៦នាក់ និងសេវាផ្សេងៗទៀតបានធ្វើជូន ប្រជាជន តាមសំណូមពរ និងទាន់ពេលវេលា។

ការទំនាក់ទំនង ការគាំទ្រ និងសហប្រតិបត្តិការ រវាងរដ្ឋបាលឃុំជាមួយរដ្ឋបាលក្រុង ស្រុក ខេត្ត មន្ទីអង្គភាពនានា រយៈពេល៥ឆ្នាំ ឃុំបានទំនាក់ទំនងស្វែងរកការងារ គាំទ្រ ពីស្រុក ខេត្តអង្គភាពនានា មន្ទីវិស័យ អង្គការ សប្បុរសជន និងដៃគូរអភិវឌ្ឍន៍ រូបវន្ត និងអរូបវន្តដើម្បីសំដៅអោយជីវភាពប្រជាពលរដ្ឋកាន់តែប្រសើរឡើង និងកាត់បន្ថយភាពក្រីក្រ។

**២. ប្រាក់មូលនិធិឃុំ ឆ្នាំ ២០១២-២០១៧ សម្រាប់ការអភិវឌ្ឍនៅឃុំប្រាសាទ**

- ជួសជុលផ្លូវលំដីស ប្រវែង ១២១៣០ ម៉ែត្រ
- ក្រាលខ្សាច់ក្រួំ ប្រវែង ៤០៩០ ម៉ែត្រ
- ថែទាំផ្លូវ ប្រវែង ៤៧០០ ម៉ែត្រ
- លូ ទោល ១០ កន្លែង មុខកាត់ ៦០
- លូ ភ្លោះ ២ កន្លែង មុខកាត់ ៨០

សរុបថវិកាចំនួន ៥ ៩២១ ៦៥០ ០០០៛, សរុបទុនចូលរួម ២ ១៥០ ០០០៛

បន្ថែមពីនេះ ឃុំក៏បានកសាងអាគារមួយខ្នង បណ្តោយ ប្រវែង ៨ ម៉ែត្រ ទទឹង៤ ម៉ែត្រ ប្រក់ដែក ដោយទទួលបានការឧបត្ថម្ភពីសប្បុរសជន ប្រជាពលរដ្ឋ អាចារ្យ នាយកសាលា នាយករងសរុប ១៤ ៥២០ ០០០៛។

## ៣. ប្រាក់មូលនិធិមនុស្សធម៌ ស ខេង

ការផ្តត់ផ្គង់សមាគមន៍មូលនិធិ មនុស្សធម៌ ស ខេង គិតចាប់ពីថ្ងៃទី ១៦ ខែតុលា ឆ្នាំ២០១៣ ដល់ថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ២០១៦

- ស្ត្រីសម្រាលកូន ៥១៥នាក់ កូន ៥២១នាក់ ទឹកប្រាក់ ៧៨ ៧៩៩ ០០០៛
- ចូលបុណ្យសព ១៤៥នាក់ ទឹកប្រាក់ ២៨ ៨០០ ០០០៛
- អ្នកជំងឺ ១នាក់ ទឹកប្រាក់ ២០០ ០០០៛

សរុប ១០៧ ៧០០ ០០០៛។

## ៤. វិស័យសេដ្ឋកិច្ច

ការបង្កបង្កើនផលរយៈពេល ៥ឆ្នាំ បានទទួលផលជាមធ្យមលើ ផ្ទៃដីសរុប ២៩០៨ ហិចតា។ ការចិញ្ចឹមសត្វ គោឈ្មោលចំនួន ១៧៧៦ក្បាល គោញី ១០៦៣ក្បាល ក្របីឈ្មោចំនួន ៥២ក្បាល ក្របីញីចំនួន ៦១ក្បាល ជ្រូកបាចំនួន ១៣ក្បាល ជ្រូកមេចំនួន ៩១៣ក្បាល ជ្រូកសាច់ ១២៣៤ កូនចំនួន ២៨០១ក្បាល មាន់ស្រែចំនួន ៣៩២៧ក្បាល មាន់ពូជ ១៧៩៨ក្បាល ទាចំនួន ៣៥១៧ ក្បាល។

ជីវភាពរស់នៅរបស់ប្រជាជនមានភាពធូរធាសមរម្យរយៈពេល៥ឆ្នាំនេះ គឺប្រជាជនមានផ្ទះសរុប ២៥១២ ចំនួនផ្ទះថ្ម ២៧១ ចំនួនផ្ទះប្រក់ក្បឿង ១០១៥ ចំនួនផ្ទះប្រក់ស័ង្កសី ១១៩៧ ចំនួនផ្ទះស្លឹក ២៩។ ចំពោះអ្នកដែលមានរថយន្តចំនួន ១៣៥គ្រឿង ម៉ូតូគ្រប់ធុនចំនួន ២៧១១គ្រឿង កង់ចំនួន ១៧៩៦ ម៉ាស៊ីនច្រូតស្រូវ និងបោក ៥គ្រឿង គោយន្ត ៥៤២គ្រឿង ត្រាក់ទ័រ ៨គ្រឿង ម៉ាស៊ីនច្រូត ១១គ្រឿង ម៉ាស៊ីនបោក ១៥គ្រឿង។

## ៥. វិស័យអប់រំ

- មតេយ្យរដ្ឋមាន ៣កន្លែង មាន ៥ថ្នាក់ គ្រូ ៥នាក់ សិស្ស ១៤៥នាក់ ស្រី ៧២នាក់
- មតេយ្យសហគមន៍មាន ៣កន្លែង គ្រូ ៣នាក់ សិស្ស ៥១នាក់ ស្រី ២៦នាក់
- សាលាបឋមសិក្សាមាន ៤កន្លែង
- អនុវិទ្យាល័យ និងវិទ្យាល័យមាន ១កន្លែង។

អាគារសាលាបឋមសិក្សាប្រាសាទ ត្រូវបានកសាងថ្មី ១ខ្នង បង្គន់ ៤បន្ទប់ អណ្តូង ១ ជាអំណោយរបស់ ក្រសួងអប់រំយុវជន និងកីឡា សមិទ្ធផល និងការចូលរួមរបស់សហគមន៍ និងអង្គការដៃគូ។

## ៦. វិស័យសុខាភិបាល

- ពង្រឹង និងពង្រីកប្រព័ន្ធ សុខាភិបាល ដើម្បីធានាការផ្តល់សេវាសុខាភិបាលជូនប្រជាជន ប្រកបដោយប្រសិទ្ធិភាព គុណភាព និងសមធម៌។ ជំរុញការថែទាំ លើកកំពស់សុខភាព មាតា ទារក និងកុមារ សុខភាពបន្តពូជ អាហាររូបត្ថម្ភ និងអប់រំសុខភាព។ បង្កើនការងារ បង្ការនិងប្រយុទ្ធនិងជំងឺឆ្លង និងជំងឺរុំារ៉ៃផ្សេងៗ។
- ពង្រីកសេវា សង្គ្រោះបន្ទាន់ និងសេវាថែទាំសេវានៅមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក ក្នុងនោះគឺមានមន្ទីរពេទ្យបង្អែកកំពង់ត្របែក។
- បង្កើនអត្រាគ្របដណ្តប់នៃការផ្តល់ថ្នាំបង្ការគ្រប់មុខ វ៉ាក់សាំង រួមទាំងបញ្ចូលវ៉ាក់សាំងថ្មីៗពង្រឹងយុទ្ធនាការ ផ្តល់ថ្នាំបង្ការបន្ថែម ដើម្បីឈានទៅបំបាត់ជំងឺគ្រុនចាញ់ សំដៅឈានទៅបំបាត់ទាំងស្រុងនូវជំងឺនេះនៅត្រឹមឆ្នាំ២០១៥។

ក. ការងារពិនិត្យពិគ្រោះជំងឺ : ករណីសរុបចំនួន ១៧៩៧០

ខ. ផ្នែកការពារសុខភាព :

- ពិនិត្យផ្ទៃពោះសរុប ៤៦៣០នាក់
- ចាក់ថ្នាំបង្ការ
  - ការពារជំងឺរបេង ២១១០នាក់
  - ការពាររលាកថ្លើមពេលកើត ២៦៥៩នាក់
  - ការពារជំងឺខាន់ស្លាក់ ក្អកមាន់ តេតាណូស រលាកថ្លើម រលាកស្រោមខួរ លើកទី៣ មានចំនួន ១២៨០នាក់
  - ការពារជំងឺគ្រុនស្វិតដៃជើងលើកទី៣ មានចំនួន ១២៨០នាក់
  - ការពារជំងឺកញ្រ្ជិល ស្អូច ១៥៤៥នាក់
  - ការពារជំងឺរលាកស្រោមខួរក្បាល ១៥៤៥នាក់
  - កុមារបានចាក់ថ្នាំគ្រប់មុខវ៉ាក់សាំង ១៥៤៥នាក់
  - ចាក់ថ្នាំការពារស្ត្រីមានផ្ទៃពោះលើកទី២ មានចំនួន ១៥២៥នាក់
  - ចាក់ថ្នាំការពារស្ត្រីអាយុ ១៥ឆ្នាំ-៤៤ឆ្នាំ ១៧៤៥នាក់

  - ស្ត្រីពន្យាកំណើតលើកដំបូង ២៧០នាក់
  - ស្ត្រីកំពុងប្រើប្រាស់ ពន្យាកំណើតបន្ត ១៣៦០នាក់
- ផ្នែកមីក្រូសារជាតិ
  - ផ្តល់ជីវជាតិអា ដល់កុមារអាយុក្រោម៥ឆ្នាំ ៥៩៦៥នាក់
  - ផ្តល់ជាតិដែក ដល់ស្ត្រីមានផ្ទៃពោះ ៨២០នាក់
  - ផ្តល់ជាតិដែក ដល់ស្ត្រីក្រោយសម្រាល ៤៧៥នាក់
- ថ្នាំទម្លាក់ព្រូន
  - ផ្តល់អោយកុមារអាយុក្រោម៥ឆ្នាំ ៥៣៨៥នាក់
  - ផ្តល់អោយតាមសាលារៀន ២១៣៦០នាក់
  - ផ្តល់អោយស្ត្រីមានផ្ទៃពោះ ៨៥០នាក់
  - ផ្តល់អោយស្ត្រីក្រោយសម្រាល ៤៧៥នាក់
  - ផ្តល់អោយស្ត្រី អាយុ១៥ឆ្នាំ-៤៩ឆ្នាំ ២៦៤៤នាក់។

**៧. វិស័យគមនាគមន៍** : ប្រវែងផ្លូវតាមប្រភេទ

| | | |
|---|---|---|
| • ផ្លូវក្រាលខ្សាច់ក្នំ | ៣ខ្សែ | ប្រវែង ៤០៩០ម៉ែត្រ |
| • ផ្លូវដីស | ៨ខ្សែ | ប្រវែង ១២១៣០ម៉ែត្រ |
| • ថែទាំ | ២ខ្សែ | ប្រវែង ៤៧០០ម៉ែត្រ |
| • ផ្លូវកអណ្តើក-មេសាង | ១ខ្សែ | ប្រវែង ២៨០០ម៉ែត្រ |

- ផ្លូវក្រាលកៅស៊ូ ពីផ្សារកអណ្តើក ទៅភ្នំឈើកាច់ក្នុងនោះប្រវែង ១ ៩៥០ម៉ែត្រ ជាថវិការបស់រាជរដ្ឋាភិបាល
- ផ្លូវធម្មជាតិលើកដោយប្រជាជន មានប្រវែង ១៤.១៤០ម៉ែត្រ។

**៨. វិស័យធារាសាស្ត្រ**

- ស្តារប្រឡាយ អកអំបុក ប្រវែង ៨០០០ម៉ែត្រ
- ដាក់លូរំដោះទឹកភ្លៀងតាមបណ្តោយផ្លូវជាតិ ប្រវែង ១៨០០ម៉ែត្រ
- បានធ្វើលូរំដោះទឹកស្អុយ ប្រវែង ១២០០ម៉ែត្រ

**៩. ការផ្គត់ផ្គង់ទឹកស្អាត និងអគ្គីសនី**

- ផ្គត់ផ្គង់ទឹកស្អាតចំនួន ៥ភូមិ មានចំនួន ៨៥៥គ្រួសារ

- បណ្តាញអគ្គីសនីបានដាក់ខ្សែភ្លើង ឆ្លងកាត់បាន ៨ភូមិគឺ ភូមិប្រាសាទ ចំបក់ ពាន់វត្ត ជ្រលង ដូនទុង ភូមិបី ភូមិត្លង និងភូមិច្ចូវ ប្រជាជនមានអគ្គីសនីប្រើប្រាស់បាន ២៤៧៥គ្រួសារ ស្មើរនឹង៩០%។

## ១០. ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន

លូបង្ហូរទឹកស្អុយប្រវែង ១៦៥០ម៉ែត្រ នៅពេលដែលប្រជាពលរដ្ឋជួបការលំបាក ដូចជាគ្រោះធម្មជាតិ ទឹកជំនន់ និងគ្រោះថ្នាក់ផ្សេងៗ។ លើសពីនេះ គណៈកម្មាធិការបក្សឃុំប្រាសាទបានយកចិត្តទុកដាក់បំផុសដល់ព្រះសង្ឃ អាចារ្យវត្ត សប្បុរសជន អង្គការនានា និងកាកបាទក្រហម ដើម្បីស្វែងរកអំណោយសង្គ្រោះបន្ទាន់ ជាលទ្ធផលកាកបាទក្រហមបានផ្តល់សំភារៈដល់អ្នករងគ្រោះខ្យល់ព្យុះ ៣គ្រួសារ នៅក្នុងភូមិច្ចូវ និងភូមិដូនទុង របើកដំបូល១គ្រួសារ នៅក្នុងភូមត្លងទទួលអំណោយពីកាកបាទក្រហមខេត្តមាន អង្ករ មី ទឹកត្រី ទឹកស៊ីអ៊ីវ សារ៉ុង ភួយ។ ជាក់ស្តែង នាយប់ថ្ងៃទី២៥ ខែ១១ ឆ្នាំ២០១៤ មានហេតុការណ៍ភ្លើងឆេះផ្សារកអណ្តើក អស់ផ្ទះ ចំនួន២៨ខ្នង តូបលក់ ចំនួន១៧៣តូប គ្រួសារដែលទទួលបានការឧបត្ថម្ភពីកាកបាទក្រហមខេត្តមាន ចំនួន១២៩ គ្រួសារ សំភារៈដែលទទួលបានមាន អង្ករ ២៥គីឡូក្រាមក្នុង១គ្រួសារ មី១កេះ ក្រម៉ា១ សារ៉ុង១ មុង ១ កន្ទេល១ ភួយចំនួន១។ ម៉្យាងក៏ធ្លាប់មាន អំណោយរបស់ឯកឧត្តម ស សុខា បានឧបត្ថម្ភអណ្តូងទឹក២ ជូនដល់ប្រជាជនដែលរស់នៅក្នុងភូមិបី និងភូមិជ្រលង។

## ១១.វិស័យសាសនា

ឃុំប្រាសាទមានវត្ត ចំនួន៤គឺ វត្តអំពិល វត្តកស្សបៈ វត្តប្រាសាទ និងវត្តសិរីសង្គម ។ ប្រជាពលរដ្ឋឃុំប្រាសាទ៩៩% កាន់សាសនាព្រះពុទ្ធ ក្នុងនោះមាន អាចារ្យចំនួន ៥នាក់ និងគណៈកម្មាការ ១១រូប។ វត្តកស្សបៈមានភិក្ខុ ចំនួន៦អង្គ សាមណេរ ចំនួន៨អង្គ អាចារ្យ ៥នាក់ គណៈកម្មាការ ១២នាក់។ ចំណែកឯវត្តប្រាសាទ មានព្រះភិក្ខុ៥អង្គ សាមណេរ ៩អង្គ អាចារ្យ ៥នាក់ គណៈកម្មាការ១៣នាក់។

សមិទ្ធិផលនានាក្នុងវត្តនីមួយៗ មានការរីកចំរើនគួរអោយចាប់អារម្មណ៍ និងជាទីមោទនៈ។ វិស័យព្រះពុទ្ធសាសនានៅក្នុងឃុំ មានការរីកចំរើនជាបន្តបន្ទាប់ ដូចជាចាក់បេតុងនៅក្នុងទីធ្លាវត្ត ផ្លូវចូលវត្ត កសាងព្រះវិហារ សាលាឆាន់ កុដិ ស្រះទឹក។ល។ ក្រៅពីសាសនាព្រះពុទ្ធ ក្នុងឃុំមានសាសនាគ្រីះ១កន្លែង។

## ១២. ការលើកកំពស់សមាសភាពសមធមិយេនឌ័រ និងការជួយជនរងគ្រោះ

ក. ការលើកកំពស់សមាសភាពសមធមិយេនឌ័រ

នៅឃុំប្រាសាទមានស្ត្រីជា គ.ក.ន.ក ជាថ្នាក់ដឹកនាំតាមភូមិ ជាភ្នាក់ងារស្ម័គ្រចិត្តភូមិ សំខាន់ស្ត្រីជា គ.ក.ន.ក បានចូលរួមប្រជុំលើកផែនការ និងកម្មវិធីវិនិយោគឃុំ បញ្ចូលនូវគម្រោងមួយចំនួនដែលពាក់ព័ន្ធនឹងស្ត្រី និងកុមារ ដើម្បីក្រុមប្រឹក្សាឃុំធ្វើការអនុម័ត។

ខ. ការជួយជនរងគ្រោះនៅក្នុងឃុំ

ចំណាយមនុស្សធម៌របស់កាកបាទក្រហមខេត្តព្រៃវែង បានឧបត្ថម្ភដល់កុមារដែលផ្ទុកមេរោគអេដស៍ ចំនួន៥នាក់ រស់នៅក្នុងភូមិអំពិល ភូមិចំបក់ ភូមិជ្រលង ភូមិប្រាសាទ និងភូមិដូនទុង ចំនួន៣លើក ក្នុង១នាក់ៗទទួលបានអង្ករ ៥០គីឡូក្រាម មីកន្លះកេះ ត្រីខ៥កំប៉ុង ថវិកា៥ម៉ឺនរៀល ។ កាកបាទក្រហមកម្ពុជាក៏បានចែកអំណោយដល់កុមារកំព្រាដែលផ្ទុកមេរោគ ចំនួន៥នាក់ នូវអង្ករ៥គីឡូក្រាម មី១កេះ សៀវភៅ ៥ក្បាល ប៊ិច ៥ក្បាល ត្រីខ ១យួរ ប្រេងកូឡា ១ដប ប្រេងខ្យល់ ១ដប និងប្រាក់ ២០០,០០០៛។

អំណោយមនុស្សធម៌របស់ក្រុមសហព័ន្ធយុវជន បាននាំយកអំណោយមានដូចជា អង្ករ ទឹកត្រី ទឹកស៊ីអ៊ីវ មី និងថវិកា ទៅចែកជូនដល់ប្រជាពលរដ្ឋក្រីក្រលំបាក ដែលរស់នៅក្នុងភូមិភ្លូង ១គ្រួសារ ភូមិពាន់វត្ត ២គ្រួសារ ភូមិដូនទង់ ២គ្រួសារ។

អំណោយមនុស្សធម៌របស់លោកអភិបាលស្រុកកំពង់ត្របែក បានឧបត្ថម្ភជូនអ្នកទីទ័លក្រចំនួន១៥គ្រួសារ ដែលរស់នៅក្នុងភូមិថ្កូវ ភូមិបី ភូមិអំពិល និងភូមិដូនទុង អំណោយដែលចែកជូនមាន អង្ករ ទឹកត្រី ទឹកស៊ីអ៊ីវ មី និងថវិកា។

អំណោយរបស់គ្រឹះសាសនា (ដំណឹងល្អទាំង៤) បានឧបត្ថម្ភចំនួន ២០៥គ្រួសារ ក្នុងគ្រួសារនីមួយៗ ទទួលបានអង្ករ២២គីឡូក្រាម កម្រាលពូក១ ត្រីខ៥កំប៉ុង មី៥កញ្ចប់ ត្រណាប់ម៉ម ១ថង់ ថ្នាំពេទ្យបាត់ក្តៅខ្លួន ១០០គ្រាប់។

**១៣. ការងារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ**

ក. ការអនុវត្តគោលនយោបាយភូមិឃុំ មានសុវត្ថិភាព : ក្នុងរយៈពេល៥ឆ្នាំកន្លងមក ឃុំប្រាសាទមានសន្តិសុខល្អប្រសើរ ប្រជាពលរដ្ឋទទួលបានសេចក្តីសុខ មិនមានការព្រួយបារម្ភអ្វីឡើយ។

ខ.បទល្មើសព្រហ្មទណ្ឌ : បានបង្ក្រាបឃាត់ខ្លួនជនសង្ស័យចំនួន ៩នាក់ ប្រុស និងវត្ថុតាង មានម៉ូតូចំនួន៣គ្រឿង បានបញ្ជូនទៅកាន់តុលាការ។

គ. គ្រោះថ្នាក់សង្គម : គ្រោះថ្នាក់ចរាចរណ៍បានកើតឡើង ៩ករណី ស្លាប់៧នាក់ ស្រី១នាក់ របួស ៦នាក់ ស្រី២នាក់ ខូចម៉ូតូ៧គ្រឿង កង់១។

ឃ. ការងារអនុវត្តភូមិឃុំមានសុវត្ថិភាព :

- បានចុះផ្សព្វផ្សាយផែនការ តាមរោងបុណ្យ និងតាមវត្តអារាម បានចំនួន ១៥លើក មានប្រជាពលរដ្ឋចំនួន២៨៧នាក់ ស្រី៩៨នាក់។
- បានចុះផ្សព្វផ្សាយគោលនយោបាយភូមិឃុំមានសុវត្ថិភាព ចំនួន៩ភូមិ មានលក្ខណៈ៩យ៉ាង ចំនួន ១៤លើក មានប្រជាពលរដ្ឋចូលរួម ចំនួន ៥៩៨៧នាក់ ក្នុងនោះស្រី ២៦០៣នាក់។
- បានផ្សព្វផ្សាយបើកវេទិកាសាធារណៈចំនួន ៩ភូមិ បាន៦លើក ប្រជាពលរដ្ឋចូលរួមចំនួន ៤៦៥០នាក់ ក្នុងនោះស្រី ២២០៧នាក់។

**២.៤.២.២ បញ្ហាដែលជួបប្រទះ**

ទន្ទឹមនឹងភាពជោគជ័យក្នុងការអភិវឌ្ឍជីវភាពប្រជាជននៅក្នុងឃុំប្រាសាទទាំងអស់ខាងលើនេះ ឃុំក៏ជួបនូវបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

- ផ្លូវពិបាកធ្វើដំណើរ : បញ្ហានេះកើតមានគ្រប់ភូមិទាំងអស់ដែលនៅក្នុងឃុំប្រាសាទ ពោលគឺចំនួន៩ភូមិ ដែលមូលហេតុនៃបញ្ហានេះគឺដោយសារ ផ្លូវលិចទឹក, ខ្វះលូ, ពេលភ្លៀងរអិល, និង ខ្វះការថែទាំ។
- ទិន្នផលស្រូវទាប : បញ្ហានេះកើតមានគ្រប់ភូមិក្នុងឃុំប្រាសាទ ហើយមូលហេតុគឺបណ្តាលមកពី ខ្វះពូជស្រូវទិន្នផលខ្ពស់, ខ្វះបច្ចេកទេសដំណាំស្រូវ, ដីខ្សោះជីជាតិ, និង ខ្វះបច្ចេកទេសប្រើប្រាស់ជីគីមី និងថ្នាំសម្លាប់សត្វល្អិត។
- ទឹកស្រោចស្រព្វដីកសិកម្មមិនគ្រប់គ្រាន់ : បញ្ហានេះកើតមានឡើងគ្រប់ភូមិក្នុងឃុំប្រាសាទ ដែលមូលហេតុគឺបណ្តាលមកពី ខ្វះប្រឡាយ, ខ្វះទរបណ្តែត, និង ខ្វះម៉ាស៊ីនបូមទឹក។
- សត្វឈឺច្រើន : បញ្ហានេះកើតមានឡើងគ្រប់ភូមិក្នុងឃុំប្រាសាទ ហើយវាបណ្តាលមកពី ខ្វះវ៉ាក់សាំងចាក់ការពារជំងឺសត្វ, ខ្វះបច្ចេកទេសចិញ្ចឹមសត្វ, និង ខ្វះបច្ចេកទេសផលិតចំណីសត្វ។
- ប្រាក់ចំណូលគ្រួសារទាប : បញ្ហានេះកើតមានគ្រប់ភូមិក្នុងឃុំប្រាសាទ ដែលបណ្តាលមកពីមូលហេតុដូចជា ខ្វះទុនប្រកបមុខរបរ, ខ្វះពូជចិញ្ចឹមសត្វ,ខ្វះពូជបន្លែ, ខ្វះបច្ចេកទេសដំណាំបន្លែ, ខ្វះពូជត្រីចិញ្ចឹម, , ខ្វះបច្ចេកទេសចិញ្ចឹមត្រី, និង ខ្វះស្រះចិញ្ចឹមត្រី។
- ចំណាកស្រុកច្រើន : កើតមានឡើងគ្រប់ភូមិទាំងអស់ក្នុងឃុំប្រាសាទ ដែលបណ្តាលមកពីប្រជាជនខ្វះជំនាញវិជ្ជាជីវៈ។

- កុមារអាយុពី០៦ទៅ១១ឆ្នាំមួយចំនួនមិនបានចូលរៀន : បញ្ហានេះកើតមានគ្រប់ភូមិក្នុងឃុំប្រាសាទ ហើយវាកើតឡើងដោយសារតែឪពុកម្តាយខ្វះការយល់ដឹងពីសារៈប្រយោជន៍នៃការសិក្សា និងដោយសារភាពក្រីក្រ។
- កុមារអាយុពី០៣ទៅ០៥ឆ្នាំមួយចំនួនមិនបានចូលរៀន : បញ្ហាមួយនេះកើតមាននៅគ្រប់ភូមិទាំងអស់ក្នុងឃុំនេះ ដែលវាបណ្តាលមកពី ខ្វះថ្នាក់មត្តេយ្យសហគមន៍, ខ្វះគ្រូមត្តេយ្យសហគមន៍, ខ្វះសម្ភារៈថ្នាក់មត្តេយ្យ, និងខ្វះការយល់ដឹងពីសារៈប្រយោជន៍ថ្នាក់មត្តេយ្យ។
- ក្រុមជនងាយរងគ្រោះ : បញ្ហានេះកើតមានឡើងគ្រប់ភូមិក្នុងឃុំនេះ ហើយមូលហេតុគឺ ខ្វះការយល់ដឹងពីវិធានការការពារ និងទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍, ពិការពីកំណើត, ខ្វះជំនាញវិជ្ជាជីវៈសម្រាប់ជនពិការ, ខ្វះការយល់ដឹងពីច្បាប់ចរាចរជើងគោក, និងចាស់ជរា កុមារកំព្រាគ្មានទីពឹង។
- ប្រជាពលរដ្ឋឈឺច្រើន : បញ្ហានេះកើតឡើងគ្រប់ភូមិក្នុងឃុំនេះ ហើយវាកើតឡើងដោយសារ ខ្វះការយល់ដឹងពីសុខភាពអនាម័យ, ខ្វះបង្គន់អនាម័យ, ខ្វះវ៉ាក់សាំងចាក់ការពារជំងឺផ្សេងៗ, និងខ្វះការយល់ដឹងពីការប្រែប្រួលអាកាសធាតុ។
- ទឹកស្អាតប្រើប្រាស់មិនគ្រប់គ្រាន់ : បញ្ហានេះកើតមានគ្រប់ភូមិក្នុងឃុំនេះ ដែលមូលហេតុគឺ ខ្វះជើងចម្រោះទឹកស្អាត, ខ្វះប្រព័ន្ធទឹកស្អាត, និងខ្វះការយល់ដឹងពីការបរិភោគទឹកមានសុវត្ថិភាព។
- ប្រជាពលរដ្ឋមួយចំនួនមិនបានចុះបញ្ជីអត្រានុកូលដ្ឋាន : បញ្ហានេះកើតមានគ្រប់ភូមិក្នុងឃុំនេះ ដែលវាបណ្តាលមកពី ខ្វះការយល់ដឹងពីសារៈប្រយោជន៍នៃការចុះអត្រានុកូលដ្ឋាន, និងខ្វះសំបុត្របញ្ជាក់កំណើត និងមរណៈភាព។
- អសន្តិសុខ : បញ្ហានេះកើតឡើងគ្រប់ភូមិក្នុងឃុំនេះ ដែលកើតឡើងដោយសារ ខ្វះការយល់ដឹងពីច្បាប់គោលនយោបាយភូមិឃុំមានសុវត្ថិភាព, ខ្វះការរាយការណ៍ជនមុខសញ្ញា, សកម្មភាពក្រុមប្រជាការពារនៅមានកម្រិត។
- ទំនាស់ដីធ្លី : បញ្ហានេះកើតឡើងគ្រប់ភូមិក្នុងឃុំនេះ ហើយមូលហេតុគឺ ខ្វះការយល់ដឹងពីច្បាប់ភូមិបាល, និងខ្វះប្លង់កម្មសិទ្ធិដីធ្លី។
- អំពើរហឹង្សាក្នុងគ្រួសារ : បញ្ហានេះកើតមានឡើងគ្រប់ភូមិក្នុងឃុំនេះ ដែលវាបណ្តាលមកពី ខ្វះការយល់ដឹងពីច្បាប់សិទ្ធិមនុស្ស, ខ្វះការយល់ដឹងពីច្បាប់ទប់ស្កាត់ប្រឆាំងអំពើរហិង្សាក្នុងគ្រួសារ, និងខ្វះការយល់ដឹងពីយែនឌ័រ។

- ផលនេសាទត្រីថយចុះ : បញ្ហានេះកើតមានឡើងគ្រប់ភូមិក្នុងឃុំនេះ ដែលបណ្តាលមកពីខ្វះការយល់ដឹងពីច្បាប់ជលផល, ស្រះសហគមន៍រាក់, និងខ្វះពូជត្រីធម្មជាតិ។
- ការទុកដាក់កាកសំណល់មិនបានសមរម្យ : បញ្ហានេះកើតមានឡើងក្នុងភូមិចំនួនពីគឺ ភូមិប្រាសាទ និងភូមិដូនទុង។ មូលហេតុនៃបញ្ហានេះគឺខ្វះលូបង្ហូរទឹកស្អុយ,និងខ្វះធុងសំរាម។[37]

### ២.៤.៣ ដំណោះស្រាយ

យោងទៅតាមបញ្ហាដែលជួបប្រទះទាំងអស់ខាងលើនេះ ឃុំប្រាសាទមានដំណោះស្រាយឆ្លើយតបទៅនឹងបញ្ហានីមួយៗដូចខាងក្រោមៈ

- ផ្លូវពិបាកធ្វើដំណើរ : ដំណោះស្រាយចំពោះបញ្ហានេះគឺ ជួសជុលផ្លូវដីស, សាងសង់លូកាត់ផ្លូវ, ជួសជុលផ្លូវក្រាលខ្សាច់, និងថែទាំផ្លូវខ្សាច់ភ្នំ។
- ទិន្នផលស្រូវទាប : ដំណោះស្រាយចំពោះបញ្ហានេះគឺ ផ្តល់ពូជស្រូវទិន្នផលខ្ពស់, បណ្តុះបណ្តាលបច្ចេកទេសដំណាំស្រូវ, ផ្សព្វផ្សាយពីសារៈប្រយោជន៍នៃការប្រើប្រាស់ជីធម្មជាតិ, និងបណ្តុះបណ្តាលបច្ចេកទេសប្រើប្រាស់ជីគីមី និងថ្នាំសម្លាប់សត្វល្អិត។
- ទឹកស្រោចស្រព្វដីកសិកម្មមិនគ្រប់គ្រាន់ : ដំណោះស្រាយចំពោះបញ្ហានេះគឺ ជីកប្រឡាយ, សាងសង់ទរបណ្តោត, និងផ្តល់ម៉ាស៊ីនបូមទឹក។
- សត្វឈឺច្រើន : ដំណោះស្រាយចំពោះបញ្ហានេះគឺ ផ្តល់វ៉ាក់សាំងចាក់ការពារជំងឺសត្វ, បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វ, និងបណ្តុះបណ្តាលបច្ចេកទេសផលិតចំណីសត្វ។
- ប្រាក់ចំណូលគ្រួសារទាប : ដំណោះស្រាយចំពោះបញ្ហានេះគឺ ផ្តល់ទុនប្រកបមុខរបរ, ឥណទានការប្រាក់ទាប, ផ្តល់ពូជជ្រូក, ផ្តល់ពូជគោ ក្របី, ផ្តល់ពូជមាន់ ទា, ផ្តល់ពូជបន្លែគ្រប់មុខ, បណ្តុះបណ្តាលបច្ចេកទេសដំណាំបន្លែ, ផ្តល់ពូជត្រីចិញ្ចឹម, បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រី, និងជីកស្រះចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ។
- ចំណាកស្រុកច្រើន : ដំណោះស្រាយចំពោះបញ្ហានេះគឺ បណ្តុះបណ្តាលជំនាញសំអាងការ, បណ្តុះបណ្តាលជំនាញកាត់ដេរ, បណ្តុះបណ្តាលជំនាញជួសជុលម៉ាស៊ីនគ្រប់ធុន, និងបណ្តុះបណ្តាលជំនាញជួសជុលគ្រឿងអេឡិចត្រូនិច និងបង្កើតរោងចក្រកាត់ដេរ។
- កុមារអាយុពី០៦ទៅ១១ឆ្នាំមួយចំនួនមិនបានចូលរៀន : ដំណោះស្រាយចំពោះបញ្ហានេះគឺ ផ្សព្វផ្សាយដល់ឪពុកម្តាយឲ្យយល់ដឹងពីសារៈប្រយោជន៍នៃការសិក្សា និងផ្តល់អាហាររូបករណ៍សិស្សក្រីក្រ។

[37] ឯកសារ "ផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ (២០១៧-២០២១) ឃុំប្រាសាទ", ឆ្នាំ២០១៧, ទំព័រទី៤៥-៤៩

- កុមារអាយុពី០៣ទៅ០៥ឆ្នាំមួយចំនួនមិនបានចូលរៀន : ដំណោះស្រាយចំពោះបញ្ហានេះគឺ បើកថ្នាក់មត្តេយ្យសហគមន៍, បណ្តុះបណ្តាលគ្រូមត្តេយ្យសហគមន៍, ផ្តល់សម្ភារៈថ្នាក់មត្តេយ្យ, និងផ្សព្វផ្សាយការយល់ដឹងពីសារៈប្រយោជន៍នៃការសិក្សា។
- ក្រុមជនងាយរងគ្រោះ : ដំណោះស្រាយចំពោះបញ្ហានេះគឺ ផ្សព្វផ្សាយវិធានការការពារទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍, ផ្តល់ឈើច្រត់ រទេះរុញ ជើងសុប្បនិម្មិត, បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈសម្រាប់ជនពិការ, ផ្សព្វផ្សាយពីច្បាប់ចរាចរជើងគោក, និងបញ្ជូនចាស់ជរា កុមារកំព្រាទៅមណ្ឌល។
- ប្រជាពលរដ្ឋឈឺច្រើន : ដំណោះស្រាយចំពោះបញ្ហានេះគឺ ផ្សព្វផ្សាយពីសុខភាពអនាម័យ, សាងសង់បង្គន់អនាម័យ, ផ្តល់វ៉ាក់សាំងចាក់ការពារជំងឺផ្សេងៗ, ផ្សព្វផ្សាយពីការប្រែប្រួលអាកាសធាតុ។
- ទឹកស្អាតប្រើប្រាស់មិនគ្រប់គ្រាន់ : ដំណោះស្រាយចំពោះបញ្ហានេះគឺ ផ្តល់ជើងចម្រោះទឹកស្អាត, សាងសង់ប្រព័ន្ធទឹកស្អាត, និងផ្សព្វផ្សាយពីការបរិភោគទឹកមានសុវត្ថិភាព។
- ប្រជាពលរដ្ឋមួយចំនួនមិនបានចុះបញ្ជីអត្រានុកូលដ្ឋាន : ដំណោះស្រាយចំពោះបញ្ហានេះគឺ ផ្សព្វផ្សាយពីសារៈប្រយោជន៍នៃការចុះអត្រានុកូលដ្ឋាន និងផ្តល់សបុត្របញ្ជាក់កំណើត និងមរណៈភាព។
- អសន្តិសុខ : ដំណោះស្រាយចំពោះបញ្ហានេះគឺ ផ្សព្វផ្សាយពីច្បាប់គោលនយោបាយភូមិឃុំមានសុវត្ថិភាព, ផ្សព្វផ្សាយពីសារៈប្រយោជន៍នៃការរាយការណ៍ជនមុខសញ្ញា, និងផ្សព្វផ្សាយជម្រុញសកម្មភាពក្រុមប្រជាការពារ។
- ទំនាស់ដីធ្លី : ដំណោះស្រាយចំពោះបញ្ហានេះគឺ ផ្សព្វផ្សាយពីច្បាប់ភូមិបាល, និងផ្តល់ប្លង់កម្មសិទ្ធិដីធ្លី។
- អំពើហឹង្សាក្នុងគ្រួសារ : ដំណោះស្រាយចំពោះបញ្ហានេះគឺ ផ្សព្វផ្សាយពីច្បាប់សិទ្ធិមនុស្ស, ផ្សព្វផ្សាយពីច្បាប់ទប់ស្កាត់ប្រឆាំងអំពើរហិង្សាក្នុងគ្រួសារ, និងបណ្តុះបណ្តាលពីយែនឌ័រ។
- ផលនេសាទត្រីថយចុះ : ដំណោះស្រាយចំពោះបញ្ហានេះគឺ ផ្សព្វផ្សាយពីច្បាប់ជលផល,ស្តាស្រះសហគមន៍, និងផ្តល់ពូជត្រីធម្មជាតិ។
- ការទុកដាក់កាកសំណល់មិនបានសមរម្យ : ដំណោះស្រាយចំពោះបញ្ហានេះគឺ សាងសង់លូបង្ហូរទឹកស្អុយ, និងផ្តល់ធុងសំរាម។[38]

[38] ផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ (២០១៧-២០២១) ឃុំប្រាសាទ, ឆ្នាំ២០១៧, ទំព័រទី៤៥-៤៩

## សន្និដ្ឋានជំពូក

សរុបសេចក្តីមក ឃុំនេះជាឃុំដែលមានអាយុកាលដ៏ចំណាស់មកហើយ មានទីតាំងស្ថិតនៅចម្ងាយពីទីរួមស្រុកកំពង់ត្របែក ៧គីឡូម៉ែត្រ និងមានភូមិចំនួន ៩ ។ មិនខុសពីឃុំដទៃទៀតដែរ ឃុំនេះមានចក្ខុវិស័យ គោលបំណង គោលដៅ និងយុទ្ធសាស្ត្រនៃការអភិវឌ្ឍ ដែលសម្រេចបាននូវសមិទ្ធិផលជាច្រើនដល់ឃុំ ក៏ដូចជាដល់ប្រជាជនក្នុងឃុំ មានដូចជា សាលារៀន មណ្ឌលសុខភាព ផ្លូវ...។ ទន្ទឹមនឹងសមិទ្ធិផល និងភាពជោគជ័យទាំងនេះ ឃុំក៏បានជួបប្រទះនូវបញ្ហារាំងស្ទះជាច្រើន ដែលរារាំងដល់ដំណើរការអភិវឌ្ឍ ដែលជាបច្ច័យអវិជ្ជមានជះឥទ្ធិពលដល់ការប្រកបមុខរបររបស់ប្រជាជនក្នុងឃុំ។ បញ្ហាទាំងអស់នោះទាមទារឲ្យមានដំណោះស្រាយដ៏មានប្រសិទ្ធភាព និងភាពសក្តិសិទ្ធ ក្នុងគោលដៅកាត់បន្ថយភាពក្រីក្រ និងបង្កើនកម្រិតជីវភាពរបស់ប្រជាជននៅក្នុងឃុំ តាមរយៈការធ្វើឲ្យផលិតភាពក្នុងដំណើរការលើមុខរបររកស៊ីរបស់ពួកគាត់កើនឡើង នាំឲ្យពួកគាត់មានជីវភាពប្រសើរជាងមុន និងធ្វើឲ្យមានកំណើននៃការអភិវឌ្ឍក្នុងឃុំទាំងមូល ដែលបញ្ហាទាំងនេះនឹងត្រូវធ្វើការបកស្រាយរកដំណោះស្រាយក្នុងជំពូកបន្ទាប់។

# ជំពូកទី ៣

# ការពិភាក្សាលើលទ្ធផល

# ស្រាវជ្រាវ

# ជំពូកទី ៣

# ការពិភាក្សាលើលទ្ធផលស្រាវជ្រាវ

## ៣.១ ស្ថានភាពទូទៅ និងស្ថានភាពផលិតកម្មកសិកម្ម, សេវាកម្ម, និងសិប្បកម្ម

### ៣.១.១ ស្ថានភាពទូទៅ

#### ៣.១.១.១ មុខរបរចម្បងរបស់ប្រជាជនក្នុងឃុំប្រាសាទ

ក្រាហ្វិក ៣.១ ៖ ក្រាបបង្ហាញពីមុខរបរចម្បងរបស់ប្រជាជនក្នុងឃុំ




ឆ្លងតាមលទ្ធផល ដែលបានមកពីពត៌មានដែលទទួលបានពីការសម្ភាសន៍ផ្ទាល់មាត់ទៅលើគ្រួសារចំនួន១០៤ ដែលកំពុងរស់នៅក្នុងភូមិទាំង៩ នៃឃុំនេះ បានបង្ហាញឲ្យឃើញថា ចំនួនប្រជាជនក្នុងភូមិនីមួយៗប្រកបមុខរបរចម្បងទាំង៣ (កសិកម្ម, សេវាកម្ម, និងសិប្បកម្ម ឬឧស្សាហកម្ម) ខុសៗគ្នាដូចខាងក្រោម៖

- ភូមិប្រាសាទ : ក្នុងចំណោមអង្កេតទាំង១៤ គ្រួសារ ក្នុងនោះមាន ៣៥,៧១% ប្រកបមុខរបរចម្បងផ្នែកកសិកម្ម ហើយមាន ៥០% ប្រកបមុខរបរចម្បងផ្នែកសេវាកម្ម ចំណែកឯ ១៤,២៩% ប្រកបមុខរបរផ្នែកសិប្បកម្ម ឬឧស្សាហកម្ម។
- ភូមិជ្រលង : ក្នុងចំណោមអង្កេតទាំង១១ គ្រួសារ ក្នុងនោះមាន ៧២,៧៣% ប្រកបមុខរបរចម្បងផ្នែកកសិកម្ម ហើយមាន ២៧,២៧% ប្រកបមុខរបរចម្បងផ្នែកសេវាកម្ម។
- ភូមិចំបក់ : ក្នុងចំណោមអង្កេតទាំង១២ គ្រួសារ ក្នុងនោះមាន ៧២,៧៣% ប្រកបមុខរបរចម្បងផ្នែកកសិកម្ម ហើយមាន ២៧,២៧% ប្រកបមុខរបរចម្បងផ្នែកសេវាកម្ម។
- ភូមិដូនទុង : ក្នុងចំណោមអង្កេតទាំង១៥ គ្រួសារ ក្នុងនោះមាន ៣៨,៤៦% ប្រកបមុខរបរចម្បងផ្នែកកសិកម្ម ហើយមាន ៤៦,១៥% ប្រកបមុខរបរចម្បងផ្នែកសេវាកម្ម ចំណែកឯ ១៥,៣៨% ប្រកបមុខរបរផ្នែកសិប្បកម្ម ឬឧស្សាហកម្ម។

- ភូមិភ្លូង : ក្នុងចំណោមអង្កេតទាំង១១ គ្រួសារ ក្នុងនោះមាន ៦៣,៦៤% ប្រកបមុខរបរចម្បងផ្នែកកសិកម្ម ហើយមាន ៣៦,៣៦% ប្រកបមុខរបរចម្បងផ្នែកសេវាកម្ម។
- ភូមិបី : ក្នុងចំណោមអង្កេតទាំង១១ គ្រួសារ ក្នុងនោះមាន ៧២,៧៣% ប្រកបមុខរបរចម្បងផ្នែកកសិកម្ម ហើយមាន ២៧,២៧% ប្រកបមុខរបរចម្បងផ្នែកសេវាកម្ម។
- ភូមិថ្កូវ : ក្នុងចំណោមអង្កេតទាំង១០ គ្រួសារ ក្នុងនោះ ១០០% នៃគ្រួសារទាំងនោះប្រកបមុខរបរចម្បងផ្នែកកសិកម្ម។
- ភូមិពាន់វត្ត : ក្នុងចំណោមអង្កេតទាំង១១ គ្រួសារ ក្នុងនោះមាន ៨១,៨២% ប្រកបមុខរបរចម្បងផ្នែកកសិកម្ម ហើយមាន ១៨,១៨% ប្រកបមុខរបរចម្បងផ្នែកសេវាកម្ម។
- ភូមិអំពិល : ក្នុងចំណោមអង្កេតទាំង៩ គ្រួសារ ក្នុងនោះ ១០០% នៃគ្រួសារទាំងនោះប្រកបមុខរបរចម្បងផ្នែកកសិកម្ម។

### ៣.១.១.២ កម្រិតជីវភាពរបស់ប្រជាជននៅក្នុងឃុំ

ក្រាហ្វិក ៣.២ ៖ ក្រាបបង្ហាញពីកម្រិតជីវភាពរបស់ប្រជាជនក្នុងឃុំ




សម្គាល់៖ កម្រិតទាបបំផុត ទាប(ទីពីរ) កណ្ដាល ខ្ពស់(ទីបួន) ខ្ពស់បំផុត ដកស្រង់ពី Cambodia Socio-Economic Survey 2016 របស់វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ។

ជាទូទៅ ការបែងចែកកម្រិតជីវភាពប្រជាជននៅជនបទផ្សេងៗ គេធ្វើតាមបញ្ជាភាគបែងចែកប្រាក់ចំណូលសុទ្ធសម្រាប់មនុស្សម្នាក់គិតជាតម្លៃជាមធ្យមក្នុងមួយខែ ដែលបែងចែកជា ៥ក្រុម (វិធី Quintile) ដូចខាងក្រោម៖

- ក្រុមទាបបំផុត មានប្រាក់ចំណូលសុទ្ធសម្រាប់មនុស្សម្នាក់គិតជាតម្លៃជាមធ្យមក្នុងមួយខែស្មើចន្លោះពី ៤៩០០០ ដល់ក្រោម ១៥៩០០០រៀល។

- ក្រុមទាបទីពីរ មានប្រាក់ចំណូលសុទ្ធសម្រាប់មនុស្សម្នាក់គិតជាតម្លៃជាមធ្យមក្នុងមួយខែស្មើចន្លោះពី ១៥៩០០០ ដល់ក្រោម ២៦៣០០០រៀល។
- ក្រុមកណ្តាល មានប្រាក់ចំណូលសុទ្ធសម្រាប់មនុស្សម្នាក់គិតជាតម្លៃជាមធ្យមក្នុងមួយខែស្មើចន្លោះពី ២៦៣០០០ ដល់ក្រោម ៣៩៣០០០រៀល។
- ក្រុមខ្ពស់ទីបួន មានប្រាក់ចំណូលសុទ្ធសម្រាប់មនុស្សម្នាក់គិតជាតម្លៃជាមធ្យមក្នុងមួយខែស្មើចន្លោះពី ៣៩៣០០០ ដល់ក្រោម ៨៧១០០០រៀល។
- ក្រុមខ្ពស់បំផុត មានប្រាក់ចំណូលសុទ្ធសម្រាប់មនុស្សម្នាក់គិតជាតម្លៃជាមធ្យមក្នុងមួយខែស្មើនឹង ៨៧១០០០រៀលឡើងទៅ។[39]

ដោយផ្អែកទៅលើក្រាបវិភាគទិន្នន័យក្នុងកម្មវិធី Microsoft Excel ខាងលើ យើងអាចមើលឃើញពីកម្រិតជីវភាពរបស់ប្រជាជនក្នុងឃុំប្រាសាទទាំងមូល។ ដូចនេះ យើងអាចនិយាយបានថា នៅក្នុងឃុំប្រាសាទ ប្រជាជនគិតជាភាគរយចំនួនដល់ទៅ ៦១.៤៨% ស្ថិតក្នុងជីវភាពក្រុមកណ្តាល។ ចំណែង ២២.៤២% ផ្សេងទៀតមានជីវភាពក្រុមខ្ពស់ទីបួន និងមាន ៧.៤៤% ទៀតមានជីវភាពក្រុមខ្ពស់បំផុត។ ដោយឡែក នៅមាន ៦.៣៧% ស្ថិតក្នុងក្រុមទាបទីពីរ និងចុងក្រោយ ២.២៩%នៃប្រជាជនទាំងអស់មានជីវភាគក្នុងក្រុមទាបបំផុត។

### ៣.១.១.៣ កម្រិតជីវភាពតាមមុខរបរចម្បងនាំងបីក្នុងឃុំ

តារាង ៣.១ ៖ កម្រិតជីវភាពតាមមុខរបរចម្បងនីមួយៗក្នុងឃុំ

| មុខរបរចម្បង | បញ្ជាភាគបែងចែកកម្រិតប្រាក់ចំណូល | | | | |
|---|---|---|---|---|---|
| | ទាបបំផុត | ទាប (ទីពីរ) | កណ្តាល | ខ្ពស់ (ទីបួន) | ខ្ពស់បំផុត |
| កសិកម្ម | ៩១,៨៩% | ៥៩,០៩% | ៦១,១១% | ៤៥,០០% | ២៨,៥៧% |
| សេវាកម្ម | ៨,១១% | ៤០,៩១% | ៣៨,៨៩% | ៤០,០០% | ៥៧,១៤% |
| សិប្បកម្ម | 0% | 0% | 0% | ១៥,០០% | ១៤,២៩% |
| សរុប | ១០០% | ១០០% | ១០០% | ១០០% | ១០០% |

ប្រភព : ទិន្នន័យវិភាគដោយយោងតាមបញ្ជាភាគបែងចែកកម្រិតប្រាក់ចំណូល

យោងតាមតារាងវិភាគទិន្នន័យ ដែលទទួលបានពីបទសម្ភាសន៍របស់ប្រជាជនក្នុងឃុំនេះផ្ទាល់ និងយោងទៅតាមបញ្ជាភាគបែងចែកកម្រិតប្រាក់ចំណូល បានបញ្ជាក់ឲ្យឃើញថា ប្រជាជនដែលមានជីវភាពក្នុងកម្រិតទាបបំផុត ភាគច្រើន(៩១,៨៩%) ជាអ្នកប្រកបមុខរបរផ្នែកកសិកម្ម

[39] "Cambodia Socio-Economic Survey 2016", National Institute of Statistics, Ministry of Planning, Phnom Penh, October 2017, page 74

ចំណែកឯ ៨,១១% ទៀតប្រកបមុខរបរផ្នែកសេវាកម្ម។ ចំពោះប្រជាជនដែលមានជីវភាពកម្រិតទាបទីពីរ ក្នុងនោះ៥៩,០៩% ជាអ្នកប្រកបរបរផ្នែកកសិកម្ម និង៤០,៩១% ជាអ្នកប្រកបរបរផ្នែកសេវាកម្ម។ ចំណែកជីវភាពក្នុងកម្រិតកណ្តាលមាន ៦១,១១% ការងារផ្នែកកសិកម្ម និង ៣៨,៨៩% ប្រកបរបរផ្នែកសេវាកម្ម។ រីឯប្រជាជនក្នុងជីវភាពកម្រិតខ្ពស់ទីបួនមាន ៤៥% ជាអ្នកប្រកបរបរកសិកម្ម និង ៤០% ផ្នែកសេវាកម្ម ហើយមាន ១៥% ផ្នែកសិប្បកម្ម។ ចុងក្រោយគឺប្រជាជនក្នុងកម្រិតជីវភាពខ្ពស់បំផុតមាន ២៨,៥៧% ជាអ្នកមានមុខរបរផ្នែកកសិកម្ម និង ៥៧,១៤% ផ្នែកសេវាកម្ម ហើយ ១៤,២៩% ផ្សេងទៀតប្រកបរបរផ្នែកសិប្បកម្ម។

### ៣.១.១.៤ ចំនួនសមាជិកនៃគ្រួសារក្នុងឃុំ

តារាង៣.២ : ចំនួនសមាជិកគ្រួសារក្នុងឃុំ

| ចំនួនសមាជិក | ចំនួនគ្រួសារ | ភាគរយ |
|---|---|---|
| ១ | ៥ | ៤.៨ |
| ២ | ២១ | ២០.២ |
| ៣ | ២៥ | ២៤.០ |
| ៤ | ១៨ | ១៧,៣ |
| ៥ | ១៧ | ១៦,៣ |
| ៦ | ៨ | ៧,៧ |
| ៧ | ៦ | ៥,៨ |
| ៨ | ២ | ១,៩ |
| ៩ | ១ | ១,០ |
| ២០ | ១ | ១,០ |
| សរុប | ១០៤ | ១០០,០ |

យោងតាមលទ្ធផលវិភាគនៅក្នុងកម្មវិធី SPSS លើចំនួនសមាជិករបស់គ្រួសារដែលរស់នៅក្នុងឃុំប្រាសាទ បានបង្ហាញឲ្យឃើញថា ក្នុងចំណោមអង្កេតទាំងអស់ (១០៤អង្កេត) គ្រួសារដែលមានសមាជិក ១នាក់ មានចំនួន ៥គ្រួសារ, គ្រួសារដែលមានសមាជិក ២នាក់ មានចំនួន ២១គ្រួសារ , គ្រួសារដែលមានសមាជិក ៣នាក់ មានចំនួន ២៥គ្រួសារ, គ្រួសារដែលមានសមាជិក ៤នាក់ មានចំនួន ១៨គ្រួសារ, គ្រួសារដែលមានសមាជិក ៥នាក់ មានចំនួន ១៧គ្រួសារ, គ្រួសារដែលមានសមាជិក ៦នាក់ មានចំនួន ៨គ្រួសារ, គ្រួសារដែលមានសមាជិក ៧នាក់ មានចំនួន ៦គ្រួសារ,

គ្រួសារដែលមានសមាជិក ៨នាក់ មានចំនួន ២គ្រួសារ, គ្រួសារដែលមានសមាជិក ៩នាក់ មានចំនួន ១គ្រួសារ, និង គ្រួសារដែលមានសមាជិក ២០នាក់ មានចំនួន ១គ្រួសារ។

### ៣.១.២ បកស្រាយតម្រុយសំនួរលើមុខរបរផ្នែកកសិករ

#### ៣.១.២.១ ផ្នែកកសិកម្មធ្វើស្រែ

ដើម្បីជាការងាយស្រួលក្នុងការបកស្រាយទិន្នន័យ យើងខ្ញុំបានបែងចែកចំនួនដីធ្វើស្រែរបស់ប្រជាកសិករនៅក្នុងឃុំជា៥ក្រុម និងទិន្នផលជាមធ្យមរបស់ក្រុមនីមួយៗ ដូចខាងក្រោម៖

- ក្រុមទី១ ដីស្រែចាប់ពី០,១ ដល់ក្រោម ០,៥ ហិចតា ទិន្នផលជាមធ្យមរបស់ដីស្រែប្រភេទនេះ និងចំនួនដងនៃការប្រមូលផលក្នុងមួយឆ្នាំ។
- ក្រុមទី២ ដីស្រែចាប់ពី០,៥ ដល់ក្រោម ១ ហិចតា ទិន្នផលជាមធ្យមរបស់ដីស្រែប្រភេទនេះ និងចំនួនដងនៃការប្រមូលផលក្នុងមួយឆ្នាំ។
- ក្រុមទី៣ ដីស្រែចាប់ពី១ ដល់ក្រោម ២ ហិចតា ទិន្នផលជាមធ្យមរបស់ដីស្រែប្រភេទនេះ និងចំនួនដងនៃការប្រមូលផលក្នុងមួយឆ្នាំ។
- ក្រុមទី៤ ដីស្រែចាប់ពី ២ដល់ក្រោម ៣ ហិចតា ទិន្នផលជាមធ្យមរបស់ដីស្រែប្រភេទនេះ និងចំនួនដងនៃការប្រមូលផលក្នុងមួយឆ្នាំ។
- ក្រុមទី៥ ដីស្រែចាប់ពី ៣ ហិចតាឡើងទៅ ទិន្នផលជាមធ្យមរបស់ដីស្រែប្រភេទនេះ និងចំនួនដងនៃការប្រមូលផលក្នុងមួយឆ្នាំ។

តារាង ៣.៣ : តារាងចំនួនដីធ្វើស្រែសរុប ចំនួនដងនៃការប្រមូលផល និងទិន្នផលក្នុង១ឆ្នាំ

**ក្រុមទី១**

| លេខរៀង | ចំនួនដីធ្វើស្រែសរុប (ហិចតា) | ចំនួនដងនៃការប្រមូលផលក្នុងមួយឆ្នាំ | ទិន្នផល (តោន) |
|---|---|---|---|
| ១ | ០,៤ | ១ | ១ |
| ២ | ០,២ | ១ | ០,២ |
| ៣ | ០,៣ | ១ | ០,៥ |
| ៤ | ០,១៩ | ១ | ០,៥ |
| ៥ | ០,៣ | ១ | ០,៦ |
| ៦ | ០,១ | ១ | ០,២ |
| ៧ | ០,២ | ១ | ០,២៤៧ |
| ៨ | ០,២ | ១ | ០,២៧៥ |
| ៩ | ០,៤ | ១ | ០,៧៥ |
| ១០ | ០,៣ | ១ | ០,៩ |
| ១១ | ០,៣ | ១ | ០,៩ |

| | | | |
|---|---|---|---|
| ១២ | ០,៤ | ១ | ០,៨ |
| ១៤ | ០,៣ | ១ | ១ |
| ១៥ | ០,៣ | ១ | ០,៦ |
| ១៦ | ០,៤ | ១ | ០,៦៦ |
| ១៧ | ០,៤ | ១ | ០,៧៥ |
| ១៨ | ០,២ | ២ | ១,១ |
| ១៩ | ០,៤ | ២ | ១,១៧៥ |
| ២០ | ០,៤ | ២ | ៣ |

ចំពោះទិន្នន័យក្រុមទី១ បានបង្ហាញឲ្យឃើញថាមានកសិករចំនួន ២០គ្រួសារស្មើនឹង ៣១,៧៤% នៃកសិករទាំងអស់ ក្នុងនោះគ្រួសារចំនួន១៧ ឬស្មើនឹង ៨៥% ធ្វើស្រែបាន១ដងក្នុង១ឆ្នាំទទួលបានទិន្នផលជាមធ្យមក្នុងមួយឆ្នាំស្មើនឹង ១,៧៦តោន ចំណែកឯ ៣គ្រួសារទៀត ឬស្មើនឹង ១៥% ធ្វើស្រែបាន២ដងក្នុង១ឆ្នាំទទួលបានទិន្នផលជាមធ្យមក្នុងមួយឆ្នាំស្មើនឹង ១,៩៥តោន។

**ក្រុមទី ២**

| លេខរៀង | ចំនួនដីធ្វើស្រែសរុប | ចំនួនដងនៃការប្រមូលផលក្នុងមួយឆ្នាំ | ទិន្នផល |
|---|---|---|---|
| ១ | ០,៥ | ១ | ១ |
| ២ | ០,៥ | ១ | ១ |
| ៣ | ០,៩ | ១ | ២,៧៥ |
| ៤ | ០,៥ | ១ | ០,៨ |
| ៥ | ០,៧ | ១ | ១,៥ |
| ៦ | ០,៦ | ១ | ១ |
| ៧ | ០,៥ | ១ | ១ |
| ៨ | ០,៧ | ១ | ១,៤ |
| ៩ | ០,៥ | ១ | ១,៥ |
| ១០ | ០,៧ | ១ | ២,១ |
| ១១ | ០,៥ | ១ | ១,៥ |
| ១២ | ០,៥ | ១ | ១ |
| ១៣ | ០,៥ | ១ | ១ |
| ១៤ | ០,៥ | ១ | ១ |
| ១៥ | ០,៧ | ១ | ១,៤ |
| ១៦ | ០,៥ | ២ | ២,២ |
| ១៧ | ០,៥ | ៣ | ៣,១ |

ចំពោះទិន្នន័យក្រុមទី២ បានបង្ហាញឲ្យឃើញថាមានកសិករចំនួន ១៧គ្រួសារស្មើនឹង ២៦,៩៨% នៃកសិករទាំងអស់ ក្នុងនោះគ្រួសារចំនួន១៥ ឬស្មើនឹង ៨៨,២៣% ធ្វើស្រែបាន១ដងក្នុង១ឆ្នាំទទួលបានទិន្នផលជាមធ្យមក្នុងមួយឆ្នាំស្មើនឹង ១,៣៣តោន ចំណែកឯ ១គ្រួសារទៀត ឬស្មើនឹង ៥,៨៨% ធ្វើស្រែបាន២ដងក្នុង១ឆ្នាំ ទទួលបានទិន្នផលជាមធ្យមក្នុងមួយឆ្នាំស្មើនឹង ២,២តោន

និង១គ្រួសារផ្សេងទៀតឬស្មើនឹង ៥,៨៨% ធ្វើស្រែបាន៣ដង ក្នុង១ឆ្នាំទទួលបានទិន្នផលជាមធ្យម ក្នុងមួយឆ្នាំស្មើនឹង ៣,១តោន។

## ក្រុមទី ៣

| លេខរៀង | ចំនួនដីធ្វើស្រែសរុប | ចំនួនដងនៃការប្រមូលផលក្នុងមួយឆ្នាំ | ទិន្នផល |
|---|---|---|---|
| ១ | ១,៥ | ១ | ១ |
| ២ | ១ | ១ | ២,២ |
| ៣ | ១ | ១ | ០,៨ |
| ៤ | ១ | ១ | ៣ |
| ៥ | ១ | ១ | ០,៩ |
| ៦ | ១ | ១ | ១ |
| ៧ | ១ | ១ | ៣ |
| ៨ | ១ | ១ | ២ |
| ៩ | ១ | ១ | ៣ |
| ១០ | ១ | ១ | ៣ |
| ១១ | ១ | ១ | ៣ |
| ១២ | ១,៥ | ១ | ៤ |
| ១៣ | ១ | ១ | ១ |
| ១៤ | ១ | ១ | ២,៤ |
| ១៥ | ១ | ១ | ២ |
| ១៦ | ១ | ១ | ២ |
| ១៧ | ១,៥ | ២ | ៦ |
| ១៨ | ១ | ២ | ៦ |

ចំពោះទិន្នន័យក្រុមទី៣ បានបង្ហាញឲ្យឃើញថាមានកសិករចំនួន ១៨គ្រួសារស្មើនឹង ២៨,៥៧% នៃកសិករទាំងអស់ ក្នុងនោះគ្រួសារចំនួន ១៦ ឬស្មើនឹង ៨៨.៨៨% ធ្វើស្រែបាន១ដងក្នុង ១ឆ្នាំទទួលបានទិន្នផលជាមធ្យមក្នុងមួយឆ្នាំស្មើនឹង ២,១៤តោន ចំណែកឯ ២គ្រួសារទៀត ឬស្មើនឹង ១១,១១% ធ្វើស្រែបាន២ដងក្នុង១ឆ្នាំទទួលបានទិន្នផលជាមធ្យមក្នុងមួយឆ្នាំស្មើនឹង ៦តោន។

## ក្រុមទី ៤

| លេខរៀង | ចំនួនដីធ្វើស្រែសរុប | ចំនួនដងនៃការប្រមូលផលក្នុងមួយឆ្នាំ | ទិន្នផល |
|---|---|---|---|
| ១ | ២ | ១ | ៤ |
| ២ | ២ | ១ | ៥,៥ |
| ៣ | ២ | ១ | ៤ |
| ៤ | ២ | ១ | ៣,៥ |

ចំពោះទិន្នន័យក្រុមទី៤ បានបង្ហាញឲ្យឃើញថាមានកសិករចំនួន ៤គ្រួសារស្មើនឹង ៦,៣៥% នៃកសិករទាំងអស់ អាចធ្វើស្រែបាន១ដងក្នុង១ឆ្នាំទទួលបានទិន្នផលជាមធ្យមក្នុងមួយឆ្នាំស្មើនឹង ៤,២៥តោន។

**ក្រុមទី៥**

| លេខរៀង | ចំនួនដីធ្វើស្រែសរុប | ចំនួនដងនៃការប្រមូលផលក្នុងមួយឆ្នាំ | ទិន្នផល |
|---|---|---|---|
| ១ | ៣ | ១ | ៤ |
| ២ | ៣ | ១ | ៣ |
| ៣ | ៣ | ១ | ៩ |
| ៤ | ៣ | ១ | ៥ |
| ៥ | ៣ | ១ | ៥ |

ចំពោះទិន្នន័យក្រុមទី៥ បានបង្ហាញឲ្យឃើញថាមានកសិករចំនួន ៥គ្រួសារស្មើនឹង ៧,៩៤% នៃកសិករទាំងអស់ អាចធ្វើស្រែបាន១ដងក្នុង១ឆ្នាំទទួលបានទិន្នផល ៥,២តោន។

*សម្គាល់ : តារាងនៃក្រុម៥ខាងលើមានប្រភពពីទិន្នន័យវិភាគ។

ក្រាហ្វិក ៣.៣ ៖ ការប្រើប្រាស់ពូជ




កសិករនៅក្នុងឃុំមានចំនួន ៩០,៤៧%បានទុកពូជសម្រាប់ធ្វើស្រែ ចំណែកឯកសិករចំនួន ៩,៥២% បានទិញពូជពីគេ ដោយពួកគាត់ត្រូវចំណាយអស់ទឹកប្រាក់ជាមធ្យមនៅក្នុង ១ហិកតា គឺ ២៩៤៨០០៛។

ក្រាហ្វិក ៣.៤ ៖ ការភ្ជួររាស់



តាមទិន្នន័យ បានបង្ហាញឲ្យឃើញថាប្រជាកសិករបានប្រើប្រាស់ម៉ាស៊ីនគ្រឿងចក្រសម្រាប់ភ្ជួររាស់ដីស្រែរហូតទៅដល់ ១០០% ដោយចំណាយអស់ថវិកាជាមធ្យម ២៩៦០០០៛ ក្នុង១ហិកតា។

ក្រាហ្វិក ៣.៥ ៖ ការប្រើប្រាស់ជី




ចំពោះការប្រើប្រាស់ជី មានកសិករជាច្រើនគឺបានប្រើប្រាស់ជីដែលទិញពីក្រុមហ៊ុន(ជីគីមី) រហូតទៅដល់ ៩៨,៤១% ដោយចំណាយអស់ថវិកាចំនួន ៥៨៨០០៛ នៅក្នុងមួយហិកតា ប៉ុន្តែក៏មានកសិករចំនួន ១,៥៨% ផងដែរដែលបានប្រើប្រាស់ជីធម្មជាតិ។

ក្រាហ្វិក ៣.៦ ៖ ការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិត




យោងតាមទិន្នន័យខាងលើបានបង្ហាញឲ្យឃើញថា កសិករចំនួន ៦៩.៨៥% មិនបានបាញ់ថ្នាំសម្លាប់សត្វល្អិត ប៉ុន្តែមានកសិករចំនួន ៣០,១៥% បានប្រើប្រាស់ថ្នាំគីមីសម្លាប់សត្វល្អិត។

ក្រាហ្វិក ៣.៧ ៖ ច្រូតកាត់



បើយោងតាមទិន្នន័យ មានកសិករដល់ទៅ ១០០% ទៅហើយបានប្រើប្រាស់ម៉ាស៊ីនក្នុងការច្រូតកាត់ប្រមូលផលស្រូវ ដោយត្រូវចំណាយអស់ថវិកាចំនួន ២៧៦៩០០៛ ក្នុងមួយហិកតា។

**៣.១.២.១ ផ្នែកកសិកម្មចិញ្ចឹមសត្វ**

តារាង ៣.៤ ៖ ពណ៌នាប្រភេទសត្វ រយៈពេលទទួលផល និងចំណូលដែលទទួលបាន

| ប្រភេទសត្វចិញ្ចឹម | ចំនួនសត្វ (គិតជាក្បាល) | រយៈពេលទទួលផល (គិតជាឆ្នាំ) | ចំណូលដែលទទួលបានជាមធ្យមក្នុង១ក្បាលក្នុង១ឆ្នាំ (គិតជារៀល) |
|---|---|---|---|
| គោ | ២,៧០ | ២,២០ | ៩២០០០០,០០ |
| ជ្រូក | ៤,៦៧ | ០,៣៥ | ១១៨៦១១១,១១ |
| ត្រី | ៣០០០,០០ | ០,៧៥ | ៤៣១៦,០០ |
| មាន់ ទា | ៦៣,៣៣ | ០,០៨ | ៦២៣៣៣,៣៣ |

តាមរយៈទិន្នន័យដែលបានពីការសម្ភាសន៍ប្រជាជនក្នុងឃុំផ្ទាល់ យើងបានវិភាគចេញជាលទ្ធផលដូចដែលបានបង្ហាញក្នុងតារាងខាងលើ។ យើងអាចពណ៌នាបានថា មានសត្វ ៤ប្រភេទដែលអ្នកភូមិកំពុងចិញ្ចឹមក្នុងការប្រកបរបរចិញ្ចឹមជីវិតសព្វថ្ងៃគឺ សត្វគោ ជ្រូក ត្រី និង មាន់ ឬទា។ ចំពោះសត្វទាំង ៤ប្រភេទនេះ បរិមាណនៃការចិញ្ចឹមជាមធ្យមមានចំនួនខុសៗគ្នាគឺ សត្វគោត្រូវបានចិញ្ចឹមជាមធ្យមចំនួន ៣ក្បាល រីឯ សត្វជ្រូកត្រូវបានចិញ្ចឹមជាមធ្យមចំនួន ៥ក្បាល និង សត្វត្រីត្រូវបានចិញ្ចឹមជាមធ្យមចំនួន ៣០០០ក្បាល និងចុងក្រោយសត្វមាន់ ឬទា ត្រូវបានចិញ្ចឹមជាមធ្យមចំនួន ៦៣ក្បាល។ បើនិយាយពីរយៈពេលទទួលផលវិញ ក៏មានចំនួនខុសគ្នាដែរចំពោះសត្វទាំង ៤ ប្រភេទ ដែលយើងបានវិភាគជាមធ្យមឃើញថា សត្វគោរយៈពេលទទួលបានផលជាមធ្យមស្មើនឹង ២ឆ្នាំ ២ខែ និង១២ថ្ងៃ។ ចំណែកឯសត្វជ្រូក រយៈពេលទទួលបានផលជាមធ្យមស្មើនឹង ៤ខែ និង ៦ថ្ងៃ។ ហើយចំពោះសត្វត្រីវិញគឺ រយៈពេលទទួលបានផលជាមធ្យមស្មើនឹង ៩ខែ។ ដោយឡែក សត្វមាន់ ឬទា រយៈពេលទទួលបានផលជាមធ្យមស្មើនឹង ២៩ថ្ងៃ។ បើក្រឡេកទៅមើលចំណូលក្នុងមួយក្បាលវិញ គឺ សត្វគោជាមធ្យមក្នុង១ក្បាលក្នុង១ឆ្នាំទទួលបានចំណូលស្មើនឹង ៩២០០០០រៀល រីឯសត្វជ្រូក គឺស្មើនឹង ១១៨៦១០០រៀល ហើយចំពោះសត្វត្រីគឺស្មើនឹង ៤៣០០រៀល និងចុងក្រោយចំពោះសត្វមាន់ ឬទា គឺស្មើនឹង ៦២៣០០រៀល។

តារាង ៣.៥ ៖ អំពីចំណាយជាមធ្យមក្នុងមុខរបរកសិកម្មចិញ្ចឹមសត្វ

| ប្រភេទសត្វចិញ្ចឹម | ចំណាយជាមធ្យម | | | | |
|---|---|---|---|---|---|
| | ការប្រើប្រាស់ពូជ (ទិញ, ខ្លួនឯង) | ថ្លៃពូជជាមធ្យម (១ក្បាល,រៀល) | ការប្រើប្រាស់ចំណី (ទិញ, តាមធម្មជាតិ) | ថ្លៃចំណីជាមធ្យម (១ក្បាល,រៀល) | ថៃទាំនិងផ្សេងៗ (១ក្បាល,រៀល) |
| គោ | ទិញ= ១៤,២៩%<br>ខ្លួនឯង= ៨៥,៧១% | ៣០០០០០<br>0 | ទិញ = 0%<br>តាមធម្មជាតិ=១០០% | 0<br>0 | ៥០០០០ |
| ជ្រូក | ទិញ= ៥៥,៥៦%<br>ខ្លួនឯង= ៤៤,៤៤% | ៧៦៧១៤,២៩<br>0 | ទិញ = ៤៤,៤៤%<br>តាមធម្មជាតិ= ៥៥,៥៦% | ២៨៣១២៥<br>0 | ៨៦៥២៩ |
| ត្រី | ទិញ= ១០០%<br>ខ្លួនឯង= 0% | ២០០<br>0 | ទិញ = ១០០%<br>តាមធម្មជាតិ= 0% | ១៣៥០<br>0 | ៨០០ |
| មាន់ ទា | ទិញ= 0%<br>ខ្លួនឯង= ១០០% | 0<br>0 | ទិញ = ១០០%<br>តាមធម្មជាតិ= 0% | ៥៨៣៣,៣៣<br>0 | 0 |

ទន្ទឹមនឹងការវិភាគលើបរិមាណ និងរយៈពេលចិញ្ចឹមហើយនោះ យើងក៏បានវិភាគទៅលើផ្នែកចំណាយនៃមុខរបរមួយនេះផងដែរ ដែលបានចេញជាលទ្ធផលដូចបង្ហាញក្នុងតារាងខាងលើ។ តាមរយៈទិន្នន័យវិភាគនេះ ជាទូទៅការចំណាយក្នុងដំណើរការប្រកបមុខរបរនេះមាន ៣ប្រភេទផ្សេងគ្នា ដែលទី១ គឺការចំណាយថ្លៃពូជសត្វចិញ្ចឹម ប៉ុន្តែមិនមែនរាល់គ្រួសារដែលចិញ្ចឹមសត្វត្រូវចាយទៅលើចំណាយមួយនេះទាំងអស់ឡើយ ពោលគឺមានគ្រួសាខ្លះមានពូជសត្វចិញ្ចឹមស្រាប់។ ចំណាយទី ២ គឺ ចាយលើការប្រើប្រាស់ចំណីសត្វ ក៏ដូចគ្នាដែរចំណាយមួយនេះមិនត្រូវបានចាយគ្រប់គ្រួសារចិញ្ចឹមសត្វឡើយ ពោលគឺមានគ្រួសារខ្លះចិញ្ចឹមដោយចំណីធម្មជាតិ។ ចំណាយទី ៣ គឺចំណាយការថែទាំ និងចំណាយផ្សេងៗ ក្នុងនោះមានសត្វចិញ្ចឹមខ្លះត្រូវទទួលបានការថែទាំ និងខ្លះទៀតមិនត្រូវការចាយទៅលើការថែទាំឡើយ (ដូចពណ៌នាក្នុងតារាងខាងលើ)។

ចំណាយថ្លៃពូជ ចំពោះសត្វគោ គិតជាមធ្យមក្នុងមួយក្បាលគឺ ៣០០០០០រៀល ដែលក្នុងនោះមានតែ ១៤,២៩% នៃគ្រួសារចិញ្ចឹមសត្វប្រភេទនេះប៉ុណ្ណោះដែលប្រើប្រាស់ពូជដោយទិញគេ។ រីឯសត្វជ្រូកវិញ គឺចំណាយថ្លៃពូជគិតជាមធ្យមក្នុង១ក្បាលស្មើនឹង ៧៦៧០០រៀល ដែលចំណាយដោយ ៥៥,៥៦% នៃគ្រួសារចិញ្ចឹមចសត្វប្រភេទនេះទាំងអស់។ ចំពោះសត្វត្រី ថ្លៃពូជជាមធ្យមក្នុង១ក្បាលគឺ ២០០រៀល ដែលគ្រួសារទាំង ១០០% ដែលចិញ្ចឹមសត្វប្រភេទនេះមានការចំណាយ។

ចំណែកឯសត្វមាន់ ឬទា គឺគ្រួសារទាំង ១០០% ដែលចិញ្ចឹមសត្វប្រភេទនេះមិនមានការចំណាយថ្លៃពូជឡើយ។

ចំណាយថ្លៃចំណី ចំពោះគ្រួសារដែលចិញ្ចឹមសត្វគោទាំង ១០០% មិនបានចំណាយលើចំណីរបស់វាឡើយ ពោលគឺឲ្យចំណីតាមធម្មជាតិ។ បើចំពោះសត្វជ្រូកវិញ គ្រួសារដែលចិញ្ចឹមសត្វប្រភេទនោះមាន ៩៩,៩៩% បានចំណាយថ្លៃចំណីគិតជាមធ្យមក្នុង១ក្បាលក្នុង១ឆ្នាំគឺ ២៨៣១០០ រៀល។ ចំពោះសត្វត្រីវិញគឺ គ្រួសារដែលចិញ្ចឹមសត្វប្រភេទនេះទាំង ១០០% បានចំណាយថ្លៃចំណីក្នុង១ក្បាលក្នុង១ឆ្នាំស្មើនឹង ១៣០០រៀល។ ចុងក្រោយគឺ សត្វមាន់ ឬទា គ្រួសារទាំង ១០០% ដែលចិញ្ចឹមសត្វប្រភេទនេះ បានចំណាយថ្លៃចំណីជាមធ្យមក្នុង១ក្បាលក្នុង១ឆ្នាំ ស្មើនឹង ៨៨០០រៀល។

បើនិយាយពីចំណាយថែទាំ ឬចំណាយផ្សេង គឺសត្វគោ ត្រូវបានចំណាយអស់ ៥០០០០ រៀលជាមធ្យមក្នុង១ក្បាលក្នុង១ឆ្នាំ។ រីឯ សត្វជ្រូក ក៏ត្រូវចំណាយលើការថែទាំផងដែរគឺ ស្មើនឹង ៨៦៨០០រៀលជាមធ្យមក្នុង១ក្បាលក្នុង១ឆ្នាំ។ សត្វត្រី ក៏ត្រូវបានចំណាយលើការថែទាំដូចគ្នាដែរគឺ ស្មើនឹង ៨០០រៀលក្នុង១ក្បាលក្នុង១ឆ្នាំ។ ដោយឡែក ចំពោះសត្វមាន់ ឬទា មិនត្រូវបានចាយលើចំណាយមួយនេះឡើយ យោងទៅតាមការសម្ភាសន៍ពីគ្រួសារចិញ្ចឹមសត្វប្រភេទនេះផ្ទាល់។

ក្រាហ្វិក ៣.៨ ៖ បញ្ហាទឹកភ្លើងដែលកើតមានឡើងក្នុងមុខរបរផ្នែកកសិកម្ម




ចំពោះបញ្ហាអគ្គិសនី និងទឹកស្អាតនៅតាមភូមិជួបបញ្ហាសំខាន់ៗពីរគឺ៖

- មិនមានបណ្តាញអគ្គិសនី និងទឹកស្អាតមាន ៧% នៅក្នុងភូមិភ្លូង

- មានបណ្តាញអគ្គិសនី និងទឹកស្អាតប៉ុន្តែមានតម្លៃថ្លៃ មាន ៣,១៧% នៅភូមិពាន់វត្ត និងភូមិអំពិល។

ក្រាហ្វិក ៣.៩ ៖ បញ្ហាផ្លូវ ដែលកើតមានក្នុងមុខរបរផ្នែកកសិកម្ម




ផ្លូវនៅក្នុងបណ្តាភូមិនៃឃុំនេះ ជួបប្រទះនូវបញ្ហាច្រើនជាងគេគឺផ្លូវពិបាកធ្វើដំណើរដែលនៅក្នុងមានដូចជា ភូមិប្រាសាទមាន ៤,៧៨% ភូមិជ្រលង និងភូមិចំបក់មាន៥,៥២% ភូមិដូនទង់ និងភូមិបីមាន ៣,១៧% ភូមិភ្លងមាន ៤,៧៨% ភូមិថ្កូវមាន ១១,១១% ភូមិពាន់វត្ត និងភូមិអំពិលមាន ៩,៥២% ដូចគ្នា។

ក្រាហ្វិក ៣.១០ ៖ បញ្ហាប្រព័ន្ធធារាសាស្ត្រ ដែលកើតមានក្នុងមុខរបរផ្នែកកសិកម្ម



ប្រព័ន្ធធារាសាស្ត្រ ជាពិសេសប្រឡាយទឹកនៅក្នុងបណ្ដាភូមិនៃឃុំនេះ ជួបប្រទះនូវបញ្ហាសំខាន់ៗដែលរាំងស្ទះដល់ការប្រកបមុខរបររបស់ប្រជាកសិករគឺ ៖

- មិនមានប្រព័ន្ធប្រឡាយទឹកមានដូចជា ភូមិប្រាសាទ ៣,១៧% ភូមិជ្រលង ១២,៧០% ភូមិចំបក់មាន ៩,៥២% ភូមិដូនទង់ ១,៥៩% ភូមិភ្លង ៤,៧៨% ភូមិបី ៧,៩៤% ភូមិពាន់វត្ត ៩,៥២% និងភូមិអំពិល ៦,៣៦%
- មានប្រឡាយប៉ុន្តែមិនមានទឹកគ្រប់គ្រាន់សម្រាប់ស្រោចស្រពមានដូចជា : ភូមិប្រាសាទ ៣,១៧% ភូមិដូនទង់ និងភូមិថ្កូវ ១,៥៩% ដូចគ្នា ចំណែកឯ ភូមិអំពិល ៦,៣៥%។

ក្រាហ្វិក ៣.១១ ៖ បញ្ហាបច្ចេកទេសកសិកម្ម ដែលកើតមានក្នុងមុខរបរផ្នែកកសិកម្ម




បញ្ហាបច្ចេកទេសកសិកម្មដែលប្រជាកសិករនៅក្នុងឃុំនេះ កំពុងជួបប្រទះមានរហូតទៅដល់បញ្ហាសំខាន់ៗបីគឺ៖ ខ្វះអ្នកជំនាញចុះបណ្ដុះបណ្ដាលមានដូចជា ភូមិប្រាសាទ ៤,៧៨% ភូមិជ្រលង ១២,៧០% ភូមិចំបក់ ១១,១១% ភូមិដូនទុង និងភូមិភ្លង ៤,៧៨% ភូមិបី ៧,៩៤% ភូមិថ្កូវ ១៤,២៩% ភូមិពាន់វត្ត ១១,១១% និងភូមិអំពិល ៤,៧៨%។ ចំពោះបញ្ហាដែលថាមានកម្មវិធីបណ្ដុះបណ្ដាល ប៉ុន្តែមិនបានចូលរួមមាន ៣,១៧% ស្ថិតនៅក្នុងភូមិអំពិល។ រីឯ មិនដឹងថាមានកម្មវិធី ឬអត់មាន ១,៩៩% ស្ថិតនៅក្នុងភូមិអំពិល។ ម្យ៉ាងទៀត បញ្ហានេះជាបញ្ហាចោទសំខាន់ទៅលើគ្រួសារអ្នកចិញ្ចឹមសត្វផងដែរ ជាពិសេសគឺសត្វជ្រូក និងត្រី។ ដោយសារកើតមានជំងឺប្លែកៗលើសត្វចិញ្ចឹមទាំងនោះ ធ្វើឲ្យគ្រួសារបាត់បង់ប្រាក់ចំណូល និងបន្ថែមចំណាយច្រើនជាងមុន ទាំងនេះជាហេតុនាំឲ្យគ្រួសារខ្លះលែងចង់ចិញ្ចឹម ឬកាត់បន្ថយការចិញ្ចឹមរបស់ខ្លួន។

ក្រាហ្វិក ៣.១២ ៖ បញ្ហាទីផ្សារ ដែលកើតមានក្នុងមុខរបរផ្នែកកសិកម្ម




បញ្ហាទីផ្សារ ដែលបង្កផលលំបាកដល់ការប្រកបមុខរបររបស់កសិករគឺ បញ្ហាថ្លៃធ្លាក់ចុះទាបជាងការរំពឹងទុក កសិករដែលជួបប្រទះនូវបញ្ហានេះស្ថិតនៅតាមបណ្តាភូមិដូចជា ភូមិត្លូងមាន ៣,១៧% ភូមិថ្លុវមាន ៧,៩៤% ភូមិពាន់វត្ត និងភូមិអំពិលមាន ៤,៧៨%។

ក្រាហ្វិក ៣.១៣ ៖ បញ្ហាថ្លៃដើម ដែលកើតមានក្នុងមុខរបរផ្នែកកសិកម្ម




បញ្ហាថ្លៃដើមសំខាន់ៗពីរ ដែលប្រជាកសិករកំពុងតែជួបនូវប្រទះគឺ : តម្លៃពូជឡើងថ្លៃមាន ៣,១៧% នៅក្នុងភូមិថ្លុវ និងភូមិអំពិល ចំណែកឯតម្លៃចំណីឡើងថ្លៃមាន ១,៥៩% ក្នុងភូមិអំពិល។

ក្រាហ្វិក ៣.១៤ ៖ បញ្ហាដើមទុន ដែលកើតមានក្នុងមុខរបរផ្នែកកសិកម្ម




បញ្ហាដែលប្រជាកសិករពិបាកនឹងទទួលបានកម្ចីនេះមានបញ្ហាបីគឺ ៖ នីតិវិធីស្មុគស្មាញមុនពេលទទួលបានប្រាក់កម្ចី ភូមិដែលជួបប្រទះបញ្ហានេះរួមមាន ភូមិចំបក់ និងភូមិភ្លូងមាន ១,៥៩% ភូមិថ្កូវមាន ៣,១៧% ភូមិប្រាសាទ និងភូមិពាន់វត្តមាន ១,៥៩%។ ចំពោះបញ្ហាដែលថាទាមទារវត្ថុបញ្ចាំខ្ពស់រួមមាន ភូមិថ្កូវ និងភូមិអំពិលមាន ១,៥៩%។ រីឯមិនហ៊ានទៅខ្ចីពីធនាគារពាណិជ្ជ ឬមីក្រូហិរញ្ញវត្ថុដោយសារ ពួកគាត់មិនមានលទ្ធភាពក្នុងការសងមាន ភូមិថ្កូវ ភូមិពាន់វត្ត ១,៥៩% និងភូមិអំពិលមាន ៦,៣៥%។

### ៣.១.៣ បកស្រាយកម្រងសំនួរលើមុខរបរផ្នែកសេវាកម្ម

ក្រាហ្វិក ៣.១៥ ៖ ប្រភេទសេវាកម្ម




យោងតាមទិន្នន័យដែលទទួលបានពីកម្រងសំនួរដែលយើងខ្ញុំបានធ្វើការសម្ភាសន៍ទៅកាន់ប្រជាជនដែលប្រកបមុខរបរចំបងផ្នែកសេវាកម្មនៅក្នុងឃុំនេះ មាន៧ប្រភេទគឺ លក់ដូរមាន

៥៥.១១% រីឯបម្រើសេវាកម្មធ្វើកូនឈ្នួលគេមាន ២០.៥៨% ចំណែកឯអ្នកបម្រើសេវាកម្មផ្នែកសំណង់ ផ្នែករោងចក្រ មាន ៥.៨៨%ដូចគ្នា បន្ទាប់មកអ្នកបម្រើសេវាកម្មផ្នែកដឹកជញ្ជូនមាន ៨.៨២% ហើយអ្នកចំពោះជាងកាត់ដេរវិញមាន ២.៩៤% និងមន្ត្រីរាជការមានចំនួន ១១.៧៦% ។

ដើម្បីទទួលពត៌មានឲ្យកាន់តែលំអិត នៅក្នុងមុខរបរចម្បងៗនេះយើងខ្ញុំបានចែកជាមុខរបរតូចៗជាច្រើនដូចខាងក្រោម ៖

- លក់ដូរមាន លក់ដូរតវ៉ាន់ លក់ផ្លែឈើ លក់បបរ លក់ខោអាវ លក់ភេសជ្ជៈនិងកាហ្វេ និងលក់គ្រឿងសំណង់
- កូនឈ្នួលគេមាន ជួយលក់ខោអាវ កម្មករក្នុងរោងម៉ាស៊ីនកិនស្រូវ កម្មករនៅកន្លែងកាត់កញ្ចក់ អ្នករត់តុក្នុងកម្មវិធីបុណ្យ ឬអាពាហ៍ពិពាហ៍
- ដឹកជញ្ជូនមាន បើករថយន្តដឹកដី អ្នកជូនព្រះសង្ឃ
- ចំណែកឯសំណង់មាន កូនជាង និងមេកា
- មន្ត្រីរាជការមាន គ្រូពេទ្យ គ្រូបង្រៀន ទាហាន និងមន្ត្រីរាជការចូលនិវត្តន៍
- ចំណែកឯរោងចក្រ និងជាងកាត់ដេរ គឺយើងខ្ញុំមិនមានបែងចែកនោះទេ។

តារាង ៣.៦ ៖ ពណ៌នាដំណើរការផលិតកម្មក្នុងមុខរបរផ្នែកសេវាកម្ម

| ប្រភេទសេវាកម្ម | ចំណូលសរុបជាមធ្យម ១ឆ្នាំ | ចំណាយជាមធ្យម | | | | | | | | ចំណាយសរុបជាមធ្យម ១ឆ្នាំ | ចំណូល-ចំណាយ |
|---|---|---|---|---|---|---|---|---|---|---|---|
| | | ប្រាក់ឈ្នួលកម្មករ ១ខែ | ចំណាយថ្លៃជួលតូប | ថ្លៃដើម ១ថ្ងៃ | ថ្លៃទឹក ឬ ភ្លើង ១ខែ | ថ្លៃប្រេង ១ថ្ងៃ | ថ្លៃថែទាំ ឬ អនាម័យផ្សារ ១ថ្ងៃ | ជួសជុល ឬថែទាំ ១ខែ | ដឹកជញ្ជូន ១ថ្ងៃ | | |
| លក់ដូរ | ៧២,៥៦២,៥០០៛ | ៧៣៦,៦៦៧៛ | ០ | ១៦១,៧៩២៛ | ៤៣,៨៩២៛ | ៦០,០០០៛ | ៤២៥៛ | ៨៩៩,៩៩៦៛ | ៥,៦៦៧៛ | ៦៨,១៩៦,៤៩៨៛ | ៤,៣៦៦,០០២៛ |
| ឈ្នួលគេ | ៨,៥៧១,៤២៩៛ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | ៨,៥៧១,៤២៩៛ |
| សំណង់ | ៩,៩០០,០០០៛ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | ៩,៩០០,០០០៛ |
| រោងចក្រ | ៩,៦០០,០០០៛ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | ៩,៦០០,០០០៛ |
| មន្ត្រីរាជការ | ៦,៦៩០,០០០៛ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | ៦,៦៩០,០០០៛ |
| ដឹកជញ្ជូន | ១២,០០០,០០០៛ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | ១២,០០០,០០០៛ |
| ជាងកាត់ដេរ | ៧,២០០,០០០៛ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | ៧,២០០,០០០៛ |

ចំណូល និងចំណាយជាមធ្យមរបស់ប្រជាជននៅក្នុងឃុំដែលប្រកបមុខរបរផ្នែកសេវាកម្មបានបង្ហាញឃើញថា ចំណូល និងចំណាយរបស់ពួកគាត់មានភាពខុសៗគ្នាទៅតាមប្រភេទនៃសេវាកម្មនីមួយៗមានដូចតទៅ៖ អ្នកបម្រើសេវាកម្មផ្នែកលក់ដូរទទួលបានចំណូលក្នុង១ឆ្នាំជាមធ្យម ៧២,៥៦២,៥០០៛ ប៉ុន្តែពួកគាត់ត្រូវចំណាយទៅលើថ្លៃដើមដូចជាប្រាក់ឈ្នួលកម្មករ ចំណាយជួលតូប ថ្លៃដើម ថ្លៃទឹកឬភ្លើង ថ្លៃប្រេង ថ្លៃថែទាំឬអនាម័យផ្សារ ជួសជុលឬថែទាំ ដោយចំណាយជាមធ្យមអស់ថវិកាចំនួន ៦៨,១៩៦,៥០០៛ ក្នុង១ឆ្នាំ បន្ទាប់ពីផាត់ទាត់ចំណាយអស់ពួកគាត់នៅសល់ថវិកាជាមធ្យមចំនួន ៤,៣៦៦,០០០៛ ។ ចំណែកឯ អ្នកប្រកបមុខរបរធ្វើជាកូនឈ្នួលរបស់គេ ទទួលបានប្រាក់ចំណូលជាមធ្យមនៅក្នុង ១ឆ្នាំ

៨,៥៧១,៤២៩៛ ចំពោះអ្នកបម្រើសេវាកម្មផ្នែកសំណង់ទទួលបានប្រាក់ចំណូលជាមធ្យមក្នុង១ឆ្នាំ ៩,៩០០,០០០៛ រោងចក្រ ៩,៦០០,០០០៛ មន្ត្រីរាជការ ៦,៦៩០,០០០៛ ដឹកជញ្ជូន ១២,០០០,០០០៛ ជាងកាត់ដេរ ៧,២០០,០០០៛ ប៉ុន្តែចំពោះការចំណាយវិញអ្នកដែលប្រកបរបរបម្រើសេវាកម្មដូចបានរៀបរាប់ខាងលើមិនបានចំណាយនៅក្នុងផលិតកម្មនោះទេ។

ក្រាហ្វិក ៣.១៦ ៖ បញ្ហាផ្លូវ ក្នុងមុខរបរផ្នែកសេវាកម្ម




ដោយផ្អែកលើការវិភាគពីទិន្នន័យ ដែលប្រមូលបានពីបទសម្ភាសន៍របស់ប្រជាពលរដ្ឋដែលមានមុខរបរចម្បងផ្នែកសេវាកម្មនៅក្នុងឃុំប្រាសាទទាំងមូល បញ្ហាទី១គឺផ្លូវធ្វើដំណើរ ពោលគឺមានផ្លូវគ្រប់គ្រាន់ប៉ុន្តែពិបាកក្នុងការធ្វើដំណើរ (ផ្លូវតូចចង្អៀត ផ្លូវមានគ្រហុកច្រើន ផ្លូវលិចទឹកជាដើម)។ ក្នុងនោះ គ្រួសារដែលរស់នៅក្នុងភូមិចំបក់ ភូមិដូនទុង ភូមិភ្លូង និងភូមិបី (ដូចបង្ហាញក្នុងក្រាបខាងលើ) ដែលវាចំនួនភាគរយរៀងគ្នាគឺ ១០,៧១% ៧,១៤% ១០,៧១% និង ៧,១៤% ក្នុងចំណោមគ្រួសារប្រកបរបរសេវាកម្មដែលបានផ្តល់បទសម្ភាសន៍ដល់យើងខ្ញុំ។

ក្រាហ្វិក ៣.១៧ ៖ បញ្ហាថ្លៃដើម ក្នុងមុខរបរផ្នែកសេវាកម្ម




ក្នុងមុខរបររបស់ប្រជាជនផ្នែកសេវាកម្មនេះដដែល នៅមានបញ្ហាសំខាន់មួយទៀតដែលពួកគាត់ជួបប្រទះ ដោយបង្ហាញចេញតាមរយៈការវិភាគលទ្ធផលបញ្ហាប្រឈមរបស់គ្រួសារប្រកបរបរនេះ គឺ បញ្ហាថ្លៃដើម ពោលគឺការឡើងថ្លៃថ្លៃដើមនៃមុខរបររបស់ពួកគាត់។ បញ្ហាមួយនេះបានកើតឡើងចំពោះតែប្រជាជនដែលរស់នៅភូមិជ្រលងប៉ុណ្ណោះ (តាមក្រាបវិភាគខាងលើ) ដែលភាគរយស្មើនឹង ៣,៥៧% ក្នុងចំណោមគ្រួសារប្រកបរបរសេវាកម្មដែលបានផ្តល់បទសម្ភាសន៍ដល់យើងខ្ញុំ។

### ៣.១.៣ បកស្រាយគម្រូងសំនួរលើមុខរបរផ្នែកសិប្បកម្ម

ក្រាហ្វិក ៣.១៨ ៖ ប្រភេទនៃសិប្បកម្ម



យោងតាមទិន្នន័យដែលទទួលបានពីកម្រងសំនួរដែលយើងខ្ញុំបានធ្វើការសម្ភាសន៍ទៅកាន់ប្រជាជនដែលប្រកបមុខរបរចំបងផ្នែកសិប្បកម្មនៅក្នុងឃុំនេះ មានចំនួន៣ប្រភេទគឺ រោងម៉ាស៊ីនកិនស្រូវមាន ៥០% ដែលក្នុងនោះយើងខ្ញុំបានចែកចេញជា២គឺរោងម៉ាស៊ីនខ្នាតតូច និងរោងម៉ាស៊ីនខ្នាតមធ្យម ចំណែកឯសិប្បកម្មកាត់កញ្ចក់ និងសិប្បកម្មផ្នែកសង្ហារឹមមាន ២៥%ដូចគ្នា។

តារាង ៣.៧ ៖ ពណ៌នាដំណើរការផលិតកម្មក្នុងមុខរបរផ្នែកសិប្បកម្ម

| ប្រភេទសេវាកម្ម | ចំណូលសរុបជាមធ្យម ១ឆ្នាំ | ចំណាយជាមធ្យម | | | | | | | | ចំណាយសរុបជាមធ្យម ១ឆ្នាំ | ចំណូល-ចំណាយ |
|---|---|---|---|---|---|---|---|---|---|---|---|
| | | ប្រាក់ខែ/ឈ្នួលកម្មករ ១ខែ | ចំណាយថ្លៃជួល | ថ្លៃដើម ១ថ្ងៃ | ថ្លៃទឹកឬភ្លើង ១ខែ | ថ្លៃប្រេង ១ថ្ងៃ | ជួសជុលឬថែទាំ ១ខែ | ដឹកជញ្ជូន ១ថ្ងៃ | រដ្ឋបាល ១ឆ្នាំ | | |
| រោងម៉ាស៊ីនកិនស្រូវ | ២៦១,០០០,០០០៛ | ៣,៣០០,០០០៛ | | ១១០,០០០៛ | ៨៣,៨០០៛ | ៧០,០០០៛ | ៦,៣០០,០០០៛ | ១៧,៥០០៛ | ១៣៥,០០០៛ | ៩៨,៣៤០,៦០០៛ | ១៦២,៦៥៩,៤០០៛ |
| កាត់កញ្ចក់ | ១៣២,០០០,០០០៛ | ៣,៦០០,០០០៛ | | ១១១,១១១៛ | ៨០០,០០០៛ | | | | | ៩២,៧៩៩,៩៦០៛ | ៣៩,២០០,០៤០៛ |
| សង្ហារឹម | ៩,៦០០,០០០៛ | | | ៦,០០០៛ | ៣៥,០០០៛ | ២,០០០៛ | ១០០,០០០៛ | | | ៣,៤០០,០០០៛ | ៦,២០០,០០០៛ |

យោងតាមទិន្នន័យបានបង្ហាញឲ្យឃើញថាចំណូល និងចំណាយរបស់ពួកគាត់មានភាពខុសៗគ្នាទៅតាមប្រភេទនៃសិប្បកម្មនីមួយៗមានដូចតទៅ ៖ ចំពោះរោងម៉ាស៊ីនកិនស្រូវទទួលបានចំណូលជាមធ្យមនៅក្នុងមួយឆ្នាំចំនួន ២៦១,០០០,០០០៛ តែពួកគាត់ត្រូវចំណាយទៅលើ ប្រាក់ខែឬប្រាក់ឈ្នួលបុគ្គលិក ថ្លៃវត្ថុធាតុដើម(ស្រូវ) ថ្លៃទឹកភ្លើង ថ្លៃប្រេង ថ្លៃជួសជុលឬថែទាំ ដឹកជញ្ជូន និងបង់លើរដ្ឋបាលសាធារណៈ ដោយចំណាយជាមធ្យមលើចំណាយដែលបានរៀបរាប់ខាងលើអស់ ៩៨,៣៤០,៦០០៛ បន្ទាប់ពីទូទាត់ចំណាយរួចមកប្រាក់ចំណេញជាមធ្យមនៅក្នុង១ឆ្នាំរបស់គាត់គឺ

១៦២,៦៥៩,៤០០៛។ រីឯសិប្បកម្មកាត់កញ្ចក់ ទទួលបានប្រាក់ចំណូលជាមធ្យមនៅក្នុង១ឆ្នាំ ១៣២,០០០,០០០៛ ប៉ុន្តែពួកគាត់ត្រូវចំណាយលើ ប្រាក់ខែ ឬប្រាក់ឈ្នួលកម្មករ ចំណាយថ្លៃជួល ថ្លៃដើម(កញ្ចក់...) ដោយចំណាយអស់ជាមធ្យមក្នុង១ឆ្នាំ ៩២,៧៩៩,៩៦០៛ បន្ទាប់ពីទូទាត់ចំណាយ រួមមកប្រាក់ចំណេញជាមធ្យមនៅក្នុង១ឆ្នាំគឺ ៣៩,២០០,០០០៛។ និងចុងក្រោយគេ គឺសិប្បកម្មធ្វើគ្រឿងសង្ហារឹមទទួលបានចំណូលជាមធ្យមក្នុង១ឆ្នាំ ៩,៦០០,០០០៛ ប៉ុន្តែពួកគាត់ត្រូវចំណាយទៅលើ ថ្លៃដើម(ឈើ...) ថ្លៃទឹកភ្លើង ថ្លៃប្រេង អស់ជាមធ្យមនៅក្នុង១ឆ្នាំចំនួន ៣,៤០០,០០០៛ បន្ទាប់ពីទូទាត់ចំណាយរួចមកប្រាក់ចំណេញជាមធ្យមក្នុង១ឆ្នាំរបស់ពួកគាត់គឺ ៦,២០០,០០០៛។

ក្រាហ្វិក ៣.១៩ ៖ បញ្ហាផ្លូវ ក្នុងមុខរបរផ្នែកសិប្បកម្ម




យោងទៅតាមលទ្ធផលវិភាគ បានឲ្យដឹងថា នៅក្នុងការប្រកបរបរសិប្បកម្ម ឬឧស្សាហកម្ម នៅក្នុងឃុំនេះមាន បញ្ហាផ្លូវ ពោលគឺផ្លូវពិបាកធ្វើដំណើរ (មានគ្រហុកតូចធំ និងផ្លូវហុយខ្លាំង)។ ក្នុងចំណោម ៤គ្រួសារដែលផ្តល់បទសម្ភាសន៍ ក្នុងនោះ ទីតាំងសិប្បកម្ម ២កន្លែង (សិប្បកម្មធ្វើគ្រឿងសង្ហារឹម និងសិប្បកម្មរោងម៉ាស៊ីនកិនស្រូវ) ដែលស្ថិតនៅក្នុងភូមិដូនទុងបានជួបនូវបញ្ហានេះ ក្នុងដំណើរផលិតកម្មរបស់ពួកគាត់ ដែលផ្ទុយពីទីតាំងសិប្បកម្មផ្សេងទៀតក្នុងភូមិប្រាសាទដែលមានផ្លូវល្អស្អាត (ផ្លូវក្រាលកៅស៊ូ)។

ក្រាហ្វិក ៣.២០ ៖ បញ្ហាបច្ចេកទេស ក្នុងមុខរបរផ្នែកសិប្បកម្ម




ក្នុងការប្រកបមុខរបរផ្នែកសិប្បកម្ម ឬឧស្សាហកម្មក្នុងឃុំនេះដដែល មានលេចចេញនូវបញ្ហាប្រឈមមួយផ្សេងទៀតគឺ បញ្ហាបច្ចេកទេសផលិតកម្ម ដែលគ្រួសារប្រកបមុខរបរនេះបានប្រាប់ឲ្យដឹងថា ការខ្វះខាតសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ និងការខ្វះខាតកម្មករជំនាញជាបញ្ហាដែលកំពុងជួបប្រទះ។ ក្នុងនោះទីតាំងសិប្បកម្មពីរស្ថិតក្នុងភូមិដូនទុងជួបបញ្ហាមួយនេះ ដែលស្មើនឹង ៥០% នៃគ្រួសារដែលបានសាកសួរ (២៥% ថាជាបញ្ហាខ្វះសាលាបណ្តុះបណ្តាល និង ២៥% ទៀតថាខ្វះកម្មករជំនាញធ្វើការ)។ ចំពោះ ៥០%ផ្សេងទៀតដែលមានទីតាំងក្នុងភូមិប្រាសាទមិនជួបបញ្ហាបច្ចេកទេសផលិតកម្មនេះឡើយ។

ក្រាហ្វិក ៣.២១ ៖ បញ្ហាទីផ្សារ ក្នុងមុខរបរផ្នែកសិប្បកម្ម



ក្រោយពេលធ្វើការវិភាគទិន្នន័យ បានបង្ហាញថាក្រៅពីបញ្ហាពីរខាងលើនោះហើយ នៅមានបញ្ហាមួយទៀតគឺ បញ្ហាទីផ្សារ ដែលវាក៏ជាបញ្ហាប្រឈមក្នុងរបរផ្នែកសិប្បកម្មនេះផងដែរ។ ជាក់ស្តែង ទីតាំងសិប្បកម្មមួយកន្លែងនៅក្នុងភូមិដូនទុងដដែលបានឲ្យដឹងថា តម្លៃផលិតផលដែលគាត់ផលិតបានតែងតែធ្លាក់ចុះជាងតម្លៃដែលរំពឹងទុក ដូច្នេះហើយវាតែងតែរាំងដំណើរផលិតកម្មរបស់គាត់ជារឿយៗ។

ក្រាហ្វិក ៣.២២ ៖ បញ្ហាថ្លៃដើម ក្នុងមុខរបរផ្នែកសិប្បកម្ម




បញ្ហាប្រឈមចុងក្រោយក្នុងដំណើរប្រកបមុខរបរផ្នែកសិប្បកម្ម ឬឧស្សាហកម្មរបស់ប្រជាជនក្នុងឃុំ គឺ បញ្ហាថ្លៃដើមផលិតកម្ម ដោយផ្តោតសំខាន់លើការកើនឡើងថ្លៃនៃតម្លៃថ្លៃដើមផលិតកម្មរបស់ពួកគាត់។ វាជាបញ្ហាដែលជះឥទ្ធិពលខ្លាំងផងដែរ ព្រោះថាបើយោងតាមក្រាបទិន្នន័យវិភាគខាងលើយើងអាចនិយាយបានថា ៧៥% ក្នុងចំណោមគ្រួសារប្រកបមុខរបរសិប្បកម្មដែលបានផ្តល់បទសម្ភាសន៍ បានកំពុងតែជួបបញ្ហាមួយនេះ។ ក្នុងនោះ ២៥% មានទីតាំងស្ថិតនៅភូមិប្រាសាទ និង ៥០%ទៀតមានទីតាំងក្នុងភូមិដូនទុង។

ក្រៅពីបញ្ហាប្រឈមទាំងអស់ខាងលើនេះហើយ នៅមានបញ្ហាប្រឈមមួយទៀតគឺ បញ្ហាបច្ចេកវិទ្យាគ្រឿងម៉ាស៊ីន ដែលចោទចំពោះគ្រួសារដែលប្រកបរបរម៉ាស៊ីនកិនស្រូវទាំង ២។ ចំពោះរោងម៉ាស៊ីនកិនស្រូវខ្នាតតូច បានឲ្យដឹងថា គាត់មានបំណងចង់ផ្លាស់ប្តូរម៉ាស៊ីនដែលប្រើប្រាស់រាល់ថ្ងៃ ដោយសារតែ ម៉ាស៊ីនរបស់គាត់កិនបានតិច និងអង្ករមិនសូវល្អ។ រីឯ រោងម៉ាស៊ីនខ្នាតមធ្យមបានឲ្យដឹងដូចគ្នាដែរថា គាត់មានបំណងផ្លាស់ប្តូរម៉ាស៊ីនរបស់គាត់ទៅស្វ័យប្រវត្តិ ព្រោះផលិតភាពលឿនជាងមុន និងកិនអង្ករបានល្អ ដែលអាចលក់បានតាមតម្រូវការទីផ្សារសព្វថ្ងៃ។

## ៣.២ ការវិភាគលើអថេរបញ្ហាក្នុងការប្រកបមុខរបរ

### ៣.២.១ បញ្ហាចម្បងក្នុងមុខរបរផ្នែកកសិកម្ម

ក្រាហ្វិក ៣.២៣ ៖ បញ្ហាចម្បងៗកើតមានក្នុងមុខរបរផ្នែកកសិកម្ម




តាមរយៈការវិភាគទិន្នន័យ ដូចបង្ហាញក្នុងរូបភាពខាងលើ យើងឃើញថា ប្រជាជនដែលប្រកបមុខរបរនេះជួបប្រទះបញ្ហាប្រឈមជាច្រើនដូចជា ៖ បញ្ហាទឹកភ្លើង បញ្ហាផ្លូវ បញ្ហាប្រព័ន្ធធារាសាស្ត្រ បញ្ហាបច្ចេកទេស បញ្ហាទីផ្សារ បញ្ហាថ្លៃដើម បញ្ហាដើមទុន និងបញ្ហាផ្សេងៗ។ ក្នុងចំណោមបញ្ហាទាំងអស់នេះ ទិន្នន័យបង្ហាញឲ្យឃើញថា បញ្ហាដែលចម្បង គឺ បញ្ហាប្រព័ន្ធធារាសាស្ត្រ បញ្ហាបច្ចេកទេស ដែលមានភាគរយធំជាងគេ ២៦,៨៨% ស្មើគ្នា និងបញ្ហាផ្លូវ ដែលមានភាគរយធំបន្ទាប់ ២៣,១២%។

### ៣.២.២ បញ្ហាចម្បងក្នុងមុខរបរផ្នែកសេវាកម្ម

ក្រាហ្វិក ៣.២៤ ៖ បញ្ហាចម្បងៗកើតមានក្នុងមុខរបរផ្នែកសេវាកម្ម




យោងទៅតាមទិន្នន័យវិភាគក្នុងរូបភាពខាងលើ យើងឃើញថា ប្រជាជនដែលប្រកបមុខរបរផ្នែកសេវាកម្ម ជួបប្រទះបញ្ហាចំនួន ៣ គឺ បញ្ហាផ្លូវ បញ្ហាថ្លៃដើម និងបញ្ហាផ្សេងៗ។ ចំពោះបញ្ហាចម្បងក្នុងមុខរបរនេះគឺ បញ្ហាផ្លូវ និងបញ្ហាផ្សេងៗ (ប្រាក់ខែ ឬប្រាក់ឈ្នួលទាប) ដែលមានភាពរយស្មើនឹង ៧៥,០០%។

### ៣.២.៣ បញ្ហាចម្បងក្នុងមុខរបរផ្នែកសិប្បកម្ម

ក្រាហ្វិក ៣.២៥ ៖ បញ្ហាចម្បងៗកើតមានក្នុងមុខរបរផ្នែកសិប្បកម្ម




តាមការវិភាគទិន្នន័យខាងលើ បានបង្ហាញឲ្យឃើញថា ប្រជាជនដែលប្រកមុខរបរផ្នែកសិប្បកម្ម ជួបប្រទះបញ្ហាចំនួន ៦ គឺ បញ្ហាផ្លូវ បញ្ហាបច្ចេកទេស បញ្ហាទីផ្សារ បញ្ហាថ្លៃដើម បញ្ហាបច្ចេកវិទ្យា និងបញ្ហាផ្សេងៗ។ ក្នុងចំណោមបញ្ហាទាំង ៦ប្រភេទ បញ្ហាដែលចម្បងជាងគេគឺ បញ្ហាបច្ចេកទេស និងបញ្ហាបច្ចេកវិទ្យា ដែលមានភាគរយធំជាងគេ ២៧,២៧% ដូចគ្នា។

## ៣.៣ ដំណោះស្រាយ

ក្នុងចំណុចនេះ យើងនឹងធ្វើការដោះស្រាយទៅលើចំពោះតែបញ្ហាចម្បងៗក្នុងមុខរបរវិស័យនីមួយៗក្នុងបំណង បង្កើនកម្រិតជីវភាពប្រជាជនតាមមុខរបរដែលគាត់កំពុងធ្វើសព្វថ្ងៃ ដែលស្របតាមគោលដៅនៃការអភិវឌ្ឍក្នុង ទ្រឹស្តីលោក Michel P. Todaro គឺអភិវឌ្ឍដើម្បីបង្កើនភាពដែលអាចរកបាន រួមជាមួយនឹងការបំពេញតម្រូវការជាមូលដ្ឋាន, ដើម្បីលើកស្ទួយកម្រិតជីវភាពរស់នៅ និងការបន្ថែមប្រាក់ចំណូលឲ្យកាន់តែខ្ពស់ និងដូចគ្នាដែរចំពោះ ទ្រឹស្តីរបស់លោក Mabud Vi-Haq ដែលថា ការអភិវឌ្ឍសេដ្ឋកិច្ចសំដៅលើ ការបង្កើនប្រាក់ដើម្បីបំប៉នជីវភាពគ្រួសារ។ យោងទៅតាមទ្រឹស្តី Big Push ដើម្បីឲ្យមានកំណើនសេដ្ឋកិច្ចរបស់ប្រទេសមួយ ឬកំណើនសេដ្ឋកិច្ចគ្រួសារមួយតាមរយៈការបង្កើននូវការវិនិយោគឲ្យកាន់តែច្រើនទៅលើហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងការអប់រំ រួមផ្សំនឹងការវិនិយោគជាលក្ខណៈឯកជន នាំឲ្យកើនឡើងនូវផលិតភាពក្នុងការផលិតទំនិញ និងសេវា។ ចំពោះផ្នែកវិនិយោគលក្ខណៈឯកជន ដូចគ្នាទៅនឹងទ្រឹស្តី Salter Cycle ដែរគឺ ការវិនិយោគលើឧបករណ៍ (Capital investment) បន្ថែមបច្ចេកវិទ្យាថ្មី និងរីកចម្រើនវិធីសាស្ត្រផលិត និង Economies of Scale ធ្វើឲ្យកើនឡើងលទ្ធភាពផលិត និងនាំឲ្យប្រជាជនមានកម្រិតជីវភាពប្រសើរឡើង។ ចំពោះ

ផ្នែកការអប់រំ ស្របទៅនឹងទ្រឹស្តី Cognitive capitalism ការបង្កើនកម្រិតជីវភាពប្រជាជន តាមរយៈប្រាជ្ញា ភាពឆ្លាតវៃ និងចំណេះដឹងគាំទ្រការរុករកនូវគំនិតច្នៃប្រឌិតថ្មីៗ។ ចំពោះផ្នែកវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ដូចទៅនឹងទ្រឹស្តីរបស់លោក Walt Withman Rostow ដែរដែលថា លក្ខណៈនៃការអភិវឌ្ឍរួមមានការពង្រីកលើហេដ្ឋារចនាសម្ព័ន្ធ។

### ៣.៣.១ ដំណោះស្រាយចំពោះមុខរបរចម្បងផ្នែកកសិកម្ម

កសិកម្មនៅប្រទេសកម្ពុជាយើង ជាកសិកម្មអន់ថយ ដែលមានលក្ខណៈជាយថាផល ដែលការដាំដុះច្រើនពឹងផ្អែកលើទឹកភ្លៀង ប្រើជី និងថ្នាំសម្លាប់សត្វល្អិតតិចតួច ឬមិនត្រឹមត្រូវ។ល។ ដែលទាំងនេះជាហេតុនាំឲ្យទិន្នផលទាប និងធ្វើឲ្យបរិមាណផលិតផលប្រចាំឆ្នាំមិនទៀងទាត់ ហើយនៅតាមតំបន់ខ្លះទៀត ទឹកជំនន់ និងភាពរាំងស្ងួត ជាឧបសគ្គចំពោះការអភិវឌ្ឍកសិកម្មជនបទ។[40]

ដោយឡែក ចំពោះកសិកម្មនៅក្នុងឃុំប្រាសាទក៏មិនខុសពីនេះប៉ុន្មានដែរ ពោលគឺជាកសិកម្មអន់ថយ ដោយមិនមានការអនុវត្តត្រឹមត្រូវតាមបច្ចេកទេសជំនាញកសិកម្មច្បាស់លាស់នោះទេ ដូចនេះទិន្នផលក៏មានចំនួនតិចតួចមិនតាមស្តង់ដារផងដែរ។ ដើម្បីអភិវឌ្ឍមុខរបរនេះឲ្យប្រសើរជាងមុន យើងត្រូវដោះស្រាយនូវបញ្ហាដែលកំពុងជួបប្រទះ ជាពិសេសគឺបញ្ហាចម្បងដែលមានឥទ្ធិពលលើបញ្ហាតូចៗដ៏ទៃទៀត។ ដូច្នេះ តាមរយៈការបកស្រាយបញ្ហាចម្បងៗខាងលើ យើងត្រូវរកដំណោះស្រាយចំពោះបញ្ហាប្រព័ន្ធធារាសាស្ត្រ បញ្ហាបច្ចេកទេស និង បញ្ហាផ្លូវ។ យោងតាមទ្រឹស្តី Big Push (ដោយលើកលែងការវិនិយោគលក្ខណៈឯកជន) ស្របជាមួយ ទ្រឹស្តីរបស់លោក Walt Withman Rostow និង ទ្រឹស្តី Cognitive capitalism ដោយបញ្ចូលគ្នានូវទ្រឹស្តីទាំងនេះ យើងអាចឃើញដំណើរការនៃការអភិវឌ្ឍ ដែលឆ្លើយតបទៅនឹងបញ្ហាប្រឈមរបស់ប្រជាជនក្នុងឃុំ ដូចខាងក្រោម ៖




[40] សៀវភៅ "សេដ្ឋកិច្ចកម្ពុជា" ដឹកនាំដោយសាស្ត្រាចារ្យ ថៅ សុខមុនី ឆ្នាំ ២០០៧ ទំព័រ ២១

**បញ្ហាប្រព័ន្ធធារាសាស្ត្រ:** ឆ្លើយតបចំពោះបញ្ហានេះ រាជរដ្ឋាភិបាល និងក្រសួងស្ថាប័នពាក់ព័ន្ធ ជាពិសេសក្រសួងធនធានទឹកនិងឧត្តុនិយម គួរតែពិនិត្យ យកចិត្តទុកដាក់ និងដោះស្រាយបញ្ហាគ្មានប្រព័ន្ធស្រោចស្រព (ប្រជាជនក្នុងឃុំភាគច្រើនកំពុងជួបប្រទះ) និងបញ្ហាមិនមានទឹកគ្រប់គ្រាន់ក្នុងការស្រោចស្រព។ ស្របទៅតាម គោលនយោបាយទឹក និងប្រព័ន្ធធារាសាស្ត្រសម្រាប់នីតិកាលទី ៥ រួមមានការលើកកម្ពស់ការគ្រប់គ្រងធនធានទឹក និងការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រ បង្កើនប្រសិទ្ធភាពនៃការថែទាំ និងជួសជុលហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ។ ជាក់ស្តែង យោងតាមប្រភពទិន្នន័យខាងលើក្នុងឃុំនេះត្រូវធ្វើការដោះស្រាយបញ្ហាប្រព័ន្ធធារាសាស្ត្រដោយ ៖

- កសាងប្រព័ន្ធធារាសាស្ត្រថ្មី នៅគ្រប់ភូមិទាំងអស់ដោយចាប់ផ្តើមពីភូមិដែលជួបប្រទះបញ្ហាច្រើនទៅតិចតាមលំដាប់រៀងគ្នាដូចជា ភូមិជ្រលង និងភូមិថ្កូវ (បញ្ហាស្មើគ្នា), ភូមិចំបក់ និងពាន់វត្ត (បញ្ហាស្មើគ្នា), ភូមិបី, ភូមិអំពិល, ភូមិភ្លង, ភូមិប្រាសាទ, និងភូមិដូនទុង។
- ធ្វើការជួសជុល ឬស្តារប្រព័ន្ធធារាសាស្ត្រ នៅភូមិចំនួន ៤ ដោយចាប់ផ្តើមពីភូមិដែលជួបប្រទះបញ្ហាច្រើនទៅតិចតាមលំដាប់រៀងគ្នាដូចជា ភូមិអំពិល, ភូមិប្រាសាទ, ភូមិដូនទុង និងភូមិថ្កូវ (បញ្ហាស្មើគ្នា)។

សម្គាល់ ៖ ភូមិចំនួន ៤ មានភូមិអំពិល ភូមិប្រាសាទ ភូមិដូនទុង និងភូមិថ្កូវ ជួបបញ្ហាទាំង២ខាងលើ ដោយគ្រួសារខ្លះក្នុងភូមិទាំងនេះមានដីស្រែដែលមិនមានប្រឡាយទឹក និងគ្រួសារខ្លះទៀតមានប្រឡាយ ប៉ុន្តែមិនមានទឹកស្រោចស្រពគ្រប់គ្រាន់។

យោងតាមទិន្នន័យវិភាគដែលទទួលបានពីប្រជាជន ជាទូទៅ ដីស្រែដែលនៅជិត ប្រព័ន្ធធារាសាស្ត្រ អាចមានលទ្ធភាពធ្វើការដាំដុះបាន ២រដូវ ឬ ៣រដូវ ប៉ុន្តែចំពោះដីស្រែដែលគ្មានប្រព័ន្ធធារាសាស្ត្រ អាចធ្វើការដាំដុះបានតែម្តងគត់។ ប្រសិនបើដោះស្រាយបញ្ហានោះបាន នោះពិតជាធ្វើឲ្យកើនឡើងកម្រិតជីវភាពរបស់ប្រជាកសិករមែន ព្រោះបើតាមទិន្នន័យវិភាគបានបញ្ជាក់ថា ទិន្នផលជាមធ្យមនៃការដាំដុះតែមួយរដូវ ស្មើនឹង ២,១១តោនក្នុង១ហិកតា។ រីឯទិន្នផលជាមធ្យមនៃការដាំដុះ ២រដូវ ស្មើនឹង ៥,៣០តោនក្នុង១ហិកតា ហើយចំពោះទិន្នផលជាមធ្យមនៃការដាំដុះ ៣រដូវ ស្មើនឹង ៦,២០ តោនក្នុង១ហិកតា។

ចំពោះអាជ្ញាធរដែនដីមូលដ្ឋានក្នុងឃុំប្រាសាទផ្ទាល់ មានគោលដៅឲ្យប្រជាកសិករមានទឹកស្រោចស្រពដំណាំកសិកម្មគ្រប់គ្រាន់ដែលតម្រូវឲ្យជួសជុល ស្តារ និងកសាងប្រព័ន្ធធារាសាស្ត្រថ្មីប្រវែង ១៥ គីឡូម៉ែត្រនៅឆ្នាំ ២០២២ (សព្វថ្ងៃមានប្រវែងត្រឹមតែ ៣ គីឡូម៉ែត្រតែប៉ុណ្ណោះ)។

**បញ្ហាបច្ចេកទេសកសិកម្ម:** ឆ្លើយតបចំពោះបញ្ហានេះ រាជរដ្ឋាភិបាល និងក្រសួងស្ថាប័នពាក់ព័ន្ធជាពិសេសក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គួរយកចិត្តទុកដាក់ និងដោះស្រាយបញ្ហានេះ ជាពិសេសបញ្ជូនមន្ត្រីជំនាញចុះសិក្សាស្រាវជ្រាវក្នុងឃុំផ្ទាល់ទៅតាមលក្ខណៈបច្ចេកទេស បន្ទាប់មកបង្កើតកម្មវិធីបណ្តុះបណ្តាលពីបច្ចេកទេសកសិកម្ម ស្របទៅតាមលទ្ធភាពដែលប្រជាកសិករអាចធ្វើបាន ឬក៏ឈានទៅដល់ការបើកជាមជ្ឈមណ្ឌលកសិកម្មគំរូនៅជិតឃុំដែលឲ្យប្រជាជនអាចទៅដល់។ ស្របទៅតាម យុទ្ធសាស្ត្រនៃការអភិវឌ្ឍសហគមន៍, គោលនយោបាយអភិវឌ្ឍន៍កសិកម្ម, និងគោលនយោបាយលើកស្ទួយវិស័យកសិកម្ម (ការលើកកម្ពស់ផលិតភាព ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្ម និង ការលើកកម្ពស់ការចិញ្ចឹមសត្វ និងវារីវប្បកម្ម) នៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៤-២០១៨ រួមមាន ការពង្រឹង ការពង្រីក និងការធានាចីរភាពនៃប្រព័ន្ធសេវាបច្ចេកទេស, ការលើកម្ពស់ការស្រាវជ្រាវ និងការអភិវឌ្ឍ ការផ្សព្វផ្សាយមុខដំណាំថ្មីៗដែលមានសក្តានុពលសម្រាប់ដាំដុះ, ការផ្ទេរចំណេះដឹង ចំណេះធ្វើ និងបច្ចេកវិទ្យាថ្មីៗដល់កសិករ, និងជំរុញអនុវត្តវិធានការអនាម័យសត្វ ភូតគាមអនាម័យដើម្បីបង្ការទប់ស្កាត់ និងលុបបំបាត់ការឆ្លងរាលដាលជំងឺសត្វ រួមជាមួយការលើកកម្ពស់ប្រព័ន្ធផ្តល់សេវាបច្ចេកទេស។ ជាក់ស្តែង យោងតាមប្រភពទិន្នន័យខាងលើក្នុងឃុំនេះត្រូវ ការដោះស្រាយបញ្ហាបច្ចេកទេសកសិកម្មដោយ ៖

- បង្កើតឲ្យមានកម្មវិធីបណ្តុះបណ្តាលពីបច្ចេកទេសកសិកម្ម នៅគ្រប់ភូមិទាំងអស់ដោយចាប់ផ្តើមពីភូមិដែលជួបប្រទះបញ្ហាច្រើនទៅតិចតាមលំដាប់រៀងគ្នាដូចជា ភូមិថ្កូវ, ភូមិជ្រលង, ភូមិចំបក់ និងភូមិពាន់វត្ត (បញ្ហាស្មើគ្នា), ភូមិបី, ភូមិប្រាសាទ ភូមិដូនទុង ភូមិភ្លូង និងភូមិអំពិល (បញ្ហាស្មើគ្នា)។
- ត្រូវផ្សព្វផ្សាយពីផលប្រយោជន៍នៃការចូលរួម និងផ្តល់ដំណឹងពីកម្មវិធីឲ្យបានដល់ប្រជាកសិករគ្រប់គ្រួសារ ជាពិសេសគឺគ្រួសារដែលនៅក្នុងភូមិអំពិល។

យោងទៅតាមឯកសារដែលបានស្រាវជ្រាវតាមប្រព័ន្ធអនឡាញ (online) ពីការស្រាវជ្រាវរបស់ធនាគារអភិវឌ្ឍអាស៊ី ក្នុងឆ្នាំ ២០១៤ ដែលបានបង្ហាញថា ទិន្នផលស្រូវទៅតាមស្តង់ដាររបស់ប្រទេសកម្ពុជា ទទួលបានជាមធ្យម ៣,៣តោន ក្នុង១ហិកតា (រួមបញ្ចូលទាំងបច្ចេកទេសកសិកម្ម និងបច្ចេកវិទ្យាទំនើបនៅក្នុងផលិតកម្មស្រូវ)[41]។ ប្រសិនបើដោះស្រាយបញ្ហានោះបាន នោះពិតជាធ្វើឲ្យកើនឡើងកម្រិតជីវភាពរបស់ប្រជាកសិករមែន ព្រោះថា ទិន្នផលស្រូវក្នុងឃុំសព្វថ្ងៃទទួលបានជាមធ្យមត្រឹមតែ ២,១១តោនក្នុង១ហិកតាតែប៉ុណ្ណោះ។

[41] Agriculture Production, *Open Development Cambodia*, 6 April 2016

ចំពោះអាជ្ញាធរដែនដីមូលដ្ឋានក្នុងឃុំប្រាសាទផ្ទាល់ មានគោលដៅចាប់ពីបច្ចុប្បន្នដល់ត្រឹមឆ្នាំ ២០២២ គឺបង្កើនទិន្នផលស្រូវ និងការចិញ្ចឹមសត្វ ដើម្បីបង្កើនប្រាក់ចំណូលរបស់ប្រជាពលរដ្ឋ តាមរយៈ ការបណ្តុះបណ្តាលបច្ចេកទេសដំណាំស្រូវ, ផ្តល់ពូជស្រូវទិន្នផលខ្ពស់, បណ្តុះបណ្តាលបច្ចេកទេសផលិតជីកំប៉ុស្ត៍ និងប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិត, បណ្តុះបណ្តាលចិញ្ចឹមសត្វ...។

**បញ្ហាផ្លូវ:** ឆ្លើយតបចំពោះបញ្ហានេះ រាជរដ្ឋាភិបាល និងក្រសួងស្ថាប័នពាក់ព័ន្ធ គួរពិនិត្យយកចិត្តទុកដាក់ និងដោះស្រាយបញ្ហានេះជាពិសេសធ្វើការពង្រីក និងជួសជុលផ្លូវ។ ស្របជាមួយនឹងគោលនយោបាយអភិវឌ្ឍន៍ជនបទ រួមជាមួយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៤-២០១៨ ក្នុងគោលនយោបាយការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងហេដ្ឋារចនាសម្ព័ន្ធ នៃនីតិកាលទី ៥ រួមមាន ជំរុញកសាងផ្លូវជាតិ ផ្លូវខេត្ត និងផ្លូវជនបទ ជាពិសេសការខិតខំក្រាលកៅស៊ូនិងចាក់បេតុង ផ្លូវជនបទឲ្យបានពី ៣០០ ទៅ ៤០០គីឡូម៉ែត្រក្នុងមួយឆ្នាំ។

ជាក់ស្តែង យោងតាមប្រភពទិន្នន័យខាងលើក្នុងឃុំនេះត្រូវ ការដោះស្រាយបញ្ហាផ្លូវដោយធ្វើការពង្រីក និងជួសជុលផ្លូវនៅគ្រប់ភូមិទាំងអស់ដោយចាប់ផ្តើមពីភូមិដែលជួបប្រទះបញ្ហាច្រើនទៅតិចតាមលំដាប់រៀងគ្នាដូចជា ភូមិថ្កូវ, ភូមិជ្រលង ភូមិចំបក់ ភូមិពាន់វត្ត និងភូមិអំពិល (បញ្ហាស្មើគ្នា), ភូមិប្រាសាទ និងភូមិក្លូង (បញ្ហាស្មើគ្នា), ភូមិដូនទុង និងភូមិបី (បញ្ហាស្មើគ្នា)។ ប្រសិនបើដោះស្រាយនូវបញ្ហានេះបាន នោះនឹងសម្រួលដល់ការដឹកជញ្ជូនផលិតផល (ស្រូវ សត្វចិញ្ចឹម) កាត់បន្ថយថ្លៃដើមផលិតផល ធ្វើឲ្យថ្លៃទាប និងងាយស្រួលក្នុងការប្រកួតប្រជែងក្នុងទីផ្សារ នាំឲ្យជីវភាពប្រសើរជាងមុន។

ចំពោះអាជ្ញាធរដែនដីមូលដ្ឋានក្នុងឃុំប្រាសាទផ្ទាល់ មានគោលដៅចាប់ពីបច្ចុប្បន្នដល់ត្រឹមបំណាច់ឆ្នាំ ២០២២ ផ្លូវលំដែលខូចខាតត្រូវបានជួសជុលឲ្យបានល្អប្រសើរឡើងវិញ និងកសាងថ្មីសរុបប្រវែង ២៥ គីឡូម៉ែត្រ។

### ៣.៣.២ ដំណោះស្រាយចំពោះមុខរបរចម្បងផ្នែកសេវាកម្ម

មុខរបរផ្នែកសេវាកម្ម គឺជាមុខរបរមួយដែលអាចបង្កើនតម្លៃបន្ថែមដល់សេដ្ឋកិច្ចជាតិយ៉ាងច្រើន តាមរយៈការបង្កើតការងារដល់ប្រជាជន និងបានកើនឡើងក្នុងចំណែករុញច្រានកំណើនផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ២០១៧ចំនួន ៦,៥% ធៀបនឹងឆ្នាំ២០១៦។ ដើម្បីអភិវឌ្ឍមុខរបរនេះឲ្យប្រសើរជាងមុន យើងត្រូវដោះស្រាយនូវបញ្ហាដែលកំពុងជួបប្រទះ ជាពិសេសគឺបញ្ហាចម្បងដែលមានឥទ្ធិពលលើបញ្ហាតូចៗដ៏ទៃទៀត។

ចំពោះអ្នកប្រកបរបរសេវាកម្មលក់ដូរ និងដឹកជញ្ជូន ៖ តាមរយៈការបកស្រាយបញ្ហាចម្បងៗខាងលើ យើងត្រូវរកដំណោះស្រាយចំពោះបញ្ហាផ្លូវ។ យោងតាមទ្រឹស្តី Big Push (ដោយលើកលែងការអប់រំ និងការវិនិយោគលក្ខណៈឯកជន) ស្របជាមួយ ទ្រឹស្តីរបស់លោក Walt Withman Rostow យើងអាចឃើញដំណើរការនៃការអភិវឌ្ឍ ដែលឆ្លើយតបទៅនឹងបញ្ហាប្រឈមរបស់ប្រជាជនក្នុងឃុំដូចខាងក្រោម ៖




ឆ្លើយតបចំពោះបញ្ហាផ្លូវ រាជរដ្ឋាភិបាល និងក្រសួងស្ថាប័នពាក់ព័ន្ធ គួរពិនិត្យ យកចិត្តទុកដាក់ និងដោះស្រាយបញ្ហានេះជាពិសេសធ្វើការពង្រីក និងជួសជុលផ្លូវ។ ស្របជាមួយនឹងគោលនយោបាយអភិវឌ្ឍន៍ជនបទ រួមជាមួយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៤-២០១៨ ក្នុងគោលនយោបាយការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងហេដ្ឋារចនាសម្ព័ន្ធ នៃនីតិកាលទី ៥ រួមមាន ជំរុញកសាងផ្លូវជាតិ ផ្លូវខេត្ត និងផ្លូវជនបទ ជាពិសេសការខិតខំក្រាលកៅស៊ូនិងចាក់បេតុង ផ្លូវជនបទឲ្យបានពី ៣០០ ទៅ ៤០០គីឡូម៉ែត្រក្នុងមួយឆ្នាំ។

ជាក់ស្តែង យោងតាមប្រភពទិន្នន័យខាងលើក្នុងឃុំនេះត្រូវការដោះស្រាយបញ្ហាផ្លូវដោយធ្វើការពង្រីក និងជួសជុលផ្លូវនៅភូមិចំនួន៤ ដោយចាប់ផ្តើមពីភូមិដែលជួបប្រទះបញ្ហាច្រើនទៅតិចតាមលំដាប់រៀងគ្នាដូចជា ភូមិចំបក់ និងភូមិភ្លង (បញ្ហាស្មើគ្នា), ភូមិដូនទុង និងភូមិបី (បញ្ហាស្មើគ្នា)។ ប្រសិនបើដោះស្រាយនូវបញ្ហានេះបាន នោះនឹងសម្រួលដល់ការដឹកជញ្ជូនផលិតផល កាត់បន្ថយថ្លៃដើមផលិតផល ធ្វើឲ្យថ្លៃទាប និងងាយស្រួលក្នុងការប្រកួតប្រជែងក្នុងទីផ្សារ នាំឲ្យជីវភាពប្រសើរជាងមុន។

បញ្ហាផ្លូវក្នុងមុខរបរនេះដូចគ្នានឹងបញ្ហាក្នុងមុខរបរកសិកម្មដែរ ដែលអាជ្ញាធរដែនដីមូលដ្ឋានក្នុងឃុំប្រាសាទផ្ទាល់ មានគោលដៅចាប់ពីបច្ចុប្បន្នដល់ត្រឹមបំណាច់ឆ្នាំ ២០២២ ផ្លូវលំដែលខូចខាតត្រូវបានជួសជុលឲ្យបានល្អប្រសើរឡើងវិញ និងកសាងថ្មីសរុបប្រវែង ២៥ គីឡូម៉ែត្រ។

ចំពោះអ្នកប្រកបមុខរបរសេវាកម្មដូចជា អ្នកស៊ីឈ្នួលគេ អ្នកធ្វើសំណង់ រោងចក្រ មន្ត្រីរាជការ និងជាងកាត់ដេរ ជួបនូវបញ្ហាមួយទៀតគឺ ប្រាក់ខែ ឬប្រាក់ឈ្នួលទាប។ យោងតាមទ្រឹស្តី Big Push (ដោយលើកលែងការវិនិយោគឯកជន និងវិនិយោគលក្ខណៈឯកជន) ស្របជាមួយ ទ្រឹស្តី

Cognitive capitalism ដោយបញ្ចូលគ្នានូវទ្រឹស្តីទាំងនេះ យើងអាចឃើញដំណើរការនៃការអភិវឌ្ឍ ដែលឆ្លើយតបទៅនឹងបញ្ហាប្រឈមរបស់ប្រជាជនក្នុងឃុំ ដូចខាងក្រោម ៖




ឆ្លើយតបចំពោះបញ្ហានេះ រាជរដ្ឋាភិបាល និងក្រសួងស្ថាប័នពាក់ព័ន្ធ គួរពិនិត្យ យកចិត្តទុកដាក់ និងដោះស្រាយដោយបណ្តុះបណ្តាលទៅលើវិជ្ជាជីវៈលើមុខរបររបស់គាត់នីមួយៗ។ ស្របតាមយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី ៣ របស់រាជរដ្ឋាភិបាលនីតិកាលទី ៥ នៃរដ្ឋសភា ក្នុងចតុកោណទី ៤ ស្តីអំពីការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស ដែលមុំទី១ រួមមាន ការពង្រឹង និងលើកកម្ពស់វិស័យអប់រំ, វិទ្យាសាស្ត្រ, បច្ចេកវិទ្យា ព្រមទាំងបណ្តុះបណ្តាលបច្ចេកទេស។ កាលណាពួកគាត់ទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈត្រឹមត្រូវ នឹងធ្វើឲ្យផលិតភាពគាត់កើនឡើង ទទួលបានប្រាក់ខែ ឬប្រាក់ឈ្នួលខ្ពស់ជាងមុន នាំឲ្យជីវភាពប្រសើរឡើង។

ចំពោះអាជ្ញាធរដែនដីមូលដ្ឋានក្នុងឃុំប្រាសាទផ្កាល់ ក៏មានយុទ្ធសាស្ត្រចាប់ពីបច្ចុប្បន្នដល់ត្រឹមបំណាច់ឆ្នាំ ២០២២ ក្នុងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈផ្សេងៗដែរ។

### ៣.៣.៣ ដំណោះស្រាយចំពោះមុខរបរចម្បងផ្នែកសិប្បកម្ម

វិស័យនេះ ក៏ជាមុខរបរមួយដែលដើរតួនាទីសំខាន់ក្នុងការជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជាតិជារៀងរាល់ឆ្នាំ ជាក់ស្តែងវិស័យឧស្សាហកម្ម រួមផ្សំនឹងសិប្បកម្មបានកើនឡើងក្នុងចំណែករុញច្រានកំណើនផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ២០១៧ចំនួន ១០,៧% ធៀបនឹងឆ្នាំ២០១៦។ ដើម្បីអភិវឌ្ឍមុខរបរក្នុងវិស័យនេះឲ្យប្រសើរជាងមុន យើងត្រូវដោះស្រាយនូវបញ្ហាដែលកំពុងជួបប្រទះ ជាពិសេសគឺបញ្ហាចម្បងដែលមានឥទ្ធិពលលើបញ្ហាតូចៗដ៏ទៃទៀត។ ដូច្នេះ តាមរយៈការបកស្រាយបញ្ហាចម្បងៗខាងលើ យើងត្រូវរកដំណោះស្រាយចំពោះបញ្ហាបច្ចេកទេស និងបញ្ហា បច្ចេកវិទ្យា។ យោងតាមទ្រឹស្តី Big Push (ដោយលើកលែងការវិនិយោគហេដ្ឋារចនាសម្ព័ន្ធ) ស្របជាមួយទ្រឹស្តីរបស់លោក Walt Withman Rostow និង ទ្រឹស្តី Cognitive capitalism ដោយបញ្ចូលគ្នានូវទ្រឹស្តីទាំងនេះ យើងអាចឃើញដំណើរការនៃការអភិវឌ្ឍ ដែលឆ្លើយតបទៅនឹងបញ្ហាប្រឈមរបស់ប្រជាជនក្នុងឃុំ ដូចខាងក្រោម ៖




**បញ្ហាបច្ចេកទេស:** ឆ្លើយតបចំពោះបញ្ហានេះ រាជរដ្ឋាភិបាល និងក្រសួងស្ថាប័នពាក់ព័ន្ធ គួរយកចិត្តទុកដាក់ និងដោះស្រាយបញ្ហានេះ ជាពិសេសបង្កើតសាលាបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈ ឬបើកវគ្គសិក្សាខ្លីៗបង្កើនចំណេះដឹងពាក់ព័ន្ធនឹងការងារដែលពួកគាត់កំពុងធ្វើ ដែលស្ថិតនៅជិតកន្លែងដែលមានបញ្ហា បន្ទាប់មកបង្កើតកម្មវិធីបណ្ដុះបណ្ដាលជំនាញបច្ចេកទេស ស្របទៅតាមលទ្ធភាពដែលប្រជាជនអាចធ្វើបាន។ ស្របតាម គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ស្ដីពីការអភិវឌ្ឍ និងធ្វើទំនើបកម្មសហគ្រាសធុនតូច និងមធ្យម និងសម្របសម្រួលគោលនយោបាយគាំទ្រ (ការអភិវឌ្ឍធនធានមនុស្ស / បណ្ដុះបណ្ដាលជំនាញ) រួមជាមួយនឹង យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលនីតិកាលទី ៥ នៃរដ្ឋសភា ក្នុងចតុកោណទី៣ ស្ដីអំពី ការអភិវឌ្ឍវិស័យឯកជន និងការងារ ដែលមុំទី២ រួមមាន ការអភិវឌ្ឍឧស្សាហកម្ម និងសហគ្រាសធុនតូច និងមធ្យម។ ជាក់ស្ដែង យោងតាមប្រភពទិន្នន័យខាងលើក្នុងឃុំនេះត្រូវការដោះស្រាយនៅ ភូមិចំនួន ២គឺ ភូមិប្រាសាទ និងភូមិដូនទុង។ កាលណាពួកគាត់ទទួលបានការបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈបានត្រឹមត្រូវ នឹងធ្វើឲ្យផលិតភាពគាត់កើនឡើង ទទួលបានប្រាក់ចំណូល ប្រាក់ខែ ឬប្រាក់ឈ្នួលខ្ពស់ជាងមុន នាំឲ្យជីវភាពប្រសើរឡើង។

ចំពោះអាជ្ញាធរដែនដីមូលដ្ឋានក្នុងឃុំប្រាសាទផ្ទាល់ ក៏មានយុទ្ធសាស្ត្រចាប់ពីបច្ចុប្បន្នដល់ត្រឹមបំណាច់ឆ្នាំ ២០២២ ក្នុងការបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈផ្សេងៗដែរ។

**បញ្ហាបច្ចេកវិទ្យា:** បញ្ហានេះទាក់ទងទៅនឹងការវិនិយោគលក្ខណៈឯកជនផង និងការជួយជ្រោមជ្រែងពីរដ្ឋាភិបាល ក្រសួងស្ថាប័នពាក់ព័ន្ធនានាផង។ ឆ្លើយតបចំពោះបញ្ហានេះរាជរដ្ឋាភិបាល និងក្រសួងស្ថាប័នពាក់ព័ន្ធ គួរយកចិត្តទុកដាក់ និងដោះស្រាយបញ្ហានេះ ជាពិសេសធនាគារ ឬស្ថាប័នហិរញ្ញវត្ថុផ្សេងៗ គួរតែសម្របសម្រួលនីតិវិធីក្នុងការទទួលបានកម្ចី ទាមទារវត្ថុបញ្ចាំខ្ពស់ ការទាមទារថ្លៃសេវាផ្សេងៗខ្ពស់ ជាពិសេសត្រួតពិនិត្យលើអត្រាការប្រាក់ដែលសមស្របនឹងលទ្ធភាពដែលប្រជាជន ក៏ដូចជាសមស្របនឹងលទ្ធភាពដែលធនាគារពាណិជ្ជ ឬមីក្រូហិរញ្ញវត្ថុ

អាចផ្តល់កម្ចីបាន។ ស្របទៅតាមគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម រួមមាន ការអភិវឌ្ឍ និងផ្ទេរបច្ចេកវិទ្យា, ការអភិវឌ្ឍ និងធ្វើទំនើបកម្មសហគ្រាសធុនតូច និងមធ្យម និងការសម្របសម្រួលគោលនយោបាយគាំទ្រ (ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រ និងប្រព័ន្ធបច្ចេកវិទ្យា) និង ស្របជាមួយយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលនីតិកាលទី ៥ នៃរដ្ឋសភា ក្នុងចតុកោណទី៣ មុំទី៤ ស្តីពីការអភិវឌ្ឍវិស័យធនាគារ និងហិរញ្ញវត្ថុ ត្រង់ចំណុចអាទិភាពទី៥ គឺ ការបន្តខិតខំពង្រីកសេវាមីក្រូហិរញ្ញវត្ថុ តាមថ្លៃ និងលក្ខខណ្ឌកាន់តែមានលក្ខណៈអនុគ្រោះសំដៅលើកស្ទួយសេដ្ឋកិច្ចជនបទ និងការបន្តពង្រីកការផ្តល់ឥណទានដល់សហគ្រាសធុនតូច និងមធ្យម។ ជាក់ ស្តែង យោងតាមប្រភពទិន្នន័យខាងលើក្នុងឃុំនេះត្រូវការដោះស្រាយនៅទីតាំងសហគ្រាសចំនួនពីរ (ម៉ាស៊ីនកិនស្រូវ) ក្នុងភូមិប្រាសាទ និងភូមិដូនទុង។ កាលណាពួកគាត់ទទួលបានកម្ចីងាយស្រួលក្នុងការវិនិយោគលើម៉ាស៊ីនក្នុងផលិតកម្មឲ្យមានលក្ខណៈទំនើបជាងមុន នោះផលិតភាពរបស់គាត់នឹងកើនឡើងជាងមុន នាំឲ្យកម្រិតជីវភាពគាត់ប្រសើរឡើង។

## សន្និដ្ឋានជំពូក

សរុបសេចក្តីមក តាមរយៈការវិភាគទិន្នន័យដែលបានពីប្រជាជនក្នុងឃុំប្រាសាទផ្ទាល់ យើងបានដឹងថា ប្រជាជនក្នុងឃុំភាគច្រើនជាអ្នកប្រកបរបរផ្នែកកសិកម្ម បន្ទាប់មកគឺផ្នែកសេវាកម្ម និងតិចជាងគេគឺផ្នែកសិប្បកម្ម សហគ្រាស។ ក្នុងមុខរបរផ្នែកកសិកម្ម និងសិប្បកម្ម/សហគ្រាស យើងឃើញថាមានការប្រែប្រួលពីការធ្វើបែបប្រពៃណី ដោយជំនួសខ្លះៗដោយគ្រឿងយន្ត គ្រឿងចក្រក្នុងដំណើរផលិតកម្ម។ ទន្ទឹមនឹងការប្រែប្រួលជាវិជ្ជមាននេះ ប្រជាជនក៏ជួបប្រទះនូវបញ្ហាមួយចំនួនដែលរាំងស្ទះដល់ការប្រកបមុខរបរនីមួយៗផងដែរ រួមមានបញ្ហាចម្បងៗដូចជា បញ្ហាប្រព័ន្ធធារាសាស្ត្រ បញ្ហាបច្ចេកទេសកសិកម្ម បញ្ហាផ្លូវ បញ្ហាបច្ចេកទេស និងបញ្ហាបច្ចេកវិទ្យា ដែលទាមទារឲ្យស្វែងរកដំណោះស្រាយឲ្យមានប្រសិទ្ធភាពយោងទៅតាមទ្រឹស្តីអ្នកប្រាជ្ញ យុទ្ធសាស្ត្រ និងគោលនយោបាយរបស់រដ្ឋាភិបាល។ រីឯមុខរបរផ្នែកសេវាកម្ម យើងឃើញថាតម្រូវការទីផ្សារ (សម្រាប់អ្នកលក់ដូរ) និងតម្រូវការការងារ (សម្រាប់បំរើការងារ) មានលក្ខណៈសមស្របក្នុងការផ្គត់ផ្គង់។ ទន្ទឹមនឹងការប្រែប្រួលជាវិជ្ជមាននេះ ប្រជាជនក៏ជួបប្រទះនូវបញ្ហាមួយចំនួនដែលរាំងស្ទះដល់ការប្រកបមុខរបរមួយនេះផងដែរ ដែលបញ្ហាចម្បងមានដូចជា បញ្ហាផ្លូវ និងបញ្ហាប្រាក់ខែ/ឈ្នួលទាប ដែលជាបញ្ហាទាមទារឲ្យស្វែងរកដំណោះស្រាយឲ្យមានប្រសិទ្ធភាពស្របទៅតាមទ្រឹស្តីអ្នកប្រាជ្ញ យុទ្ធសាស្ត្រ និងគោលនយោបាយរបស់រដ្ឋាភិបាលផងដែរ។ យើងខ្ញុំមានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា បន្ទាប់ពីប្រើប្រាស់នូវដំណោះស្រាយដែលបានបកស្រាយខាងលើ នឹងអាចជួយលើកស្ទួយនូវផលិតភាពក្នុងវិស័យទាំងបី ដែលវាជាបច្ច័យក្នុងការរុញច្រានឲ្យកម្រិតជីវភាពរបស់ប្រជាជនក្នុងឃុំនេះទាំងមូលមានការរីកចម្រើនជាងមុនជាលំដាប់។

# សេចក្តីសន្និដ្ឋាន
# និង ការផ្តល់អនុសាសន៍

# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

ឃុំប្រាសាទ គឺជាឃុំដែលមានអាយុកាលដ៏ចំណាស់មកហើយ មានភូមិចំនួន ៩ និងមានទីតាំងស្ថិតនៅខាងកើតទីរួមស្រុកកំពង់ត្របែកចម្ងាយ ៧គីឡូម៉ែត្រ។ ប្រជាជនក្នុងឃុំភាគច្រើនជាអ្នកប្រកបរបរផ្នែកកសិកម្ម បន្ទាប់មកគឺផ្នែកសេវាកម្ម និងតិចជាងគេគឺផ្នែកសិប្បកម្មសហគ្រាស។ ឃុំនេះបានសម្រេចបាននូវសមិទ្ធិផល និង ភាពជោគជ័យជាច្រើនតាមរយៈការអនុវត្តតាមនូវចក្ខុវិស័យ គោលបំណង គោលដៅ និងយុទ្ធសាស្ត្រនៃការអភិវឌ្ឍឃុំ។ ទន្ទឹមនឹងភាពជោគជ័យទាំងនោះ ឃុំក៏បានជួបប្រទះនូវបញ្ហារាំងស្ទះជាច្រើនដែលរារាំងដល់ដំណើរការអភិវឌ្ឍ ដែលជាបច្ច័យអវិជ្ជមានជះឥទ្ធិពលដល់ការប្រកបមុខរបររបស់ប្រជាជនក្នុងឃុំផងដែរ ដែលបញ្ហាទាំងអស់នោះទាមទារឲ្យមានដំណោះស្រាយដ៏មានប្រសិទ្ធភាព និងភាពសក្តិសិទ្ធ ក្នុងគោលដៅកាត់បន្ថយភាពក្រីក្រ និងបង្កើនកម្រិតជីវភាពរបស់ប្រជាជននៅក្នុងឃុំ តាមរយៈការធ្វើឲ្យផលិតភាពក្នុងដំណើរការលើមុខរបររកស៊ីរបស់ពួកគាត់កើនឡើង នាំឲ្យពួកគាត់មានជីវភាពប្រសើរជាងមុន និងធ្វើឲ្យមានកំណើននៃការអភិវឌ្ឍក្នុងឃុំទាំងមូល។ ប៉ុន្តែក្នុងចំណោមបញ្ហាទាំងនោះ មានបញ្ហាខ្លះមានគម្រោងនឹងដោះស្រាយដែរតែមិនមានថវិការគាំទ្រ និងខ្លះទៀតមិនមានលទ្ធភាពដោះស្រាយ។ ដោយឡែកក្នុងការវិភាគលើទិន្នន័យជាក់ស្តែងដែលទទួលបានពីប្រជាជនប្រកបមុខរបរនីមួយៗក្នុងឃុំ (មុខរបរផ្នែកកសិកម្ម, សេវាកម្ម, និងសិប្បកម្ម/សហគ្រាស) បង្ហាញថា ពួកគាត់បានជួបប្រទះនូវបញ្ហាប្រឈមជាច្រើនប្រភេទ ដោយក្នុងនោះយើងរកឃើញនូវបញ្ហាចម្បងៗក្នុងការប្រកបមុខរបរផ្នែកនីមួយៗ ដែលមានដូចជា បញ្ហាប្រព័ន្ធធារាសាស្ត្រ បញ្ហាបច្ចេកទេសកសិកម្ម បញ្ហាផ្លូវ បញ្ហាបច្ចេកទេស បញ្ហាបច្ចេកវិទ្យា និងបញ្ហាប្រាក់ខែ/ឈ្នួលទាប ដែលសុទ្ធសឹងតែជាបញ្ហាទាមទារឲ្យស្វែងរកដំណោះស្រាយជាបន្ទាន់ និងមានប្រសិទ្ធភាព។ ដោយហេតុដូច្នេះហើយទើប យើងខ្ញុំបានធ្វើការបកស្រាយ និងបង្ហាញពីរបៀបនៃការដោះស្រាយបញ្ហាទាំងអស់នេះដូចដែរបានបង្ហាញក្នុងជំពូកទី៣ ខាងលើ ហើយយើងខ្ញុំជឿជាក់ថា វានឹងអាចជួយសម្រេចបំណងក្នុងការកាត់បន្ថយភាពក្រីក្រ លើកស្ទួយកម្រិតជីវភាពប្រជាជននៅជនបទ និងធ្វើឲ្យជីវភាពរស់នៅមានការប្រសើរឡើង ក៏ដូចជាអភិវឌ្ឍសេដ្ឋកិច្ចជនបទប្រកបដោយចីរភាព។

## ២. ការផ្តល់អនុសាសន៍

❖ **អនុសាសន៍**

ដើម្បីឲ្យប្រជាជនដែលប្រកបមុខរបរចម្បងទាំងបីផ្នែកក្នុងឃុំ មានជីវិភាពប្រសើរឡើង តាមរយៈការបង្កើនផលិតភាព យើងខ្ញុំសូមផ្តល់អនុសាសន៍មួយចំនួនដូចជា ៖

- ផ្នែកកសិកម្ម : យើងខ្ញុំសូមសំណូមពរដល់រាជរដ្ឋាភិបាល មេត្តាជួយដោះស្រាយ ៖

1. បញ្ហាប្រព័ន្ធធារាសាស្ត្រ និងបញ្ហាបច្ចេកទេសកសិកម្ម ដែលជាបញ្ហាតម្រូវឲ្យមានការដោះស្រាយមុនគេ ពីព្រោះយោងទៅតាមសំណូមពររបស់ប្រជាជន និងតាមរយៈដំណោះស្រាយក្នុងជំពូកទី៣ បានបង្ហាញថា បើដោះស្រាយបញ្ហាទាំងពីរនេះ វានឹងជះឥទ្ធិពលខ្លាំងជាងគេទៅលើផលិតភាពដែលនាំឲ្យកើនឡើងនូវទិន្នផល។
2. បញ្ហាផ្លូវ ដែលជាបញ្ហាបន្ទាប់ទាមទារឲ្យមានការដោះស្រាយ ព្រោះយោងទៅតាមសំណូមពររបស់ប្រជាជន និងតាមរយៈដំណោះស្រាយក្នុងជំពូកទី៣ បានបង្ហាញថា បើដោះស្រាយបញ្ហានេះ វានឹងធ្វើឲ្យកាត់បន្ថយថ្លៃដើមផលិតកម្ម។

- ផ្នែកសេវាកម្ម : យើងខ្ញុំសូមសំណូមពរដល់រាជរដ្ឋាភិបាល មេត្តាជួយដោះស្រាយ នូវបញ្ហាពីដែលតម្រូវឲ្យដោះស្រាយជំណាលគ្នា៖

1. បញ្ហាផ្លូវ (ចំពោះអ្នកលក់ដូរ និងអ្នកដឹកជញ្ជូន) ដែលតម្រូវឲ្យមានការដោះស្រាយព្រោះយោងទៅតាមសំណូមពររបស់ប្រជាជន និងតាមរយៈដំណោះស្រាយក្នុងជំពូកទី៣ បានបង្ហាញថា បើដោះស្រាយបញ្ហានេះ វានឹងធ្វើឲ្យកាត់បន្ថយថ្លៃដើមផលិតកម្ម។
2. បញ្ហាប្រាក់ខែ/ឈ្នួលទាប (ផលិតភាពទាប) ដែលកើតមានចំពោះអ្នកបំរើសេវាកម្មដូចជាឈ្នួលគេ សំណង់ រោងចក្រ មន្ត្រីរាជការ ជាងកាត់ដេរ។ បញ្ហានេះតម្រូវឲ្យមានការដោះស្រាយព្រោះយោងទៅតាមសំណូមពររបស់ប្រជាជន និងតាមរយៈដំណោះស្រាយក្នុងជំពូកទី៣ បានបង្ហាញថា បើដោះស្រាយបញ្ហានេះ វានឹងជំរុញឲ្យផលិតភាពគាត់កើនឡើង នាំឲ្យទទួលបានប្រាក់ខែ/ឈ្នួលច្រើនជាងមុន។

- ផ្នែកសិប្បកម្ម/សហគ្រាស : យើងខ្ញុំសូមសំណូមពរដល់រាជរដ្ឋាភិបាល មេត្តាជួយដោះស្រាយ នូវបញ្ហាពីដែលតម្រូវឲ្យដោះស្រាយជំណាលគ្នា៖

1. បញ្ហាបច្ចេកទេស ដែលតម្រូវឲ្យមានការដោះស្រាយ ព្រោះយោងទៅតាមសំណូមពររបស់ប្រជាជន និងតាមរយៈដំណោះស្រាយក្នុងជំពូកទី៣ បានបង្ហាញថា បើដោះស្រាយបញ្ហានេះ វានឹងជំរុញឲ្យផលិតភាពគាត់កើនឡើង(កម្មករ) នាំឲ្យថ្លៃដើមថយចុះ(ម្ចាស់)។

2. បញ្ហាបច្ចេកវិទ្យា ដែលតម្រូវឲ្យមានការដោះស្រាយ ព្រោះយោងទៅតាមសំណូមពររបស់ប្រជាជន និងតាមរយៈដំណោះស្រាយក្នុងជំពូកទី៣ បានបង្ហាញថា បើដោះស្រាយបញ្ហានេះ វានឹងជំរុញឲ្យផលិតភាពគាត់កើនឡើង(ម៉ាស៊ីនគ្រឿងចក្រ) នាំឲ្យថ្លៃដើមថយចុះ។

❖ **យោបល់បន្ថែម**

យោងតាមបទពិសោធន៍ដ៏ជោគជ័យនៃចលនាភូមិ១ផលិតផល១ របស់ប្រទេសជប៉ុន ដែលមានគោលការណ៍ជាមូលដ្ឋានចំនួន ៣ គឺ គិតជាសាកល ដោយធ្វើតាមមូលដ្ឋាន, ភាពម្ចាស់ការឬការពឹងផ្អែកលើខ្លួនឯង និងការច្នៃប្រឌិតរស់រវើក, និង ការជម្រុញការអភិវឌ្ឍធនធានមនុស្ស ភ្ជាប់ជាមួយនឹងយុទ្ធសាស្ត្រខ្សែសង្វាក់ផលិតកម្ម យើងខ្ញុំមានយោបល់បន្ថែមក្នុងការជំរុញការអភិវឌ្ឍក្នុងឃុំឲ្យកាន់តែមានប្រសិទ្ធភាព និងមានកំណើនឆាប់រហ័ស ដោយត្រូវការការចូលរួមពីបណ្ដាអាជ្ញាធរក្នុងឃុំ អង្គការ ឬភ្នាក់ងារ ស្ថាប័នអភិវឌ្ឍន៍សហគមន៍នៅថ្នាក់ជាតិ និងដៃគូអភិវឌ្ឍន៍ផ្សេងទៀត និងការចូលរួមរបស់ប្រជាជនផ្ទាល់ (ស្របតាមយុទ្ធសាស្ត្រនៃការអភិវឌ្ឍសហគមន៍) ក្នុងការពិភាក្សារិះរកនូវយុទ្ធសាស្ត្ររួមគ្នាដោយ ៖

- ចាប់ផ្ដើមពីផលិតផលដែលជាវត្ថុធាតុដើម ដែលអាជ្ញាធរ និងប្រជាជនគួរតែរិះរកផលិតផលដែលជាវត្ថុធាតុដើមថ្មីៗ ជាពិសេសមុខដំណាំកសិកម្មថ្មីៗដែលសមស្របនឹងសក្ដានុពលដី និងជាផលិតផលដែលមានតម្រូវការខ្ពស់លើទីផ្សារ។ បន្ទាប់មកគួរតែបណ្ដុះបណ្ដាលប្រជាជនទៅតាមបច្ចេកទេសនៃការដាំដុះផលិតផលថ្មីៗទាំងនោះ ដើម្បីឲ្យការផលិតមានប្រសិទ្ធភាព និងផលិតអស់សក្ដានុពល។
- គួរតែជំរុញការកែច្នៃឲ្យបានច្រើន ទាំងផលិតផលវត្ថុធាតុដើមដែលមានស្រាប់ និងរកឃើញថ្មី ហើយបង្កើតឲ្យបានច្រើនមុខទំនិញ និងកែច្នៃឲ្យអស់លទ្ធភាព។ វាតម្រូវឲ្យមានការបណ្ដុះបណ្ដាលនូវបច្ចេកទេស បច្ចេកវិទ្យា ចំណេះដឹងក្នុងការរុករកនូវគំនិតបង្កើតថ្មី។
- គួរតែជំរុញការស្វែងរកទីផ្សារ ទាំងទីផ្សារមានស្រាប់ និងទីផ្សារថ្មី ទាំងក្នុង និងក្រៅប្រទេសក្នុងការលក់ផលិតផលដែលផលិតបាន ដោយប្រើប្រាស់យុទ្ធសាស្ត្រទីផ្សារ ដូចជា 4P និង 7P ជាដើម។

# ឯកសារយោង

# ឯកសារយោង


1. សៀវភៅ "សេដ្ឋកិច្ចអភិវឌ្ឍន៍", រៀបរៀងដោយបណ្ឌិត ជ្រឹង ហៃ និងបណ្ឌិត ទិន ហេង, បោះពុម្ពនៅថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៧
2. មេរៀនក្នុងសៀវភៅ "អភិវឌ្ឍន៍ជនបទ " របស់សាស្ត្រាចារ្យបណ្ឌិត ឈុន ពហុ ឆ្នាំសិក្សា ២០១៧-២០១៨
3. មេរៀនក្នុងសៀវភៅ "សេដ្ឋកិច្ចកសិកម្ម" របស់សាស្ត្រាចារ្យបណ្ឌិត ឈុន ពហុ សិក្សា ២០១៦-២០១៧
4. សៀវភៅ "សេដ្ឋកិច្ចសហគ្រាស" រៀបរៀងដោយសាស្ត្រាចារ្យ ស សុភាព, បោះពុម្ព លើកទី១ ឆ្នាំ ២០១៣
5. សៀវភៅ "ការអភិវឌ្ឍជនបទ" របស់សាស្ត្រាចារ្យ ព្រំ ទេវី, សាកលវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំ ២០០៥
6. Prof. Dr. DUY CHANDINA, *"Economic Development"*, Academic year 2013-2014
7. សារណាបញ្ចប់ការសិក្សា "ការចូលរួមរបស់សហគ្រាសធុនតូច និងមធ្យមក្នុងការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា" របស់និស្សិត ពេជ្រ សម្បត្តិ និងជួរ ចន្ទារី ឆ្នាំសរសេរ ២០១២
8. សារណាបញ្ចប់ការសិក្សា "ការអភិវឌ្ឍអគ្គិសនីភាវូបនីយកម្មជនបទដើម្បីកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ករណីភូមិព្រែកកែវ" របស់និស្សិត តឹក ហង្សនិតា និង ទូច ម៉េងឡេង ឆ្នាំសរសេរ ២០១៤
9. សារណាបញ្ចប់ការសិក្សា "វិស័យកសិកម្ម និងការអភិវឌ្ឍ" របស់និស្សិត កង តារ៉ាវុធ និង ពូក សុភាព ឆ្នាំសរសេរ ២០១២
10. Rostow's stage of Growth ដកស្រង់ចេញពីសៀវភៅ *Micheal P.Todaro Economic Development, Eight Edition*
11. មេរៀនក្នុងមុខវិជ្ជា "កំណើនសេដ្ឋកិច្ច" របស់សាស្ត្រាចារ្យ ហាស់ វង់ដារ៉ា
12. សៀវភៅ "គោលការណ៍ មីក្រូសេដ្ឋកិច្ច" រៀបចំឡើងដោយសាស្ត្រាចារ្យ ទៀប សារ៉ាឌី និងសាស្ត្រាចារ្យ ទូន ផល្លា
13. ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨
14. សៀវភៅ "តើអ្វីជាការជំរុញចលនាភូមិ១ផលិតផល១?" និពន្ធដោយ ហាស់ វង់ដារ៉ា ឆ្នាំ២០១៦

15. បទបង្ហាញ "កម្ពុជា អតីតកាល បច្ចុប្បន្ន និងអនាគត", បង្ហាញដោយ ឯកឧត្តម វង្សី វិស្សុត រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាអនុប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ, ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១៧
16. សៀវភៅ "យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី ៣" របស់រាជរដ្ឋាភិបាលនីតិកាលទី ៥ នៃរដ្ឋសភា, រាជធានីភ្នំពេញ ខែកញ្ញា ឆ្នាំ ២០១៣
17. Cheam Phan Viriya. *NGOs Approach to Community Development in Rural Cambodia*. (October 2004). *CICP Working Paper, No 30*. Retrieved on May 27, 2018, from http://www.cicp.org.kh/userfiles/file/Working%20Paper/CICP%20Working%20Paper%20No%2030_NGOs%20Approach%20to%20Community%20Development%20in%20Rural%20Cambodia.pdf
18. បទសម្ភាសន៍ផ្ទាល់ពីលោកយាយជីនៅក្នុងវត្តប្រាសាទ និងលោកមេភូមិជ្រលងនៃឃុំប្រាសាទ, ថ្ងៃទី៩ ខែ មេសា ឆ្នាំ ២០១៨
19. ឯកសារ "កម្មវិធីវិនិយោគឃុំឆ្នាំ ២០១៧ ឃុំប្រាសាទ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង" ខែមករា ឆ្នាំ២០១៧
20. របាយការណ៍បូកសរុបវាយតម្លៃការអនុវត្តកម្មវិធីនយោបាយរបស់គណបក្សក្នុងការអភិវឌ្ឍឃុំប្រាសាទឆ្នាំ ២០១២-២០១៧
21. គោលនយោបាយរបស់គណបក្សសម្រាប់អភិវឌ្ឍន៍ឃុំប្រាសាទពីឆ្នាំ ២០១៧-២០២២, ថ្ងៃទី ០១ ខែមករា ឆ្នាំ ២០១៧
22. ឯកសារ "ផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ (២០១៧-២០២១) ឃុំប្រាសាទ", ឆ្នាំ២០១៧
23. ឯកសារពីឃុំ "ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ" របស់ក្រសួងមហាផ្ទៃ, ខែកក្កដា ឆ្នាំ២០១៧
24. ឯកសារ "កម្មវិធីវិនិយោគបីឆ្នាំរំកិល (២០១៨-២០២០) ឃុំប្រាសាទស្រុកកំពង់ត្របែក ខេត្តព្រៃវែង"
25. National Institute of Statistics, Ministry of Planning. *Cambodia Socio-Economic Survey 2016.* (Phnom Penh, October 2017). Retrieved on June 09, 2018, from https://www.nis.gov.kh/nis/CSES/Final%20Report%20CSES%202016.pdf
26. សៀវភៅ "សេដ្ឋកិច្ចកម្ពុជា" ដឹកនាំដោយសាស្ត្រាចារ្យ ថៅ សុខមុនី ឆ្នាំ ២០០៧

27. Open Development Cambodia. (2016, April 06). *Agricultural Production*. Retrieved on June 18, 2018, from *https://opendevelopmentcambodia.net/topics/agricultural-production/*

28. Ministry of Economy and Finance. (June 16, 2017). *Recent Macro-economic Indicators (GDP Growth Rate).* Retrieved on June 18, 2018, from *http://www.mef.gov.kh/*

# ឧបសម្ព័ន្ធទី ១

# ឧបសម្ព័ន្ធទី ១ ៖ ផែនទីខេត្តព្រៃវែង



# ឧបសម្ព័ន្ធទី ២

# ផែនទីឃុំប្រាសាទ


ជើង
ឃុំកន្ទ្រាំងអរក
ឃុំព្រៃឈរ
ឃុំតាំងក្រសាំង
ឃុំអន្ទ្រាង
ភូមិភ្នង
បុស្ដិ៍រដ្ឋបាល
វត្តសេរីសង្គម
ភូមិជួនខុង
សាលាឃុំ
បឋម. សេរីសង្គម
ភូមិផ្លូវ
ភូមិបី
វត្តប្រាសាទ
ភូមិប្រាសាទ
បឋម. វត្តប្រាសាទ
មន្ទីរពេទ្យបង្អែក ស្រុកកំពង់ត្របែក
ផ្សារកអណ្ដើក
កំពង់ត្របែក
បឋម. ប្រាសាទ
វត្តកស្សបៈ
វត្តអំពិល
បឋម. អំពិល
ស្ថានីយ៍ប្រេងឥន្ធនៈ
ភូមិចំបក់
ភូមិពាន់វត្ត
ភូមិអំពិល
ភូមិជ្រលង
កំណត់សំគាល់
ស្ពាន
ប្រឡាយទឹក
វត្ត
មន្ទីរពេទ្យ
ព្រំប្រទល់ឃុំ
ផ្លូវលំ
ផ្សារ
សាលារៀន
ផ្លូវជាតិលេខ ១
ភូមិ
សាលាឃុំ
បុស្ដិ៍រដ្ឋបាល
តំបន់ឆ្លងកាត់
មុខសញ្ញាលួច
មុខសញ្ញាសង្ស័យ
មុខសញ្ញាដោះលែង

# ឧបសម្ព័ន្ធទី ៣

**ចក្ខុវិស័យ៖** ប្រជាពលរដ្ឋ ឃុំប្រាសាទ ស្រុកកំពង់ត្របែក មានសុខមាលភាពល្អ ចំណូលកើនឡើង មានប្រព័ន្ធគមនាគមន៍ ធារាសាស្ត្រ ហើយរ
នៅក្នុងបរិស្ថានល្អ និងប្រកបដោយសុខសន្តិភាព ។

| គោលបំណង និងគោលដៅ | សូចនាករ | | | | យុទ្ធសាស្ត្រអភិវឌ្ឍន៍ |
|---|---|---|---|---|---|
| | ការបរិយាយ | ឯកតា | ដើមគ្រា | ២០២២ | |
| **១.ផ្នែកសេដ្ឋកិច្ច** | | | | | |
| ១.១. គោលបំណងទី១៖ ប្រជាពលរដ្ឋមានផ្លូវល្អសម្រាប់ធ្វើដំណើរ និងដឹកជញ្ជូនផលិតផល មានទឹកស្រោចស្រពដីកសិកម្មគ្រប់គ្រាន់ ទិន្នផលស្រូវកើនឡើង ធានាបានសន្តិសុខស្បៀង និងយល់ដឹងពីបច្ចេកទេសកសិកម្ម បច្ចេកទេសចិញ្ចឹមសត្វ ដើម្បីបង្កើនប្រាក់ចំណូល ។ | | | | | |
| ១.១.១. គោលដៅទី១៖ នៅបំណាច់ឆ្នាំ ២០២២ ផ្លូវលំដែលខូចខាតត្រូវបានជួសជុលបានល្អប្រសើរឡើងវិញ | ប្រជាពលរដ្ឋមានផ្លូវល្អសម្រាប់ធ្វើដំណើរ ប្រវែង ២៥ គីឡូម៉ែត្រ | គ.ម<br>គ.ម<br>គ.ម<br>គណៈកម្មការ<br>កន្លែង | ៥<br>៥<br>៣<br>១<br>៣ | ២៥<br>២៥<br>១៥<br>៥<br>១៥ | • ជួសជុលផ្លូវលំ ក្រាលខ្សាច់ក្រួស<br>• ជួសជុលផ្លូវលំដីស<br>• ថែទាំផ្លូវក្រាលខ្សាច់<br>• បង្កើតគណៈកម្មការថែទាំផ្លូវ<br>• ដាក់លូកាត់ផ្លូវ |
| ១.១.២.គោលដៅទី២៖ កសិករមានទឹកស្រោចស្រពដំណាំកសិកម្មគ្រប់គ្រាន់ | ប្រព័ន្ធធារាសាស្ត្រត្រូវជួសជុល ប្រវែង ១៥ គ.ម | គ.ម<br>ម៉ាស៊ីន | ៣<br>២ | ១៥<br>១០ | • ស្តារប្រឡាយស្រោចស្រព<br>• ផ្តល់ម៉ាស៊ីនបូមទឹក |

| គោលបំណង និងគោលដៅ | សូចនាករ | | | | យុទ្ធសាស្ត្រអភិវឌ្ឍន៍ |
|---|---|---|---|---|---|
| | ការពិពណ៌នា | ឯកតា | ដើមគ្រា | ២០២២ | |
| ១.១.៣.គោលដៅទី៣៖ បង្កើនទិន្នផលស្រូវ និងការចិញ្ចឹមសត្វ ដើម្បីបង្កើនប្រាក់ចំណូល | ទិន្នផលកើនឡើងពី ៣,៥ តោន ទៅ ៥ តោន/១ហិកតា និងជម្រុញការចិញ្ចឹមសត្វ | វគ្គ | ២ | ១០ | • បណ្តុះបណ្តាលបច្ចេកទេសដំណាំស្រូវ |
| | | តោន | ១,៥ | ៧,៥ | • ផ្តល់ពូជស្រូវទិន្នផលខ្ពស់ |
| | | វគ្គ | ២ | ១០ | • បណ្តុះបណ្តាលបច្ចេកទេសប្រើប្រាស់ជីគីមី និងថ្នាំសម្លាប់សត្វល្អិត |
| | | វគ្គ | ២ | ១០ | • បណ្តុះបណ្តាលបច្ចេកទេសផលិតជីកំប៉ុស្ត៍ |
| | | វគ្គ | ២ | ១០ | • បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វ |
| | | លើក | ១ | ៥ | • ផ្តល់វ៉ាក់សាំងការពារជម្ងឺសត្វ |
| | | វគ្គ | ១ | ៥ | • ពង្រឹងសមត្ថភាពពេទ្យសត្វភូមិ |
| | | ក្បាល | ៨០ | ៤០០ | • ផ្តល់ពូជសត្វល្អសម្រាប់ចិញ្ចឹម |
| | | វគ្គ | ២ | ១០ | • បណ្តុះបណ្តាលវិជ្ជាជីវៈផ្សេងៗ |
| | | ក្បាល | ៨០០ | ៤០.០០០ | • ផ្តល់ពូជត្រីចិញ្ចឹម |
| | | វគ្គ | ២ | ១០ | • វគ្គស្រែបង្ហាញដំណាំស្រូវ និងបង្ហាញចម្រុះ |
| | | កន្លែង | ២ | ១០ | • សាងសង់ឡជីវឧស្ម័ន |
| | | កន្លែង | ៥ | ២៥ | • ជីកស្រះចិញ្ចឹមត្រីលក្ខណៈគ្រួសារ |
| | | លើក | ៩ | ៤៥ | • ផ្សព្វផ្សាយពីការប្រើប្រាស់ឥណទាន |
| | | វគ្គ | ២ | ១០ | • បណ្តុះបណ្តាលបច្ចេកទេសដំណាំបន្លែ |

## ២.ផ្នែកសង្គមកិច្ច

២.១.គោលបំណងវិស័យអប់រំ៖ ប្រជាពលរដ្ឋមានចំណេះដឹង និងសមត្ថភាព រួមចំណែកយ៉ាងសំខាន់ក្នុងការងារសង្គម ។

| គោលបំណង និងគោលដៅ | សូចនាករ<br>ការបរិយាយ | ឯកតា | ដើមគ្រា | ២០២២ | យុទ្ធសាស្ត្រអភិវឌ្ឍន៍ |
|---|---|---|---|---|---|
| ២.១.១.គោលដៅទី១៖ កុមារអាយុពី ០៣ទៅ ០៥ ឆ្នាំ បានចូលរៀនគ្រប់គ្នា | បើកថ្នាក់មត្តេយ្យបន្ថែម ៨ ថ្នាក់ | ថ្នាក់<br>កំប្លេ<br>នាក់ | ១<br>៩<br>១ | ៦<br>៤៥<br>៩ | • បើកថ្នាក់មត្តេយ្យសហគមន៍<br>• ផ្តល់សម្ភារៈថ្នាក់មត្តេយ្យ<br>• ផ្តល់គ្រូមត្តេយ្យ |
| ២.១.២.គោលដៅទី២៖ ជំរុញក្មេងគ្រប់អាយុចាប់ពីអាយុ ០៦ទៅ ១១ឆ្នាំ ឲ្យបានចូលរៀនគ្រប់ៗគ្នា | ជំរុញកុមារដល់អាយុអោយចូលរៀនបាន១០០%<br>សិស្សក្រីក្រ១ឆ្នាំ១២០នាក់ | %<br>នាក់<br>អគារ<br>នាក់ | ៩៣<br>១២០<br>១<br>៥៥០ | ១០០<br>៦០០<br>២<br>២,៧៥០ | • ជម្រុញឪពុកម្តាយនាំកូនចូលរៀន<br>• ផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រ<br>• សាងសង់អគារសិក្សា<br>• ផ្តល់អាហារពេលព្រឹក |
| **២.២. គោលបំណងវិស័យសុខាភិបាល៖** ប្រជាពលរដ្ឋមានសុខភាពល្អ យល់ដឹងពីសុខភាពអនាម័យ ជាពិសេសអត្រាមរណៈភាពមាតា និងទារកត្រូវបានលុបបំបាត់ ។ | | | | | |
| ២.២.១.គោលដៅទី១៖ ប្រជាពលរដ្ឋមានសុខភាពល្អ និងរស់នៅប្រកបដោយផាសុខភាព | ប្រជាពលរដ្ឋយល់ដឹងពីការថែទាំសុខភាព និងរស់នៅប្រកបដោយអនាម័យ | បង្គន់<br>អណ្តូង<br>ធុង<br>នាក់<br>លើក<br>លើក<br>លើក<br>លើក | ២៤០<br>១០<br>១៦០<br>៨០<br>៩<br>៩<br>៩<br>៩ | ១២០០<br>៥០<br>៨០០<br>៤០០<br>៤៥<br>៤៥<br>៤៥<br>៤៥ | • សង់បង្គន់អានាម័យតាមខ្នងផ្ទះ<br>• ជីកអណ្តូងទឹកស្អាត<br>• ផ្តល់ធុងចម្រោះទឹកស្អាត<br>• ផ្តល់អាហារូបត្ថម្ភ<br>• ផ្សព្វផ្សាយពីសុខភាពអនាម័យ<br>• ផ្សព្វផ្សាយពីសុខភាពបន្តពូជ<br>• ផ្តល់ការពិនិត្យទឹកអណ្តូងរកជាតិអាសេនិច<br>• ផ្សព្វផ្សាយពីការបរិភោគទឹកមានសុវត្ថិភាព |
| ២.២.២. គោលដៅទី២៖ កាត់បន្ថយការឈឺ និងស្លាប់របស់មាតាទារក និងកុមារ | អត្រាឈឺ និងស្លាប់ មាតាទារកត្រូវបានលុបបំបាត់ | វគ្គ<br>លើក | ១<br>៩ | ៥<br>៤៥ | • បណ្តុះបណ្តាលសមត្ថភាពឆ្មប<br>• ផ្សព្វផ្សាយពីសារៈប្រយោជន៍ការពិនិត្យផ្ទៃពោះនៅមណ្ឌលសុខភាព |

| គោលបំណង និងគោលដៅ | សូចនាករ | | | | យុទ្ធសាស្ត្រអនុវត្តន៍ |
|---|---|---|---|---|---|
| | ការបរិយាយ | ឯកតា | ដើមគ្រា | ២០២២ | |
| | | លើក | ៩ | ៤៥ | • ជំរុញអ្នកមានផ្ទៃពោះមកទទួលសេវានៅមណ្ឌលសុខភាព |
| | | លើក | ២ | ១០ | • ផ្តល់អាហារូបត្ថម្ភដល់ស្ត្រីមានផ្ទៃពោះ |
| ២.២.៣.គោលដៅទី៣៖ កាត់បន្ថយអត្រាឈឺ និងស្លាប់ដោយសារជម្ងឺអេដស៍ | កាត់បន្ថយការរីករាលដាលនៃមេរោគអេដស៍ជម្ងឺអេដស៍ | លើក | ៩ | ៤៥ | • អប់រំនិងផ្សព្វផ្សាយពីការឆ្លងនៃជម្ងឺអេដស៍ |
| | | លើក | ១ | ៥ | • ផ្តល់ការគាំទ្រអ្នក ផ្ទុក និងអ្នកជម្ងឺអេដស៍ |
| **២.៣.គោលបំណងវិស័យសង្គមកិច្ច៖** បង្កើនប្រសិទ្ធិភាព ការផ្តល់សេវាសុខាភិបាល ដើម្បីរក្សាសុខមាលភាពប្រជាពលរដ្ឋ និងបង្កើនការយកចិត្តទុកដាក់ក្រុមជនងាយរងគ្រោះ កុមារកំព្រា ជនពិការ ស្ត្រីមេម៉ាយ និងការរំលោភបំពានផ្សេងៗ និងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ។ | | | | | |
| ២.៣.១.គោលដៅទី១៖ ជនរងគ្រោះ និងក្រុមងាយរងគ្រោះ ត្រូវបានយកចិត្តទុកដាក់ ហើយប្រជាពលរដ្ឋចំណាកស្រុកប្រកបដោយសុវត្ថិភាព | ក្រុមជនងាយរងគ្រោះត្រូវបានកាត់បន្ថយ និងជម្រុញការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋពីចំណាកស្រុក | គ្រឿង | ៥ | ២៥ | • ឈើច្រត់ រទេះរុញ ជើងសិប្បនិម្មិត្ត |
| | | វគ្គ | ១ | ៥ | • បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈសម្រាប់ជនពិការ |
| | | លើក | ៩ | ៤៥ | • ផ្សព្វផ្សាយពីច្បាប់ចរាចរផ្លូវគោក |
| | | លើក | ១ | ៥ | • បញ្ជូនកុមារកំព្រា ចាស់ជរាគ្មានទីពឹងទៅមណ្ឌល |
| | | លើក | ៩ | ៤៥ | • ផ្សព្វផ្សាយពីច្បាប់ប្រឆាំងការជួញដូរស្រ្តីនិងកុមារ |
| | | លើក | ៩ | ៤៥ | • ផ្សព្វផ្សាយពីល្បិចកលឆបោករបស់ជនល្មើស |
| | | លើក | ៩ | ៤៥ | • ផ្សព្វផ្សាយពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព |

| គោលបំណង និងគោលដៅ | សូចនាករ | | | | យុទ្ធសាស្ត្រអភិវឌ្ឍន៍ |
|---|---|---|---|---|---|
| | ការបរិយាយ | ឯកតា | ដើមគ្រា | ២០២២ | |
| **២.៨.គោលបំណងវិស័យយេនឌ័រ៖ កាត់បន្ថយអំពើ ហិង្សាក្នុងគ្រួសារ ។** | | | | | |
| ២.៨.១.គោលដៅទី១៖ លើកកម្ពស់ការយល់ដឹងពីច្បាប់ទប់ស្កាត់អំពើ ហិង្សាក្នុងគ្រួសារ | ប្រជាពលរដ្ឋយល់ដឹងពីច្បាប់ទប់ស្កាត់អំពើ ហិង្សាក្នុងគ្រួសារ | លើក<br>លើក<br>វគ្គ | ៩<br>៩<br>២ | ៤៥<br>៤៥<br>១០ | • ផ្សព្វផ្សាយច្បាប់សិទ្ធិមនុស្ស<br>• ផ្សព្វផ្សាយពីច្បាប់ទប់ស្កាត់អំពើ ហិង្សាក្នុងគ្រួសារ<br>• បណ្តុះបណ្តាលពីយេនឌ័រ |
| **៣.ផ្នែកធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនិងការប្រែប្រួលអាកាសធាតុ** | | | | | |
| ៣.១.គោលបំណងវិស័យធនធានធម្មជាតិ បរិស្ថាន៖ ប្រជាពលរដ្ឋមានការយល់ដឹងពីបំរែបំរួលអាកាសធាតុ ការការពារបរិស្ថាន កាត់បន្ថយជាតិពុល ដើម្បីបង្កើតត្រីធម្មជាតិ និងជីវៈចម្រុះ ។ | | | | | |
| ៣.១.១.គោលដៅទី១៖ លុបបំបាត់ការនេសាទដោយប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ | បង្កើនពូជត្រីធម្មជាតិតាមរយៈការលើកកម្ពស់ការយល់ដឹងពីច្បាប់ជលផល | លើក<br>កន្លែង<br>ក្បាល<br>លើក | ១១<br>១<br>២.១០០<br>៩ | ៥៥<br>១<br>២.១០០<br>៤៥ | • ផ្សព្វផ្សាយច្បាប់ជនផល<br>• ស្តារបឹងធម្មជាតិ<br>• ផ្តល់ពូជត្រីធម្មជាតិ<br>• ផ្សព្វផ្សាយពង្រឹងសកម្មភាពសហគមន៍នេសាទ |
| ៣.២.គោលបំណងវិស័យការបន្សាំនិងការប្រែប្រួលអាកាសធាតុ៖ប្រជាជនដែលរងគ្រោះដោយគ្រោះមហន្តរាយទទួលបានសេវាសង្គ្រោះបន្ទាន់និងការឆ្លើយតប ភ្លាមៗ និងបន្សាំ ទៅនឹងអាកាសធាតុ ។ | | | | | |
| ៣.២.១.គោលដៅទី២៖បង្កើនការយល់ដឹងដល់ប្រជាជនពីហានិភ័យគ្រោះមហន្តរាយនិងការប្រែប្រួលអាកាសធាតុ | នៅបំណាច់ឆ្នាំ២០២២ប្រជាពលរដ្ឋយល់ដឹងពីការប្រែប្រួលអាកាសធាតុ | លើក<br>លើក | ៩<br>៩ | ៤៥<br>៤៥ | • ផ្សព្វផ្សាយពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ<br>• ផ្សព្វផ្សាយពីវិធីត្រៀមបង្ការគ្រោះមហន្តរាយនៃការប្រែប្រួលអាកាសធាតុ |
| **៤.ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ** | | | | | |

| | ការបរិយាយ | ឯកតា | ដើមគ្រា | ២០២២ | យុទ្ធសាស្ត្រអនុវត្ត |
|---|---|---|---|---|---|
| **៤.១.គោលបំណងវិស័យរដ្ឋបាល៖ បង្កើនការបម្រើសេវាសាធារណៈដល់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន ភូមិ ឃុំ ឲ្យបានកាន់តែមានប្រសិទ្ធិភាព ។** | | | | | |
| ៤.១.១.គោលដៅទី១៖ ប្រជាពលរដ្ឋនឹងទទួលបានឯកសារអត្រានុកូលដ្ឋានគ្រប់ៗគ្នា | បង្កើនការយល់ដឹងពីសារៈប្រយោជន៍នៃការឯកសារអត្រានុកូលដ្ឋានតាមរយៈការផ្សព្វផ្សាយ | លើក | ៩ | ៤៥ | • ផ្សព្វផ្សាយពីសារៈប្រយោជន៍នៃការចុះបញ្ជីអត្រានុកូលដ្ឋាន |
| ៤.១.២.គោលដៅទី២៖ក្រុមប្រឹក្សាឃុំ និងថ្នាក់ដឹកនាំភូមិជាស្ត្រីមានសមត្ថភាពគ្រប់គ្រាន់ក្នុងការអនុវត្តតួនាទីភារកិច្ចក្នុងការផ្តល់សេវារដ្ឋបាលដល់ប្រជាជន | បង្កើនសមត្ថភាពស្ត្រីតាមរយៈការបណ្តុះបណ្តាល | វគ្គ | ១ | ៥ | • បណ្តុះបណ្តាលភាពជាអ្នកដឹកនាំដល់ស្ត្រី |
| **៤.២.គោលបំណងវិស័យសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ៖ ប្រជាពលរដ្ឋរស់នៅ ប្រកបដោយសុវត្ថិភាពនិងភាពសុខសាន្តនៅក្នុងសង្គម ។** | | | | | |
| ៤.២.១.គោលដៅទី២៖កាត់បន្ថយទំនាស់ដីធ្លីរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន | បង្កើនការយល់ប្រជាពលរដ្ឋតាមរយៈការផ្សព្វផ្សាយ | លើក | ៩ | ៤៥ | • ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋអំពី ច្បាប់និងខិតបទដ្ឋានពាក់ព័ន្ធនឹងវិស័យដីធ្លី |
| ៤.២.២.គោលដៅទី៣៖ អនុវត្តច្បាប់ដើម្បីរក្សាសន្តិសុខសង្គម | បង្កើនការយល់ដល់ប្រជាពលរដ្ឋស្តីពីការអនុវត្តច្បាប់តាមរយៈការផ្សព្វផ្សាយជាប្រចាំ | លើក<br>លើក<br>លើក | ៩<br>៩<br>៩ | ៤៥<br>៤៥<br>៤៥ | • ជម្រុញអនុវត្តគោលនយោបាយភូមិឃុំមានសុវត្ថិភាព<br>• ផ្សព្វផ្សាយពីសារៈប្រយោជន៍ការរាយកាណ៍ជនមុខសញ្ញា<br>• ផ្សព្វផ្សាយជម្រុញសកម្មភាពក្រុមប្រជាការពារ |

# ឧបសម្ព័ន្ធទី ៤

## ១.១ ព័ត៌មាននៃសកម្មភាពដែលបានអនុវត្តក្នុងឆ្នាំ ២០១៦

| ល.រ | ឈ្មោះគម្រោងឬសកម្មភាព | ទីតាំងអនុវត្ត | លទ្ធផល | | ចំនួនថវិកា | អ្នកទទួលផល | | ប្រភពអ្នកគាំទ្រ |
|---|---|---|---|---|---|---|---|---|
| | | | ចំនួន | ឯកតា | | សរុប | ស្រី | |
| ក/ ផ្នែកហេដ្ឋារចនាសម្ព័ន្ធរូបវន្ត | | | | | | | | |
| ១ | ជួសជុលផ្លូវលំដីក្រាលខ្សាច់ភ្នំ | ០១,០៦,០៨ | ២.៤៨០ | ម | ៦៩.០៣២.៧០០៛ | ៥.៧៦៣ | ២.៩៨០ | មូលនិធិឃុំ២០១៦ |
| ខ/ ផ្នែកហេដ្ឋារចនាសម្ព័ន្ធអរូបវន្ត | | | | | | | | |
| ១ | ចុះផ្តល់សេវានៅមូលដ្ឋាន | គ្រប់ភូមិ | ២១៦ | លើក | ៣.៤៥៦.០០០៛ | ២១៦ | ១០ | ការិ.សុខាភិបាល |
| ២ | យុទ្ធនាការដាក់ថ្នាំអាបែតនៅតាមពាង និងអាងទឹក | គ្រប់ភូមិ | ១៨ | លើក | ៥១៦.០០០៛ | ១៨ | ៧ | ការិ.សុខាភិបាល |
| ៣ | ចុះអប់រំផ្សព្វផ្សាយជម្ងឺគ្រុនឈាមដល់ប្រជាជននៅតាមសហគមន៍ | គ្រប់ភូមិ | ៤ | លើក | ២.០៦៤.០០០៛ | ៨ | ៦ | ការិ.សុខាភិបាល |
| ៤ | សេវាឥណទាន | គ្រប់ភូមិ | ១ | ឆ្នាំ | មិនកំណត់ | | | ACLIDA,នីរន្ត,វីស៊ិនហ្វាន់,ស្ថាបនា,មហានគរ,LOPC,អម្រឹត, |
| ៥ | សេវាដាក់ប្រាក់បញ្ញើ សន្សំ | គ្រប់ភូមិ | ១ | ឆ្នាំ | មិនកំណត់ | | | អេស៊ីលីដា |
| ៦ | សេវាផ្ទេរប្រាក់ | គ្រប់ភូមិ | ១ | ឆ្នាំ | មិនកំណត់ | | | អេស៊ីលីដា |
| ៧ | សេវាចាត់ចែងសាច់ប្រាក់ | គ្រប់ភូមិ | ១ | ឆ្នាំ | មិនកំណត់ | | | អេស៊ីលីដា |
| ៨ | សេវាធានារ៉ាប់រងអាយុជីវិត | គ្រប់ភូមិ | ១ | ឆ្នាំ | មិនកំណត់ | | | អេស៊ីលីដា |
| ៩ | សេវាអេឡិចត្រូនិច | គ្រប់ភូមិ | ១ | ឆ្នាំ | មិនកំណត់ | | | អេស៊ីលីដា |
| ១០ | កម្មវិធីបង់ការ ការថែទាំជម្ងឺអេដស៍តាមសហគមន៍ | គ្រប់ភូមិ | ១២ | ខែ | | ១៩ | ១៣ | វ័រមែន |
| ១១ | ផ្នែកកុមារគេបោះបង់ចោល | ភូមិចំបក់ | | | | ១២ | ២ | អង្គការកុមារ |
| ១២ | ជួយក្មេងដែលឪពុកធ្វើចំណាកស្រុក ឬក្រដែលជាប់ចំណាត់ថ្នាក់មានប្រាក់ជួយដល់ក្មេងរៀនក្នុង១នាក់ ៦០.០០០ ៛ | | | | | | | អង្គការកុមារ |

# ឧបសម្ព័ន្ធទី ៥

# តារាង ២.៣ គម្រោង សកម្មភាពវិនិយោគឃុំដែលមានថវិកាគាំទ្រ

| ល.រ | ឈ្មោះគម្រោង | ទីតាំងគម្រោង | លទ្ធផលគម្រោង | | រយៈពេលអនុវត្ត | តម្លៃគម្រោង | ប្រភពមូលនិធិ | កំរិតទុនវិនិយោគ(លានរៀល) | | | | អង្គភាពអនុវត្ត | កំណត់សម្គាល់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | បរិមាណ | ឯកតា | | | | 2018 | 20 | 20 | សរុប | | |
| គម្រោង សកម្មភាពប្រើប្រាស់មូលនិធិឃុំ | | | | | | | | | | | | | |
| ១. ផ្នែកសេដ្ឋកិច្ច | | | | | | | | | | | | | |
| ១ | ជួសជុលផ្លូវលំដីស | អំពិល | ២,៦ | គ.ម | ១ខែ | ៩៦.២០0.000 | មូលនិធិឃុំ | ៩៦,២ | | | ៩៦,២ | ឃុំ | |
| ២ | សាងសង់លូកាត់ផ្លូវ | អំពិល | ៣ | កន្លែង | ១ខែ | ១៣.៥00.000 | មូលនិធិឃុំ | ១៣,៥ | | | ១៣,៥ | ឃុំ | |
| គម្រោង សកម្មភាពដែលទទួលបានការគាំទ្រពីផ្នែក អ្នកពាក់ព័ន្ធ | | | | | | | | | | | | | |
| ១ | ថែទាំផ្លូវជាប្រចាំ(DBST) | ចំបក់ | ១,២ | គ.ម | | ១២ | | ១២ | | | | មន្ទីរអភិ | |
| ២ | ការអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គម | ឃុំ | | | | $1800 | JSDF WB | | | | | | |
| ៣ | កម្មវិធីផ្តល់ការថែទាំគាំទ្រដល់អ្នកជំងឺអេដស៍និងអ្នកផ្ទុករោគអេដស៍ | ឃុំ | | | | 7,690,000 | NCHAD | | | | | | |
| ៤ | សេវាឥណទាន | | | | | | ACLEDA | | | | | | |
| ៥ | សេវាបញ្ញើ-សន្សំ | | | | | | ACLEDA | | | | | | |
| ៦ | សេវាផ្ទេរប្រាក់ | | | | | | ACLEDA | | | | | | |
| ៨ | សេវាធនាគារអេឡិចត្រូនិក | | មិនកំណត់ | | | | ACLEDA | | | | | | |

| ល.រ | ឈ្មោះគម្រោង | ទីតាំងគម្រោង | លទ្ធផលគម្រោង | | រយៈពេលអនុវត្ត | តម្លៃគម្រោង | ប្រភពមូលនិធិ | កំរិតទុនវិនិយោគ(លានរៀល) | | | | អង្គភាពអនុវត្ត | កំណត់សម្គាល់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | បរិមាណ | ឯកតា | | | | 2018 | 20 | 20 | សរុប | | |
| ៩ | សេវាចាត់ចែងសាច់ប្រាក់ | | មិនកំណត់ | | | | ACLEDA | | | | | | |
| ១០ | សេវាហិរញ្ញប្បទានពាណិជ្ជកម្ម | | មិនកំណត់ | | | | ACLEDA | | | | | | |
| ១១ | សេវាធានារ៉ាប់រងអាយុជីវិត | | មិនកំណត់ | | | | ACLEDA | | | | | | |
| ១២ | សេវាភតិសន្យាហិរញ្ញវត្ថុ | | មិនកំណត់ | | | | ACLEDA | | | | | | |
| ១៣ | ឥណទានសាច់ប្រាក់ | LOLC | | | 12ខែ | ៥00.000.000 | LOLC | | | | | | ១៨០/១៥០ |
| ១៤ | ឥណទានសាច់ប្រាក់ | គ្រប់ភូមិ | | | 12ខែ | $1.200.000 | ប្រាសាក់ | | | | | | 350/300 |

# ឧបសម្ព័ន្ធទី ៦

[illegible]

| ល.រ | ឈ្មោះគម្រោងសកម្មភាព | ទីតាំង | លទ្ធផល | | រយៈពេល | អ្នកទទួលផល | | តម្លៃប៉ាន់ស្មាន | ប្រភពមូលនិធិ |
|---|---|---|---|---|---|---|---|---|---|
| | | | បរិមាណ | ឯកតា | | សរុប | ស្រី | | |
| **១.ផ្នែកសេដ្ឋកិច្ច** | | | | | | | | | |
| ១ | ជួសជុលផ្លូវលំដីស | ០១.០២.០៤<br>០៥.០៧.០៩ | ៦,៦ | គីឡូម៉ែត្រ | ១ខែ | ១០,៦៥៨ | ៥,២២៩ | ១៥៨,៤០០,០០០ | |
| ២ | ជួសជុលផ្លូវលំក្រាលខ្សាច់ក្រហម | ០១.០២.០៣.០៤<br>០៥.០៧.០៩ | ៧,៦ | គីឡូម៉ែត្រ | ១,៥ខែ | ១០,៦៥៨ | ៥,២២៩ | ២០១,៤០០,០០០ | |
| ៣ | ដាក់លូកាត់ផ្លូវ | ០១.០២.០៤<br>០៥.០៩ | ១១ | កន្លែង | ២សប្តាហ៍ | ៩,៧៨៧ | ៤,៨៤៣ | ៧៧,០០០,០០០ | |
| ៤ | ស្តារប្រឡាយស្រោចស្រព | ០១.០៣.០៤.០៥<br>០៦.០៧.០៩ | ១០ | គីឡូម៉ែត្រ | ២ខែ | ៩,៧៨៧ | ៤,៨៤៣ | ១៨០,០០០,០០០ | |
| ៥ | បណ្តុះបណ្តាលបច្ចេកទេសដំណាំស្រូវ | ឃុំ | ២ | វគ្គ | ៤ថ្ងៃ | ៩០ | ៣២ | ៤,០០០,០០០ | |
| ៦ | បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វ | ឃុំ | ២ | វគ្គ | ៤ថ្ងៃ | ៩០ | ៤៥ | ៤,០០០,០០០ | |
| ៧ | ផ្តល់ពូជបន្លែគ្រប់មុខ | គ្រប់ភូមិ | ១៣៥ | កញ្ចប់ | ១សប្តាហ៍ | ៦៧៥ | ៣៤០ | ២,៧០០,០០០ | |
| ៨ | ឥណទានការប្រាក់ទាប | គ្រប់ភូមិ | ៣៥០ | គ្រួសារ | ១២ខែ | ១,៧៥០ | ៨៨០ | ១៤០,០០០,០០០ | |
| **២.ផ្នែកសង្គមកិច្ច** | | | | | | | | | |
| ១ | បើកថ្នាក់មត្តេយ្យសហគមន៍ | ០១.០២.០៤.០៧<br>០៨.០៩ | ៦ | ថ្នាក់ | ៣ខែ | ១៥០ | ៨០ | ១២,០០០,០០០ | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ២ | ថ្នាក់មត្តេយ្យសិក្សាសហគមន៍ | គ្រប់ភូមិ | ៩ | លើក | ១ខែ | ១៣០៧៨ | ៦៥២៧ | ៣,៦០០,០០០ | |
| ៣ | ផ្តល់សម្ភារៈថ្នាក់មត្តេយ្យ | គ្រប់ភូមិ | ៩ | កំប្លេ | ១សប្តាហ៍ | ២២៥ | ១៩០ | ៣,៦០០,០០០ | |
| ៤ | ផ្តល់គ្រូមត្តេយ្យ | ឃុំ | ១ | លើក | ១សប្តាហ៍ | ៩ | ៩ | ៣,៦០០,០០០ | |
| ៥ | ផ្តល់អាហារូបករណ៍សិស្សក្រីក្រ | គ្រប់ភូមិ | ៤៤៣ | នាក់ | ១សប្តាហ៍ | ៤៤៣ | ២៩០ | ៨៨,៦០០,០០០ | |
| ៦ | ផ្សព្វផ្សាយពីសារៈប្រយោជន៍នៃចាក់វ៉ាក់សាំង | គ្រប់ភូមិ | ៩ | លើក | ១សប្តាហ៍ | ១៣,០៧៨ | ៦,៥២៧ | ៣,៦០០,០០០ | |
| ៧ | សាងសង់បង្គន់អនាម័យតាមខ្នង់ផ្ទះ | គ្រប់ភូមិ | ៤៥ | បង្គន់ | ១ខែ | ២២៥ | ១១៥ | ១៨,០០០,០០០ | |
| ៨ | សាងសង់ប្រព័ន្ធទឹកស្អាត | ប្រាសាទ | ១ | កន្លែង | ១ឆ្នាំ | ១៣,០៧៨ | ៦,៥២៧ | ៤០០,០០០,០០០ | |
| ៩ | ផ្សព្វផ្សាយពីសុខភាពអនាម័យ | គ្រប់ភូមិ | ៩ | លើក | ១ខែ | ១៣,០៧៨ | ៦,៥២៧ | ៣,៦០០,០០០ | |
| ១០ | ផ្តល់ការគាំទ្រដល់អ្នកកើតមេរោគអេដស៍ | គ្រប់ភូមិ | ១ | លើក | ១សប្តាហ៍ | ១០ | ៤ | ៤,០០០,០០០ | |
| ១១ | ផ្តល់លើច្រៃ‌ត់៖ រទេះរុញ ជើងសិប្បនិម្មិត | គ្រប់ភូមិ | ១ | លើក | ១ខែ | ២០ | ៥ | ១៧,៥០០,០០០ | |
| ១២ | ផ្សព្វផ្សាយច្បាប់ចរាចរណ៍ផ្លូវគោក | គ្រប់ភូមិ | ៩ | លើក | ១ខែ | ១៣,០៧៨ | ៦,៥២៧ | ៣,៦០០,០០០ | |
| ១៣ | បណ្តុះបណ្តាលពីយេនឌ័រ | ឃុំ | ១ | វគ្គ | ១ថ្ងៃ | ៥០ | ៣០ | ១,០០០,០០០ | |
| ១៤ | ផ្សព្វផ្សាយច្បាប់ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារដល់សហគមន៍ | គ្រប់ភូមិ | ៩ | លើក | ១ខែ | ១៣,០៧៨ | ៦,៥២៧ | ៣,៦០០,០០០ | |
| ១៥ | ស្នើសុំបុគ្គលិកពេទ្យបន្ថែម៥នាក់ | មណ្ឌល | ៥ | នាក់ | ១សប្តាហ៍ | ១៣,០៧៨ | ៦,៥២៧ | ២០០,០០០ | |
| ១៦ | ស្នើសុំសំភារៈពិនិត្យផ្ទៃពោះ | មណ្ឌល | ១ | កំប្លេ | ១សប្តាហ៍ | ១៣,០៧៨ | ៦,៥២៧ | ១០០,០០០ | |
| ៣.ផ្នែកធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនិងការប្រែប្រួលអាកាសធាតុ | | | | | | | | | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ១ | ផ្សព្វផ្សាយពីផលប៉ះពាល់នៃការប្រែប្រួល អាកាសធាតុ | គ្រប់ភូមិ | ៩ | លើក | ១ខែ | ១៣,០៧៨ | ៦,៥២៧ | ៣,៦០០,០០០ | |
| ២ | ផ្សព្វផ្សាយវិធានការត្រៀមបង្ការគ្រោះមហន្តរាយ | គ្រប់ភូមិ | ៩ | លើក | ១ខែ | ១៣,០៧៨ | ៦,៥២៧ | ៣,៦០០,០០០ | |
| ៤.ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ | | | | | | | | | |
| ១ | ផ្សព្វផ្សាយពីសារប្រយោជន៍នៃការចុះអត្រានុកូលដ្ឋាន | គ្រប់ភូមិ | ៩ | លើក | ១ខែ | ១៣,០៧៨ | ៦,៥២៧ | ៣,៦០០,០០០ | |
| ២ | បណ្តុះបណ្តាលភាពជាអ្នកដឹកនាំដល់ស្ត្រី | ឃុំ | ១ | វគ្គ | ៤ថ្ងៃ | ១៨ | ១៨ | ៤,០០០,០០០ | |
| ៣ | សាងសង់អាគារសាលាឃុំ | ដូនទុង | ១ | អាគារ | ៣ខែ | ១៣,០៥២ | ៦,៨០៩ | ៨០,០០០,០០០ | |
| ៤ | ផ្សព្វផ្សាយច្បាប់ភូមិបាល | គ្រប់ភូមិ | ៩ | លើក | ១ខែ | ១៣,០៧៨ | ៦,៥២៧ | ៣,៦០០,០០០ | |

# ឧបសម្ព័ន្ធទី ៧

# កំរងសំណួរស្រាវជ្រាវ

ក្នុងនាមយើងខ្ញុំជាអ្នកស្រាវជ្រាវ យើងខ្ញុំសូមស្នើ លោក លោកស្រី អ្នកនាង កញ្ញា មេត្តាជួយឆ្លើយនឹងសំណួរស្រាវជ្រាវខាងក្រោមនេះ និងជួយផ្តល់ពត៌មានអោយបានសុក្រឹត។ កម្រងសំណួរធ្វើឡើងដើម្បីបំពេញអោយការស្រាវជ្រាវរបស់យើងខ្ញុំដែលទាក់ទងទៅនឹង ការជំរុញលើកស្ទួយសេដ្ឋកិច្ចជនបទសំដៅដោះស្រាយបញ្ហាក្នុងផលិតកម្មនៃវិស័យកសិកម្ម សេវាកម្ម និងសិប្បកម្ម ។ រាល់ព័ត៌មានទាំងអស់ដែលក្រុមយើងខ្ញុំទទួលបានពីលោកអ្នកទាំងអស់ គឺមានសារៈសំខាន់ខ្លាំងណាស់ សម្រាប់ជាជំនួយក្នុងការធ្វើរបាយការណ៍បញ្ចប់ការសិក្សារបស់យើងខ្ញុំផង និង ផលិតចេញជាដំណោះស្រាយដែលអាចធ្វើទៅបានតាមរយៈបញ្ហាដែលកើតមានជាក់ស្តែង ដើម្បីអភិវឌ្ឍន៍ជីវភាពរបស់បងប្អូនឲ្យមានការរីកចម្រើន ប្រកបដោយចីរភាព។ ចំពោះព័ត៌មានទាំងអស់យើងខ្ញុំសូមសន្យាថានឹងរក្សាទុកជាការសំងាត់។

➢ សម្គាល់៖ សូមមេត្តាបំពេញ និង គូសសញ្ញា (√) នៅខាងមុខចម្លើយរបស់អ្នក។

ឈ្មោះ ........................................... អាយុ...............ឆ្នាំ, នៅភូមិ...............

ភេទ ៖ ☐ ១.ប្រុស ☐ ២.ស្រី

សមាជិកគ្រួសារ...............................នាក់

❖ **ផ្នែកកសិកម្ម ៖**

- **ធ្វើស្រែ**

1. ចំនួនដីធ្វើស្រែសរុប .........................., ដីកម្មសិទ្ធិ........................., ដីជួលគេ.....................
2. ចំនួនដងនៃការប្រមូលផលក្នុងមួយឆ្នាំ.................ដង
3. ទិន្នផល...............................
4. ដំណើរការ ការជ្រើសរើសពូជ ៖ ☐ ១. ទិញពីក្រុមហ៊ុន ☐ ២. ធ្វើខ្លួនឯង
   ចំណាយថ្លៃពូជ.................................................
5. ចំណាយការប្រើប្រាស់ដី ៖
   – ភ្ជួររាស់ ៖ ☐ ១. ប្រើគោក្របី ☐ ២. ប្រើម៉ាស៊ីនគ្រឿងចក្រ
     ចំណាយ.................................................
   – ស្ទូង ៖ ☐ ១. ខ្លួនឯង ☐ ២. ជួលគេ
     ចំនួនកម្លាំងពលកម្ម.....................នាក់, ចំណាយក្នុងម្នាក់........................
6. ការថែទាំ/ការប្រើប្រាស់ដី ៖ ☐ ១.ជីទិញពីក្រុមហ៊ុន ☐ ២. ជីធម្មជាតិធ្វើខ្លួនឯង
   ចំណាយថ្លៃជី .......................................................
   ចំណាយការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិត..............................................
7. ច្រូតកាត់ ៖ ☐ ១. ប្រើម៉ាស៊ីន ☐ ២. ប្រើមនុស្ស
   ចំណាយថ្លៃប្រើម៉ាស៊ីន......................................................................

ចំនួនកម្លាំងពលកម្ម.....................នាក់, ចំណាយក្នុងម្នាក់.........................
8. ចំណាយជួលដី..........................................................................
9. ចំណាយបន្ទាប់បន្សំផ្សេងៗ....................................................................

- **ចិញ្ចឹមសត្វ**

1. ប្រភេទសត្វចិញ្ចឹម...................., ចំនួនសត្វចិញ្ចឹម.......................ក្បាល
2. រយៈពេលទទួលផល................,ចំណូលដែលទទួលបាន..................ប៉ុន្មានក្បាល...............
ឬគីឡូ.........
3. ពូជ ៖ ☐ ១.ទិញគេ ☐ ២.មានស្រាប់
ចំណាយទិញពូជ...................................................
4. ចំណាយចំណី ៖ ☐ ១. ទិញពីក្រុមហ៊ុន ☐ ២. ធម្មជាតិ
ចំណាយ..........................................................................
5. ចំណាយថែទាំ (ចាក់ថ្នាំ,ទឹក...) ......................................................
6. ចំណាយបន្ទាប់បន្សំផ្សេងៗ.........................................................
7. តាមរយៈការប្រកបមុខរបរនេះ តើលោកអ្នកមានជួបប្រទះនូវបញ្ហាប្រឈមដែរឬទេ?
☐ ១. បាទ/ចាស៎ ☐ ២. មិនមានទេ
8. បើមាន តើបញ្ហាប្រឈមទាំងនោះមានអ្វីខ្លះ?
* បញ្ហាហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ៖
(a) ទឹក/ភ្លើង ៖
   - ☐ មិនទាន់មានទឹក/ភ្លើងប្រើប្រាស់
   - ☐ មានប្រើប៉ុន្តែតម្លៃថ្លៃ, ប៉ុន្មាន................/kwh ឬប៉ុន្មាន............/$m^3$

(b) ផ្លូវធ្វើដំណើរសម្រាប់ដឹកជញ្ជូនកសិផល ៖
   - ☐ ផ្លូវលំបាកធ្វើដំណើរ
   - ☐ មិនទាន់មានផ្លូវធ្វើដំណើរគ្រប់គ្រាន់

(c) ប្រព័ន្ធធារាសាស្ត្រសម្រាប់ស្រោចស្រព ៖
   - ☐ មានប្រព័ន្ធធារាសាស្ត្រ ប៉ុន្តែបរិមាណទឹកស្រោចស្រពមិនគ្រប់គ្រាន់
   - ☐ ប្រព័ន្ធធារាសាស្ត្រមិនសមស្របនឹងផ្ទៃដីកសិកម្ម
   - ☐ មិនមានប្រព័ន្ធធារាសាស្ត្រ

(d) ខ្វះជំនាញបច្ចេកទេសកសិកម្ម ៖
   - ☐ ខ្វះអ្នកជំនាញចុះបណ្តុះបណ្តាល
   - ☐ មានកម្មវិធីបណ្តុះបណ្តាល ប៉ុន្តែមានបានចូលរួម
   - ☐ មិនដឹងថាមានកម្មវិធី ឬអត់

(e) ខ្វះទីផ្សារ ៖

- ☐ តម្លៃថោកជាងថ្លៃដើម
- ☐ លក់មិនចេញ
- ☐ តម្លៃធ្លាក់ចុះទាបជាងការរំពឹងទុក

(f) ថ្លៃដើម ៖

- ☐ តម្លៃពូជឡើងថ្លៃ
- ☐ តម្លៃចំណីឡើងថ្លៃ

(g) ខ្វះខាតដើមទុន ៖

- ☐ ខ្វះស្ថាប័នហិរញ្ញវត្ថុ
- ☐ នីតិវិធីស្មុគស្មាញក្នុងការទទួលបានកម្ចី
- ☐ ទាមទារវត្ថុបញ្ចាំខ្ពស់
- ☐ អត្រាការប្រាក់ខ្ពស់

☐ ផ្សេងៗ.........................................។

9. សំណូមពរចំពោះរដ្ឋាភិបាល ៖

.................................................................................................................................................

.................................................................................................................................................

......................................................។

សូមអរគុណសម្រាប់ការចំណាយពេលវេលាដ៏មានតម្លៃរបស់លោកអ្នក រាល់បញ្ហាទាំងឡាយ យើងខ្ញុំនឹងព្យាយាមរកដំណោះស្រាយដ៏មានប្រសិទ្ធិភាពតាមសមត្ថភាពរបស់យើងខ្ញុំមាន ក្នុងគោលបំណងធ្វើឲ្យកម្រិតជីវភាពរបស់លោកអ្នកប្រសើរឡើងជាងមុន។

# កំរងសំណួរស្រាវជ្រាវ

ក្នុងនាមយើងខ្ញុំជាអ្នកស្រាវជ្រាវ យើងខ្ញុំសូមស្នើ លោក លោកស្រី អ្នកនាង កញ្ញា មេត្តាជួយឆ្លើយនឹងសំណួរស្រាវជ្រាវខាងក្រោមនេះ និងជួយផ្តល់ពត៌មានអោយបានសុក្រឹត។ កម្រងសំណួរធ្វើឡើងដើម្បីបំពេញអោយការស្រាវជ្រាវរបស់យើងខ្ញុំដែលទាក់ទងទៅនឹង ការជំរុញលើកស្ទួយសេដ្ឋកិច្ចជនបទសំដៅដោះស្រាយបញ្ហាក្នុងផលិតកម្មនៃវិស័យកសិកម្ម សេវាកម្ម និងសិប្បកម្ម ។ រាល់ព័ត៌មានទាំងអស់ដែលក្រុមយើងខ្ញុំទទួលបានពីលោកអ្នកទាំងអស់ គឺមានសារៈសំខាន់ខ្លាំងណាស់ សម្រាប់ជាជំនួយក្នុងការធ្វើរបាយការណ៍បញ្ចប់ការសិក្សារបស់យើងខ្ញុំផង និង ផលិតចេញជាដំណោះស្រាយដែលអាចធ្វើទៅបានតាមរយៈបញ្ហាដែលកើតមានជាក់ស្តែង ដើម្បីអភិវឌ្ឍន៍ជីវភាពរបស់បងប្អូនឲ្យមានការរីកចម្រើន ប្រកបដោយចីរភាព។ ចំពោះព័ត៌មានទាំងអស់យើងខ្ញុំសូមសន្យាថានឹងរក្សាទុកជាការសំងាត់។

➢ សម្គាល់៖ សូមមេត្តាបំពេញ និង គូសសញ្ញា (√) នៅខាងមុខចម្លើយរបស់អ្នក។

ឈ្មោះ ........................................... អាយុ...............ឆ្នាំ, នៅភូមិ................

ភេទ ៖ ☐ ១.ប្រុស ☐ ២.ស្រី

សមាជិកគ្រួសារ...............................នាក់

❖ **ផ្នែកសេវាកម្ម ៖**

1. ប្រភេទសេវាកម្ម.........................................................................
2. ប្រាក់ខែ/ ប្រាក់ឈ្នួល/ ថ្លៃដើម ក្នុង១ថ្ងៃ..................ក្នុង១ខែ.....................
3. ម៉ោងការងារ..........................................................................
4. ចំណូលលក់បាន/រកបានក្នុងមួយថ្ងៃ.......................................................
5. ចំណាយ ៖
   - ចំណាយថេរ ៖
     (a) ប្រាក់ខែ/ប្រាក់ឈ្នួលកម្មករ..........................................................
     (b) ចណាយថ្លៃជួល...................................................................
   - ចំណាយប្រែប្រួល ៖
     (c) ចំណាយថ្លៃដើម.................................................................
     (d) ចំណាយថ្លៃទឹក/ភ្លើង...........................................................
     (e) ចំណាយថ្លៃប្រេង...............................................................
     (f) ចំណាយថ្លៃថែទាំ/អនាម័យផ្សារ....................................................
     (g) ចំណាយជួសជុល/ថែទាំ.........................................................
     (h) ចំណាយដឹកជញ្ជូន..............................................................

– ចំណាយផ្សេងៗ.............................................................................................

6. តាមរយៈការប្រកបមុខរបរនេះ តើលោកអ្នកមានជួបប្រទះនូវបញ្ហាប្រឈមដែរឬទេ?

☐ ១. បាទ/ចាស     ☐ ២. មិនមានទេ

7. បើមាន តើបញ្ហាប្រឈមទាំងនោះមានអ្វីខ្លះ?

* បញ្ហាហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ៖

(a) ទឹក/ភ្លើង ៖

- ☐ មិនទាន់មានទឹក/ភ្លើងប្រើប្រាស់
- ☐ មានប្រើប៉ុន្តែតម្លៃថ្លៃ, ប៉ុន្មាន................/kwh ឬប៉ុន្មាន............/$m^3$

(b) ផ្លូវធ្វើដំណើរសម្រាប់ដឹកជញ្ជូនផលិតផល ៖

- ☐ ផ្លូវលំបាកធ្វើដំណើរ
- ☐ មិនទាន់មានផ្លូវធ្វើដំណើរគ្រប់គ្រាន់

(c) ខ្វះទីផ្សារ ៖

- ☐ លក់មិនចេញ
- ☐ តម្លៃធ្លាក់ចុះទាបជាងការរំពឹងទុក

(d) ថ្លៃដើម ៖

- ☐ ថ្លៃដើមឡើងថ្លៃ
- ☐ តម្លៃកម្មករឡើងថ្លៃ
- ☐ ខ្វះខាតកម្មករ

(e) ខ្វះខាតដើមទុន ៖

- ☐ ខ្វះស្ថាប័នហិរញ្ញវត្ថុ
- ☐ នីតិវិធីស្មុគស្មាញក្នុងការទទួលបានកម្ចី
- ☐ ទាមទារវត្ថុបញ្ចាំខ្ពស់
- ☐ អត្រាការប្រាក់ខ្ពស់

☐ ផ្សេងៗ.........................................។

8. សំណូមពរចំពោះរដ្ឋាភិបាល ៖

..................................................................................................................................

..................................................................................................................................

.......................................................។

សូមអរគុណសម្រាប់ការចំណាយពេលវេលាដ៏មានតម្លៃរបស់លោកអ្នក រាល់បញ្ហាទាំងឡាយ យើងខ្ញុំនឹងព្យាយាមរកដំណោះស្រាយដ៏មានប្រសិទ្ធិភាពតាមសមត្ថភាពរបស់យើងខ្ញុំមាន ក្នុងគោលបំណងធ្វើឲ្យកម្រិតជីវភាពរបស់លោកអ្នកប្រសើរឡើងជាងមុន។

# កំរងសំណួរស្រាវជ្រាវ

ក្នុងនាមយើងខ្ញុំជាអ្នកស្រាវជ្រាវ យើងខ្ញុំសូមស្នើ លោក លោកស្រី អ្នកនាង កញ្ញា មេត្តាជួយឆ្លើយនឹងសំណួរស្រាវជ្រាវខាងក្រោមនេះ និងជួយផ្តល់ពត៌មានអោយបានសុក្រឹត។ កម្រងសំណួរធ្វើឡើងដើម្បីបំពេញអោយការស្រាវជ្រាវរបស់យើងខ្ញុំដែលទាក់ទងទៅនឹង ការជំរុញលើកស្ទួយសេដ្ឋកិច្ចជនបទសំដៅដោះស្រាយបញ្ហាក្នុងផលិតកម្មនៃវិស័យកសិកម្ម សេវាកម្ម និងសិប្បកម្ម ។ រាល់ព័ត៌មានទាំងអស់ដែលក្រុមយើងខ្ញុំទទួលបានពីលោកអ្នកទាំងអស់ គឺមានសារៈសំខាន់ខ្លាំងណាស់ សម្រាប់ជាជំនួយក្នុងការធ្វើរបាយការណ៍បញ្ចប់ការសិក្សារបស់យើងខ្ញុំផង និង ផលិតចេញជាដំណោះស្រាយដែលអាចធ្វើទៅបានតាមរយៈបញ្ហាដែលកើតមានជាក់ស្តែងដើម្បីអភិវឌ្ឍន៍ជីវភាពរបស់បងប្អូនឲ្យមានការរីកចម្រើន ប្រកបដោយចីរភាព។ ចំពោះព័ត៌មានទាំងអស់យើងខ្ញុំសូមសន្យាថានឹងរក្សាទុកជាការសំងាត់។

➢ សម្គាល់៖ សូមមេត្តាបំពេញ និង គូសសញ្ញា (√) នៅខាងមុខចម្លើយរបស់អ្នក។

ឈ្មោះ ........................................... អាយុ................ឆ្នាំ, នៅភូមិ................

ភេទ ៖ ☐ ១.ប្រុស ☐ ២.ស្រី

សមាជិកគ្រួសារ................................នាក់

❖ **ផ្នែកសិប្បកម្ម / ឧស្សាហាកម្ម**

1. ប្រភេទសិប្បកម្ម/ឧស្សាហាកម្ម..................................................................
2. ចំនួនកម្មករបម្រើការងារ..............នាក់
3. ម៉ោងការងារ...............................ម៉/ម្នាក់, ផលិតភាព.............................................
4. ចំនួនម៉ាស៊ីនដែលប្រើប្រាស់..........គ្រឿង, ចំនួនម៉ោងដែលប្រើប្រាស់......................
5. តើមានបំណងចង់ផ្លាស់ប្តូរម៉ាស៊ីនទាំងនេះដែរឬទេ? ☐ ចង់ ☐ មិនចង់
   ព្រោះ..........................................................................................................
   ហើយមានកត្តារាំងស្ទះអ្វីខ្លះក្នុងការផ្លាស់ប្តូរម៉ាស៊ីនថ្មី.............................................
6. តម្លៃលក់ចេញក្នុងមួយឯកតា..................................................................
7. ចំនួនទំនិញដែលលក់បានក្នុងមួយខែ......................................................
8. ចំណាយ ៖
   - ចំណាយថេរ ៖
     (a) ប្រាក់ខែ/ប្រាក់ឈ្នួលកម្មករ...........................................................
     (b) ចំណាយថ្លៃជួល.........................................................................
   - ចំណាយប្រែប្រួល ៖
     (c) ចំណាយថ្លៃវត្ថុធាតុដើម..............................................................
     (d) ចំណាយថ្លៃទឹក/ភ្លើង...................................................................

(e) ចំណាយថ្លៃប្រេង.............................................................................

(f) ចំណាយថ្លៃជួលជុល/ថែទាំ..........................................................

(g) ចំណាយដឹកជញ្ជូន....................................................................

(h) ចំណាយរដ្ឋបាល........................................................................

– ចំណាយផ្សេងៗ...........................................................................

9. តាមរយៈការប្រកបមុខរបរនេះ តើលោកអ្នកមានជួបប្រទះនូវបញ្ហាប្រឈមដែរឬទេ?

☐ ១. បាទ/ចាស់ ☐ ២. មិនមានទេ

10. បើមាន តើបញ្ហាប្រឈមទាំងនោះមានអ្វីខ្លះ?

* បញ្ហាហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ៖

(a) ទឹក/ភ្លើង ៖

- ☐ មិនទាន់មានទឹក/ភ្លើងប្រើប្រាស់
- ☐ មានប្រើប៉ុន្តែតម្លៃថ្លៃ, ប៉ុន្មាន................/kwh ឬប៉ុន្មាន............/$m^3$

(b) ផ្លូវធ្វើដំណើរសម្រាប់ដឹកជញ្ជូនផលិតផល ៖

- ☐ ផ្លូវលំបាកធ្វើដំណើរ
- ☐ មិនទាន់មានផ្លូវធ្វើដំណើរគ្រប់គ្រាន់

(c) ខ្វះជំនាញបច្ចេកទេស៖

- ☐ ខ្វះសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ
- ☐ កម្មករខ្វះជំនាញ

(d) ខ្វះទីផ្សារ ៖

- ☐ តម្លៃថោកជាងថ្លៃដើម
- ☐ លក់មិនចេញ
- ☐ តម្លៃធ្លាក់ចុះទាបជាងការរំពឹងទុក

(e) ថ្លៃដើម ៖

- ☐ តម្លៃវត្ថុធាតុដើមឡើងថ្លៃ
- ☐ តម្លៃកម្មករឡើងថ្លៃ
- ☐ ខ្វះខាតកម្មករ

(f) ខ្វះខាតដើមទុន ៖

- ☐ ខ្វះស្ថាប័នហិរញ្ញវត្ថុ
- ☐ នីតិវិធីស្មុគស្មាញក្នុងការទទួលបានកម្ចី
- ☐ ទាមទារវត្ថុបញ្ចាំខ្ពស់

- ☐ អត្រាការប្រាក់ខ្ពស់

☐ ផ្សេងៗ.......................................។

11. សំណូមពរចំពោះរដ្ឋាភិបាល ៖

.........................................................................................................................................

.........................................................................................................................................

...................................................។

សូមអរគុណសម្រាប់ការចំណាយពេលវេលាដ៏មានតម្លៃរបស់លោកអ្នក រាល់បញ្ហាទាំងឡាយ យើងខ្ញុំនឹងព្យាយាមរកដំណោះស្រាយដ៏មានប្រសិទ្ធិភាពតាមសមត្ថភាពរបស់យើងខ្ញុំមាន ក្នុងគោលបំណងធ្វើឲ្យកម្រិតជីវភាពរបស់លោកអ្នកប្រសើរឡើងជាងមុន។